# មគ្គុទេសក៍ព័ត៌មាន
# បឹងទន្លេសាប









បោះពុម្ពដោយអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live & Learn)

ផ្ទះលេខ ៣៦៤ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ
91 ទូរសព្ទ 855 23 224 053 អ៊ីម៉ែល:livelearn@online.com.kh
គេហទំព័រ http://www.idea.org.au/liveandlearn/

ខែ កុម្ភៈ ២០០៧

ការចេញផ្សាយនេះគឺជាផ្នែកមួយនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) និងយុទ្ធនាការផ្សព្វផ្សាយ
និងអប់រំបរិស្ថានថ្នាក់ជាតិ (NEEAC)
ចុះកិច្ចសន្យាដោយ ក្រសួងបរិស្ថាន
ផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី (Loan 1939 CAM(SF))

និពន្ធ និងចងក្រងដោយ : ភីធ័រ ស្តារ និង សេចក្តីផ្តើម ដោយ ជេឌី ស្មីត
កែសំរួលដោយ : ជុំ សំអូន ពេជ្រ សុខដានី និង គាត ប៊ុនថាន
បកប្រែជាភាសាខ្មែរដោយ : ស្រេង សុផល ជុំ សំអូន និង ពេជ្រ សុខដានី
ពិនិត្យកែសំរួលដោយ : ពេជ្រ សុខដានី និង គាត ប៊ុនថាន
រចនាដោយ : ខារិន យាំង
រូបភាពដោយ : សូមថ្លែងអំណរគុណដល់អង្គការ WCS – អេលីន ព្រីក តូនី លីណាំ អាឡាន មីឆូដ និង ចូ វ៉ាលស្តូន។
សុនញ៉ា អែនឌុលវ៉ៃបឺ មីតឈែល អីសសាក់ ខារិន យាំង ធារី វ៉ូលត័រតុន គណៈកម្មការទន្លេមេគង្គ

រក្សាសិទ្ធិ ក្រសួងបរិស្ថាន អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live & Learn Environmental Education)
អត្ថបទនេះអាចទាញយកមកប្រើបានក្នុងគោលបំណងអប់រំ ដោយមានបញ្ជាក់ពីប្រភព។

សេចក្តីបញ្ជាក់ : ឯកសារអប់រំបរិស្ថាននេះត្រូវបានរៀបចំដោយទីប្រឹក្សាអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន
សំរាប់ក្រសួងបរិស្ថាន (MoE)។

សេចក្តីថ្លែងអំណរគុណ : ឯកសារនេះត្រូវបានដកស្រង់ចេញពីឯកសារជាច្រើន ដែលមានបញ្ជាក់នៅចុងបញ្ចប់ផ្នែកនីមួយៗ។

Published by Live & Learn Environmental Education

#364, St. Preah Monivong, Phsar Domthkov, Khan Chamkarmon, Phnom Penh, Cambodia
PO Box: 91 Phone: (855) 23 224 053 Email: livelearn@online.com.kh
http://www.idea.org.au/liveandlearn/

February 2007

This publication forms part of the Tonle Sap Environmental Management Project (TSEMP)
and National Environmental Education and Awareness Campaign (NEEAC)
Contracted by the Ministry of Environment
Supported by the Asian Development Bank (Loan 1939 CAM (SF))

Written and compiled by: Peter Starr, Introduction by Jady Smith
Edited by: Chum Som Onn, Pich Sokdany and Keat Bunthan
Translated by: Sreng Sophal, Chum Som Onn and Pich Sokdany
Proofed by: Pich Sokdany and Keat Bunthan
Design and layout by Karen Young
Photos: Thank you to WCS – Eleanor Briggs, Tony Lynam, Allan Michaud and Joe Walston.
Sonja Endlweber, Mitchell Issacs, Reach Sambath, Carly Starr, Terry Wooltorton, Karen Young, MRC
Printed by: Graphic Roots

© Copyright Ministry of Environment, Live & Learn Environmental Education.
This text is reusable for educational purposes. If used please cite the source.

Disclaimer: This educational document was prepared by consultants
Live & Learn Environmental Education for the Ministry of Environment (MoE).

**Acknowlegements:** This document has been complied from numerous existing materials,
these are acknowlegements at the end of key sections.

This CD contains PDFs of the Infomation Guide in Khmer and English. These can be opened using the program Adobe Acrobat. Text from the PDF can copied and pasted. This text is reusable for educational purposes. If used please cite the source.

To copy text: open the document in Adobe Acrobat and use the TEXT TOOL to highlight the text you require. Then choose: Edit > Copy, Edit > Paste into a new document.

ស៊ីឌីនេះមានឯកសារ មគ្គុទេសក៍សារព័ត៌មានបឹងទន្លេសាបជាភាសាខ្មែរ និងអង់គ្លេស។ ឯកសារនេះអាចបើកបានដោយប្រើកម្មវិធីអាក្រូបាត។ អត្ថបទនេះអាចចំលងយកទៅប្រើបានក្នុងគោលបំណងអប់រំ។ ប្រសិនបើអ្នកប្រើ សូមបញ្ជាក់ពីប្រភពដើម។

ដើម្បីចំលងអត្ថបទ : សូមបើកឯកសារនៅក្នុងកម្មវិធីអាក្រូបាត និងប្រើ TEXT TOOL ដើម្បីជ្រើសយកអត្ថបទដែលចង់បាន។
បន្ទាប់មកជ្រើសរើសយក : Edit > Copy, Edit > Paste ចូលទៅក្នុងឯកសារថ្មី។

TEXT TOOL



មគ្គុទេសក៍ព័ត៌មាន
បឹងទន្លេសាប

# មាតិកា


១. **សេចក្ដីផ្ដើម** ០៤

២. **ការបរិច្ឆេទសំខាន់ៗ** ១០
ប្រភពផ្សេងៗ

៣. **សំណួរដែលត្រូវបានសួរជាញឹកញាប់** ១៤
ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការយូណេស្កូ គណៈកម្មាធិការជាតិទន្លេមេគង្គ

៤. **តំបន់ការពារធម្មជាតិ** ២០
ធនាគារអភិវឌ្ឍន៍អាស៊ី Jady Smith, Frederic Goes

៥. **ថបនីយជីវមណ្ឌលបឹងទន្លេសាប** ២៣
ធនាគារភិវឌ្ឍន៍អាស៊ី អង្គការយូណេស្កូ គណៈកម្មាធិការជាតិទន្លេមេគង្គ

៦. **រុក្ខជាតិទូទៅនៃតំបន់បឹងទន្លេសាប** ៣២
អង្គការសមាគមអភិរក្សសត្វព្រៃ (WCS)

៧. **ព្រៃលិចទឹក** ៣៦
ធនាគារអភិវឌ្ឍន៍អាស៊ី វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

៨. **តំបន់ដីសើម** ៣៨
មជ្ឈមណ្ឌលជលផលពិភពលោក គណៈកម្មាធិការជាតិទន្លេមេគង្គ

៩. **ជលផល** ៤៤
គណៈកម្មាធិការជាតិទន្លេមេគង្គ

១០. **សហគមន៍នេសាទ** ៥១
រដ្ឋបាលជលផល

១១. **ការគ្រប់គ្រងព្រៃឈើនៅខេត្តសៀមរាប** ៥៥
គណៈកម្មាធិការជាតិទន្លេមេគង្គ

១២. **គុណភាពទឹក និងអនាម័យ** ៥៨
ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិសហប្រជាជាតិសំរាប់កុមារ (UNICEF)

ក. **ទិន្នន័យគុណភាពទឹក និងប្រព័ន្ធអនាម័យ** ៦០
ក្រសួងផែនការ

១៣. **ប្រភេទត្រី និងសត្វក្នុងទឹកផ្សេងៗ** ៦៦
អង្គការសមាគមអភិរក្សសត្វព្រៃ
លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប

១៤. **ពពួកសត្វស្លាបផ្សេងៗ** ៧០
អង្គការសមាគមអភិរក្សសត្វព្រៃ មូលនិធិសារព័ត៌មានឯករាជ្យ

១៥. **នានាភាពនៃពពួកល្មូន** ៧៧
អង្គការសមាគមអភិរក្សសត្វព្រៃ

១៦. **ពពួកថនិកសត្វផ្សេងៗ** ៨២
អង្គការសមាគមអភិរក្សសត្វព្រៃ

១៧. **ជីវៈចំរុះនៅតំបន់ស្នូលបឹងទន្លេសាប** ៨៦
ក្រសួងបរិស្ថាន

១៨. **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** ៨៩
ក្រសួងផែនការ

១៩. **ការអប់រំបរិស្ថាន** ៩៤
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live and Learn)

២០. **សន្ទានុក្រម** ៩៧
គណៈកម្មាធិការជាតិទន្លេមេគង្គ

២១. **អក្សរកាត់** ១១១
គណៈកម្មាធិការជាតិទន្លេមេគង្គ គណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា

២២. **បញ្ជីឈ្មោះ និងអាសយដ្ឋានរបស់ស្ថាប័ន** ១១៨
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live and Learn)

២៣. **ការអប់រំ និងផ្សព្វផ្សាយបរិស្ថាន** ១២៩
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live and Learn)

# ០១

# សេចក្តីផ្តើម

បញ្ហាបរិស្ថានបានក្លាយជាចំណុចដដែកគ្នារបស់ពិភពលោកជាថ្មីម្តងទៀត អំពីផលប៉ះពាល់ដ៏ខ្លាំងក្លានៃការប្រែប្រួលអាកាសធាតុ ដែលជាចំណោទបញ្ហាត្រូវបានគេទទួលស្គាល់នៅពេលបច្ចុប្បន្ន ។ នៅក្នុងទំនាក់ទំនងបញ្ហានេះ ផលវិបាកដែលកើតចេញពីការមិនបានគ្រប់គ្រងបរិស្ថាន និងមិនបានកាត់បន្ថយការប្រើប្រាស់របស់យើង កំពុងតែបង្ហាញចេញជារូបរាងយ៉ាងច្បាស់ និងគ្រោះថ្នាក់ច្រើនឡើងៗ ។ ចំពោះការប្រែប្រួលអាកាសធាតុក្នុងខណៈនេះគឺ កំពុងស្ថិតក្នុងបណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិ និងកម្មវិធីនយោបាយ ។ នៅពេលដែលបណ្តាញផ្សព្វផ្សាយព័ត៌មានផ្តោតចំណាប់អារម្មណ៍លើការប្រែប្រួលអាកាសធាតុ ជាការសំខាន់ណាស់ ត្រូវរក្សាចំណាប់អារម្មណ៍នោះឱ្យផ្តោតទៅលើបញ្ហាបរិស្ថានដទៃទៀតផងដែរ ដែលប្រជាពលរដ្ឋអាចប្រឈមមុខរាល់ថ្ងៃ ហើយនិងត្រូវតែរៀនគ្រប់គ្រងបញ្ហាទាំងនោះ ។ ដើម្បីធ្វើអោយការយល់ដឹងមានន័យខ្លឹមសារអំពីអ្វី ដែលយើងជួបប្រទះ ថាតើវាពាក់ព័ន្ធដូចម្តេច ហើយហេតុអ្វីបានជាវាសំខាន់ ដែលត្រូវតែគ្រប់គ្រង និងការពារនោះ គឺជាបញ្ហាដែលយើងចាំបាច់ត្រូវធ្វើការផ្តោតអារម្មណ៍រួមគ្នា ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មានអ្នកអានកើនឡើងច្រើន ដែលពួកគេមានការចាប់អារម្មណ៍ និងការព្រួយបារម្ភខ្លាំងអំពីបរិស្ថាន ។ ដូច្នេះ យើងគួរចាប់យកឱកាសល្អនេះ មិនត្រឹមតែចែករំលែកព័ត៌មានអំពីបញ្ហាវិបត្តិបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវតែពង្រឹងអំណាចប្រជាជនអោយធ្វើសកម្មភាពផងដែរ ដែលជាទម្លាប់ ដោយការផ្លាស់ប្តូរឥរិយាបថ ដូចជា ការបោះចោលសំរាមកាកសំណល់ ការដើរជំនួសការបើកបរជាដើម ។ ប្រព័ន្ធព័ត៌មាន ត្រូវតែមានតួនាទីនាំមុខគេក្នុងការលើកកំពស់ចំណេះដឹងសហគមន៍ និងអប់រំប្រជាពលរដ្ឋ ។ យើងចាំបាច់ត្រូវពង្រីកអោយមានការយល់ដឹងអំពីបរិស្ថានក្នុងចំណោមប្រជាពលរដ្ឋ ដែលនឹងនាំទៅរកការសំរេចចិត្តនៃការគ្រប់គ្រងរបស់យើង ដូចដែលយើងខិតខំធ្វើសំរាប់អនាគតមួយប្រកបដោយចិរភាព ។

ការអប់រំ និងការសិក្សាគឺជាគ្រឿងផ្សំដ៏សំខាន់បំផុតក្នុងការប្រែក្លាយអោយកាន់តែមានចិរភាព ។ ក្នុងការឆ្លើយតបទៅនឹងការយល់ដឹង ដែលមានការកើតឡើងដែលថា បរិស្ថានកំពុងតែទទួលរងឥទ្ធិពលដ៏អាក្រក់តាមរយៈទង្វើរបស់មនុស្សនោះ ការអប់រំត្រូវបានគេផ្តោតយកចិត្តទុកដាក់ថា បានបង្ហាញពីរបៀបកាត់បន្ថយទង្វើប៉ះពាល់របស់យើងទៅលើបរិស្ថាន របៀបកែលំអឡើងវិញនូវការខូចខាតដែលយើងបានបំផ្លាញ និងរបៀបធ្វើផែនការ និងអភិវឌ្ឍដើម្បីអោយអនាគតមួយកាន់តែមានចិរភាពថែម

ទៀត ។ របៀបនៃការអប់រំនេះស្ថិតនៅក្រោមអ្នកដឹកនាំជាច្រើន ដែលបានចងក្រងជាក្រុមក្រោមលក្ខខណ្ឌមួយស្តីពីការអប់រំបរិស្ថាន ។ អស់ពេល៣០ឆ្នាំកន្លងមកហើយ គេបានលើកកំពស់យ៉ាងខ្លាំងក្លានូវការអប់រំបរិស្ថានតាមរយៈការធ្វើវេទិកាអន្តរជាតិជាច្រើនលើក ។ ជាពិសេស គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ ក៏បានជំរុញអោយប្រើប្រាស់វិធានការអប់រំជាចលនាឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ ។ ថ្មីៗនេះទៀត មហាសន្និបាតអង្គការសហប្រជាជាតិ ក៏បានប្រកាសអំពី ទសវត្សរ៍អប់រំការអភិវឌ្ឍប្រកបដោយចីរភាព សំរាប់ឆ្នាំ ២០០៥-២០១៤ ដោយបានសង្កត់ធ្ងន់ថា ការអប់រំគឺជាធាតុមួយដែលមិនអាចខ្វះបានដើម្បីសំរេចបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

កាលពីមុនមានជម្លោះក្នុងស្រុក ប្រទេសកម្ពុជាគឺជាអ្នកនាំមុខគេមួយក្នុងតំបន់ខាងផ្នែកអក្សរសាស្ត្រ និងមានការសិក្សាអប់រំខ្ពស់ ហើយក្នុងឆ្នាំ ១៩២៥ កម្ពុជាជាប្រទេសដំបូងគេដែលបានបង្កើតតំបន់ការពារធម្មជាតិ ។ ជាអកុសល ដោយសារជម្លោះអស់ពេលជាច្រើនឆ្នាំ បានធ្វើឱ្យមូលដ្ឋានគ្រឹះដ៏ល្អនេះវិនាសវិចវិលទៅវិញ ។ ការអប់រំបរិស្ថាននៅប្រទេសកម្ពុជា ទើបតែមានប្រវត្តិឡើងវិញក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដែលបានដាក់បញ្ចូលជាលើកដំបូងទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈ ការបង្កើតអោយមានក្រសួងបរិស្ថាននៅឆ្នាំ១៩៩៣ ។ តាំងពីពេលនោះមក ការអប់រំបរិស្ថានទទួលបាននូវការគាំទ្រ និងទទួលស្គាល់ច្រើនថាជាឧបករណ៍សំខាន់មួយក្នុងការកាត់បន្ថយបញ្ហានានាផ្នែកបរិស្ថានដែលកំពុងតែមានឥទ្ធិពលទៅដល់ប្រទេសនាពេលបច្ចុប្បន្ននេះ ។ សហគមន៍ អ្នកផ្តល់ជំនួយបានកត់សំគាល់ឃើញជាពិសេស អំពីសារសំខាន់នៃការអប់រំក្នុងការជួយជួសជុលកែលំអបរិស្ថានដែលខូចខាត អោយល្អឡើងវិញ និងដើម្បីគ្រប់គ្រង និងការពារបរិស្ថាននៃប្រទេសកម្ពុជាអោយបានល្អប្រសើរឡើងវិញនាពេលអនាគត ។

មានការដាក់បញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីសិក្សាតាមសាលា ទោះជាយ៉ាងនេះក្តី ជារួមសកម្មភាពអប់រំក្រៅប្រព័ន្ធធ្វើឱ្យការអប់រំបរិស្ថានក្នុងប្រទេសកម្ពុជារីកសាយទូលំទូលាយ ។ ការសហការជាដៃគូជាមួយអ្នកសារព័ត៌មាន ដើម្បីភ្ជាប់ទំនាក់ទំនងបញ្ហាបរិស្ថានទៅដល់អ្នកអាននោះ វាមានសក្តានុពលខ្លាំងណាស់ ។ ព័ត៌មានដែលត្រឹមត្រូវ និងមិនលំអៀងរបស់អ្នកសារព័ត៌មាន អាចធ្វើអោយប្រសើរឡើងនូវការយល់ដឹង និងការពិភាក្សាដោយផ្ទាល់អំពីតំរូវការចាំបាច់ សំរាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ វាជាការប្រសើរ ដែលប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់នូវអត្ថបទ និងរបាយការណ៍ព័ត៌មានផ្សេងៗស្តីពី ស្ថានភាពបរិស្ថាន ប៉ុន្តែគេនៅតែត្រូវការបន្ថែម និងចែករំលែកការយល់ដឹងអោយបានច្រើនថែមទៀតអំពីតំរូវការបរិស្ថានក្នុងតំបន់ ។

នៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០០៥ ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា បានអនុម័តអោយអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន(L&L) អនុវត្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយបរិស្ថានថ្នាក់ជាតិ (NEEAC) ដែលស្ថិតនៅក្រោមផ្នែកមួយរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) ។ TSEMP ទទួលបានការឧបត្ថម្ភថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមប្រាក់កម្ចីលេខ ១៩៣៩ CAM (SF) ដែលជាផ្នែកមួយនៃកំរងគំរោងបឹងទន្លេសាប (TSI) ។ បឹងទន្លេសាបមានសារសំខាន់ក្រៃលែងសំរាប់យើងទាំងអស់ និងជាបេះដូងរបស់ប្រទេសកម្ពុជា ។ ជាអកុសល សារសំខាន់នៃធម្មជាតិនេះ ត្រូវទទួលរងនូវសម្ពាធឥតឈប់ឈរពីសកម្មភាព ដែលគ្មាន

ចីរភាពរបស់មនុស្ស ។ បរិស្ថាន កំពុងត្រូវបានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ហើយដោយពុំមានការអន្តរាគមន៍ និងការផ្លាស់នូវឥរិយាបថ ធ្វើអោយប្រព័ន្ធអេកូឡូស៊ីដែលខ្ចេចខ្ចាំទាំងស្រុងនោះ ស្ថិតនៅក្នុងការប្រឈមមុខនៃការហិនហោចអស់ ។ យុទ្ធនាការអប់រំ និងផ្សព្វផ្សាយបរិស្ថានថ្នាក់ជាតិ (NEEAC) មានគោលបំណងលើកកំពស់ចំណេះដឹងស្តីពី បញ្ហាបរិស្ថាននៅគ្រប់កំរិតនៅក្នុងសង្គមកម្ពុជា ដោយផ្តោតយ៉ាងពិសេសអំពីប្រព័ន្ធអេកូឡូស៊ីទាំងមូលនៃបឹងទន្លេសាប ។

ជាផ្នែកមួយនៃវិធីសាស្ត្រជាយុទ្ធសាស្ត្រ យើងខិតខំជុំរុញក្រុមអ្នកសារព័ត៌មានអោយមានការយល់ដឹងបានល្អប្រសើរ និងចេះប្រើប្រាស់បាននូវសម្ភារៈពាក់ព័ន្ធស្តីពីបរិស្ថានបឹងទន្លេសាប ។ សៀវភៅមគ្គុទ្ទេសក៍ព័ត៌មានបឹងទន្លេសាប ត្រូវបានបោះពុម្ពឡើងសំរាប់ក្រុមអ្នកសារព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍ ដែលនឹងបង្ហាញអំពីបឹងទន្លេសាប និងដើម្បីបំពេញលើកង្វះខាតចំពោះធនធានមានស្រាប់ ដែលផ្តល់លទ្ធភាពដល់ក្រុមអ្នកសារព័ត៌មាន ជាពិសេសអត្ថបទជាភាសាខ្មែរ ។

សៀវភៅ មគ្គុទ្ទេសក៍ព័ត៌មានបឹងទន្លេសាប គឺជាការប្រមូលចងក្រងនូវឯកសារពាក់ព័ន្ធផ្នែកបរិស្ថានច្រើន ដែលផ្តោតសំខាន់សំរាប់ជាជំនួយព័ត៌មានដល់អ្នកសារព័ត៌មាន ។ សៀវភៅនេះអាចនឹងប្រើជាឯកសារយោងដ៏មានប្រយោជន៍សំរាប់ក្រុមអ្នកស្រាវជ្រាវ និងអ្នកសរសេរអត្ថបទ ព្រមទាំងអ្នកដទៃទៀត ដែលចាប់អារម្មណ៍នឹងបរិស្ថានបឹងទន្លេសាប ។ សៀវភៅមគ្គុទ្ទេសក៍នេះ សរសេរអំពីព័ត៌មានហេតុការណ៍ពិត១ មានកាលបរិច្ឆេទ និងសំណួរទាំងឡាយដែលគេតែងតែសួរជាញឹកញាប់អំពីបឹងទន្លេសាប ។ អត្ថបទនេះ នឹងជួយអ្នកសារព័ត៌មានអោយបែកគំនិតច្រើនក្នុងការសរសេរអត្ថបទ និងរបាយការណ៍ព័ត៌មានពាក់ព័ន្ធទាំងឡាយបានល្អ ព្រមទាំងជួយបង្ហាញផ្លូវពួកគេឆ្ពោះទៅរកព័ត៌មានទាក់ទងផ្សេង១ទៀតនៅក្នុងសៀវភៅមគ្គុទ្ទេសក៍នេះ ។

ផ្នែកទីពីរ សៀវភៅមគ្គុទ្ទេសក៍នេះ ផ្តល់ជាទិដ្ឋភាពទូទៅមួយអំពីតំបន់ការពារធម្មជាតិ និងតំបន់ជំរកសត្វបឹងទន្លេសាប ។ ផ្នែកនេះផ្តោតសំខាន់អំពីរដូវទាំង ៥ របស់បឹងទន្លេសាប និង តំបន់ព្រៃលិចទឹក និងតំបន់ដីសើម ។ បឹងទន្លេសាបគឺជាតំបន់ការពារធម្មជាតិធំបំផុតមួយក្នុងចំណោមតំបន់ការពារធម្មជាតិទាំងឡាយក្នុងប្រទេសកម្ពុជា ហើយប្រជាជន មួយភាគបីរស់នៅក្នុងតំបន់នេះ ហើយក៏ជាបឹងមួយដ៏មានសារសំខាន់បំផុត ។ សារសំខាន់របស់បឹងទន្លេសាប ត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ដោយមានការដាក់បឹងនេះជា ជំរកសត្វមួយ និងត្រូវបានដាក់បញ្ចូលជាតំបន់ដីសើមរ៉ាំសារ ។ រដូវកាលរបស់បឹងនេះ និងដំណើរទឹកហូរត្រូវបានគេពិពណ៌នា ដោយហេតុថា វាមានសារសំខាន់ដល់ព្រៃលិចទឹក ។ តំបន់ដីសើមនៃប្រទេសកម្ពុជាក៏ត្រូវបានរៀបរាប់នៅក្នុងផ្នែកនេះផងដែរ ។

ផ្នែកទីបី សង្កត់ធ្ងន់បន្ថែមអំពីបឹងទន្លេសាបថាជាប្រភពធនធានធម្មជាតិមួយ ដូចជា ធនធានជលផល សហគមន៍នេសាទ ការគ្រប់គ្រងព្រៃឈើ និងគុណភាពទឹក ។ សារសំខាន់របស់បឹងទន្លេសាបដែលជាធនធានមួយមិនគួរត្រូវគេឱ្យតំលៃទាបនោះឡើយ ។ របបទឹកឡើង និងស្រកទៅវិញរបស់បឹងទន្លេសាបនាំមកនូវភាពសម្បូរបែបនៃប្រភពម្ហូបអាហារដ៏ធំរបស់ប្រទេសកម្ពុជា មានដូចជាមច្ឆជាតិ និងស្រូវជាដើម ។ បឹងទន្លេសាបផ្តល់នូវរបបសារជាតិប្រូតេអ៊ីនដល់ប្រទេសកម្ពុជារហូតដល់៧០% ។ ការគ្រប់គ្រង និងការការពារបរិស្ថានបឹងទន្លេសាបដោយវិធានការចំរុះ មានសារសំខាន់យ៉ាងខ្ពស់បំផុត ដើម្បីទ្រទ្រង់ដល់ធនធានទាំងឡាយរបស់បឹងនេះ ។

ជីវៈចំរុះ គឺជាប្រធានបទត្រង់ផ្នែកទី៤ ។ ប្រធានបទនេះរួមមានពួកមច្ឆា សត្វស្លាប សត្វល្មូន ថនិក

សត្វ ជាដើម ហើយនិងផ្តោតសំខាន់ទៅលើតំបន់បឹងទន្លេឆ្មារដែលជាតំបន់ត្រី និងបក្សីពងកូន ។ ការថែរក្សាជីវៈចំរុះ មានសារសំខាន់ដល់ការថែរក្សាសុខភាព បូរណភាព និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី ។ ប្រព័ន្ធអេកូឡូស៊ីពឹងផ្អែកទៅលើទំនាក់ទំនងនៃភាពសាំញ៉ាំ និងការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃភាវៈក្នុងប្រព័ន្ធទាំងអស់ និងពឹងអាស្រ័យលើសុខភាពប្រព័ន្ធបរិស្ថាន ដែលមានទំនាក់ទំនងគ្នាជានិច្ច ។ ប្រជាជនកម្ពុជា ពឹងផ្អែកជាពិសេសទៅលើប្រព័ន្ធជីវៈចំរុះ ការពឹងអាស្រ័យទៅវិញទៅមក ពីព្រោះវាជាអន្តរអំពើរវាងពពួកភាវៈទាំងឡាយ និងនៅក្នុងបរិស្ថាន ដែលផ្តល់ប្រភពធនធានស្បៀងអាហារដ៏សំខាន់សំរាប់ប្រជាពលរដ្ឋដែលមានការកើនឡើងជាលំដាប់នេះ ។ ប្រព័ន្ធអេកូឡូស៊ី តំរូវអោយមានការគ្រប់គ្រង និងការការពារ ដើម្បីថែរក្សាសុខភាព និងផលិតភាពរបស់ខ្លួន ។

ផ្នែកទី៥ ផ្តោតទៅលើរូបភាពដ៏ធំមួយអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងការអប់រំបរិស្ថាន ។ នៅកំរិតថ្នាក់អន្តរជាតិ មានកិច្ចខិតខំប្រឹងប្រែងសំខាន់ៗជាច្រើន ដើម្បីសំរបសំរួលសកម្មភាពឆ្ពោះទៅរកការធ្វើអោយមានចីរភាពខាងវិស័យបរិស្ថាន ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) គឺជាវិធីសាស្ត្រមួយ ប៉ុន្តែគោលដៅ ទាំងនេះត្រូវតែទទួលបានការឧបត្ថម្ភគាំទ្រតាមរយៈសកម្មភាពទាំងឡាយ ដើម្បីអោយគោលដៅទាំងនោះសំរេចបានជោគជ័យ ។ ការអប់រំបរិស្ថាន ដើរតួយ៉ាងសំខាន់ក្នុងការលើកកំពស់ការគ្រប់គ្រងបរិស្ថាន និងត្រូវបានកំណត់ដើម្បីជំរុញចលនាប្រជាជនអោយកាន់តែមានជីវភាពប្រកបដោយចីរភាពប្រសើរឡើងថែមទៀត ។

នៅក្នុងសៀវភៅមគ្គុទ្ទេសក៍ នឹងជួយមួយកំរិតថែមទៀត ដោយមានសទ្ទានុក្រមពន្យល់ពាក្យល្អៗ ពាក្យកាត់ និងអក្សរកាត់ និងបញ្ជីឈ្មោះអង្គការពាក់ព័ន្ធនានា ។ កង្វះខាតពាក្យពេចន៍ដែលមិនទាន់ស្របគ្នា គឺជាឧបសគ្គធំមួយទៅនឹងការចងក្រងឯកសារអោយមានប្រសិទ្ធភាព និងការបកប្រែជាភាសាខ្មែរអំពីព័ត៌មានសំខាន់ៗខាងផ្នែកបរិស្ថាន ។ សទ្ទានុក្រមដែលធ្លាប់ប្រើកន្លងមក ត្រូវបានរៀបចំដោយដាក់បញ្ចូលជាមួយ សទ្ទានុក្រមរបស់គំរោងគណៈកម្មការទន្លេមេគង្គ និងវចនានុក្រមពាក្យបរិស្ថាន ហើយសង្ឃឹមថា នឹងជួយនាំមកនូវភាពច្បាស់លាស់ និងជាកំលាំងមួយសំរាប់ការងារដ៏ល្អនេះ ។



ការធ្វើដំណើរផ្លូវឆ្ងាយត្រូវចាប់ផ្តើមពីជំហានដំបូងតាមផ្លូវមួយដែលត្រឹមត្រូវ ។ យើងសង្ឃឹមថា សៀវភៅ មគ្គុទ្ទេសក៍ព័ត៌មានបឹងទន្លេសាប នឹងចាប់ផ្តើមធ្វើដំណើរតាមផ្លូវមួយ ដែលត្រឹមត្រូវសំរាប់អ្នកសារព័ត៌មាន និងអ្នកផ្សេងៗទៀតដែលធ្វើការពាក់ព័ន្ធជាមួយការអប់រំដល់សាធារណៈជនអំពីបរិស្ថាន ដែលស្អាត តែទទួលរងនូវការខូចខាតនេះ ។ យើងសង្ឃឹមយ៉ាងមុតមាំថានឹងបានឃើញ និងបានឮច្រើនបន្ថែមអំពីសារសំខាន់នៃបឹងទន្លេសាបនាពេលខាងមុខ ។

# បឹងទន្លេសាប និងបម្រុងជីវមណ្ឌលបឹងទន្លេសាប

## ភូមិសាស្ត្រ

- គឺជាបឹងទឹកសាបដែលធំជាងគេនៅក្នុងអាស៊ីអាគ្នេយ៍ ដោយគ្របដណ្តប់លើផ្ទៃដី ១,៥ លានហិកតា
- នៅឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យបានដាក់បឹងទន្លេសាបជាតំបន់ការពារធម្មជាតិ សំរាប់ការប្រើប្រាស់ច្រើនយ៉ាង
- ទន្លេសាបមាននៅក្នុងបញ្ជីសាកលលោកចំនួន ២០០របស់អង្គការ WWF ពីតំបន់ សំខាន់ៗនៃលក្ខខណ្ឌចំបងសំរាប់ការអភិរក្ស
- ត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅឆ្នាំ ១៩៩៧ ជាបម្រុងជីវមណ្ឌល ជាមួយនឹងតំបន់ស្នូល ៣ (ព្រែកទាល់ បឹងទន្លេឆ្មារ និងស្ទឹងសែន) ក្រោមកម្មវិធី មនុស្ស និងជីវមណ្ឌល របស់អង្គការ UNESCO
- រួមបញ្ចូលតំបន់ព្រៃវាលភក់ និងព្រៃលិចទឹកដែលធំជាងគេនៅអាស៊ីទាំងមូល
- ព្រៃលិចទឹកផ្តល់នូវជំរកត្រីពងកូនយ៉ាងសំខាន់សំរាប់រដូវពងកូន កន្លែងធំធាត់ និងកន្លែងរកចំណីសំរាប់ត្រីដែលផ្លាស់ទីពីទន្លេមេគង្គ
- ផលិតផលស្រូវនៅវាលទំនាបបឹងទន្លេសាប ស្មើរនឹងប្រមាណ ១២% នៃទិន្នផលស្រូវប្រចាំឆ្នាំ
- ទន្លេសាបត្រូវបានកំនត់ជាកន្លែង ដែលមានបញ្ហាបរិស្ថានខ្លាំងមួយនៃសារៈសំខាន់ជាសាកល
- អាងស្តុកទឹកទន្លេសាបលាតសន្ធឹងជាង ៨០០០០គ.ម២ រឺ ៤៤% នៃផ្ទៃដីកម្ពុជាសរុប
- ៣២%នៃប្រជាជនកម្ពុជារស់នៅជាមួយអាងទន្លេសាប

## ជលសាស្ត្រ

- លក្ខណៈជលសាស្ត្រពិសេសនៃទន្លេសាប
- បឹងទន្លេសាបត្រូវបានភ្ជាប់ទន្លេមេគង្គដោយទន្លេសាប ដែលមានប្រវែង ១០០គ.ម។ រាល់ឆ្នាំ ទន្លេសាបហូរត្រលប់ក្នុងទំរង់ជាទឹកជំនន់ពីទន្លេមេគង្គចូលទៅក្នុងបឹងទន្លេសាប និងចាក់បំពេញបឹង
- មានទំហំ ២៥០.០០០-៣០០.០០០ ហិកតា នៅរដូវប្រាំង និងកើនដល់ ១-១,៦ លានហិកតា នៅរដូវវស្សា
- កំពស់ពី ១-២ម ធៀបនឹងនីវ៉ូសមុទ្រនៅរដូវប្រាំង ទៅ ៨-១១ម ពីនីវ៉ូសមុទ្រនៅរដូវវស្សា
- ២០% នៃបរិមាណទឹកជំនន់ទន្លេមេគង្គត្រូវបានស្រូបដោយបឹង និងទន្លេសាប
- ៦២% នៃទឹកទន្លេសាបបានពីទន្លេមេគង្គ
- ៣៨%នៃទឹកទន្លេសាបបានមកពីអាងទន្លេសាប

## ជលផល

- ទន្លេសាប ជាបឹងដែលមានផលិតផលត្រីច្រើនជាងគេមួយលើពិភពលោក និងត្រូវបានប៉ាន់ប្រមាណប្រហែល ៦០%នៃបរិមាណទិន្នផលត្រីទឹកសាបនៅកម្ពុជា
- ជលផល និងធនធានទឹកផ្សេងទៀតត្រូវបានប៉ាន់ប្រមាណនៅតំលៃ ២៣៣លានដុល្លាអាមេរិកក្នុងមួយឆ្នាំ
- នានាភាពត្រីខ្ពស់ ប៉ុន្តែទិន្នផលត្រីភាគច្រើននៅកម្ពុជាសំបូរដោយត្រីចំនួន ១០ប្រភេទ
- ភ្នាក់ងារសហគមន៍ជលផលច្រើនជាង ៤០០ ត្រូវបានបង្កើតឡើងនៅតាមភូមិជុំវិញបឹង ដើម្បីគ្រប់គ្រងធនធានធម្មជាតិទន្លេសាប

- ទិន្នផលត្រីប្រមាណ ២៣០.០០០តោនក្នុងមួយឆ្នាំ នេះត្រូវបានចាត់ទុកថាទាបជាងឆ្នាំមុនៗ ដែលទិន្នផលត្រីប្រចាំឆ្នាំមានរហូតដល់ ៤០០០.០០០តោន
- ទន្លេសាបផ្តល់រហូតដល់ ៨០%នៃប្រូតេអ៊ីនដល់ប្រជាជនកម្ពុជា

## ព្រៃលិចទឹក

- ព្រៃលិចទឹកមានរបាយ និងលក្ខណៈខុសពីព្រៃវាលភក់នៅកន្លែងផ្សេងទៀតនៅលើពិភពលោក
- ព្រៃលិចទឹកមានប្រមាណ ២០០ប្រភេទ
- ព្រៃលិចទឹកដំបូងលាតសន្ធឹងជាង ១លានហិកតា ៦១៤ ០០០ហិកតានៅទស្សវត្សរ៍ទី ៦០ និង ៣៦២.០០០ហិកតា នៅឆ្នាំ១៩៩១។ បច្ចុប្បន្នមាន ទំហំយ៉ាងតិច ២៤០.០០០ ហិកតា

## ប្រជាពលរដ្ឋ

- ប្រជាជនភាគច្រើននៅលើ និងជុំវិញបឹងពឹងអាស្រ័យខ្លាំងលើត្រី និងធនធានទឹកផ្សេងទៀត
- តិចជាង ១០% នៃប្រជាពលរដ្ឋដែលរស់នៅលើ និងជុំវិញបឹងមានទឹកស្អាតសំរាប់បរិភោគ និង បង្គន់សំរាប់ប្រើប្រាស់
- ប្រជាជន ១,២លាននាក់ រស់នៅក្នុងតំបន់ដែលព័ទ្ធជុំវិញដោយផ្លូវជាតិលេខ ៥ និង លេខ ៦ ប្រហែល ៣លាននាក់ រស់នៅក្នុងខេត្ត៥ ដែលជាប់ មាត់ទឹក និងប្រហែល ៣៤០០០០នាក់ រស់នៅជុំវិញបឹង
- ប្រមាណ ៣៧% នៃប្រជាពលរដ្ឋរស់នៅក្នុងបណ្តាខេត្តជុំវិញបឹងឋិតនៅក្រោមខ្សែបន្ទាប់នៃភាពក្រីក្រ
- វិធីនៃការប្រើប្រាស់ឧបករណ៍ខុសច្បាប់រួមមាន : ការដាក់ថ្នាំពុល ការប្រើគ្រឿងផ្ទុះ ការប្រើគ្រឿងអគ្គីសនី និងមងក្រឡាល្អិត
- មានការប៉ាន់ប្រមាណថា មានគ្រួសារច្រើនជាង ៨០% នៅមិនទាន់ទទួលបានទឹកស្អាតប្រើប្រាស់
- ជំងឺគ្រុនចាញ់ គ្រុនឈាម ការប៉ះពាល់ផ្លូវដង្ហើមធ្ងន់ធ្ងរ និងរោគរបេងមួយចំនួនកើតឡើង
- ពាក់កណ្តាលនៃកុមារអាយុក្រោម ៥ឆ្នាំ មិនទទួលបានអាហារគ្រប់គ្រាន់
- កុមារ ៧០%មិនបានបញ្ចប់ថ្នាក់បឋមសិក្សា ធៀបទៅនឹងចំនួនទូទាំងប្រទេសជាតិ ដែលតិចជាង ៦០%

## ជីវៈចំរុះ

- ជាកន្លែងដែលមានការប្រមូលផលពស់ទឹកធំជាងគេលើពិភពលោក ដែលកើនឡើងដោយសារការលួចលាស់ខ្លាំងនៅក្នុងកសិដ្ឋានចិញ្ចឹមក្រពើ
- មានបន្ទាយសត្វស្លាបទឹកកំរធំជាងគេមួយនៅអាស៊ីអាគ្នេយ៍ : ហើយក៏ជាកន្លែងដែលសំខាន់ជាងគេសំរាប់ប្រភេទផ្សេងទៀត ដែលកំពុងរងការគំរាមកំហែង
- ដំបូងមានថនិកសត្វធំៗជាច្រើនដូចជាដំរី ក្របីព្រៃ និងក្តាន់ ប៉ុន្តែទាំងនេះបានបាត់បង់ទៅហើយ
- ប្រភេទរុក្ខជាតិច្រើនជាង ២០០ប្រភេទមាននៅបឹងទន្លេសាប
- ទន្លេសាបមានត្រីយ៉ាងតិច ២២៥ប្រភេទ ល្មូន ៤២ប្រភេទ សត្វស្លាប ២២៥ប្រភេទ និងថនិកសត្វ ៤៦ប្រភេទ

# ០២

# កាលបរិច្ឆេទសំខាន់ៗ



PHOTO: SONJA ENDLWEBER

# កាលបរិច្ឆេទសំខាន់ៗ

**១៨៦៣:** អាជ្ញាធរបានដាក់អោយប្រើប្រាស់ប្រព័ន្ធឡូតិ៍នេសាទជាបរិបាលកិច្ចសក្តិភូមិ ។ ប្រាក់ចំណូលត្រូវបង់ទៅអោយបារាំងនៅឈ្មួងសមុទ្រថៃ ។

**១៨៨៤:** ប្រព័ន្ធឡូតិ៍នេសាទត្រូវបានបោះបង់ចោល ដោយសារមានការបះបោរពីកសិករ ដែលប្រឆាំងតវ៉ាលើការរំលោភទៅលើដែននេសាទរបស់ពួកគេ ។

**១៩០៨:** ប្រព័ន្ធគ្រប់គ្រងឡូតិ៍នេសាទថ្មីបានបង្កើតឡើង មានកំណត់តាមរដូវនេសាទ ការបង្កើតឡូតិ៍បំរុង និងការដាក់កំរិតលើឧបករណ៍នេសាទមួយចំនួន ។ អ្នកភូមិមូលដ្ឋានត្រូវបានគេផ្តល់សិទ្ធិអោយនេសាទនៅក្នុងដែននេសាទ ហើយវិទ្យាស្ថានស្រាវជ្រាវក៏ត្រូវបានបង្កើតឡើងនៅពេលនោះផងដែរ ។ អាណានិគមបារាំងបានប្រើប្រាស់ប្រាក់ចំណូលក្នុងការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ផ្លូវថ្នល់ និងផ្លូវដែក រហូតដល់ទទួលបានឯករាជ្យឆ្នាំ ១៩៥៣ ។

**១៩៥៦:** ច្បាប់នេសាទត្រូវបានដាក់អោយប្រើប្រាស់ ។ ទំនាស់ឡូតិ៍នេសាទបានកើតមានឡើងបន្ទាប់មក ព្រះមហាក្សត្រ នរោត្តម សីហនុ បានបញ្ជាអោយបញ្ឈប់ដំណើរការឡូតិ៍នេសាទមួយចំនួន ។

**ទសវត្សរ៍ទី ៦០:** មានសេចក្តីរាយការណ៍ថា ម្ចាស់ឡូតិ៍នេសាទ និងអ្នកគ្រប់គ្រងឡូតិ៍នេសាទត្រូវបានសំលាប់នៅក្នុងជំលោះជាមួយមន្ត្រីមូលដ្ឋាន និងអ្នកភូមិ ។

**១៩៧០:** អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) បានចាប់ផ្តើមអនុវត្តកម្មវិធីមនុស្ស និងជីវមណ្ឌល ។

**១៩៧១:** សន្និសីទអន្តរជាតិនៅក្នុងទីក្រុងអ៊ីរ៉ង់ បានអនុម័តអនុសញ្ញារ៉ាមសារ ស្តីពី សារៈសំខាន់ជាសកលនៃតំបន់ដីសើម ជាពិសេសការការពារជំរកសត្វបក្សីទឹកត្រូវបានចាត់ចូលក្នុងអនុសញ្ញានេះ ។

**១៩៧៣:** លោក លន់ ណុល ហាមឃាត់មិនអោយធ្វើអាជីវកម្មឡូតិ៍នេសាទទាំងអស់ ។

**១៩៧៥:** ឡូតិ៍នេសាទភាគច្រើនត្រូវបានហាមឃាត់ នៅពេលខ្មែរក្រហមត្រួតត្រាប្រទេសកម្ពុជា ។

**១៩៨៧:** រដ្ឋាភិបាលបានប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងរដ្ឋបាលជលផល ។ ច្បាប់ថ្មីនេះ បានកំណត់ដែននេសាទជាសម្បត្តិសាធារណៈ និងបានបែងចែកការនេសាទជាបីប្រភេទដូចជា ការនេសាទទ្រង់ទ្រាយធំ ការនេសាទទ្រង់ទ្រាយមធ្យម និងការនេសាទទ្រង់ទ្រាយតូច ។

**១៩៩៣:** ក្រសួងបរិស្ថានត្រូវបានបង្កើតឡើង ។ ព្រះរាជក្រឹត្យ ស្តីពីការបង្កើតឡើងនូវប្រព័ន្ធតំបន់ការពារធម្មជាតិ

**១៩៩៤:** ទីភ្នាក់ងារជាច្រើន ដូចជា អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ(FAO) ផ្តួចផ្តើមអោយមានកិច្ចខិតខំប្រឹងប្រែងបង្កើតការគ្រប់គ្រងរួមលើការនេសាទ ។

**១៩៩៥:** ប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាមបានចុះហត្ថលេខា លើកិច្ចព្រមព្រៀង ស្តីពី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតំបន់អាងទន្លេមេគង្គ ។

ជំលោះលើផ្ទៃកនេសាទ ជំលោះលើសិទ្ធិនៃការប្រើប្រាស់ទឹក និងសិទ្ធិកាន់កាប់ដីបានចាប់ផ្តើមរាលដាលរវាងសហគមន៍កសិករ និងសហគមន៍នេសាទ ដូចជា : ម្ចាស់ឡូតិ៍នេសាទ កម្មករឡូតិ៍នេសាទ អាជ្ញាធរមូលដ្ឋាន នគរបាល និងយោធា ។



**១៩៩៦:** រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន និងច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

ប្រទេសកម្ពុជាបានយល់ព្រមចូលជាសមាជិកអនុសញ្ញារ៉ាមសារ ។

អង្គការយូនីស្កូ បានអនុម័តយល់ព្រមលើយុទ្ធសាស្ត្រ និងគំរោងការងារសំរាប់បណ្តាញការងារជាសកលនៃជំបនីយជីវមណ្ឌល ដូចជាសន្និសីទអន្តរជាតិនៅទីក្រុងសេវីល នៃប្រទេសអេស្ប៉ាញនាឆ្នាំ ១៩៩៥ ។

**១៩៩៧:** អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) បានបង្កើតជំបនីយជីវមណ្ឌលបឹងទន្លេសាបឡើង ។

ក្រសួងបរិស្ថានបានផ្តួចផ្តើមរៀបចំគំរោងសាកល្បងនៅព្រែកទាល់ និងសាងសង់ស្ថានីយ៍ស្រាវជ្រាវបរិស្ថានលើកដំបូងនៅកម្ពុជា ។

**១៩៩៨:** បានបង្កើតបណ្តាញការងារជំបនីយជីវមណ្ឌលនៅអាស៊ីអាគ្នេយ៍ ។ ក្រៅពីប្រទេសកម្ពុជា បណ្តាញការងារនេះមានប្រទេសចិន ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ថៃ និង ប្រទេសវៀតណាម ។

**១៩៩៩:** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា ៖ ជាច្រើនឆ្នាំមកនេះ វិស័យជលផល គឺស្ថិតនៅក្នុងសភាព "អនាធិបតេយ្យ" និងមានជំលោះច្រើនទៅលើឡូតិ៍នេសាទ ។

ប្រទេសកម្ពុជាបានបង្កើតតំបន់ដីសើមដែលមានសារៈសំខាន់ជាសាកលចំនួន ០៣ ក្រោមអនុសញ្ញារ៉ាមសារ ដែលក្នុងនោះមាន ៖ បឹងទន្លេឆ្មារ ក្នុងខេត្តកំពង់ធំ ទន្លេមេគង្គប៉ែកខាងជើង ខេត្តស្ទឹងត្រែង និងកោះកាពិនៅខេត្តកោះកុង និងកោះតូចៗនៅជិតនោះ ។

រដ្ឋសភាជាតិបានអនុម័តច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម (និងច្បាប់ ស្តីពី ការគ្រប់គ្រងធនធានទឹក) ។

អនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក និងគ្រប់គ្រងសំណល់រឹងត្រូវបានអនុម័ត ។

សេចក្តីព្រាង ស្តីពី ផែនការសកម្មភាព "ដីសើម" ត្រូវបានរៀបចំឡើង ។

**២០០០:** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសកាត់ឡូតិ៍នេសាទមានផ្ទៃដី ៨០០០ ហ.ត ផ្តល់អោយសហគមន៍គ្រប់គ្រងវិញ និងចាប់ផ្តើមដកមន្ត្រីជលផលដែលប្រព្រឹត្តអំពើពុករលួយចេញ ។ នៅក្នុងដំណាក់កាលនេះ ឡូតិ៍នេសាទប្រទេសកម្ពុជាចំនួន ២៣៩ឡូតិ៍ មានវិសាលភាពសរុបធំជាងមួយលានហិកតា ដែលផ្តល់ប្រាក់ចំណូលប្រហែល ២លានដុល្លា ទៅដល់រដ្ឋាភិបាល ។ ភាគច្រើននៃឡូតិ៍នេសាទដែលបានលុបចោល គឺឡូតិ៍នេសាទមានទំហំតូចៗ និងមានតំលៃនីមួយៗមិនតិចជាង ៣០ លានរៀល ។

**២០០១:** ប្រទេសកម្ពុជាបានក្លាយជាប្រទេសទី១នៅអាស៊ី ដែលបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងមានទីតាំងនៅក្នុងនាយកដ្ឋានជលផល ។ ការិយាល័យនេះបង្កើតឡើងក្នុងគោលបំណងលើកទឹកចិត្តដល់សហគមន៍ក្នុងការដើរតួនាទីសំខាន់លើការគ្រប់គ្រងធនធានជលផល ។

- រដ្ឋាភិបាលបានស្នើសុំដល់អង្គការ ស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ ខេត្តសៀមរាប អោយ

បង្កើតគណៈកម្មការគ្រប់គ្រងជលផលនៅជុំវិញតំបន់ជីវមណ្ឌលបឹងទន្លេសាប ។

- បង្កើតអនុក្រឹត្យ ស្តីពីតួនាទី និងភារកិច្ចនៃលេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ លេខាធិការដ្ឋាននេះ ដឹកនាំដោយលេខាធិការមួយរូបមកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងលេខាធិការរងចំនួន ០៣ រូប មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម ។

- រដ្ឋសភាជាតិ បានអនុម័តច្បាប់ ស្តីពី ដីធ្លី ។

- គណៈកម្មការទន្លេមេគង្គ ប្រទេសចិន និងប្រទេសភូមាបានចុះហត្ថលេខាលើកិច្ចព្រមព្រាងស្តីពីបទបញ្ញត្តិនៃព័ត៌មានជលសាស្ត្រនៃទន្លេ ឡានសាង/ទន្លេមេគង្គ នៅក្នុងរដូវទឹកជំនន់ ។

- ធនាគារអភិវឌ្ឍន៏អាស៊ី បានអនុម័តយល់ព្រមលើគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ដែលមានទឹកប្រាក់ ២០លានដុល្លា និងមានគោលបំណង ដើម្បីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ រៀបចំសហគមន៏ និងអភិរក្សជីវៈចំរុះ ។

- សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទទួលរៀបចំកិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គ ដែលមានថ្នាក់ដឹកនាំមកពីប្រទេសចិន ឡាវ ភូមា វៀតណាម និង ប្រទេសថៃ ព្រមទាំងប្រធានធនាគារអភិវឌ្ឍន៏អាស៊ី ។ ក្នុងពេលកិច្ចប្រជុំកំពូលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពី ការធ្វើពាណិជ្ជកម្មថាមពលក្នុងតំបន់ ។

**២០០៣:** រដ្ឋសភាជាតិ បានអនុម័តច្បាប់ ស្តីពី ព្រៃឈើ ។

**២០០៥:** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៏នេសាទ ត្រូវបានប្រកាសអោយប្រើ ។ ឡូតិ៍នេសាទទាំងអស់ត្រូវបានកំណត់ជាសម្បត្តិសាធារណៈ ដោយមានចែងពីសិទ្ធិសហគមន៏ក្នុងការប្រើប្រាស់

ដែននេសាទ និងសិទ្ធិរបស់ប្រជាពលរដ្ឋដែលមិនរស់នៅក្នុងសហគមន៏ផងដែរ ។

នាយករដ្ឋមន្ត្រីចិន វេន ជាប៉ាវ ទទួលរៀបចំកិច្ចប្រជុំកំពូលនៃបណ្តាថ្នាក់ដឹកនាំប្រទេសនៅក្នុងមហាអនុតំបន់មេគង្គ ។ ថ្នាក់ដឹកនាំនៃប្រទេសទាំងនេះ បានយល់ព្រមបង្កើនល្បឿនកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងទទួលស្គាល់ថា ការបាត់បង់គុណភាពបរិស្ថានគឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនៅក្នុងតំបន់ ។

**២០០៦:** រដ្ឋសភាជាតិបានអនុម័តច្បាប់ថ្មី ស្តីពី ជលផល ។



# ០៣

# សំនួរដែលត្រូវបាន ចោទសួរជាញឹកញាប់



PHOTO: TONY LYNAM WCS

# សំនួរដែលត្រូវបានចោទសួរជាញឹកញាប់

## អ្វី?

### តើឋបនីយជីវមណ្ឌលគឺជាអ្វី?

តំបន់ការពារប្រព័ន្ធអេកូឡូស៊ីសំខាន់ៗនៅលើពិភពលោកត្រូវបានទទួលស្គាល់ជាអន្តរជាតិតាមរយៈអង្គការសហប្រជាជាតិ សំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) ។ ទីភ្នាក់ងារអង្គការសហប្រជាជាតិ បានធ្វើការពិព័ណនាពីតំបន់ទាំងនេះថាជា "ទីពិសោធន៏ភាវៈរស់" សំរាប់ធ្វើការសាកល្បងលើការបញ្ចូលការគ្រប់គ្រងដីធ្លី ទឹក និងជីវៈចំរុះ ។ ឋបនីយនីមួយៗត្រូវបានប្រកាសដោយរដ្ឋាភិបាលនៃប្រទេសនីមួយៗ និងនៅតែឋិតនៅក្រោមការគ្រប់គ្រងរបស់គេ ។

### តើតួនាទីទាំងបីរបស់ឋបនីយជីវមណ្ឌលបឹងទន្លេសាបមានអ្វីខ្លះ?

ឋបនីយនីមួយៗត្រូវបានគេកំណត់ឡើងដើម្បីជួយការពារទេសភាព ប្រព័ន្ធអេកូឡូស៊ី ប្រភេទ និងនានាភាពនៃសែ៊ន ស្របពេលជាមួយនឹងការលើកកំពស់ការអភិវឌ្ឍរបស់មនុស្ស និងស្ថេរភាពសេដ្ឋកិច្ច ។ តួនាទីទីបីគឺដើម្បីទ្រទង់សកម្មភាពផ្សេងៗ រួមមានការអនុវត្តគំរោងបង្ហាញការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការអង្កេតតាមដាន ការប្រែប្រួលបរិស្ថានដែលទាក់ទងនឹងការអភិវឌ្ឍដោយនិរន្តរភាព ការអភិរក្សនៅក្នុងកំរិតមូលដ្ឋាន កំរិតជាតិ និងអន្តរជាតិ ។

### តើអ្វីជាតំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរតំបន់?

រាល់ឋបនីយនីមួយៗមានតំបន់ស្នូលដែលជាតំបន់ការពារយ៉ាងតឹងរឹងជាមួយនឹងការកំណត់អោយមានសកម្មភាពមនុស្សតិចតួច ។ ការកំណត់តំបន់ទ្រនាប់អោយបានច្បាស់លាស់គឺ ដើម្បីការពារតំបន់ស្នូលពីការប្រែប្រួលនៃអន្តរតំបន់ ដែលជាតំបន់ដែលមានការតាំងនៅរបស់មនុស្ស និងការធ្វើកសិកម្ម ។

### តើឋបនីយជីវមណ្ឌលបឹងទន្លេសាបជាអ្វី?

តំបន់ការពារដែលមានទំហំប្រមាណ ១,៥លានហិកតា រាប់បញ្ចូលទាំងផ្ទៃបឹង វាលព្រៃលិចទឹក និងវាលស្មៅលិចទឹក ពិសេសនៅតំបន់ភាគខាងកើត ។ នៅរដូវវស្សា ផ្ទៃបឹងមានទំហំឡើងដល់ ១,៦លានហិកតា ដែលទំហំនេះកើនឡើងរហូតដល់ ៦ដងនៃទំហំបឹងនៅរដូវប្រាំងដែលមានទំហំត្រឹមតែ ២៥0.000ហិកតា ។

### តើមានកត្តាគំរាមកំហែងអ្វីខ្លះចំពោះឋបនីយជីវមណ្ឌលបឹងទន្លេសាប?

ការធ្វើអាជីវកម្មហួសកំរិតលើធនធានព្រៃឈើ មច្ឆា និងសត្វព្រៃ ។ ការគំរាមកំហែងនោះរួមមានការទន្រ្ទានយកដីនៅរដូវប្រាំង និងការកាប់រានព្រៃលិចទឹក ។ កត្តាគំរាមកំហែងជាទូទៅគឺ ការកើនឡើងនូវតំរូវការលើធនធានធម្មជាតិ សំរាប់ឆ្លើយតបនឹងកំណើនប្រជាជន ។

### តើអ្វីទៅជាបណ្តាញឋបនីយជីវមណ្ឌលអាស៊ីអាគ្នេយ៍?

បណ្តាញក្នុងតំបន់នៃឋបនីយដែលបានប្រកាសនៅឆ្នាំ១៩៩៨ ដែលក្នុងនោះមាន ប្រទេសចិន ឥណ្ឌូណេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ថៃ វៀតណាម និងកម្ពុជា ។ ការិយាល័យ UNESCO ដែលតាំងនៅទីក្រុង ហ្សាកាតា បានបង្កើតគេហទំព័រសំរាប់បណ្តាញការងារនេះ ។ ប្រទេសកម្ពុជាបានធ្វើ

ជាម្ចាស់ផ្ទះនៅក្នុងកិច្ចប្រជុំលើកទីបីរបស់បណ្តាញការងារនេះដែលប្រព្រឹត្តឡើងនៅក្នុងខេត្តសៀមរាប ក្នុងឆ្នាំ ២០០៣ និងប្រទេសឡាវបានធ្វើជាម្ចាស់ផ្ទះសំរាប់កិច្ចប្រជុំលើកទីបួននៅឆ្នាំ ២០០៥ ។

### តើគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបជាអ្វី?

ជាគំរោងដែលមានទឹកប្រាក់ ២០លានដុល្លាអាមេរិក ដោយមានការចូលរួមផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍ អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ មូលនិធិបរិស្ថានពិភពលោក និងរដ្ឋាភិបាលកម្ពុជា ។ ក្រុមប្រឹក្សានៃ ADB បានអនុម័តលើគំរោងនេះនៅឆ្នាំ ២០០២ ។ គំរោងនេះមាន ៣ផ្នែកគឺ ការពង្រឹងលើការគ្រប់គ្រងធនធានធម្មជាតិ ការបង្កើតសហគមន៍ និងអភិរក្សជីវៈចំរុះនៅថបនីយជីវមណ្ឌល ។

## តើអ្នកណា?

### តើអ្នកណាជាអ្នកនៅពីក្រោយកម្មវិធីថបនីយជីវមណ្ឌល?

UNESCO ជាអ្នកគ្រប់គ្រងកម្មវិធីដែលមានថបនីយ៤៨២ នៅក្នុងប្រទេសចំនួន១០២ គិតមកដល់ឆ្នាំ ២០០៥ ។ មានគណៈកម្មាធិការប្រឹក្សាមួយពិនិត្យលើការបង្កើតថបនីយ ដើម្បីធ្វើការពារ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិជាទូទៅ ពួកគេធ្វើការជួបប្រជុំគ្នារៀងរាល់ពីរឆ្នាំម្តង ។ ក្រុមប្រឹក្សានេះមានទីតាំងនៅទីក្រុងប៉ារីស និងមានសមាជិកចំនួន ៣៤រូប ដែលធ្វើការបោះឆ្នោតជ្រើសរើសប្រធានមួយរូប និងអនុប្រធាន ៥រូប ។



### តើអ្នកណាជាអ្នកត្រួតពិនិត្យលើថបនីយជីវមណ្ឌលរាប់រយជុំវិញពិភពលោក?

ថបនីយទាំងអស់ត្រូវបានត្រួតពិនិត្យ ទៅតាមក្របខណ្ឌការងារជាសកលរបស់អង្គការ UNESCO ប៉ុន្តែថបនីយជីវមណ្ឌលនីមួយៗត្រូវបានគ្រប់គ្រងទៅតាមប្រទេស ដែលថបនីយជីវមណ្ឌលនោះតាំងនៅ ។ ថបនីយមិនត្រូវបានគ្របដណ្តប់ដោយអនុសញ្ញាអន្តរជាតិឡើយ ប៉ុន្តែគេត្រូវតែគោរពតាមលក្ខន្តិកៈដើម្បីឆ្លើយតបទៅនឹងតួនាទីរបស់ថបនីយ ។

### តើអ្នកណាជាអ្នកត្រួតពិនិត្យលើថបនីយជីវមណ្ឌលបឹងទន្លេសាប?

ក្រសួងបរិស្ថានជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង ការធ្វើផែនការការពារ និងអភិរក្សតំបន់ស្នូលនៃថបនីយជីវមណ្ឌលបឹងទន្លេសាប តាមរយៈការសំរបសំរួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដី ។

### តើអ្នកណាជាអ្នកទទួលរ៉ាប់រងលើគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប?

ការិយាល័យអនុវត្តគំរោងត្រូវបានធ្វើឡើងនៅរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់



និងនេសាទ ក្រសួងបរិស្ថាន និងលេខាធិការដ្ឋានបម្រុងជីវមណ្ឌលបឹងទន្លេសាប ។ គំរោងនេះត្រូវបានពិនិត្យទូទៅដោយគណៈកម្មាធិការតំរែតំរង់ទិសដែលដឹកនាំដោយ ឯកឧត្តម ច័ន្ទ សារុន ដែលជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### តើអ្នកណាជាអ្នកផ្តល់ថវិកាដល់គំរោងគ្រប់គ្រងនេះ?

ភាគច្រើននៃទឹកប្រាក់ ២០លានដុល្លាអាមេរិក នៃគំរោងនេះត្រូវបានផ្តល់ដោយប្រាក់កម្ចី ADB ចំនួន ១០,៩លាន ដុល្លាអាមេរិក ជាមួយរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់ ៣,៩លានដុល្លាអាមេរិក ជារូបិយប័ណ្ណក្នុងស្រុក ។ អង្គការ សហប្រជាជាតិសំរាប់គាំទ្របរិស្ថានពិភពលោក បានផ្តល់ ៣,៩លាន ដុល្លាអាមេរិកផ្សេងទៀតជាជំនួយឥតសំណង និងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) បានផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់ចំនួន ៦២៣.០០០ដុល្លា អាមេរិកផងដែរ ។ ADB ក៏បានផ្តល់បន្ថែមនូវទឹកប្រាក់ ៥៤០.០០០ ដុល្លាអាមេរិកជាជំនួយឥតសំណងលើផ្នែកបច្ចេកទេស ។

## ហេតុអ្វី?

### ហេតុអ្វីបានជាបម្រុងជីវមណ្ឌលមានសារៈសំខាន់?

បម្រុងជីវមណ្ឌលបង្ហាញអោយឃើញថាបឹងទន្លេសាបជាអាងស្តុកជីវៈចំរុះដែលមានសារៈសំខាន់ជាសាកល និងសំខាន់សំរាប់អេកូឡូស៊ី បរិស្ថាន និងភាពចំបងរបស់វាទៅលើផ្នែកវប្បធម៌ ។ ទន្លេសាបគឺជាបឹងទឹកសាបដែលធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលបានផ្តល់នូវទិន្នផលត្រីច្រើនជាងគេមួយលើពិភពលោក និងផ្តល់ដោយផ្ទាល់នូវមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនខ្មែរប្រមាណ ១១% ។ មានប្រជាជនប្រមាណជាងមួយលាននាក់ រស់នៅក្នុងបម្រុងជីវមណ្ឌលបឹងទន្លេសាប ពិសេសនៅក្នុងតំបន់ទ្រនាប់ និងអន្តរតំបន់ ។ ការនេសាទជាសកម្ម

ភាពចំបងមួយ ប៉ុន្តែតំបន់វាលទំនាបក៏ត្រូវបានប្រើដើម្បីធ្វើស្រែ និងការដំណាំផងដែរ ។ គោលដៅចំបងនៃវបបនីយជីវមណ្ឌលគឺ ដើម្បីសិក្សា និងជំរុញលើចំណេះដឹងមូលដ្ឋានរបស់ប្រជាជនអំពីបរិស្ថាន ។ សត្វស្លាបទឹក ប្រមាណជិត ១០០ប្រភេទ ត្រូវបានរកឃើញនៅក្នុងតំបន់នេះ ហើយតំបន់នេះក៏ត្រូវបានគេស្គាល់ថា ជាតំបន់សំរាប់ក្រពើ អណ្តើក ស្វា ភេ និងពស់ទឹករស់នៅផងដែរ ។ ផ្ទៃប្រមាណ ១០% នៃតំបន់គ្របដណ្តប់ដោយ ព្រៃឈើខ្ពស់ៗ ពិសេសនៅតាមស្ទឹង និងតំបន់សើម ។

# កន្លែងណា?

## តើតំបន់ស្នូលវបបនីយឋិតនៅត្រង់ណា?

នៅភាគខាងជើង និងខាងកើតច្រាំងទន្លេ ។ តំបន់ស្នូលធំជាងគេគឺ តំបន់ស្នូលព្រែកទាល់ដែលឋិតនៅក្នុងខេត្តបាត់ដំបង ។ តំបន់ស្នូលពីរផ្សេងទៀតគឺបឹងទន្លេឆ្មារ និងស្ទឹងសែនដែលឋិតនៅក្នុងខេត្តកំពង់ធំ ។ តំបន់ស្នូលព្រែកទាល់ និងបឹងទន្លេឆ្មារគឺជាតំបន់ដែលមានសារៈសំខាន់សំរាប់ជាកន្លែងពងកូន និងកន្លែងរកចំណីសំរាប់ប្រភេទសត្វស្លាបទឹកធំៗដែលកំពុងរងការគំរាមកំហែង ។ តំបន់ស្នូលស្ទឹងសែនសំបូរដោយប្រភេទឈើកំរ និងវាលទំនាប ។

## តើតំបន់ទ្រនាប់ឋិតនៅត្រង់ណា?

តំបន់ទ្រនាប់គ្របដណ្តប់លើផ្ទែកនៃផ្ទៃបឹង និងលាតសន្ធឹងរហូតដល់វាលព្រៃលិចទឹក ។ ភាគច្រើនវាលាតសន្ធឹងនៅក្នុងខេត្តបាត់ដំបង និងគ្របដណ្តប់ក្នុងខេត្តកំពង់ធំ និងខេត្តពោធិ៏សាត់មួយភាគធំ និងនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តសៀមរាបមួយភាគតូច ។ តំបន់ទ្រនាប់ក៏ជាតំបន់ដែលត្រូវបានកំណត់ដោយព្រះរាជក្រិត្យថាជា "តំបន់ប្រើប្រាស់ច្រើនយ៉ាង" នៅឆ្នាំ ១៩៩៣ ។



PHOTO: WCS

### តើអន្តរតំបន់ឋិតនៅត្រង់ណា?

តំបន់នេះលាតសន្ធឹងនៅភាគខាងកើតខេត្តបន្ទាយមានជ័យរហូតដល់ភាគខាងត្បូងខេត្តកំពង់ឆ្នាំង ។ ព្រំប្រទល់ខេត្តបាត់ដំបង ពោធិ៍សាត់ និងខេត្តសៀមរាបតាមបណ្តោយផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦ និងលាតសន្ធឹង រហូតដល់ផ្លូវជាតិទាំងពីរនៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ តំបន់នេះរាប់បញ្ចូលទាំងផ្នែកខ្លះនៃខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងសៀមរាប ក៏ដូចជាស្វាយសុីសូផុន ប៉ុន្តែមិននៅក្នុងទីរួមខេត្តកំពង់ធំទេ ។

## នៅពេលណា?

### តើឋបនីយជីវមណ្ឌលរបស់អង្គការ UNESCO ចាប់ផ្តើមបង្កើតឡើងនៅពេលណា?

នៅឆ្នាំ ១៩៩៧ គឺនៅពេលដែលទីភ្នាក់ងារនេះបានប្រកាស "កម្មវិធីមនុស្ស និងជីវមណ្ឌល" របស់គេដើម្បីបង្កើតតំបន់ការពារសំរាប់ប្រព័ន្ធអេកូឡូសុីសំខាន់ៗ ។ ការអំពាវនាវពីកម្មវិធីនេះត្រូវបានធ្វើឡើងនៅឯសន្និសីទ UNESCO នៅឆ្នាំ ១៩៦៨ មកម្លេះ ។

### តើអង្គការ UNESCO បានព្រមព្រៀងលើយុទ្ធសាស្ត្រ និងក្របខណ្ឌការងារជាសកលរបស់គេ សំរាប់ឋបនីយជីវមណ្ឌលនៅពេលណា?

នៅឆ្នាំ ១៩៩៦ បន្ទាប់ពីសន្និសីទក្រុងសេវីលនៅប្រទេសអេស្ប៉ាញឆ្នាំ ១៩៩៥ ។

### តើឋបនីយជីវមណ្ឌលបឹងទន្លេសាបត្រូវបានបង្កើតឡើងនៅឆ្នាំណា?

បន្ទាប់ពីមានសេចក្តីសំរេចជាផ្លូវការរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិ សំរាប់កម្មវិធីមនុស្ស និងជីវមណ្ឌល របស់អង្គការ UNESCO ក្នុងការ



បញ្ចូលបឹងទន្លេសាបទៅក្នុងប្រព័ន្ធឋបនីយជីវមណ្ឌលពិភលោក នៅសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិនៅ ថ្ងៃទី ២៧-២៩ ខែតុលា ឆ្នាំ ១៩៩៧ ឋបនីយជីវមណ្ឌលបឹងទន្លេសាបត្រូវបានបង្កើតជាផ្លូវការដោយព្រះរាជក្រិត្យនៅ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១

### តើយុទ្ធសាស្ត្រអាងទន្លេសាបរបស់ ADB បានតាក់តែងឡើងនៅពេលណា?

យុទ្ធសាស្ត្រនេះត្រូវបានកំណត់ថយក្រោយទៅកាន់ឆ្នាំ ២០០៣ និងគាំទ្រលើយុទ្ធសាស្ត្ររបស់ ADB និង កម្មវិធីឆ្នាំ ២០០៥ ដល់ ២០០៦ ។ ធនាគារនេះបានលើកឡើងនៅឆ្នាំ ២០០៥ ថាយុទ្ធសាស្ត្រអាងស្តុកដែលបាន "ការផ្តល់ព័ត៌មាន និងសន្ទាប់ " ក្នុងចំណោមគោលការណ៍អនុវត្តសំខាន់ៗរបស់វា គួរជាមូលដ្ឋានគ្រឹះសំរាប់បង្កើតអាទិភាព និងជំនួយលើការធ្វើផែនការសំរាប់ប្រទេសកម្ពុជានៅរយៈពេលពី ៥ ទៅ ១០ឆ្នាំខាងមុខ ។

ប្រភព : ADB, UNESCO គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

# ០៤

# តំបន់ការពារធម្មជាតិ



# តំបន់ការពារធម្មជាតិ

ការការពារធម្មជាតិគឺជាការយកចិត្តទុកដាក់មួយនៅប្រទេសកម្ពុជា ។ ការបំផ្លាញជំរកដែលបង្កឡើងដោយសេដ្ឋកិច្ចសង្គមនៃប្រទេស ភូមិសាស្ត្រ និងលក្ខខណ្ឌអាកាសធាតុ ។ អ្នកជីវវិទូសត្វព្រៃភាគច្រើនជឿជាក់ថា វិធីល្អបំផុតដើម្បីបង្ការមិនឱ្យមានការបាត់បង់ប្រភេទសត្វព្រៃគឺ ធ្វើការបង្កើត និងថែរក្សាដែនបំរុង ឧទ្យាន ដែនជំរកសត្វព្រៃ និងតំបន់ការពារផ្សេងទៀត ។

ប្រទេសកម្ពុជាបានបង្កើតឧទ្យានជាតិដំបូងគេបង្អស់នៅអាស៊ីអាគ្នេយ៍នៅឆ្នាំ ១៩២៥ នៅពេលដែលមានការប្រកាសថា ១០.៨០០ ហិកតា នៃផ្ទៃដីព្រៃឈើនៅជុំវិញអង្គរជាតំបន់ការពារ ។ រហូតដល់ឆ្នាំ ១៩៦៩ ប្រទេសកម្ពុជាមានឧទ្យានជាតិចំនួន ៦ និងដែនជំរកសត្វព្រៃដែលគ្រប់ដណ្តប់ជិត ២,២ លានហិកតា ដែលប្រមាណស្មើ នឹង ១២% នៃផ្ទៃដីសរុប ។ នៅឆ្នាំ ១៩៩៣ ព្រះបាទ នរោត្តម សីហនុ បានចេញព្រះរាជក្រិត្យកំណត់តំបន់ការពារចំនួន ២៣កន្លែង គ្របដណ្តប់ផ្ទៃដីប្រមាណ ៣,៣លានហិកតា ដែលក្នុងនោះមាន ឧទ្យានជាតិ៧កន្លែង ដែនជំរកសត្វព្រៃ ១០កន្លែង តំបន់ការពារទេសភាព ៣កន្លែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ៣កន្លែង ។ ចំណាត់ថ្នាក់តំបន់ទាំងបួននោះ យោងទៅលើលក្ខណៈខុសៗគ្នា និងគោលបំណងនៃការគ្រប់គ្រង ដើម្បីឆ្លើយតបនឹងចំណាត់ថ្នាក់ជាអន្តរជាតិដោយអង្គការសហភាពអភិរក្សពិភពលោក (IUCN) ។

តំបន់ការពារដើរតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ការការពារទីជំរាលទឹកភ្លៀង និងផ្តល់ជំរកសំរាប់រុក្ខជាតិ និងសត្វព្រៃ ។ នៅពេលដែលតំបន់មួយត្រូវបានការពារនោះ វាមានការងាយស្រួលអនុវត្តការស្រាវជ្រាវពីជីវិតសត្វ ព្រៃ (ខ្លា ដំរីជាដើម) និងធ្វើការប្រមូលទិន្នន័យបឋមទៅលើអេកូឡូស៊ី និងការប្រើប្រាស់របស់មនុស្សទៅតាមរដូវក៏ដូចជាការទទួលផល ។ ព័ត៌មានពីតំបន់មូលដ្ឋានត្រូវបានចែករំលែកទៅដល់អ្នកពាក់ព័ន្ធតាមរយៈសិក្ខាសាលាការវាយតំលៃដំបូង និងអាទិភាពនៃការអភិរក្សត្រូវបានបង្កើតឡើង ។

រហូតដល់ដើមឆ្នាំ ២០០១ ក្រសួងបរិស្ថានបានអនុម័ត និងជួលឧទ្យានុរក្ស ៥២៥នាក់ សំរាប់ ៥៩ ស្ថានីយ ដើម្បីធ្វើការល្បាតតំបន់ការពារ ។ នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថានធ្វើការសហការយ៉ាងជិតស្និតជាមួយអង្គការអភិរក្សជាច្រើនដើម្បីជំរុញដល់ការកសាងសមត្ថភាពការអប់រំបរិស្ថាន ការបង្កើនជីវភាពសហគមន៍ និងតំបន់ការពារ ។

វេទិកាដែលផ្អែកលើប្រព័ន្ធការពារជំរកសត្វស្លាបនៅតំបន់ស្នួលព្រែកទាល់ ត្រូវបានធ្វើការសាកល្បងនៅឆ្នាំ ២០០១ ត្រូវបានពង្រីក និងគ្របដណ្តប់លើគ្រប់បន្ទាយសត្វទាំងអស់នៅក្នុងតំបន់ ។ គ្របដណ្តប់លើចំនួនពងកូននៃប្រភេទសត្វស្លាបទឹកសំខាន់ៗនៅក្នុងតំបន់ប្រមាណជិត១០០% ។

តំបន់ការពារមួយចំនួនត្រូវបានរងការគំរាមកំហែង ។ ទាំងនេះបណ្តាលមកពីភាពធូរលុងនៅក្នុងការគ្រប់គ្រងការនេសាទ ការកាប់ព្រៃខុសច្បាប់ ការប្រមូលអុស និងអនុផលព្រៃឈើ ការបាត់បង់ជំរក និងការរំខានដែលបណ្តាលមកពីសកម្មភាពរបស់មនុស្ស ។

ប្រភព : ធនាគារអភិវឌ្ឍន៍អាស៊ី លោកជេឌី ស្មីត និង ប្រែដរីក ហ្គីស

ផែនទី តំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា PROTECTED AREAS MAP OF CAMBODIA



# ០៥

# ឋបនីយជីវមណ្ឌល
# បឹងទន្លេសាប



# ឋបនីយជីវមណ្ឌល បឹងទន្លេសាប

ឋិតនៅក្រោមកម្មវិធីដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៧០ អង្គការសហប្រជាជាតិសំរាប់ការអប់រំ វប្បធម៌ និងវិទ្យាសាស្ត្រ (UNESCO) បានកំនត់បឹងទន្លេសាប និងទំនាបលិចទឹកនៅជុំវិញជា "ឋបនីយជីវមណ្ឌល" នៅឆ្នាំ ១៩៩៧។ តំបន់នេះមានទំហំប្រមាណ ១,៥ លាន ហិកតា ដោយគ្របដណ្តប់លើផ្ទៃបឹង និងតាមដងផ្លូវជាតិលេខ ៥ និង ៦។ នៅឆ្នាំ ២០០៥ ឋបនីយនេះជាឋបនីយជីវមណ្ឌលមួយក្នុងចំណោមឋបនីយទាំង ៤៨២ ក្នុងប្រទេសចំនួន ១០២ ប្រទេស។ ឋបនីយជីវមណ្ឌលបឹងទន្លេសាបឋិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ ដែលមានលេខាធិការនៃគណៈកម្មាធិការនេះជាប្រធាន  និងលេខាធិការរង ៣រូប ទៀតមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម។ ក្រសួងទាំងបីក៏បានចូលរួមគ្រប់គ្រងនៅក្នុងគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបដោយមានការចូលរួមឧត្ថម្ភថវិកា ដោយធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារអង្គការសហប្រជាជាតិ។

ឋបនីយនេះរាប់បញ្ចូលទាំងផ្ទៃបឹង ព្រៃលិចទឹក និងវាលស្មៅលិចទឹក ពិសេសនៅប៉ែកខាងកើតច្រាំង។ នៅរដូវវស្សាផ្ទៃបឹងកើនឡើងដល់ ១,៦លានហិកតាដែលទំហំនេះកើនឡើងប្រមាណ ៦ដង នៃទំហំនៅរដូវប្រាំង ដែលមានត្រឹមតែ ២៥០ ០០០ហិកតា។ បរិមាណទឹកស្ទើរតែ ២/៣នៃបឹងនេះបានមកពីទន្លេមេគង្គ និង ១/៣ ទៀតបានពីអាងស្តុកផ្សេងៗក្នុងនោះមានស្ទឹងសែន និងស្ទឹមពោធិ៍សាត់ជាដើម។ ប្រហែលជា ១០% នៃតំបន់គ្របដណ្តប់ដោយដើមឈើខ្ពស់ៗពិសេសនៅតាមស្ទឹង និងតំបន់សើម។

ព្រៃលិចទឹករបស់បឹងទន្លេសាបសំបូរដោយប្រភេទព្រៃគុម្ពោធ និងព្រៃរនាមជាងគេនៅក្នុងតំបន់អាស៊ីទាំងមូល។ នៅឆ្នាំ ១៩៩៧ ត្រូវបានប៉ាន់ប្រមាណថា អាចលាតសន្ធឹងលើផ្ទៃ ៣៥០.០០០ ហិកតា ដែលប្រហែលជា ១/៣នៃតំបន់ទាំងមូល។ ព្រៃលិចទឹកមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់ត្រី ពពួកសត្វស្លាបទឹក និងពពួកល្មូន។

ឋបនីយជីវមណ្ឌលមានតំបន់ស្នូល ៣គឺ ព្រែកទាល់ ដែលឋិតក្នុងខេត្តបាត់ដំបង តំបន់ស្នូលបឹងទន្លេឆ្មារ និងស្ទឹងសែនឋិតនៅខេត្តកំពង់ធំ។ ពពួកសត្វស្លាបទឹកប្រមាណជា ១០០ប្រភេទ ត្រូវបានគេរកឃើញនៅក្នុងតំបន់ស្នូលទាំងបីដែលមានទំហំសរុបប្រមាណជា ៤២០០០ ហិកតា។ មានប្រភេទត្រីប្រមាណជាង ៤០០ប្រភេទក៏ត្រូវបានគេឃើញមាននៅក្នុងតំបន់នេះដែរ ហើយក៏រួមបញ្ចូលទាំងក្រពើ អណ្តើក ស្វា ភេ និងពស់ទឹក។ តំបន់ស្នូលទាំងនេះមានទំហំ ២១.៣៤២ហិកតា សំរាប់តំបន់ស្នូលព្រែកទាល់ ១៤.៥៦០ហិកតា សំរាប់តំបន់ស្នូលបឹងទន្លេឆ្មារ ដែលត្រូវបានគេរាប់បញ្ចូលផងដែរថា ជាតំបន់ដីសើមអន្តរជាតិដោយអនុសញ្ញារ៉ាមសារដែលមានសារៈសំខាន់ទាំង សំរាប់សត្វស្លាបទឹកធំៗធ្វើការពងកូន និងកន្លែងសំរាប់រកចំណីដែលសត្វស្លាបទាំងនេះមានមួយចំនួនជាប្រភេទដែលកំពុងរងការគំរាមកំហែងលើពិភពលោក។ សំរាប់តំបន់ស្នូលស្ទឹងសែនមានទំហំ ៦.៣៩៥ហិកតា និងសំបូរដោយពពួកប្រភេទព្រៃលិចទឹកកំរ។ ក្រសួងបរិស្ថានបានប៉ាន់ប្រមាណថា មានប្រជាជនតិចជាង ២០.០០០នាក់ រស់នៅក្នុងតំបន់ស្នូលទាំងនេះ ដោយក្នុងនោះមានប្រមាណ ១០.០០០នាក់ នៅក្នុងតំបន់ព្រែកទាល់ ២.០០០នាក់ នៅបឹងទន្លេឆ្មារ និង ប្រហែលជា ៧.០០០នាក់ នៅក្នុងតំបន់ស្នូលស្ទឹងសែន។



បន្ទាយមានជ័យ
ស៊ីសុផុន
មង្គលបុរី
សៀមរាប
សៀមរាប
បាត់ដំបង
បាត់ដំបង
ទន្លេសាប
មោងឫស្សី
កំពង់ធំ
កំពង់ធំ
ពោធិ៍សាត់
ក្រគរ
ពោធិ៍សាត់
កំពង់ឆ្នាំង
កំពង់ចាម
ភូមិស្តុក
កំពង់ចាម
កំពង់ឆ្នាំង
ទន្លេមេគង្គ
តំបន់រាំមសារ
អន្តរតំបន់
តំបន់ទ្រនាប់
តំបន់ស្នូល
ដែនជំរកត្រី
ទីរួមខេត្ត
ក្រុង
ផ្លូវជាតិ
ផ្លូវដែក
ទន្លេ
ព្រំប្រទល់ខេត្ត

តំបន់ទ្រនាប់ គ្របដណ្ដប់លើផ្ទៃបឹង និងលាតសន្ធឹងទៅដល់ព្រំប្រទល់ព្រៃលិចទឹកខាងក្រៅ។ វាលាតសន្ធឹងធំនៅក្នុងខេត្តបាត់ដំបង និងគ្របដណ្ដប់នៅក្នុងខេត្តកំពង់ធំ និងពោធិ៍សាត់ និងភាគខ្លះនៃខេត្តកំពង់ឆ្នាំង ។ ដោយមិនរាប់បញ្ចូលតំបន់ស្នូលទាំងបី តំបន់ទ្រនាប់នេះមានទំហំ ៥៤១.៤៨២ហិកតា ហើយក៏ត្រូវបានកំនត់ដោយព្រះ
រាជក្រិត្យថា ជាតំបន់ប្រើប្រាស់ច្រើនយ៉ាង (ផ្នែកមួយនៃតំបន់ការពារធម្មជាតិ) នៅក្នុងឆ្នាំ ១៩៩៣ ។ នៅក្នុងតំបន់នេះមានភូមិបណ្ដែតទឹកប្រមាណ ៦០ភូមិ ដែលមានប្រជាជនប្រហែល ៧០.០០០ នាក់ ។

តំបន់ទ្រនាប់ត្រូវបានព័ទ្ធជុំវិញដោយអន្តរតំបន់ ដែលតំបន់នេះពទ្ធ័ជុំវិញដោយផ្លូវជាតិលេខ ៥ និងលេខ ៦ ក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ និងសៀមរាប។ វាលាតសន្ធឹងរហូតដល់ផ្លូវជាតិពីរនៅក្នុងខេត្តកំពង់ឆ្នាំង និងកំពង់ធំ



ដែលរាប់ពីភាគខាងត្បូងខេត្តកំពង់ឆ្នាំង រហូតដល់ស៊ីសុផុននៅភាគខាងជើង ។ តំបន់នេះលាតសន្ធឹងលើផ្ទៃប្រមាណ ៨៩៩.៦០០ហិកតា ដោយរាប់បញ្ចូលទាំងផ្នែកនៃក្រុងមួយចំនួនក្នុងខេត្តពោធិ៍សាត់ និងខេត្តសៀមរាប ប៉ុន្តែមិនឋិតនៅក្នុងខេត្តកំពង់ធំឡើយ ។ ចំនួនប្រជាជនមានប្រមាណជា ១,៦លាននាក់ រស់នៅក្នុងអន្តរតំបន់នេះ ។

ការនេសាទគឺជាសកម្មភាពចំបង ប៉ុន្តែវាលទំនាបលិចទឹកក៏ត្រូវបានគេប្រើសំរាប់ធ្វើស្រែ និងដាំដុះពពួកបន្លែផ្សេងៗទៀតផងដែរ ។គោលដៅចំបងរបស់ថបនីយជីវមណ្ឌលគឺដើម្បីសិក្សា និងជំរុញលើចំនេះដឹងមូលដ្ឋានលើអេកូឡូស៊ី ។

## បណ្ដាញក្នុងតំបន់របស់ថបនីយជីវមណ្ឌល

កម្ពុជាគឺជាផ្នែកមួយនៃបណ្ដាញថបនីយជីវមណ្ឌលតំបន់អាស៊ីអាគ្នេយ៍ ដែលចាប់ដំណើរការតាំងពីឆ្នាំ ១៩៩៨។ សមាជិកផ្សេងទៀតមាន ប្រទេសចិន ឥណ្ឌូនេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ថៃ និងវៀតណាម ។ ការិយាល័យ UNESCO នៅទីក្រុងហ្សាកាតា បានបង្កើតជា គេហទំព័រ សំរាប់បណ្ដាញ ដែលត្រូវបានគេស្គាល់ថា SeaBRnet ។ កម្ពុជា និងអង្គការ UNESCO បានរៀបចំការប្រជុំលើកទី៣ សំរាប់បណ្ដាញក្នុងតំបន់នៅក្នុងខេត្តសៀមរាបនៅឆ្នាំ ២០០៣ ដោយមានជំនួយពីប្រទេសជប៉ុន ការរៀបចំប្រជុំលើកទី៤ ត្រូវបានរៀបចំឡើងនៅប្រទេសថៃ ក្នុងឆ្នាំ ២០០៥ ។

បណ្ដាញក្នុងតំបន់ផ្សេងទៀតមានដូចជា បណ្ដាញថបនីយជីវមណ្ឌលអឺរ៉ុប ដែលចាប់ផ្ដើមនៅឆ្នាំ ១៩៨៧ និងថបនីយជីវមណ្ឌលអាស៊ីខាងកើតដែលចាប់ផ្ដើមនៅឆ្នាំ ១៩៩៤។



PHOTO: ELEANOR BRIGGS WCS









PHOTO: ELEANOR BRIGGS WCS

បណ្តាញក្នុងតំបន់ក៏មានសំរាប់ឋបនីយជីវមណ្ឌលក្នុងបណ្តាប្រទេសនៅអាហ្វ្រិច និងអារ៉ាប់ ក៏ដូចជានៅអាមេរិកឡាទីន អេស្បាញ និង ព័រទុយហ្គាល់ ។

## សារៈសំខាន់ដីសើមកម្ពុជា

អនុសញ្ញាដីសើមត្រូវបានធ្វើឡើងនៅទីក្រុងរ៉ាមសារ ក្នុងប្រទេសអ៊ីរ៉ង់ ក្នុងឆ្នាំ ១៩៧១។ ឋិតក្រោម អនុសញ្ញារ៉ាមសារ ប្រទេសជាច្រើនបានកំនត់ដីសើមជាសារៈសំខាន់សំរាប់ពិភពលោកដោយផ្តោតទៅលើ អេកូឡូស៊ី រុក្ខសាស្ត្រ បសុសាស្ត្រ និងជលវិទ្យា។ នៅឆ្នាំ ២០០៥ បញ្ជីរ៉ាមសារនៃដីសើមដែលមានសារៈសំខាន់ ជាអន្តរជាតិ មានចំនួន ១៤៦២កន្លែង គ្របដណ្តប់លើផ្ទៃប្រមាណ ១២៥លានហិកតា នៅក្នុងប្រទេស ១៤៦ ។

កម្ពុជាមានតំបន់រ៉ាមសារ ៣ ដែលមានទំហំ ៥៤.៦០០ហិកតា ត្រូវបានកំនត់នៅថ្ងៃ ២៣ មិថុនា ឆ្នាំ ១៩៩៩។ តំបន់ដែលធំជាងគេគឺបឹងទន្លេឆ្មារ និងប្រព័ន្ធព្រៃកជុំវិញក្នុងខេត្តកំពង់ធំ ដែលមានទំហំ ២៨.០០០ ហិកតា។ ប្រមាណជាពាក់កណ្តាលតំបន់ដីសើមនេះជាផ្នែកនៃតំបន់ស្នូលរបស់ឋបនីយជីវមណ្ឌល។ តំបន់ដីសើមទីពីរ មានទំហំ១៤.៦០០ហិកតា ឋិតនៅភាគខាងជើងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង។ តំបន់ ទីបី គឺ កោះកាពិ និងកោះនៅជុំវិញ ដែលមានទំហំ ១២.០០០ហិកតា ក្នុងខេត្តកោះកុង។ សហគមន៍អន្តរជាតិបានកត់សំគាល់ថាតំបន់ទាំងបីនេះមាន "តំលៃជាពិសេស" សំរាប់ប្រទេស និងប្រជាជនកម្ពុជាទាំងមូល។

នៅឆ្នាំ ១៩៩៩ សមាជិកនៃអនុសញ្ញារ៉ាមសារបានយល់ព្រមលើគោលការណ៍ និង គំរោងផែនការសំរាប់បង្កើតបណ្តាញដីសើមអន្តរជាតិ។ ដោយយោងលើគំរោងផែនការតំបន់ដែលត្រូវបានកំនត់ក្នុងបញ្ជីរ៉ាមសារគួរជាតំបន់ដែលមាន "សារៈសំខាន់សំរាប់ការអភិរក្សជីវៈចំរុះលើពិភពលោក និងសំរាប់ធានានូវជីវិតមនុស្សតាមរយៈតួនាទីអេកូឡូស៊ី និងចរន្តទឹក" ។ នៅឆ្នាំ ២០០០ រដ្ឋលេខាធិការនៃអនុសញ្ញាដីសើមបានស្វែងរកយុគសម័យថ្មី សំរាប់អាទិភាពរួមដើម្បីជំនួសនូវអាទិភាពដដែលៗដែលមាននៅក្នុងតំបន់រ៉ាមសារ និងឋបនីយជីវមណ្ឌល។ ឋិតនៅក្រោមប្រព័ន្ធដដែលៗដែលមាននេះ តំបន់ដីសើម ៣៣កន្លែង ត្រូវបានកំនត់ជាតំបន់រ៉ាមសារ ដែលឋិតនៅជាមួយ រឺជាន់គ្នានឹងឋបនីយជីវមណ្ឌលដែលកំនត់ដោយ UNESCO ។

## តួនាទី UNESCO នៅក្នុងឋបនីយជីវមណ្ឌល

ឋបនីយជីវមណ្ឌលជាការកំនត់ត្រលប់ទៅកាន់ឆ្នាំ ១៩៦៨ ពេលដែលសន្និសីទ UNESCO អំពាវនាវឱ្យមានកម្មវិធីសំរាប់បង្កើតតំបន់ដីគោក និងតំបន់ឆ្នេរ ដើម្បីតំណាងឱ្យប្រព័ន្ធអេកូឡូស៊ីសំខាន់ៗលើពិភពលោក។ UNESCO ចាប់ផ្តើមកំនត់ទំរង់នៅឆ្នាំ ១៩៧០ ខណៈដែលភ្នាក់ងារដែលមានទីតាំងនៅទីក្រុងប៉ារីសបានបង្កើតកម្មវិធី "មនុស្ស និងជីវមណ្ឌល" ដោយឱ្យមានតំបន់ការពារដែលត្រូវបានស្គាល់ថាជាឋបនីយជីវមណ្ឌល។ នៅឆ្នាំ ១៩៩៥ បានធ្វើសន្និសីទអន្តរជាតិមួយនៅទីក្រុងស៊ីវិល បានយល់ព្រមលើយុទ្ធសាស្ត្រឋបនីយជីវមណ្ឌល និងគំរោងផែនការបណ្តាញពិភពលោកនៃឋបនីយជីវមណ្ឌលនៅឆ្នាំ ១៩៩៦ ។

ដោយត្រូវបានកំនត់ឈ្មោះដោយរដ្ឋាភិបាល ឋបនីយជីវមណ្ឌលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ប៉ុន្តែវាត្រូវបានគ្រប់គ្រងដោយបណ្តាប្រទេសដែលជាម្ចាស់ឋបនីយជីវមណ្ឌលនោះ។ UNESCO ធ្វើការពណ៌នាពីឋបនីយជីវមណ្ឌលថាជា "ទីពិសោធន៍



សំរាប់ការរស់នៅ” សំរាប់សាកល្បងលើការបញ្ចូលការគ្រប់គ្រងដី ទឹក និងជីវៈ ចំរុះ ។ ឋបនីយជីវមណ្ឌលនីមួយៗត្រូវបានរំពឹងថា នឹងជួយអភិរក្សទេសភាព ស្ថានប្រព័ន្ធ នានាភាពនៃប្រភេទ និងសែនស្របពេលជាមួយនឹងការផ្គត់ផ្គង់សំរាប់ការអភិវឌ្ឍរបស់មនុស្ស និងសេដ្ឋកិច្ច ។ តួនាទី ទី៣ គឺដើម្បីជួយដល់ការស្រាវជ្រាវ ត្រួតពិនិត្យ ការអប់រំ និងផ្លាស់ប្តូរព័ត៌មាន ។ ឋបនីយជីវមណ្ឌលមិនត្រូវបានគ្របដណ្តប់ដោយអនុសញ្ញាអន្តរជាតិឡើយ ប៉ុន្តែគេត្រូវតែគោរពតាមលក្ខន្តិកៈ ដើម្បីឆ្លើយតបទៅនឹងតួនាទីទាំងបីរបស់ឋបនីយ ។

## ឋបនីយជីវមណ្ឌលនីមួយៗមានតំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរតំបន់។

តំបន់ស្នូលនៃឋបនីយជីវមណ្ឌល គួរតែបង្កើតដោយស្របច្បាប់ និងផ្តល់នូវការពារយូរអង្វែងលើទេសភាព ប្រព័ន្ធអេកូឡូស៊ី និងប្រភេទសត្វ និង រុក្ខជាតិដែលមាននៅក្នុងតំបន់នោះ ។ ជាមធ្យមតាតំបន់ស្នូលមិនអនុញ្ញាតឱ្យមានសកម្មភាពមនុស្សឡើយ លើកលែងតែការស្រាវជ្រាវ ការត្រួតពិនិត្យ និងការប្រើប្រាស់ជាលក្ខណៈប្រពៃណីដែលធ្វើឡើងដោយប្រជាជនក្នុងតំបន់ប៉ុណ្ណោះ ។ តំបន់ទ្រនាប់ ដែលនៅជុំវិញតំបន់ស្នូលអាចមានការស្រាវជ្រាវ ដើម្បីគ្រប់គ្រងលើការដាំដុះតាមបែបធម្មជាតិ ដីដំណាំ ព្រៃឈើ និងជលផល ដើម្បីបង្កើនទិន្នផលក្នុងខណៈដែលយើងធ្វើការអភិរក្សជីវៈចំរុះ និងធម្មជាតិអោយបានច្រើនតាមដែលអាចទៅរួច ។ តំបន់ទាំងនេះអាចត្រូវបានប្រើផងដែរ សំរាប់ការអប់រំ វគ្គបណ្តុះបណ្តាល ទេសចរណ៍ និងការបង្កើតថ្មី ។ អន្តរតំបន់លាតសន្ធឹងបន្ទាប់ពីតំបន់ទ្រនាប់ដែលតំបន់នេះអាចមានលំនៅដ្ឋានមនុស្ស ការធ្វើកសិកម្ម និងសកម្មភាពផ្សេងទៀត ។ តំបន់ស្នូលភាគច្រើនជាដីសាធារណៈ ប៉ុន្តែក៏អាចជាកម្មសិទ្ធិឯកជន រឺគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលផងដែរ ។ មានករណីជាច្រើនដែលដីនៅក្នុងតំបន់ទ្រនាប់ និងអន្តរតំបន់ ជាកម្មសិទ្ធិរបស់សហគមន៍ រឺកម្មសិទ្ធិឯកជន ។

## ឋបនីយជីវមណ្ឌលមួយចំនួនគឺជាឧទ្យានជាតិ កន្លែងរក្សាទុកធម្មជាតិ និងជាកន្លែងដែលមានការកត់សំគាល់ជាអន្តរជាតិដោយបេតិកភណ្ឌពិភពលោក និងអនុសញ្ញារ៉ាមសារ ។

សហគមន៍ក្នុងតំបន់ និងការពាក់ព័ន្ធនៅ

ក្នុងកសិកម្ម រុក្ខាកម្ម និងជលផលត្រូវបានមើលឃើញដោយអង្គការ UNESCO ថាជាផលប្រយោជន៍ចំបងសំរាប់ថបនីយជីវមណ្ឌលដោយស្របជាមួយអ្នកវិទ្យាសាស្ត្រ រដ្ឋាភិបាល និងពិភពលោកទាំងមូល ។

ដើម្បីក្លាយជាថបនីយជីវមណ្ឌលបាន តំបន់នោះត្រូវជា "តំណាងអោយជីវៈសំខាន់ៗរបស់តំបន់" ដោយរួមជាមួយតំបន់ទេសភាពស្ថានប្រព័ន្ធ រឺប្រភេទសត្វ និងរុក្ខជាតិ រឺនានាភាពដែលចាំបាច់សំរាប់ធ្វើការអភិរក្ស។ តំបន់នោះត្រូវមានទំហំគ្រប់គ្រាន់សំរាប់កំនត់ជាផ្លូវច្បាប់ថាជាតំបន់ស្នូល ដើម្បីធ្វើការការពារក្នុងរយៈពេលវែង ដោយមានការកំនត់ច្បាស់លាស់ទៅលើតំបន់ទ្រនាប់ និងអន្តរតំបន់ ។ អាជ្ញាធរមូលដ្ឋានសហគមន៍ក្នុងតំបន់ និងផ្នែកឯកជនគួរមានការចូលរួមក្នុងការធ្វើផែនការ និងគ្រប់គ្រងថបនីយជីវមណ្ឌល ក្នុងករណីដែលតំបន់ធម្មជាតិមានទំហំធំឋិតនៅជាប់នឹងព្រំប្រទល់ប្រទេសពីរ រឺច្រើន អង្គការ UNESCO ជំរុញអោយប្រទេស ដែលមានព្រំប្រទល់ជាប់ទាំងនោះធ្វើការគ្រប់គ្រងរួមគ្នា ។

ទីប្រឹក្សាគណៈកម្មាធិការ UNESCO ពិនិត្យលើគ្រប់ការកំណត់លើជីវមណ្ឌល និងធ្វើអនុសាសន៍ទៅកាន់ក្រុមប្រឹក្សាអន្តរជាតិដែលតែងតែជួបប្រជុំរាល់២ឆ្នាំម្តង។ ក្រុមប្រឹក្សាដែលបានបង្កើតឡើងនៅទីក្រុង ប៉ារីសក្នុងឆ្នាំ ២000 នេះមានសមាជិក ៣៤នាក់ ហើយធ្វើការចូលរួមបោះឆ្នោតជ្រើសរើសប្រធានម្នាក់ និងអនុប្រធាន ៥នាក់ ។ នៅឆ្នាំ ២00៤-២00៥ ប្រទេសម៉ិចស៊ិចកូរួមជាមួយប្រទេសអូស្ត្រាលី ហ្គាណា កូរេខាងត្បូង រុស្ស៊ី និងប្រទេស ទូនីសា ជាអនុប្រធាន ។ សមាជិក UNESCO ដែលមិនមានតំណាងនៅក្នុងក្រុមប្រឹក្សានេះអាចបញ្ជូនអ្នកអង្កេតការណ៍ ដើម្បីចូលរួមប្រជុំជាមួយគ្នានេះ ភ្នាក់ងារអង្គការសហប្រជាជាតិដូចជា កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ អង្គការស្បៀងអាហារ និងកសិកម្ម អង្គការផ្ទៃសមុទ្រពិភពលោក និងអង្គការសុខភាពពិភពលោក



ក៏អាចចូលរួមផងដែរ ។ ក្រុមប្រឹក្សាអន្តរជាតិនៃសហព័ន្ធ វិទ្យាសាស្ត្រ ក្រុមប្រឹក្សាវិទ្យាសាស្ត្រសង្គមអន្តរជាតិ និងសហភាពអភិរក្សពិភពលោក អាចដើរតួនាទីជាអ្នកផ្តល់មតិដល់ក្រុមប្រឹក្សា ។

## តួនាទីរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ

ការទទួលខុសត្រូវរួមសំរាប់ឋបនីយជីវមណ្ឌលបឹងទន្លេសាបជាតួនាទីរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ ។ គណៈកម្មាធិការនេះដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រីលើការអភិវឌ្ឍ ការគ្រប់គ្រង និងការថែរក្សាទឹក និងធនធានពាក់ព័ន្ធផ្សេងទៀតនៃទន្លេមេគង្គនៅក្នុងកិច្ចសហការជាមួយអជ្ញាធរខេត្ត-ក្រុងក៏ដូចជាភ្នាក់ងារ រដ្ឋាភិបាលកណ្តាល ។ កិច្ចសហការជាមួយម្ចាស់ជំនួយ និងគណៈកម្មាធិការជាតិនៅប្រទេសឡាវ ថៃ និងវៀតណាមគឺផ្អែកលើគោលការណ៍នៃ "សមភាព និងផលប្រយោជន៍ដែលសមហេតុផល" សំរាប់សមាជិកទាំងបួននៃគណៈកម្មការទន្លេមេគង្គ ។

គណៈកម្មាធិការជាតិទន្លេមេគង្គមានតំណាង ១០ក្រសួង ។ ក្រសួងទាំងនោះមានដូចជាក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការបរទេស និងសហប្រតិបត្តការណ៍អន្តរជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងផែនការណ៍ ក្រសួងដែនដី នគររូបនីយកម្ម និងរៀបចំដែនដី ក្រសួងសាធារណៈការ និងដឹកជញ្ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងទេសចរណ៍ ។ ប្រធានប្រតិបត្តិគណៈកម្មាធិការទាំងមូលគឺ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឯកឧត្តម លឹម គានហោ និង អនុប្រធាន ៣ ផ្សេងទៀតគឺ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន ឯកឧត្តម ត្រាំ អ៊ីវតឹក និងអតីតអគ្គនាយកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម ស៊ិន នីនី ។

រដ្ឋលេខាធិការសំរបសំរួលលើសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃ និងផ្តល់ប្រឹក្សាដល់ប្រធានគណៈកម្មាធិការ ។ លេខាធិការដ្ឋានរួមបញ្ចូលទាំងលេខាធិការដ្ឋានឋបនីយជីវមណ្ឌល និងនាយកដ្ឋានបីទៀត រួមនឹងការទទួល ខុសត្រូវលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ (រួមបញ្ចូលទាំងទំនាក់ទំនងសាធារណៈ) នយោបាយ និងការធ្វើផែនការណ៍ និងគំរោងជាច្រើនទៀត ។ នាយកដ្ឋានគំរោងមានក្រសួងពាក់ព័ន្ធ៤ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន) និងផ្នែក២ ផ្សេងទៀតទទួលបន្ទុកលើកម្មវិធីប្រើប្រាស់ទឹក និងបរិស្ថានរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ ។

អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គមាន ៣រូប ក្នុងនោះមាន : ឯកឧត្តម ពេជ ឌុន  ឯកឧត្តម តែ ណាវុធ (ក្រសួងធនធានទឹក និងឧតុនិយម) និង ឯកឧត្តម កុល វឌ្ឍនា (ក្រសួងបរិស្ថាន) ដែលឯកឧត្តមជារដ្ឋលេខាធិការឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ហើយក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាបនេះក៏មានអនុរដ្ឋលេខាធិការ ៣នាក់ ទៀត គឺ បណ្ឌិត នៅ បោនន័រ ជាអនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធនធានធម្មជាតិ នៃក្រសួងបរិស្ថាន ជាប្រធានប្រតិបត្តិ លោក សម នៅ អនុប្រធាន រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លោក ឡុង សារ៉ាវុធ អនុប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក នៃក្រសួងធនធានទឹក និងឧតុនិយម ។

ប្រភព : ធានាគារអភិវឌ្ឍន៍អាស៊ី
គណៈកម្មាធិការជាតិទន្លេមេគង្គ
អង្គការ យូនិស្កូ

# ០៦

# រដូវកាលទាំងប្រាំ
# នៃតំបន់បឹងទន្លេសាប



## នាពាក់កណ្ដាលរដូវប្រាំង

### ខែមករា ដល់ ខែឧសភា)

នាពាក់កណ្ដាលរហូតចុងរដូវប្រាំង ដែលមានចន្លោះពីខែមករា ដល់ខែ មេសា  ការនេសាទត្រីធ្វើអាជីវកម្ម ដែលមានលក្ខណៈជាទ្រង់ទ្រាយធំត្រូវបានធ្វើឡើងនៅតាមឡូតិ៍នេសាទ និងតាមផ្លូវទឹកនៅជុំវិញទន្លេសាប ហើយទន្ទឹមនឹងនេះដែរ ការដុតស្មៅសំរាប់ធ្វើកសិកម្ម និងដីព្រៃបានកើតមានឡើងនាពេលនោះផងដែរ ។

នៅខណៈដែលវាលទំនាបលិចទឹកបានរីងស្ងួតអស់ ការប្រមូលផ្ដុំត្រីខ្មៅគ្រប់ប្រភេទដូចជា : ត្រីរ៉ស់ ត្រីឆ្ដោ ត្រីក្រាញ់ រស់នៅក្នុងទឹក ដោយខ្លួនរបស់វាមានពណ៌ខ្មៅដោយសារតែសារធាតុគីមី ដែលបណ្ដាលមកពីការរលួយរុក្ខជាតិនៅពេលទឹកលិច ។ ត្រីប្រភេទនេះ អាចរស់នៅក្នុងទឹកដែលមានជាតិអាស៊ីត ខ្វះអុកស៊ីសែន ហើយត្រីប្រភេទនេះ ភាគច្រើនអាចដកដង្ហើមយកខ្យល់បាន និងផ្លាស់ទីទៅរកកន្លែងថ្មី និងមួយចំនួនទៀត អាចកប់ខ្លួនរបស់វាទៅនឹងល្បាប់ភក់ រង់ចាំរហូតដល់មានទឹកជំនន់មកដល់ ។

សត្វរំពេស៊ីត្រីអស់មួយចំនួននៅតាមបឹងបួរ ។ នៅតំបន់ព្រៃលិចទឹក នាពាក់កណ្ដាលរដូវប្រាំងរហូតដល់ ចុងរដូវប្រាំង គឺជាពេលវេលាសំរាប់សត្វស្លាបទឹកធ្វើការបន្ដពូជយ៉ាងសំខាន់ដូចជា : ក្រសារក្វ ទុង ចំណែកឯអណ្ដើក និងពស់ថ្លាន់ ក៏បានបន្ដពូជនៅតំបន់ព្រៃលិចទឹក និងព្រៃរបោះនាពេលនេះផងដែរ ដូចគ្នានឹងសត្វស្លាប នៅតាមវាលស្មៅ ដូចជាសត្វរំពេ  និងសត្វក្រួចជាដើម  ។

## នាដើមរដូវវស្សា

### ខែឧសភា ខែមិថុនា ខែកក្កដា)

នៅពេលរដូវភ្លៀងបានធ្លាក់នាដើមរដូវវស្សា នៅខែឧសភា ដល់ខែ កក្កដា ទឹកជំនន់ចាប់ផ្ដើមឡើង ហើយនៅពេលនោះទឹកទន្លេសាបបានទទួលទឹកពីស្ទឹង ព្រែក និងទន្លេមេគង្គ ។ ត្រីមានសប្បុរសបានចាប់ផ្ដើមធ្វើការផ្លាស់ទីពីទន្លេមេគង្គឆ្ពោះទៅកាន់បឹងទន្លេសាប ដែលជាកន្លែងផ្ដល់ចំណីអាហារ និងជាសំបុកសំរាប់ពងកូននៅខែបន្ទាប់មុននឹងពួកវាវិលត្រឡប់មកកាន់ទន្លេមេគង្គវិញនាចុងឆ្នាំ ។ ត្រីប្រភេទនេះ រស់នៅស្ទើរតែមួយជីវិតរបស់វានៅក្នុងទឹកទន្លេមេគង្គដែលហូរជាប្រចាំ ។



PHOTO: ELEANOR BRIGGS WCS



PHOTO: ELEANOR BRIGGS WCS

ត្រីប្រភេទនេះមាន : ត្រីដីរ៉ ត្រីប្រា ត្រីសណ្តាយ ត្រីកាហែ ត្រីពោ និងត្រីប្រម៉ា ។ នៅរដូវនេះដែរ ពពួកត្រីខ្មៅ ក៏បានចាប់ផ្តើមផ្លាស់ទីទៅរកជំរក និងទីកន្លែងសំរាប់ពងកូន ។

នាដើមរដូវវស្សា បានកំណត់ការចាប់ផ្តើមបន្តពូជរបស់ហ្វូងសត្វស្លាបទឹកដ៏ធំដូចជា : ក្រសារ ក្ងទុង នៅតំបន់ព្រៃលិចទឹក ។ បញ្ហានេះវាជាសញ្ញាមួយដែលបញ្ជាក់ថា រដូវវស្សាជាដើ្វបន្តពូជបានមកដល់ហើយ ពពួកសត្វទាំងនេះមានដូចជា : សត្វក្រៀល សត្វកញ្ចុះ សត្វដុំដុល និងសត្វកុក ដែលរស់នៅតាមតំបន់វាលស្មៅជុំវិញបឹងទន្លេសាប ។

នៅក្នុងតំបន់ព្រៃលិចទឹក និងតំបន់ព្រៃរបោះ ដើមឈើក៏ចាប់ផ្តើមចេញផ្លែផ្កា ។ នៅពេលនោះ ដំណាំស្រូវឡើងទឹកក៏បានចាប់ផ្តើមដុះពន្លកផងដែរ នៅតាមតំបន់វាលទំនាបខាងក្រៅ ។

នៅដើមរដូវវស្សាត្រូវបានកំណត់ចំណាំថា ជាការចាប់ផ្តើមរដូវកាលនៃការចាប់សត្វពស់ទឹក ដែលមានចំនួនដ៏ច្រើនបំផុតនៅលើពិភពលោក ។

# នៅពាក់កណ្តាលរដូវវស្សា

ខែសីហា ខែកញ្ញា ខែតុលា )

នៅពេលភ្លៀងនៅតែបន្តធ្លាក់នាពាក់កណ្តាលរដូវវស្សា រវាងខែសីហា និងខែតុលា បានធ្វើអោយបឹងទន្លេសាបលាតសន្ធឹងធំល្វឹងល្វើយ ដែលនៅពេលនោះ ត្រីបន្តរកសំបុកពងកូន រកចំណីអាហារ ហើយនិងពពួកកូនត្រីតូចៗ ក៏ចាប់ផ្តើមធំធាត់ ហើយក៏ជាពេលវេលានៃការបន្តពូជនៃពស់ទឹកនៅក្នុងតំបន់ព្រៃលិចទឹក និងតំបន់ព្រៃរបោះផងដែរ ។

ពពួកសត្វក្អែកទឹក និងសត្វស្មោញ បានវិលត្រឡប់ទៅរកសំបុករបស់ពួកវាវិញនៅក្នុងតំបន់ព្រៃលិចទឹក ហើយចាប់ផ្តើមបន្តពូជ ។ ដើមឈើបន្តចេញផ្កា និងមានផ្លែ ។

នៅខែសីហា និងខែតុលានេះ នៅតំបន់ទំនាបផ្នែកខាងក្រៅ គឺជាដំណាក់កាលសំខាន់នៃការលូតលាស់ដំណាំស្រូវ ពពួកត្រីរកចំណីនៅតាមវាលស្រែ ហើយកំរិតនៃការចាប់សត្វទឹកពស់ខ្ពស់បំផុតកើតមាននៅក្នុងរដូវនេះ ។

# នាចុងរដូវវស្សា

## ខែតុលា ខែវិច្ឆិកា)

នៅពេលដែលកំរិតទឹកទន្លេមេគង្គមានការស្រកចុះ ចរន្តទឹកបឹងទន្លេសាបបានហូរបញ្ច្រាសត្រឡប់ទៅវិញនៅចុងរដូវវស្សា ក្នុងខែតុលា និងខែវិច្ឆិកា។ កំឡុងពេលនោះ ការនេសាទត្រីក្នុងទ្រង់ទ្រាយធំបានចាប់ផ្តើមនៅតាមឡូតិ៍នេសាទ និងតាមផ្លូវទឹកសំខាន់ៗ ។ ប្រភេទត្រីសចាប់ផ្តើមផ្លាស់ទីចេញពីបឹងឆ្ពោះទៅកាន់ទន្លេមេគង្គវិញ ។

នៅតំបន់ព្រៃលិចទឹក និងតំបន់ព្រៃរបោះ ដើមឈើបានដុះត្រួយខ្ចី ចំណែកពពួកពស់ទឹកនៅតែបន្តការបន្តពូជរបស់ពួកវា ។

នៅពេលនេះ ស្មៅឡើងទឹកបានដុះ និងដំណាំស្រូវឡើងទឹកបានចាប់ផ្តើមទុំ ។

# ដើមរដូវប្រាំង

## ខែវិច្ឆិកា ខែធ្នូ និង ខែមករា )

កំរិតទឹកជំនន់បានស្រកចុះយ៉ាងលឿន ហើយការធ្វើអាជីវកម្មនេសាទខ្នាតធំនៅបឹងទន្លេសាបនៅតែបន្តក្នុងកំឡុងពេលនៃដើមរដូវប្រាំងនេះ (រដូវរំហើយ) គឺចាប់ពីខែវិច្ឆិកា ដល់ ខែមករា។ គួរកត់សំគាល់ផងដែរថា ពេលនេះការផ្លាស់ទីទៅខាងក្រៅរបស់ពពួកត្រីសប្បុរសមានកំរិតមួយខ្ពស់ពិសេសពពួកត្រីរៀល ។

ហ្វូងសត្វត្រចៀកកាំ និងសត្វរំពេ បានរកចំណីនៅតាមបឹង ហើយចំណែកពពួកសត្វក្អែកទឹក និងសត្វស្មោញបានបញ្ចប់ការបន្តពូជរបស់ពួកវានៅក្នុងតំបន់ព្រៃលិចទឹក ហើយសត្វស្លាបតូចៗចាប់ផ្តើមដុះស្លាបធំល្មមគ្រប់គ្រាន់សំរាប់ធ្វើការហោះហើរ។ សត្វបក្សីទឹកធំៗ ដូចជា : ក្រសា ក្ង ទុង បានវិលត្រឡប់ទៅរកសំបុករបស់ពួកវាវិញ ។ ពពួកដែលបន្តពូជនៅផ្ទាល់នឹងដីដូចជា : សត្វស៊ីលំអងផ្កា និងសត្វគ្រួចបានវិលត្រឡប់ទៅកាន់តំបន់វាលស្មៅ និងវាលស្រែ ហើយសត្វស្លាបដែលនៅអាស៊ីខាងជើង និងតំបន់អឺរ៉ុបបានធ្វើដំណើរទៅកាន់តំបន់បឹងទន្លេសាប ដើម្បីគេចចេញពីរដូវត្រជាក់នៅផ្នែកខាងជើង ហើយសត្វប្រភេទនេះមាន សត្វរំពេ សត្វចាបពូក សត្វគ្រួចអិន សត្វដូនតា សត្វក្រសា សត្វខ្ចប់ដី ។

នៅកំឡុងរដូវត្រជាក់នេះ ការប្រមូលផលស្រូវប្រចាំឆ្នាំបានចាប់ផ្តើម និងបន្ទាប់មកគឺការប្រមូលផលពស់ទឹក ។

ប្រភព : អង្គការសមាគមអភិរក្សសត្វព្រៃ (WCS)



PHOTO: ELEANOR BRIGGS WCS

# ០៧

## ព្រៃលិចទឹក



# ព្រៃលិចទឹក

ព្រៃលិចទឹកនៃទន្លេសាបមានសារៈសំខាន់សំរាប់ត្រីពងកូនតាមរដូវ ជាជំរក និងជាតំបន់ដែលផ្តល់ចំណីអាហារសំរាប់ត្រីដែលផ្លាស់ទីទៅទន្លេមេគង្គ។ ទោះជាទំហំរបស់វាមានការថយចុះ វានៅតែជាតំបន់វាលស្មោងលិចទឹក និងព្រៃលិចទឹកដែលលាតសន្ធឹងធំជាងគេនៅអាស៊ី និងបន្សល់ទុកជាឧទាហរណ៍ធំជាងគេនៃជំរកប្រភេទនេះនៅអាស៊ីអាគ្នេយ៍ ។

ជាមួយនឹងដីដែលមានចុល្លព្រឹក្ស ព្រៃដុះនៅតំបន់វាលភក់ ព្រៃលំអ រុក្ខជាតិនៅក្រោមទឹក និងផលជាតិទាំងឡាយ ព្រៃលិចទឹកផ្តល់ប្រយោជន៍សំខាន់ជាច្រើនសំរាប់មនុស្ស និងសត្វ ។ អ្នកវិទ្យាសាស្ត្របានកត់ត្រាទុកជាឯកសារនូវរុក្ខជាតិប្រហែល ២០០ប្រភេទ ដែលជារុក្ខជាតិដែលជិតផុតពូជពីតំបន់ដីសើមទន្លេមេគង្គ ជាពិសេសជាមួយការរាប់បញ្ចូលទៅក្នុងប្រភេទឈើ ។

ផលិតផលជលផលបឹងទន្លេសាបគឺជាផលិតផលខ្ពស់ជាងគេមួយលើពិភពលោក ។ លក្ខណៈទូទៅនេះអាចបញ្ជាក់បានថា ព្រៃលិចទឹកមិនគ្រាន់តែផ្តល់នូវទីជម្រក និងការពារដល់សត្វទាំងឡាយប៉ុណ្ណោះទេ ប៉ុន្តែក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការកកើតឡើងវិញនៃធនធានជីវសាស្ត្រដែលមានឥទ្ធិពលទៅវិញទៅមកដូចជា ខ្សែអាហារដ៏ធំមួយ ។

ផលិតផលព្រៃឈើដូចជា ផ្លែឈើ គ្រាប់ធុញ្ញជាតិ និងស្លឹកឈើ បំពេញតំរូវការចំណីអាហារដល់សត្វ ។ នៅជិតព្រែកទាល់ ព្រៃលិចទឹកទ្រទ្រង់នូវបន្ទាយសត្វស្លាបទឹកសំខាន់ជាងគេនៅឥណ្ឌូចិន និងប្រហែលជានៅអាស៊ីអាគ្នេយ៍ទាំងមូល ។ វាប្រហែលជាតំបន់ប្រសើរជាងគេរបស់កម្ពុជាសំរាប់អភិរក្សភាវៈរស់ទឹកសាប ។

នៅពេលដែលទំនប់វារីអគ្គិសនីមិនត្រូវបានគ្រោងសំរាប់តំបន់បឹងទន្លេសាប របាយការណ៍ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) នៅឆ្នាំ ២០០៥ បានធ្វើការព្រមានថាទំនប់វារីអគ្គិសនីខ្លះនៅអាងទន្លេមេគង្គអាចធ្វើអោយខូចទំនាក់ទំនងប្រព័ន្ធទឹកជាមួយបឹង ។ ការកាប់បំផ្លាញជម្រក និងយកដីសំរាប់ធ្វើកសិកម្មគឺ បញ្ហាដែលគួរធ្វើការគិតគូរ "ដ៏សំខាន់" មួយជាមួយនឹងការកើនឡើងនូវអ្នកប្រើជី ហើយហូរចូលទៅក្នុងបឹងធ្វើអោយមានការប៉ះពាល់ដល់មច្ឆា និងប្រជាជននៅក្នុងតំបន់ ។

ដើមឈើត្រូវបានកាប់ដើម្បីធ្វើឧបករណ៍នេសាទរួមមានសំរាស់ និងលប ហើយការដាក់កំហិតលើការនេសាទនៅមានកំរិត ដោយសារការនេសាទហួសហេតុ និងខុសច្បាប់ ។ របាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានព្រមានថា "ការថយចុះនូវផលស្តុកត្រីមិនគ្រាន់តែថយចំនួនត្រីទេ ប៉ុន្តែក៏ជះឥទ្ធិពលពេញទាំងរចនាសម្ព័ន្ធនៃការផ្តល់ចំណីអាហារនៃប្រព័ន្ធអេកូឡូស៊ីទៀតផង" ។

ដើម្បីអោយការនេសាទមានចីរភាព លុះត្រាតែព្រៃលិចទឹកត្រូវបានថែរក្សា ឬពង្រីក និងផលស្តុកត្រីត្រូវបានថែរក្សា ដោយធ្វើការពង្រឹងលើការត្រួតពិនិត្យ និងបង្កើនកម្មវិធីបង្កាត់ពូជ ។ ការទន្ទ្រានក្នុងទំរង់នៃការក្រវ៉ាត់យកធនធានទឹក កាប់ព្រៃយកឈើប្រណីត និងអុស និងកាប់បំផ្លាញព្រៃយកដីសំរាប់ធ្វើការដាំដុះ ដែលធ្វើអោយមានការគំរាមកំហែងទៅដល់ការបំផ្លាញតំបន់ព្រៃ ។ សកម្មភាពទាំងនោះអាចបណ្តាលអោយមានការហូរច្រោះដី ការបាត់បង់ជីវជាតិដី ធ្វើអោយខូចគុណភាពទឹកក្រោមដី បង្កអោយមានទឹកជំនន់ និងធ្វើអោយប្រភពទឹកមានសភាពល្អក់ ។

ប្រភព : ធនាគារអភិវឌ្ឍន៍អាស៊ី
វិទ្យាស្ថានអភិវឌ្ឍន៍ និងស្រាវជ្រាវជលផលទឹកសាប

# ០៨

# តំបន់ដីសើម



PHOTO: REACH SAMBATH

# តំបន់ដីសើម

ជារៀងរាល់ឆ្នាំ ការជន់លិចនៅរដូវវស្សាបានបំលែងផ្ទៃដីទំនាបនៅភាគកណ្តាលប្រទេសកម្ពុជាទៅជាប្រព័ន្ធដែនទឹកដ៏ធំល្វឹងល្វើយ ។ តំបន់ដីសើមត្រូវបានបែកចែកជា ៣តំបន់សំខាន់ៗគឺ នៅតាមបណ្តោយដងទន្លេមេគង្គនៅជុំវិញបឹងទន្លេសាប និងនៅតាមបណ្តោយដងស្ទឹងសែន ព្រមទាំងមានតំបន់ដីសើមនៅតំបន់ឆ្នេរមាន កោះប៉ោ និងស្ទឹងកែប ។ ដីសើមប្រទេសកម្ពុជាត្រូវបានប្រើប្រាស់ជាសំខាន់សំរាប់កសិកម្ម ជលផល ការផ្គត់ផ្គង់ទឹក ព្រៃឈើ ទេសចរណ៍ គមនាគមន៍ ការតាំងទីលំនៅ និងការអភិរក្ស ព្រមទាំងបានប្រើប្រាស់ក្នុងគោលបំណងដទៃទៀតដូចជា ការគ្រប់គ្រងសំណល់ ការធ្វើនិយ័តកម្មកំពស់ទឹកជំនន់ របាំងការពារខ្យល់ព្យុះ និងការទាញយកថាមពល ។ ដីសើមប្រទេសកម្ពុជា រងការគំរាមកំហែងដោយសារកំណើននៃការធ្វើអាជីវកម្ម និងការពង្រីកដី សំរាប់ធ្វើកសិកម្ម និងការតាំងលំនៅរបស់ប្រជាពលរដ្ឋ ។ ការគំរាមកំហែងនោះគឺ ការនេសាទហួសប្រមាណ ការរេចរឹលដោយសារទឹកជំនន់ និងបំផ្លាញព្រៃឈើនៅផ្នែកខាងលើ ការធ្វើជំនួញសត្វស្លាប ពងសត្វស្លាប ពស់ និង អណ្តើក ការបំផ្លាញជំរកសត្វ ការធ្វើប្រព័ន្ធស្រោចស្រព ការដឹកជញ្ជូន ទេសចរណ៍ និងការសាងសង់ទំនប់ស្តុកទឹក ។

គំរោងការងារច្បាប់គ្រប់គ្រងតំបន់ដីសើម មានចែងនៅក្នុងច្បាប់ បានផ្តល់អោយទៅស្ថាប័នរដ្ឋទទួលខុសត្រូវលើការប្រើប្រាស់ធនធាន ការប្រើប្រាស់ដី និងការអភិរក្សបរិស្ថាន។ ច្បាប់ទាំងអស់នេះរួមមាន ច្បាប់ស្តីពីជលផលឆ្នាំ ២០០៦ ច្បាប់ស្តីពីដីធ្លី ឆ្នាំ ២០០១ និងច្បាប់បរិស្ថាន ឆ្នាំ ១៩៩៦ ព្រមទាំងច្បាប់ដទៃទៀតមាន អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ ២០០៥ និងព្រះរាជក្រឹត្យស្តីពីការបង្កើតប្រព័ន្ធតំបន់ការពារ ឆ្នាំ១៩៩៣ ។ ប៉ុន្តែច្បាប់ទាំងនេះមិនបានដោះស្រាយអោយបានទូលំទូលាយលើការគ្រប់គ្រង និងការអភិរក្សតំបន់ដីសើមនោះទេ ដែលបញ្ហានេះ នាំអោយមានជំលោះលើការប្រើប្រាស់ និងការបំផ្លិចបំផ្លាញធនធានរបស់ពួកគេ ។ ទន្ទឹមនឹងនេះដែរ គំរោងផែនការគ្រប់គ្រង និងអភិរក្សត្រូវបានរារាំងដោយសារតែអវត្តមាននៃកិច្ចព្រមព្រៀង ស្តីពីវិធីសាស្ត្រ ដើម្បីបែងចែកតំបន់ដីសើម ។ ដើម្បីឆ្លើយតបទៅនឹងគុណវិបត្តិដែលបានកើតឡើងនេះ នៅឆ្នាំ ១៩៩៩ ផែនការសកម្មភាពស្តីពីការគ្រប់គ្រងដីសើមត្រូវបានរៀបរៀងឡើង ប៉ុន្តែផែនការសកម្មភាពនេះមិនត្រូវបានអនុម័តរហូតដល់ពាក់កណ្តាលឆ្នាំ ២០០៦ ។ នៅពេលដែលផែនការសកម្មភាពមិនទាន់ត្រូវបានអនុម័តនោះ មជ្ឈមណ្ឌលជលផលពិភពលោកបានសិក្សាអស់រយៈពេលពីរឆ្នាំ លើគំរោងផែនការស្ថាប័ន និងតាមគោលការណ៍ច្បាប់គ្រប់គ្រងដីសើមនៅកម្ពុជា និងការផ្តល់តំលៃលើធនធានទាំងនោះ ។ ការសិក្សានេះ ទទួលបានការសំរបសំរួលពីរដ្ឋបាលជលផល និងបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០០២ និងឆ្នាំ ២០០៣ ហើយវាក៏ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវនៃការសិក្សាថ្នាក់តំបន់ ដែលបានអនុវត្តនៅប្រទេសឡាវ ប្រទេសវៀតណាម និងថៃផងដែរ ។ របាយការណ៍នៃការសិក្សានេះ ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ២០០៦ និងបានពិពណ៌នាលើការប្រើប្រាស់ដីសើមនៅកម្ពុជា បានបង្ហាញថា ការវាយតំលៃរបស់ថ្នាក់ដឹកនាំពុំមានលក្ខណៈច្បាស់លាស់លើសារសំខាន់តំបន់ដីសើមនៅឡើយ ។ ការធ្វើកសិកម្មនៅលើតំបន់ដីសើមកម្ពុជាចែកចេញជា ៤ប្រភេទ ដូចជា ស្រូវវស្សា ស្រូវប្រាំង ស្រូវឡើងទឹក និងស្រូវប្រដេញទឹក ។ ស្រូវរដូវវស្សាត្រូវបានគេធ្វើនៅតំបន់ខ្ពស់ ដែលអាចមានទឹកជន់នៅរដូវវស្សា ។ ជាមួយនេះដែរ វាលស្រែនៅតំបន់ទំនាប ជាប្រភេទវាលស្រែដែលច្រើនជាងគេរបស់ប្រទេសកម្ពុជា ។ ស្រូវប្រដេញទឹក

ត្រូវបានធ្វើនៅរដូវទឹកសំរក ជាធម្មតាគឺនៅកំរិតទឹកជំនន់នៃប្រព័ន្ធទឹកទន្លេសាប ទន្លេបាសាក់ និងទន្លេមេគង្គ ហើយកំរិតទឹកនេះបានផ្តល់ដល់ដំណាំស្រូវប្រហែល ៩% ។ ប្រព័ន្ធស្រោចស្រពអាចធ្វើបាននៅរដូវទឹកសំរក និងសំរាប់ស្រូវប្រាំង ដែលអាចធ្វើកសិកម្មបានច្រើនដងក្នុងមួយឆ្នាំ។ ចំណែកស្រូវឡើងទឹកវិញ ត្រូវបានធ្វើនៅរដូវទឹកឡើង មានជំរៅទឹកជ្រៅ ជាពិសេសត្រូវបានធ្វើការដាំដុះនៅតំបន់ព្រៃលិចទឹកក្នុងតំបន់បឹងទន្លេសាប ដែលស្រូវប្រភេទនេះមានប្រមាណជា ៧% នៃដំណាំស្រូវសរុប ។

ដំណាំយុទ្ធសាស្ត្របានដាំដុះនៅវាលធំល្វឹងល្វើយ តាមដងទន្លេមេគង្គ លើកោះ និងជុំវិញតំបន់ទំនាបនៃបឹងទន្លេសាប ជាពិសេសនៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប ។ ដំណាំនេះរួមមាន ពោត សណ្តែក សណ្តែកដី ល្ង អំពៅ ក្តួច ដំឡូងជ្វា ល្ហុងប្រេង ក្រចៅ។ ចំណែកឯដំណាំដូចជា ល្ពៅ ត្រឡាច ឃ្លោក ត្រសក់ ឪឡឹក និងប៉េងប៉ោះ ត្រូវបានធ្វើការដាំដុះនៅចន្លោះដំណាំទាំងនោះផងដែរ ។

ស្រូវរដូវវស្សាមានការប្រើប្រាស់ថ្នាំគីមីច្រើនជាងស្រូវរដូវប្រាំង និងដំណាំផ្សេងៗទៀត ។ ការប្រើប្រាស់ថ្នាំគីមីបន្តិចបន្តួចវាអាចធ្វើអោយសត្វជាច្រើនដូចជា ត្រី ក្តាម ពពួកខ្យង និង កង្កែប អាចមានជីវិតរស់នៅក្នុងស្រែវស្សាបាន។ ចំណែកស្រូវប្រាំងវិញ តាមរបាយការណ៍របស់គំរោងសិក្សាស្រាវជ្រាវដំណាំស្រូវអន្តរជាតិកម្ពុជា-អូស្ត្រាលី បានបង្ហាញអោយឃើញថា កសិករប្រមាណ ៨0% បានប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត ហើយត្រីស្ទើរតែ ៩0% បានងាប់ក្រោយពីបានបាញ់ថ្នាំពុលកសិកម្ម។ ទោះបីជាពុំទាន់មានលទ្ធភាពធ្វើការត្រួតពិនិត្យលើសារធាតុគីមីទាំងនេះក៏ដោយ ក៏នៅតែមិនប្រាកដក្នុងការប៉ាន់ប្រមាណទៅលើបរិមាណនៃថ្នាំគីមីដែលកំពុងតែប្រើប្រាស់ ឬការបញ្ចេញសំណល់ថ្នាំគីមីទាំងនោះលើបរិស្ថានផងដែរ ។

ការនេសាទ និងវារីវប្បកម្ម គឺស្ថិតនៅក្នុងចំណោមការប្រើប្រាស់សំខាន់ៗលើដីសើមនៅប្រទេសកម្ពុជា។ កាលពីឆ្នាំ ១៩៩៧ ប្រជាពលរដ្ឋប្រមាណជា ៨៨% នៃប្រជាពលរដ្ឋចំនួន ១៧0ភូមិដែលរស់នៅជុំវិញបរិវេណជីវមណ្ឌលបឹងទន្លេសាប មានជីវភាពរស់នៅអាស្រ័យទៅលើការនេសាទ និងសកម្មភាពទាក់ទងមួយចំនួនទៀត និងផលិតផលត្រីសរុបមានប្រមាណជាង ៥00,000តោន ក្នុងមួយឆ្នាំ ( សូមពិនិត្យមើលផ្នែកផ្សេងៗស្តីពីជល



ផល) ។ ផលិតផលនៃវារីសត្វដែលទទួលបានពីតាមវាលស្រែមានប្រមាណ ១០០,០០០ តោន/ឆ្នាំ។ វារីវប្បកម្ម គឺជាបែរត្រីយ៉ាងសំខាន់នៅជុំវិញបឹងទន្លេសាប ដែលមានប្រមាណជា១០ % នៃផលិតផលត្រីសរុបទាំងអស់ ។ សត្វនៅក្នុងទឹកដែលនេសាទបានរួមមាន ក្រពើ អន្ទង់ កង្កែប បង្កង និងពស់ទឹក ។ ចំណែកការចិញ្ចឹមត្រីនៅក្នុងស្រះច្រើនធ្វើឡើងនៅខេត្តកណ្ដាល និងខេត្តដទៃទៀត ដែលនៅឆ្ងាយពីបឹងទន្លេសាប ។

**ដីសើមជួយទ្រទ្រង់ក្នុងការផ្ដល់ទឹកសំរាប់បរិភោគ បោកគក់ ងូត និងសំរាប់ស្រោចស្រព។** ប្រជាជនភាគច្រើន ដែលរស់នៅជុំវិញតំបន់បឹងទន្លេសាប ប្រើប្រាស់ទឹកពីក្នុងបឹងដោយផ្ទាល់ ហើយទឹកបឹងនេះក៏ត្រូវបានប្រើប្រាស់សំរាប់ធ្វើការស្រោចស្រពដល់កសិកម្មនៅជុំវិញបឹងទន្លេសាបផងដែរ ។

**ការប្រមូលផល និងអនុផលព្រៃឈើពីតំបន់ដីសើម សំរាប់សំណង់លំនៅស្ថាន និងប្រើប្រាស់សំរាប់ធ្វើពាណិជ្ជកម្ម។** ផលព្រៃឈើដែលបានពីតំបន់ព្រៃលិចទឹកមិនមានគុណភាពខ្ពស់ទេ ប៉ុន្តែអាចប្រើប្រាស់ សំរាប់សាងសង់លំនៅស្ថានតូចៗ និងជាជំរក ឬសំរាប់ចំអិនអាហារ និងឆ្អើរត្រីបាន។ យោងតាមរបាយការណ៍ ឆ្នាំ ២០០១ បានវាយតំលៃថា លំនៅដ្ឋាននៅភូមិបាឡត ប្រើប្រាស់អុសសំរាប់ឆ្អើរត្រីក្នុងមួយឆ្នាំមានបរិមាណ ៤០ ម៣ ដែលអុសទាំងនោះអាចលក់នៅទីផ្សារបានតំលៃពី ២.៥០ដុល្លាទៅ ៣ដុល្លា ក្នុងមួយម៉ែត្រគូប។ យោងតាមរបាយការណ៍ឆ្នាំ ១៩៩៧ បានបង្ហាញថា អ្នកភូមិច្រើនជាង ៨០% នៅពាមសីម៉ា ខេត្តបាត់ដំបង បានកាប់អុសជាច្រើនម៉ែត្រគូបក្នុងមួយថ្ងៃសំរាប់យកទៅលក់។ របាយការណ៍ដដែល នេះបានបង្ហាញថា ការប្រើប្រាស់អុសតាមលំនៅដ្ឋាននៅក្នុងសហគមន៍សំរាប់ចំអិនអាហារមាន ៨ម៣ សំរាប់គ្រួសារមួយក្នុងមួយឆ្នាំ។ ចំណែកអនុផលព្រៃឈើមាន ឬស្សីសំរាប់ធ្វើ



PHOTO: ELEANOR BRIGGS WCS

ក្បូន ត្រែង និងស្បូវសំរាប់ប្រក់ផ្ទះ កូនរុក្ខជាតិតូចៗសំរាប់ធ្វើជាឧបករណ៍នេសាទ និងកំប្លោកសំរាប់ធ្វើអង្រឹង និងបណ្ដុះផ្សិត។ រុក្ខជាតិ និងសត្វដែលមាននៅក្នុងតំបន់ដីសើមត្រូវបានគេយកទៅប្រើប្រាស់សំរាប់ជាឱសថបុរាណផងដែរ។

**តំបន់ដីសើមនៅកម្ពុជាទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើង។** នៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប មានមជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូលព្រែកទាល់បានបើកទីកន្លែងសំរាប់ស្នាក់អាស្រយ័នៅឆ្នាំ ២០០៥ និងតំបន់ស្នូលបឹងទន្លេឆ្មារបានបើកឱ្យមានទីកន្លែងសំរាប់ស្នាក់អាស្រ័យនៅឆ្នាំ ២០០៦។ នៅ ១៩៩៨ អ្នកទេសចរបានចូលទៅលេងនៅតំបន់ព្រែកទាល់ ដែលអាចប៉ាន់ប្រមាណរកប្រាក់ចំណូលបានពី ១លាន ទៅ ២លានដុល្លា ក្នុង១ឆ្នាំ ដែលក្នុងនោះប្រហែលជា ១០ % ទៅដល់សហគមន៍ក្នុងតំបន់តែម្ដង ។

**ដីសើមមានសារៈសំខាន់សំរាប់ការដឹកជញ្ជូនតាមផ្លូវទឹក និងសំរាប់ការតាំងទីលំនៅ។** ក្រសួង

សាធារណៈការ និងដឹកជញ្ជូន បានវាយតំលៃថា ចំងាយផ្លូវទឹកឆ្លងកាត់ប្រទេសកម្ពុជាមានប្រវែង ៨៥៥គ.ម នៅរដូវប្រាំង និងនៅរដូវវស្សាមានចំងាយ ១,៥៤៤គ.ម ។ លំនៅស្ថានដែលសាងសង់ដោយមានសសរខ្ពស់ៗ និងសំណង់បណ្តែតទឹកមានជាក្រុមធំៗនៅជុំវិញបឹងទន្លេសាប ហើយសំណង់បណ្តែតទឹកអាចជាសំណង់មានលក្ខណៈអចិន្ត្រៃយ៍ ឬក៏សំណង់តាមរដូវកាល ដោយភូមិទាំងមូលមានការផ្លាស់ប្តូរទៅតាមរដូវប្រាំង និងរដូវវស្សា ។

កិច្ចខិតខំប្រឹងប្រែងអភិរក្សអាចផ្តល់ប្រយោជន៍ដល់ពពួកសត្វដែលរងគ្រោះថ្នាក់នៅក្នុងតំបន់ដីសើមប្រទេសកម្ពុជា ។ ពពួកសត្វទាំងនេះរួមមាន ផ្សោតទន្លេ ក្រពើត្រី ត្រីរាជ និងត្រីត្រសក់ស ។ ពពួកសត្វស្លាប ដែលទទួលរងគ្រោះថ្នាក់ចំនួន ៨ប្រភេទទៀត ដែលបានរៀបរាប់ដោយក្រសួងបរិស្ថានស្តីពីបក្សីទឹក ដូចជា : ទាព្រៃស្លាបស ក្រៀល ក្ងោកយក្ស ក្ងោកខ្លួនខ្មៅ ត្រដក់ធំ ត្រដក់តូច រនាលស ទុងប្រផេះ ។



សត្វចិញ្ចឹមអាស្រ័យលើអាហារ ដែលបានមកពីតំបន់ដីសើម ។ គោ ក្របី ស៊ីស្មៅ និងសារពើរុក្ខជាតិ ជាអាហារ ចំណែកឯពពួកក្ងានរកចំណីអាហាររបស់វានៅតាមវាលស្រែ ។ សត្វក្ងាន និងបសុបក្សីដទៃទៀតស៊ីចំណីដូចជា រុក្ខជាតិទឹក (water spinach) ស្មៅ និងស្រូវដែលដុះនៅតំបន់ដីសើម ។

តំបន់ដីសើមជួយកាត់បន្ថយការបំពុល និងសំអាតសំណល់ ។ នៅខណៈពេលដែលប្រទេសកម្ពុជាមិនទាន់មានមធ្យោបាយសំរាប់ធ្វើប្រព្រឹត្តិកម្មនោះ ភាគច្រើននៃសំណល់រាវទីក្រុង និងការបំពុលបណ្តាលមកពីទីក្រុង និងឧស្សាហកម្ម ត្រូវបានបញ្ចេញចោលទៅក្នុងទន្លេ និងតំបន់ដីសើម ។ សំណល់រាវ និងសំណល់រឹង ត្រូវបានអ្នកភូមិនៅតំបន់ជុំវិញបឹងទន្លេសាប (ភូមិបណ្តែតទឹក) បោះចោល និងបញ្ចេញចោលដោយផ្ទាល់ទៅក្នុងទឹក ។ ចំណែកឯជីគីមី និងថ្នាំពុលកសិកម្មក៏បានបញ្ចេញចោលទៅក្នុងតំបន់ដីសើមនេះផងដែរ ដែលកន្លែងខ្លះជាប់ជាមួយរុក្ខជាតិ និងផ្សេងពីនោះ ត្រូវបានបង្ហូរចេញទៅតាមទឹកជំនន់ប្រចាំឆ្នាំ ។

បឹងបួរតូចៗ និងប្រព័ន្ធទន្លេ គឺជាអាងស្តុកទឹក និងរក្សានិយ័តកម្មកំពស់ទឹកនៅក្រោយពេលដែលមានភ្លៀង និងនៅរដូវទឹកជំនន់ប្រចាំឆ្នាំ ។ បឹងទន្លេសាប ត្រូវបានគេប៉ាន់ប្រមាណថា អាចទទួលទឹកបាន ២៨ កោដិម៉ែត្រគូប ដែលហូរចាក់ពីទន្លេផ្សេងៗ នៅក្នុងផ្ទៃអាងរងទឹកភ្លៀង និងច្រើនស្ទើរតែទាំងអស់ហូរចាក់មកពីទន្លេមេគង្គជារៀងរាល់ឆ្នាំ ។

តំបន់ព្រៃលិចទឹកត្រូវបានប្រើប្រាស់សំរាប់ជារបាំងការពារខ្យល់ព្យុះ ។ នៅរដូវវស្សា ប្រជាពលរដ្ឋបានធ្វើការផ្លាស់លំនៅស្ថានបណ្តែតទឹករបស់ពួកគាត់ទៅជិតព្រៃលិចទឹក ដើម្បីជៀសវាងពីគ្រោះមហន្តរាយដោយសារខ្យល់ព្យុះ និងរលកទឹក ។

តំបន់ដីសើមអាចជាប្រភពនៃថាមពល គឺមិន



គ្រាន់តែអាចទាញយកអុស និងធ្យូងប៉ុណ្ណោះទេ តែវាអាចផ្តល់ថាមពលដោយប្រើកំលាំងទឹកផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ កន្លងមក ប្រទេសកម្ពុជាបានសាងសង់រោងចក្រអគ្គិសនីប្រើចរន្តទឹកធន់តូចមួយចំនួន ហើយទំនប់ស្ទាក់ទឹកនេះគឺមានផលប៉ះពាល់ខ្លាំងទៅលើការបំលាស់ទីរបស់ត្រីនៅពេលដែលកំពុងសាងសង់ ហើយសំណង់នេះក៏ជាផ្នែកមួយនៃគំរោងស្ថារទំនប់ប្រព័ន្ធស្រោចស្រពស្ទឹងជីនីតក្នុងខេត្តកំពង់ធំ និងជាប្រភេទសំណង់លំដាប់ទី២នៅអាស៊ី ដែលរំពឹងទុកថា សំណង់នេះនឹងចាប់ផ្តើមដំណើរការនៅរដូវវស្សាឆ្នាំ ២០០៦ ។

តំបន់ដីសើមមានតំលៃខាងវប្បធម៌ផងដែរ ។ តំលៃទាំងនេះជារឿយៗត្រូវបានរៀបចំធ្វើនៅរដូវបុណ្យផ្សេងៗដូចជា បុណ្យអុំទូកប្រចាំឆ្នាំ ដែលប្រារព្ធធ្វើនៅដើមរដូវនេសាទ និងចុងរដូវប្រមូលផលស្រូវ ។

ការសិក្សាបានបង្ហាញអោយឃើញថា វាជាការលំបាកដើម្បីអោយតំលៃនៅក្នុងវាក្យស័ព្ទផ្នែកសេដ្ឋកិច្ច ដោយសារតែមានមធ្យោបាយផ្សេងៗ ដែលស្គាល់ដោយក្រុមផ្សេងៗ និងការយល់ដឹងនៅមានកំរិតទាប លើផ្នែកមុខងារអេកូឡូស៊ី ។ វាបង្ហាញថា ដីសើមមានសារសំខាន់ ពិសេសចំពោះការប្រកបរបរចិញ្ចឹមជីវិត និងសុខមាលភាពរបស់ប្រជាពលរដ្ឋនៅទាប ប៉ុន្តែវាបង្ហាញថា មានការលំបាកដើម្បីធ្វើការប៉ាន់ប្រមាណ តំលៃរបស់វាទៅដល់ប្រជាពលរដ្ឋក្រីក្រនៅពេលដែលផលិតផល និងសេវាកម្មមិនបានចូលក្នុងសេដ្ឋកិច្ចទីផ្សារ និងការទទួលស្គាល់នៅមានកំរិតទាប ។ នៅក្នុងពេលអវត្តមានតំលៃនៃរូបិយប័ណ្ណ ការសិក្សាបានបញ្ជាក់ថា ដីសើមអាចមានតំលៃទាក់ទងទៅនឹងភាគរយនៃការចូលរួមរបស់ប្រជាពលរដ្ឋចំពោះមុខរបរចិញ្ចឹមជីវិត ។ វាអាចរំកញ្ចេកពីការចូលរួមវាយតំលៃផ្នែកសេដ្ឋកិច្ចនៃដីសើមទៅក្នុងគោលនយោបាយលើកទឹកចិត្តដល់ការប្រើប្រាស់ធនធានប្រកបដោយចីរភាព និងជួយកាត់បន្ថយភាពក្រីក្រ ។

ប្រភព: មជ្ឈមណ្ឌលជលផលពិភពលោក គណៈកម្មការទន្លេមេគង្គ

# ០៩

## ជលផល



# ជលផល

ភាពសំបូរបែបនៃធនធានជលផលរបស់ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ និងអាចជាកត្តាមួយក្នុងការទាក់ទាញអ្នកជំនួញពីបណ្តាប្រទេសផ្សេងៗ មាន : ចិន ព័រទុយហ្គាល់ ជប៉ុន និងប្រទេសហុឡង់ នៅមុនពេលដែលបារាំងចូលមកដាក់អាណានិគមនៅសតវត្សទី១៩ ។ ក្នុងកំឡុងអាណានិគមនិយមបារាំង អាជ្ញាធរបានបង្កើតអោយមានកិច្ចសន្យា ជួលឡូតិ៍នេសាទ និងបង្កើតច្បាប់នេសាទដែលជាច្បាប់លើកទី១របស់ប្រទេសកម្ពុជា ។ យោងតាមរបាយការណ៏ឆ្នាំ ១៩១០ ប្រទេសកម្ពុជាបាននាំចេញផលនេសាទប្រហែល ៥0, 000តោន និងនៅទសវត្សឆ្នាំ១៩២0 និង១៩៣0 អ្នកជំនួញចិនបាននាំចេញផលិតផលត្រីងៀតចំនួន ២៥,000 តោន ក្នុងមួយឆ្នាំ ទៅកាន់ប្រទេសឥណ្ឌូនេស៊ីតែមួយប៉ុណ្ណោះ ។



សម្ពាធទៅលើធនធានជលផលមានការកើនខ្លាំងឡើងដោយសារកំណើនប្រជាពលរដ្ឋ ។ នៅឆ្នាំ ១៩៤0 ផលិតផលត្រីសរុបមានប្រមាណ ១២0,000តោន ដែលចាប់ពីពេលនោះមក កំណើនប្រជាពលរដ្ឋកើនបីដង បានជំរុញដល់ការនេសាទត្រីមានការកើនឡើងយ៉ាងហោចណាស់ដល់ ៤00,000តោន/ឆ្នាំ ត្រឹមឆ្នាំ២000 ចំណែកឯការវាយតំលៃពេលថ្មីៗនេះបង្ហាញថា ការនេសាទត្រីប្រចាំឆ្នាំមានប្រមាណ៧00,000តោន ។ ទាក់ទងទៅនឹងតំលៃលទ្ធផលនេះ ការនេសាទ មានការប្រណាំងប្រជែងជាមួយទិន្នផលស្រូវដែលផ្តល់ខ្ពស់បំផុតលើផលិតផលក្នុងស្រុកសរុប ដែលអាចវាស់លទ្ធផលទំនិញ និងសេវាកម្មរបស់ប្រទេសបាន ។

ការនេសាទត្រីទឹកសាបនៅប្រទេសកម្ពុជា មានវិសាលភាពធំបំផុតនៅលើពិភពលោក ទាក់ទងនឹងបរិមាណត្រី ដែលនេសាទបានរបស់ប្រជាពលរដ្ឋ ។ ដោយផ្អែកលើការនេសាទមានលក្ខណៈអភិវក្សនោះ ផលនេសាទទទួលបានមាន ប្រមាណ ៤00.000តោន ដែលជាផលមួយស្ថិតក្នុងលំដាប់ខ្ពស់ទី៤ នៅលើពិភពលោកបន្ទាប់ពីប្រទេសចិន ឥណ្ឌា បង់ក្លាដេស ។ បើវាយតំលៃខ្ពស់ជាងនេះ ប្រទេសកម្ពុជា ជាប់លំដាប់លេខ២បើប្រៀបធៀបជាមួយប្រទេសចិន ក្នុងការនេសាទត្រីទឹកសាប ហើយការនេសាទផ្សេងទៀតភាគច្រើនមានលក្ខណៈជាទ្រង់ទ្រាយតូច គឺជាការនេសាទតាមលក្ខណៈគ្រួសារ ។

រដ្ឋបាលជលផលបាននិយាយថា នៅឆ្នាំ ២00៣ ផលិតផលត្រីសរុបគឺហួសពីការស្មាន "កើនខ្ពស់ជាងឆ្នាំកន្លងមក" និងបានផ្តល់ព័តិមានថា អត្រានៃការនេសាទតាមគ្រួសារនីមួយៗ បានធ្លាក់ចុះស្របនឹងតំលៃត្រីនៅទីផ្សារ ។ នាយកដ្ឋានបានលើកឡើងថា "ប្រភេទធំៗកំពុងមានការធ្លាក់ចុះ ហើយជំនួសដោយត្រីតូចៗដែលងាយកើត និងឆាប់ធំធាត់ ប៉ុន្តែមានតំលៃទាប" ។ នៅឆ្នាំ ១៩៤0 ការនេសាទទទួលបានផល ៣៤៧ គ.ក ប៉ុន្តែរហូតដល់

## ការនេសាទទ្រង់ទ្រាយតូច មធ្យម និងធំ



អនុលោមតាមច្បាប់ឆ្នាំ ១៩៨៧ ការនេសាទនៅប្រទេសកម្ពុជាត្រូវបានចែកជា ៣ប្រភេទ គឺ ទ្រង់ទ្រាយតូច មធ្យម និងធំ ដែលផ្អែកតាមទំហំនៃឧបករណ៍នេសាទ ៥២ប្រភេទ និងមានវិសាលភាពទិន្នផលទទួលបាន ។ រដ្ឋបាលជលផលបានបែងចែកឧបករណ៍នេសាទជាង ១០០ប្រភេទផ្សេងទៀត ដែលប្រភេទទាំងនោះមិនមានចែងនៅក្នុងច្បាប់ទេ ។

ឧបករណ៍នេសាទទ្រង់ទ្រាយតូច ដែលទទួលបានបរិមាណផលត្រីចន្លោះពីពាក់កណ្តាល និង២/៣ នៃបរិមាណផលនេសាទជារៀងរាល់ឆ្នាំ ជាការនេសាទតាមលក្ខណៈគ្រួសារ និងមានទីតាំងនៅជុំវិញបឹងទន្លេសាប ដោយបានប្រើប្រាស់ឧបករណ៍ធន់តូចដូចជា : មង និងលប ហើយការនេសាទដែលមានទ្រង់ទ្រាយតូចដូច្នេះ មិនតំរូវអោយមានលិខិតអនុញ្ញាត្តិ និងធ្វើការនេសាទបានរយៈពេលពេញមួយឆ្នាំ ។ គ្រួសារដែលមានមុខរបរនេសាទស្ទើរតែ៩០% នៃគ្រួសារសរុប គេជឿជាក់ថាបានប្រើប្រាស់ឧបករណ៍ទ្រង់ទ្រាយតូច ។ នៅឆ្នាំ ១៩៩៥ ឧបករណ៍នេសាទមានចំនួន ៨៥,០០០គ្រឿង ដែលអាចនេសាទត្រីបានប្រមាណ ៧០០គ.ក ក្នុងមួយគ្រួសារ និងបរិមាណផលត្រីដែលប្រមូលបានលើសពី២/៣ នៅក្នុងខេត្តកំពង់ឆ្នាំង និងបាត់ដំបង ។ ការនេសាទត្រីនៅតាមវាលស្រែនៅជុំវិញបឹងទន្លេសាប អាចប្រមូលផលបានរហូតដល់ ១០០,០០០តោន ក្នុងមួយឆ្នាំ ដែលបរិមាណនេះស្មើនឹង ១/៤ នៃផលត្រីដែលនេសាទបាននៅទូទាំងប្រទេស ។

ការនេសាទទ្រង់ទ្រាយមធ្យម ប្រមូលផលបានប្រហែល១/៤ នៃផលនេសាទប្រចាំឆ្នាំ នេះជាការនេសាទមានលក្ខណៈជាពាណិជ្ជកម្ម និងត្រូវបានអនុញ្ញាត្តអោយធ្វើការនេសាទនៅចន្លោះខែតុលា និងខែឧសភាប៉ុណ្ណោះ គឺនៅពេលទឹកទន្លេចាប់ផ្តើមស្រក ។ ការនេសាទប្រភេទនេះមិនចាំបាច់តំរូវអោយមានអាជ្ញាប័ណ្ណទេ ហើយឧបករណ៍សំខាន់មាន មងសំរាប់ប្រើប្រាស់ក្នុងការនេសាទ ។ នៅក្នុងឆ្នាំ១៩៩៥ មានលំនៅដ្ឋានប្រហែល ៩០០០គ្រួសារ រស់នៅជុំវិញបឹងទន្លេសាប ធ្វើការនេសាទជាលក្ខណៈទ្រង់ទ្រាយមធ្យម ហើយផលនេសាទទទួលបានជាមធ្យមមាន ៥,៣តោន/គ្រួសារ ក្នុងមួយឆ្នាំ ។

ការនេសាទទ្រង់ទ្រាយធំមានប្រហែល ៥% នៃការនេសាទសរុប ហើយការនេសាទនេះគឺមានលក្ខណៈជាឧស្សាហកម្ម និងពាក់ព័ន្ធសំខាន់លើផ្ទៃកឡូតិ៍នេសាទ ដែលត្រូវបានជួលរយៈពេល២ឆ្នាំ ។ ឧបករណ៍នេសាទភាគច្រើនអាចគ្របដណ្តប់ផ្ទៃដីទំហំធំដូចជា ដាយ និងអួន ។ នៅឆ្នាំ ១៩៩៥ ផលនេសាទមធ្យមតាមឡូតិ៍និមួយៗមានប្រមាណ ៥៤,១តោន ។ ហើយការដោយប្រើប្រាស់ឧបករណ៍នេសាទដូចជាដាយត្រី មាននៅទន្លេសាបខាងជើងក្រុងភ្នំពេញត្រូវបានកំណត់ជាការនេសាទដោយទ្រង់ទ្រាយធំផងដែរ ។

(ប្រភព: រដ្ឋបាលជលផល)

នាពាក់កណ្តាលទសវត្សរ៍ ឆ្នាំ១៩៩០ បង្ហាញថា ផលនេសាទត្រីក្នុងម្នាក់ៗមានការធ្លាក់ចុះដល់ ១៩២ គ.ក គឺស្មើនឹង ៤៥% ។

ផលនេសាទនៅបឹងទន្លេសាប មានប្រមាណ ៦០% នៃផលិតផលត្រីទឹកសាបសរុបនៅក្នុងប្រទេសកម្ពុជា ។ យោងតាមមជ្ឈមណ្ឌលត្រីពិភពលោក បានវាយតំលៃកាលពីឆ្នាំ២០០៥ ប្រជាពលរដ្ឋ ១.២៥លាននាក់ រស់នៅខេត្តជុំវិញបឹងទន្លេសាបពឹងផ្អែកលើផលិតផលត្រី និងធនធានវារីជាតិ សំរាប់ជាអាហារ និងជីវភាពរស់នៅរបស់ពួកគាត់ ប៉ុន្តែផ្អែកតាមការស្រាវជ្រាវដោយឡែកមួយនៅខេត្តកំពង់ឆ្នាំង និងសៀមរាប របស់គណៈកម្មការទន្លេមេគង្គបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៩៨ បានអោយដឹងថា ប្រជាពលរដ្ឋដែលពឹងផ្អែកទៅលើផលិតផលត្រីមានប្រមាណ ១.១៧លាននាក់ ។ ការសិក្សាថ្មីនេះបានអោយដឹងថា ខេត្តចំនួន០៥ នៅជុំវិញបឹងទន្លេសាបមានចំនួនប្រជាពលរដ្ឋ ១៩៥ ០០០គ្រួសារ ជាអ្នកនេសាទ និងមានចំនួនសហគមន៍នេសាទចំនួន ១៤៥សហគមន៍ ។

តាមរបាយការណ៍ឆ្នាំ២០០៦ របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប នៃរដ្ឋបាលជលផល បានធ្វើការប៉ាន់ប្រមាណតំលៃផលនេសាទ និងធនធានវារីជាតិដទៃទៀត ដែលទទួលបានពីបឹងទន្លេសាបមាន ២៣៣លាន ដុល្លា/ឆ្នាំ ។ របាយការណ៍នេះផ្អែកតាមតួលេខប្រាក់ចំណូលលើប្រជាជនចំនួន ២០៩,០០០គ្រួសារ ដែលពួកគាត់រស់នៅដោយពឹងផ្អែកលើធនធានវារីជាតិស្ថិតក្នុង ខេត្តកំពង់ឆ្នាំង សៀមរាប បាត់ដំបង ពោធិ៍សាត់ និងកំពង់ធំ ព្រមទាំងមានប្រាក់ចំណូលប្រចាំឆ្នាំសរុបមាន ២១៥លានដុល្លា/ឆ្នាំ គឺស្មើនឹង ១៧២ដុល្លា/គ្រួសារ ដែលមានសមាជិក ៦នាក់ជាមធ្យម ។ បន្ថែមទៅលើតំលៃនៃចំណូលនេះ ១៣លានដុល្លា គឺជាតំលៃ ដែលបង្ហាញពីផលត្រីនេសាទសំរាប់បរិភោគជាជាងសំរាប់យកទៅលក់ដែលស្មើនឹង ៦៣ដុល្លា/គ្រួសារ ហើយនិងតំលៃ ៥លានដុល្លាបន្ថែម គឺជាតំលៃដែលប្រជាពលរដ្ឋទទួលផលបានពីរុក្ខជាតិ និងសត្វរស់នៅក្នុងទឹកដែលត្រូវបានចាត់ទុកជាសម្បត្តិរួម ។ ការបរិភោគត្រីប្រចាំឆ្នាំរបស់ប្រជាជននៅជុំវិញបឹងទន្លេសាបត្រូវ



PHOTO: ELEANOR BRIGGS WCS

បានប៉ាន់ប្រមាណថាមាន ៧៦គ.ក ក្នុងមនុស្សម្នាក់ ដែលជាអត្រាខ្ពស់នៅក្នុងប្រទេសកម្ពុជា និងជាអត្រាខ្ពស់បំផុតនៅលើពិភពលោកផងដែរ ។

### ចំណូលបានពីធនធានវារីជាតិនៅតំបន់បឹងទន្លេសាប      ខ្នាត លានដុល្លា)

ការប៉ាន់ស្មានប្រាក់ចំណូលប្រចាំឆ្នាំសំរាប់គ្រួសារដែលពឹងផ្អែកទៅធនធានវារីជាតិ  បូកបន្ថែមលើការប្រើប្រាស់ត្រីតាមលំនៅស្ថាន និងផលដែលប្រមូលបានពីសត្វ រុក្ខជាតិរស់នៅក្នុងទឹក ក្នុងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់  ខេត្តបាត់ដំបង  ខេត្តសៀមរាប  និង ខេត្តកំពង់ធំ ។

| កំរិតប្រាក់ចំណូលគ្រួសារ | កំពង់ឆ្នាំង | ពោធិ៍សាត់ | បាត់ដំបង | សៀមរាប | កំពង់ធំ | សរុប |
|---|---|---|---|---|---|---|
| ≤ ១,០០០ | ១៦.២ | ១៣.៧ | ១៥.២ | ១២.៨ | ១២.៧ | ៧០.៦ |
| ១,០០១-២,០០០ | ៧.១ | ១១.៦ | ៩.៥ | ៨.០ | ៧.៩ | ៤៤.១ |
| ២,០០១-៥,០០០ | ៤.៩ | ១៩.៨ | ១៣.៣ | ១១.២ | ១១.១ | ៦០.៣ |
| > ៥,០០០ | ៣.១ | ១២.២ | ៩.៣ | ៧.៨ | ៧.៧ | ៤០.១ |
| សរុប ចំណូល | ៣១.៣ | ៥៧.២ | ៤៧.៣ | ៣៩.៩ | ៣៩.៤ | ២១៥.១ |
| | | | | | | |
| ការនេសាទ សំរាប់ប្រើប្រាស់ក្នុងផ្ទះ | ១,៨ | ៣,៦ | ២,៨ | ២,៤ | ២,៤ | ១៣.០ |
| ពពួកសត្វ និងរុក្ខជាតិក្នុងទឹក | | | | | | ៥.០ |
| វាយតំលៃ សរុប | ៣៣.១ | ៦០.៨ | ៥០.១ | ៤២.៣ | ៤១.៨ | ២៣៣.១ |

ប្រភព: រដ្ឋបាលជលផល

យោងតាមរបាយការណ៍ បានបង្ហាញអោយដឹងថា ប្រជាជនរស់នៅជុំវិញបឹងទន្លេសាបមានមុខរបរចិញ្ចឹមជីវិតពឹងផ្អែកខ្ពស់ទៅលើផលនេសាទ និងធនធានវារីជាតិដទៃទៀត ។ ប្រជាពលរដ្ឋប្រមាណ ១៥០,០០០គ្រួសារ ស្មើរតែ ១/៣ភាគ នៃគ្រួសារទាំងអស់ស្ថិតក្រោមខ្សែបន្ទាប់នៃភាពក្រីក្រ មានប្រាក់ចំណូលប្រចាំឆ្នាំ១,០០០ដុល្លា ឬ តិចជាង ដែលមធ្យម ៤៧០ដុល្លា/ឆ្នាំ ឬប្រហែល៧៨ដុល្លា/ម្នាក់ ។ ពាក់ព័ន្ធការនេសាទដោយទ្រង់ទ្រាយតូច ដែលមានការកើនឡើងធ្វើអោយគ្រួសារក្រីក្រ ដែលពឹងផ្អែកទាំងស្រុងលើធនធានវារីជាតិ សំរាប់ជីវភាពរបស់ពួកគេ បានបង្ហាញថា មាន៣២%នៃប្រាក់ចំណូលសរុប ។ ផ្ទុយមកវិញ គ្រួសារអ្នកមាន ១២% រកប្រាក់ចំណូលបានច្រើនជាង ២,០០០ដុល្លា/ឆ្នាំត្រូវបានគេប៉ាន់ប្រមាណថា មានស្មើរតែពាក់កណ្តាលនៃប្រាក់ចំណូលដែលរកបានដោយគ្រួសារនៅជុំវិញបឹងទន្លេសាបទាំងមូលដែលពឹងផ្អែកលើធនធានក្នុងទឹក ។ ការសិក្សាបង្ហាញថា គ្រួសារដែលរកប្រាក់ចំណូលច្រើននេះ ទំនងជាមេគ្រួសារ ជាម្ចាស់ឡូតិ៍នេសាទ ឬ ពាក់ព័ន្ធការនេសាទធុនមធ្យម ។

## គ្រួសារដែលរស់នៅតំបន់បឹងទន្លេសាបរស់នៅដោយពឹងផ្អែកខ្ពស់ទៅលើធនធានក្នុងទឹក

គ្រួសារមានសមាជិកមធ្យមចំនួន ០៦ នាក់ នៅក្នុងខេត្ត កំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពង់ធំ

| កំរិតប្រាក់ចំណូល | កំពង់ឆ្នាំង | ពោធិ៍សាត់ | បាត់ដំបង | សៀមរាប | កំពង់ធំ | សរុប |
|---|---|---|---|---|---|---|
| ≤ 4 ១,០០០ | ៣៩,៧៤២ | ២៤,៦៣០ | ៣២,៣៨៤ | ២៧,៣០៩ | ២៦,៩២៤ | ១៥០,៩៨៨ |
| 4 ១,០០១-២,០០០ | ៥,៧៤៦ | ៨,៤៧៩ | ៧,១៩៦ | ៦,០៦៩ | ៥,៩៨៣ | ៣៣,៤៧៣ |
| 4 ២,០០១-៥,០០០ | ១,៩១៥ | ៥,៦៥៣ | ៤,០៤៨ | ៣,៤១៤ | ៣,៣៦៥ | ១៨,៣៩៥ |
| >4 ៥,០០០ | ៤៧៩ | ១,៦១៥ | ១,៣៤៩ | ១,១៣៨ | ១,១២២ | ៥,៧០៣ |
| សរុប | ៤៧,៨៨២ | ៤០,៣៧៦ | ៤៤,៩៧៨ | ៣៧,៩២៩ | ៣៧,៣៩៤ | ២០៨,៥៦០ |

ប្រភព: រដ្ឋបាលជលផល

រដ្ឋបាលជលផលបានបញ្ជាក់ថា ភាពខុសគ្នាទាំងស្រុងនៃប្រាក់ចំណូលក្នុងតំបន់បឹងទន្លេសាបគឺជា "បញ្ហាធ្ងន់ធ្ងរមួយដែលចាំបាច់ត្រូវតែបង្ហាញ" ដើម្បីអោយឃើញពីការពឹងផ្អែកកំរិតខ្ពស់ទៅលើធនធានវារីជាតិក្នុងចំណោមក្រុមគ្រួសារក្រីក្របំផុត ។ នាយកដ្ឋានបាននិយាយថា ការព្រួយបារម្ភណ៍ពីជីវភាពរស់នៅរបស់ពួកគេដូចជា ការអនុញ្ញាតអោយចូលនេសាទដោយសុវត្ថិភាព និងសិទ្ធិជាមូលដ្ឋានទៅលើសន្តិសុខស្បៀង លើការងារ ការអប់រំ និងការថែទាំសុខភាពត្រូវបានបញ្ជាក់នៅក្នុងកិច្ចពិភាក្សាអំពីការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីនៅបឹងទន្លេសាប ។ ក្រុមគ្រួសារដែលរស់នៅបឹងទន្លេសាបមាន ខ្មែរ ចិន វៀតណាម និងចាម ។

យោងតាមរបាយការណ៍បានបង្ហាញថា លទ្ធផលប្រចាំឆ្នាំ ទៅលើធនធានវារីជាតិនៅតំបន់បឹងទន្លេសាបដែលភ្ជាប់មកជាមួយ មិនមានដាក់បញ្ចូលនូវតំលៃនៃប្រព័ន្ធអេកូឡូស៊ី រឺតំលៃសង្គមមកជាមួយទេ ។ ជាងនេះទៅទៀត របាយការណ៍បានបញ្ជាក់ថា ធនធានជលផល និងធនធានវារីជាតិដទៃទៀត គឺគ្រាន់តែជាផ្នែកមួយនៃតំបន់ដីសើមទូទៅរបស់បឹងទន្លេសាប ដែលរួមមានដូចជា : ទន្លេ ស្ទឹង បឹង វាលស្រែ ព្រៃលិចទឹក និងតំបន់ផ្សេងទៀតប៉ុណ្ណោះ ។ របាយការណ៍បានជំទាស់ថាគួរតែបញ្ចូលតំលៃនៃទំនាក់ទំនងតំបន់ដីសើមបឹងទន្លេសាបទៅក្នុងនោះដោយយោងលើមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងការពឹងផ្អែកទៅធនធានរបស់ពួកគេ ។

ប្រភព: រដ្ឋបាលជលផល, គណៈកម្មការទន្លេមេគង្គ

## ការនេសាទដោយដាយត្រីមាននៅក្នុងរបាយការណ៍ឆ្នាំ ២០០៦



ការនេសាទដ៏សំខាន់១ក្នុងប្រព័ន្ធបឹងទន្លេសាបគឺ ការនេសាទដោយប្រើឧបករណ៍ដាយ នៅផ្ទៃទន្លេខាងជើងទីក្រុងភ្នំពេញដែលនេសាទបានត្រឹមតែត្រីរៀល នៅពេលដែលពួកវាចាកចេញពីបឹងរវាងខែតុលា និងកុម្ភៈជារៀងរាល់ឆ្នាំ។ ការនេសាទដាយ ជាធម្មតាទទួលបានពី ៤-៥% នៃការនេសាទប្រចាំឆ្នាំរបស់ប្រជាជន ក៏ប៉ុន្តែនៅក្នុងឆ្នាំ ២០០៥-២០០៦ ការនេសាទកើនទ្វេដងរហូតដល់៣០,០០០តោន ក៏រិតខ្ពស់បំផុតចាប់តាំងពីមានការត្រួតពិនិត្យតាមប្រព័ន្ធដែលចាប់ផ្តើមនៅឆ្នាំ១៩៩៥ ។ គណៈកម្មការទន្លេមេគង្គបានរាយការណ៍នៅពាក់កណ្តាលឆ្នាំ ២០០៦ថា ការបង្ក្រាបលើការនេសាទខុសច្បាប់ទៅលើការប្រើឧបករណ៍ដាយមានការកើនឡើងពីរដ្ឋបាលជលផលឆ្នាំ២០០៤ និង២០០៥ ។ មានកត្តាផ្សេងៗដែលធ្វើអោយត្រីមានភាពសំបូរច្រើនលើសលុបនៅរដូវកាលមុន ដែលកើនឡើងដោយលក្ខខ័ណ្ឌអំណោយផលល្អពីបរិស្ថាន ។

ប្រភព: គណៈកម្មការទន្លេមេគង្គ



PHOTOS: MITCHELL ISAACS

# ១០

# សហគមន៍នេសាទ



# សហគមន៍នេសាទ

យោងតាមអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ដែលបានប្រកាសដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍នាពាក់កណ្តាលឆ្នាំ២០០៥ ថា ប្រជាពលរដ្ឋរស់នៅក្នុងដែននេសាទ ឬ នៅជិតដែននេសាទអាចបង្កើតសហគមន៍នេសាទដោយស្ម័គ្រចិត្ត ។ សមាជិករបស់សហគមន៍ត្រូវតែជាប្រជាពលរដ្ឋខ្មែរ និងមានទីលំនៅក្នុងដែននេសាទ ។ ប្រជាពលរដ្ឋត្រូវតែអនុវត្តដូចតទៅ ៖

- គ្រប់គ្រងការនេសាទទឹកសាប និងប្រព័ន្ធអេកូឡូស៊ីនៅតាមតំបន់ដែលកាត់ចេញពីឡូតិ៍នេសាទ ។
- គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និង សមធម៌ ។
- បង្កើនការយល់ដឹង និងទទួលស្គាល់អំពីអត្ថប្រយោជន៍នៃធនធានជលផលតាមរយៈការការពារ និងការគ្រប់គ្រង ។
- ផ្តល់ក្របខណ្ឌច្បាប់សំរាប់បង្កើតសហគមន៍នេសាទ និង
- លើកកំពស់ស្តង់ដារនៃការរស់នៅ និងកាត់បន្ថយភាពក្រីក្រ
- សហគមន៍នេសាទអាចទទួលហិរញ្ញវត្ថុពីវិភាគទានរបស់សមាជិក អំណោយ ជំនួយរបស់រដ្ឋាភិបាល ពីអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងប្រាក់ចំណូលស្របច្បាប់ដទៃទៀត ។

សមាជិកសហគមន៍នេសាទត្រូវអោយគោរពបទបញ្ជារបស់រដ្ឋបាលជលផល និងចូលរួមក្នុងការបង្កើតតំបន់អភិរក្ស ។ ពួកគេក៏ទទួលខុសត្រូវផងដែរលើការធានាបាននូវសិទ្ធិស្មើគ្នាដល់សមាជិកទាំងអស់ ដូចជា ការអនុវត្តន៍ច្បាប់ ការធ្វើផែនការគ្រប់គ្រង និងការចុះកិច្ចព្រមព្រៀងជាមួយនាយកដ្ឋាន ។

សមាជិកទាំងអស់រួមជាមួយសមត្ថកិច្ច មានសិទ្ធិក្នុងការរឹបអូសវត្ថុតាងនៃការនេសាទខុសច្បាប់ ការរំលោភច្បាប់ និងឃាត់ខ្លួនជនល្មើស ។ ប៉ុន្តែពួកគេមិនអាចធ្វើអ្វីមួយនៅខាងក្នុងតំបន់សហគមន៍នេសាទដោយពុំមានការអនុញ្ញាតពីរដ្ឋបាលជលផលបានឡើយ ។ ពួកគេពុំមានសិទ្ធិកាត់ជាចំណែក ឬបង្កើតជាកម្មសិទ្ធិឯកជននៅក្នុងកន្លែងនេសាទ





សហគមន៍ ឬចុះកិច្ចព្រមព្រៀងណាមួយ ជាមួយអ្នកខាងក្រៅ សូម្បីតែក្នុងកាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក៏ដោយ ។

សហគមន៍នីមួយៗត្រូវដឹកនាំដោយគណៈកម្មាធិការដែលមានសមាជិក ៥រូប ៧រូប ឬ ១១រូប ត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតដោយសំងាត់សំរាប់អាណត្តិ ៥ឆ្នាំ ។ បុគ្គលដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ នឹងត្រូវជ្រើសតាំង ជាប្រធានគណៈកម្មាធិការ និងបុគ្គលដែលទទួលសំឡេងខ្ពស់ទី២ នឹងត្រូវជ្រើសតាំងជាអនុប្រធាន។ មន្ត្រីអាជ្ញាធរជលផល និងសមាជិកក្រុមប្រឹក្សាឃុំនឹងត្រូវអញ្ជើញចូលរួមសង្កេតការបោះឆ្នោត តែវត្តមានរបស់ពួកគាត់មិនមែនចូលរួមការបោះឆ្នោតឡើយ។

គណៈកម្មាធិការគ្រាន់តែជាអង្គការដែលបានប្រគល់សិទ្ធិក្នុងការដាក់ពាក្យទៅរដ្ឋបាលជលផលដើម្បីសុំការអនុម័តលើកិច្ចព្រមព្រៀងសហគមន៍នេសាទ ដែលបន្តរយៈពេលមិនលើសពី ៣ឆ្នាំ ។ គណៈកម្មាធិការសហគមន៍នេសាទអាចស្នើសុំរកជំនួយបច្ចេកទេសពីមន្ត្រីជលផល និងបុគ្គលនានាដើម្បីរៀបចំសេចក្តីព្រាងលើកិច្ចព្រមព្រៀងសហគមន៍នេសាទ។ កិច្ចព្រមព្រៀងតំរូវអោយមានភ្ជាប់មកជាមួយនូវផែនទីមាត្រដ្ឋាន ១:៥០ 000 បញ្ជីឈ្មោះសមាជិកទាំងអស់ និងសមាជិកគណៈកម្មាធិការសហគមន៍ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងសេចក្តីថ្លែងការណ៍អំពីគោលបំណងរបស់សហគមន៍នេសាទ។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀង ត្រូវប្រកាសបិទផ្សាយជាសាធារណៈ និងតាមការិយាល័យនានារបស់រដ្ឋាភិបាលនៅក្នុងឃុំ និងស្រុកមានរយៈពេល៣០ថ្ងៃ។ មន្ត្រីឃុំ ស្រុក ត្រូវតែទទួលខុសត្រូវដោះស្រាយទំនាស់ រដ្ឋបាលជលផលទទួលខុសត្រូវលើការអនុម័តលើសំណើ ដើម្បីបន្តកិច្ចព្រមព្រៀងក្នុងរយៈពេល ៣០ថ្ងៃ មុនអស់សុពលភាព។ កិច្ចព្រមព្រៀងត្រូវបន្តដោយស្វ័យប្រវត្តិ ប្រសិនបើរដ្ឋបាលជលផល មិនបានធ្វើសេចក្តីជូនដំណឹងឆ្លើយតបទៅនឹងសំណើសុំបន្តរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងក្នុងរយៈពេល ៣០ថ្ងៃ។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចចាត់ទុកជាមោឃៈមុនពេលអស់សុពលភាព ប្រសិនបើសហគមន៍បានបំផ្លាញធនធាន ដោយខកខានមិនបានអនុវត្ត ដោយរំលោភលើបទបញ្ជាផ្ទៃក្នុង ឬបទ

បញ្ញត្តិផ្សេងៗ ។ កិច្ចព្រមព្រៀងអាច ចាត់ទុកជាមោឃៈ ប្រសិនបើរដ្ឋាភិបាលសំរេចថា តំបន់នេះត្រូវដាក់សំរាប់ប្រើប្រាស់ជាប្រយោជន៏សាធារណៈ និងប្រយោជន៏សង្គម ។ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៏ អាចត្រូវបានចាត់ទុកជាមោឃៈផងដែរ តាមសំណើពីសមាជិកគណៈកម្មាធិការ ដែលមានសំឡេង ២/៣ ។

ក្រោយពីទទួលបានកិច្ចព្រមព្រៀងដែលបានអនុម័តរួចហើយ គណៈកម្មាធិការសហគមន៏នេសាទអាចស្នើសុំបច្ចេកទេសពីអាជ្ញាធរ សមត្ថកិច្ចជលផលដើម្បីរៀបចំផែនការគ្រប់គ្រង ។ រយៈពេលនៃសុពលភាពផែនការនេះ ត្រូវមានដូចគ្នាទៅនឹងសុពលភាពនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៏ផងដែរ ប៉ុន្តែត្រូវតែធ្វើការពិនិត្យឡើងវិញដោយការិយាល័យជលផល ខេត្ត/ស្រុក ជារៀងរាល់ឆ្នាំ ។ សមាជិកគណៈកម្មាធិការត្រូវចូលរួមត្រួតពិនិត្យ វាយតំលៃផែនការគ្រប់គ្រង ដើម្បីធានានិរន្តរភាពនៃដែននេសាទ រដ្ឋបាលជលផលត្រូវការផែនការគ្រប់គ្រងដើម្បីពិនិត្យឡើងវិញដោយអនុលោមតាមបរិធានច្បាប់ដែលពាក់ព័ន្ធនឹងការនេសាទ ។



រដ្ឋបាលជលផលបានប្រកាសថា ការផ្លាស់ប្តូរទៅរកទំរង់ថ្មីត្រឹមត្រូវ "ជានិច្ចកាលតែងតែមានជំលោះថ្មីៗ សម្ព័ន្ធភាពថ្មី កាលានុវត្តភាព និងការគំរាមកំហែងផ្សេងៗ" ។ រដ្ឋបាលលើកឡើងថា នៅដំណាក់កាលផ្លាស់ប្តូរនៃប្រទេសកម្ពុជា ចំពោះសហគមន៏នេសាទ លទ្ធភាពច្រើនអាចកើតមានឡើង "វានឹងក្លាយជាការរិះគិត ដោយផ្អែកទៅតាមសុទ្ធសាធុការពរ ជាជាងការពិតក្នុងសម័យកាល បើឋានៈតាមផ្លូវច្បាប់ត្រូវបានទទួលសិទ្ធិថ្មីចំពោះសហគមន៏នឹងត្រូវបានគោរពដោយសមាជិកនៅក្នុងសង្គម ។" ដោយដឹងពីលទ្ធភាពនៃភាពតានតឹងថ្មីរបស់សង្គម និងការជួយដល់ប្រជាពលរដ្ឋ ដើម្បីដោះស្រាយជំលោះតាមតំបន់ ដូច្នេះវានឹងក្លាយជាកិច្ចការសំខាន់មួយ ដែលមិនត្រឹមតែទីភ្នាក់ងាររដ្ឋាភិបាលប៉ុណ្ណោះទេ អង្គការសង្គមស៊ីវិលក៏មានការជាប់ពាក់ព័ន្ធក្នុងការអភិវឌ្ឍសហគមន៏នេសាទផងដែរ ។

រដ្ឋបាលជលផល បានបង្កើតបណ្តាល័យតាមបណ្តាខេត្ត ជាមួយអង្គការស្បៀងអាហារ កសិកម្ម និងអង្គការ NGO Forum ។

រដ្ឋាភិបាលកម្ពុជាមានក្រុមសកម្មភាពជលផលបានពង្រីក៤០០ក្រុមការងារបន្ថែមទៀត ។ ក៏ប៉ុន្តែការរៀបចំនោះមិនទាន់បានយល់ព្រមនៅឡើយ មានការងារបន្តជាច្រើនដែលនឹងបញ្ចប់ដោយជោគជ័យនាពេលខាងមុខ ។

យោងតាមអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសហគមន៏នេសាទ ដែលបានប្រកាសដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៏នាពាក់កណ្តាលឆ្នាំ២០០៥ថា សមាជិកទាំងអស់ រួមជាមួយសមត្ថកិច្ច មានសិទ្ធិក្នុងការរឹបអូសវត្ថុតាងនៃការនេសាទខុសច្បាប់ ការរំលោភច្បាប់ និងឃាត់ខ្លួនជនល្មើស ។ ប៉ុន្តែយោងតាមអនុក្រឹត្យនោះមិនអោយសមាជិកសហគមន៏នេសាទចូលរួមទេ ។

ប្រភព : រដ្ឋបាលជលផល

# ១១

# ការគ្រប់គ្រងព្រៃឈើ នៅខេត្តសៀមរាប



# ការគ្រប់គ្រងព្រៃឈើនៅខេត្តសៀមរាប

ប្រជាពលរដ្ឋនៅក្នុងតំបន់ និងមកពីខាងក្រៅតំបន់បានប្រើប្រាស់ធនធានធម្មជាតិខេត្តសៀមរាបជាយូរណាស់មកហើយ ដោយមិនបានពិចារណាអំពីវិធីក្នុងការទទួលផលប្រកបដោយនិរន្តរភាព និងការអនុវត្តដទៃទៀតទេ ។ សកម្មភាពបែបនេះបង្ហាញអោយឃើញពីប្រព័ន្ធ "បើកចំហ" ដោយហេតុថាធនធាន ត្រូវបានចាត់ទុកជាសម្បត្តិសាធារណៈ ឬជាកម្មសិទ្ធិរបស់សហគមន៍ដែលនៅក្បែរ ។ ការប្រើប្រាស់ធនធានហួសប្រមាណ គឺជាគ្រោះថ្នាក់ធ្ងន់ធ្ងរនៅតំបន់ព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ទោះបីជាមានការខិតខំប្រឹងប្រែងពីអាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ដោយមិនមាននិរន្តរភាពលើធនធានកសិកម្ម ជលផល និងព្រៃឈើ ដោយមិនគិតគូរនៅតែបន្ត ។

នៅក្នុងផ្នែកកសិកម្ម កសិករបានកាប់បំផ្លាញព្រៃលិចទឹកដើម្បីបង្កើនផ្ទៃដីស្រែ និងដាំសណ្តែក ។ តាមរបាយការណ៍ព្រៃលិចទឹកនៅខាងជើងបឹងទន្លេសាបមានប្រមាណ ៤០០ហិកតា ត្រូវបានរងការបំផ្លាញ ដើម្បីពង្រីកដីសំរាប់កសិកម្ម ដែលការរានដីព្រៃលិចទឹកបែបនេះ មិនត្រូវបានកំណត់ក្នុងបញ្ញត្តិច្បាប់នោះទេ ។



នៅក្នុងផ្នែកជលផល ផលនេសាទបានធ្លាក់ចុះដោយសារការនេសាទខុសច្បាប់ និងការបំផ្លាញជំរកត្រីពង និងការបន្តពូជរបស់ត្រី ។ សកម្មភាពនេសាទខុសច្បាប់នៅរដូវត្រីពងដោយមានដូចជា ការនេសាទ ដោយប្រើឧបករណ៍អគ្គិសនី ( ការឆក់ត្រី) និងការនេសាទដោយប្រើឧបករណ៍អួនខ្នាតធំ ។ នៅតំបន់ព្រែកស្រមោច មានភូមិមួយនៅក្នុងស្រុកសូទ្រនិគមបានអោយដឹងថា ការនេសាទប្រចាំថ្ងៃរបស់អ្នកនេសាទក្នុងសហគមន៍បានធ្លាក់ចុះពី ១០គ.ក្រ មកនៅ ៣គ.ក ក្នុងមួយថ្ងៃ ដែលការធ្លាក់ចុះនេះមានរយៈពេល២ឆ្នាំ កន្លងមកហើយ ។

នៅក្នុងផ្នែកព្រៃឈើ ល្បឿននៃការកាប់ឈើកាលពីពេលថ្មីៗសំរាប់ទីផ្សារនាំចេញ និងការប្រមូលទិញឈើសំរាប់ទីផ្សារនៅក្នុងស្រុក មិនអាចទប់ស្កាត់បានទេ ។ ព្រៃឈើគ្របដណ្តប់នៅជុំវិញបឹងទន្លេសាបបានទទួលរងការហិនហោចយ៉ាងធ្ងន់ធ្ងរដោយសារការកាប់ឈើដោយខុសច្បាប់ និងការបំផ្លាញព្រៃលិចទឹក ។ ទោះជាសកម្មភាពកាប់ឈើត្រូវបានកំណត់ដោយច្បាប់ក៏ដោយ ប៉ុន្តែចំពោះការរកអុស និងឈើសំរាប់ប្រើប្រាស់តាមលំនៅដ្ឋាន នៅមិនមានស្ថាប័នណាទទួលខុសត្រូវនៅឡើយទេ ។

ដើម្បីដោះស្រាយនូវបញ្ហានៃការប្រើប្រាស់ធនធានមិនប្រកបដោយនិរន្តរភាពនៅបឹងទន្លេសាប នោះទីភ្នាក់ងាររដ្ឋាភិបាល អ្នកផ្តល់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតបានជំរុញនូវរបបគ្រប់គ្រងដោយសហគមន៍ ដើម្បីកែប្រែរបៀបប្រើប្រាស់ធនធាន ។ គំរោងដែលបានផ្តួចផ្តើមដោយអង្គការ ស្បៀងអាហារ និងកសិកម្មរបស់សហប្រជាជាតិ (FAO) ដែលគំរោងនេះបានយកចិត្ត

ទុកដាក់លើនៅតំបន់ផ្តល់ដាច់មានផ្ទៃដី ២៦៦០ហិកតា នៅក្នុងស្រុកសូទ្រនិគមដែលជាទីកន្លែងធនធានធម្មជាតិត្រូវបានរងការបំផ្លាញ និងបាត់បង់ ។ ជាងនេះទៀត ផ្ទៃតំបន់នេះចែកជាព្រៃលិចទឹកមាន ៨៣០ហិកតា តំបន់វាលស្មៅ ៧៨៩ហិកតា បឹងព្រែកស្រមោច ៥០០ហិកតា ដីសំរាប់កសិកម្មរដូវប្រាំង ៤១៧ហិកតា និងផ្ទៃដាំឈូកមាន ១២៥ហិកតា ។

គំរោងគ្រប់គ្រងសហគមន៍ផ្តល់ដាច់បានបង្ហាញថា ប្រជាពលរដ្ឋក្នុងសហគមន៍មិនមានចំណេះដឹងអំពីវិធីគ្រប់គ្រងធនធានធម្មជាតិ ហើយនិងពួកគាត់មិនមានការទទួលខុសត្រូវ ដោយសារពួកគាត់មិនយល់ដឹងពីការពាក់ព័ន្ធនឹងការសំរេចចិត្តលើការរៀបចំធនធាននោះយ៉ាងណា ។ ឧទាហរណ៍ ប្រជាពលរដ្ឋមិនធ្លាប់បានទទួលការប្រឹក្សាយោបល់លើបទបញ្ញត្តិច្បាប់ទាក់ទងនឹងការនេសាទខុសច្បាប់ទេ ប៉ុន្តែពួកគាត់ត្រូវទទួលការផាកពិន័យទៅតាមច្បាប់ទៅវិញ ។ ប៉ុន្តែការខ្វះខាតការទទួលខុសត្រូវនោះ បានលាយឡំជាមួយប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់នោះ ដែលអាចចេញចូលនេសាទនៅតំបន់ព្រៃលិចទឹកដោយពុំមានការព្រួយបារម្ភអំពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការបាត់បង់ធនធានដែលកើតមានឡើយ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ មេឃុំ និងអភិបាលស្រុក ព្រមទាំងអភិបាលខេត្តផងដែរបានអនុម័តលើរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ថ្មីសំរាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ ដែលជាអ្នកប្រើប្រាស់ធនធានទាំងនេះ ។ គ្រប់ទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ដែលទទួលខុសត្រូវលើការគ្រប់គ្រងធនធានធម្មជាតិ បានអនុម័តវិធីសាស្ត្រស្វែងរកការអភិរក្សនិងការគ្រប់គ្រងធនធានធម្មជាតិដោយផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។ ដោយយោងតាមរបៀបនៃការគ្រប់គ្រងសហគមន៍នេះ ការរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរទីតាំងតំបន់អនុវត្តគំរោង មានសិទ្ធិចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិសហគមន៍ តាមរយៈការជ្រើសរើសគណៈកម្មាធិការ ។ ច្បាប់ និងបទបញ្ញត្តិទាំងអស់ត្រូវតែមានការអនុម័តយល់ព្រមដោយអាជ្ញាធរមូលដ្ឋាន និងទីភ្នាក់ងាររដ្ឋាភិបាល ។



PHOTO: ALLAN MICHAUD WCS

ដំណាក់កាលទី១ នៃការអនុម័តច្បាប់ថ្មីនៅឆ្នាំ ១៩៩៧ នៅពេលដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំតំបន់ផ្តល់ដាច់ជាស្ថានីយ៍ស្រាវជ្រាវគំរូមួយ ។ ការស្រាវជ្រាវជាបន្តបន្ទាប់ត្រូវបានពិនិត្យទៅលើប្រវត្តិ ផ្នែកសេដ្ឋកិច្ច និងធនធានធម្មជាតិរបស់សហគមន៍ និងឈានដល់ការរៀបចំសិក្ខាសាលា ដើម្បីរៀបចំផែនការគ្រប់គ្រង ។ រដ្ឋបាលជលផល បានអនុម័តលើបទបញ្ញត្តិដែលពាក់ព័ន្ធនៅឆ្នាំ ១៩៩៩ ។

គំនិតផ្តួចផ្តើមរបស់សហគមន៍ត្រូវបានទទួលយកចាប់ពីមានការដាក់បញ្ចូលនូវកម្មវិធីដាំព្រៃលិចទឹកឡើងវិញ និងសិក្សាស្រាវជ្រាវទៅលើប្រភេទនៃឧបករណ៍នេសាទដែលត្រូវបានប្រើប្រាស់មិនប្រកបដោយនិរន្តរភាព ។ បញ្ហាជាអាទិភាពមាន ការកាត់បន្ថយការនេសាទខុសច្បាប់ និងការកាប់បំផ្លាញព្រៃលិចទឹក ។ ដោយឡែកការកាត់បន្ថយឡដុត ដែលប្រើប្រាស់ឈើមកពីព្រៃលិចទឹក ក៏ជាអាទិភាពមួយផ្សេងទៀត ដោយស្របជាមួយនឹងការអប់រំដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ដើម្បីការពារធនធានធម្មជាតិ ។

ប្រភព: គណៈកម្មការជាតិទន្លេមេគង្គ

# ១២

# គុណភាពទឹក និង អនាម័យ



PHOTO: TERRY WOOLTORTON L&L

# គុណភាពទឹក និងអនាម័យ

មូលនិធិអង្គការសហប្រជាជាតិសំរាប់កុមារ (UNICEF) បានធ្វើការប៉ាន់ប្រមាណថា ប្រជាជនតិចជាង ៣០% នៅជនបទបានទទួលទឹកស្អាតប្រើប្រាស់ និងតិចជាង ១០% ទទួលបានប្រព័ន្ធអនាម័យគ្រប់គ្រាន់ ដែលអត្រានេះស្ថិតក្នុងចំណោមនៃអត្រាទាបបំផុតនៅលើពិភពលោក ។ ជាមួយនឹងការវិនិយោគទុនតិចតួច ក្នុងការធានាលើស្ថេរភាពបរិមាណ ឬត្រួតពិនិត្យលើគុណភាពនេះ ភាគច្រើននៃគ្រួសារក្រីក្រនៅតាមជនបទ (តំបន់ដាច់ស្រយាល) នៅតែពឹងលើទឹកក្រោមដី ទឹកភ្លៀង និង ទឹកនៅតាមបឹងបួរផ្សេងៗ ។

ប្រភពផ្សេងទៀតបានបង្ហាញថាប្រជាជនមួយចំនួនមានបង្គន់ប្រើប្រាស់ អាងស្តុកទឹក បរិភោគទឹកដាំពុះ និង មួយចំនួនបានសំអាតដៃបានត្រឹមត្រូវមុនពេលបរិភោគ ។ សកម្មភាពទាំងនេះគួរចែកទៅដល់តំបន់ដែលមានជំងឺដែលទាក់ទងខ្លាំងទៅនឹងទឹក ជាពិសេសនៅក្នុងចំណោមប្រជាជនជនបទក្រីក្រ និងទៅដល់កន្លែងដែលមានអត្រាមរណៈខ្ពស់របស់កុមារមានអាយុតិចជាង ៥ឆ្នាំ ។ ការប្រើប្រាស់ទឹកដែលគ្មានសុវត្ថិភាពអាស្រ័យដោយវត្តមាននៃពពួកមេរោគដែលរស់នៅក្នុងទឹក និងសារធាតុបំពុលគឺជាការប៉ះពាល់ដល់សុខភាព ផលិតភាព និងសមត្ថភាពនៃការរៀនសូត្រ ។

| សុខភាព-ទិន្នន័យជាក់ស្តែងពីទឹក និងអនាម័យ<br>UNICEF ២០០២ | |
|---|---|
| ប្រជាជនកម្ពុជាដែលទទួលបានទឹកស្អាតបើប្រាស់ | ៣៤% |
| ប្រជាជនទីក្រុងដែលទទួលបានទឹកស្អាតប្រើប្រាស់ | ៥៨% |
| ប្រជាជនជនបទដែលទទួលបានទឹកស្អាតប្រើប្រាស់ | ២៩% |
| ប្រជាជនកម្ពុជាដែលទទួលបានប្រព័ន្ធអនាម័យ | ១៦% |
| ប្រជាជនទីក្រុងដែលទទួលបានប្រព័ន្ធអនាម័យ | ៥៣% |
| ប្រជាជនជនបទដែលទទួលបានប្រព័ន្ធអនាម័យ | ៨% |

តាមការសង្កេតឃើញពីស្ថានភាពថ្មីៗនៃអនាម័យ និងគុណភាពទឹកនៅក្នុងប្រទេស រាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងលើអនុសញ្ញាស្តីពី ការគ្រប់គ្រងលើការបំពុលទឹកនៅឆ្នាំ១៩៩៩ ។ អនុសញ្ញានេះមានគោលបំណងដើម្បីកាត់បន្ថយការបំពុលទឹក និងធ្វើអោយប្រសើរឡើងលើការគ្រប់គ្រងកាកសំណល់រាវសំរាប់ស្ថេរភាពគុណភាពទឹកស្អាតសំរាប់ការប្រើប្រាស់របស់មនុស្ស ។

# ទិន្នន័យទឹកស្អាត និងប្រព័ន្ធអនាម័យល្អ

## សំរាប់ខេត្តទាំងប្រាំជុំវិញបឹងទន្លេសាប

### ខេត្តកំពង់ឆ្នាំង

| | សរុប | ទីក្រុង | ជនបទ |
|---|---|---|---|
| ទឹកស្អាត (%) | ១៩,៣ | ៥១,៩ | ១៦,២ |
| ទឹកម៉ាស៊ីន រឺ ទឹកក្បាលម៉ាស៊ីន | ០,៨ | ៣,៧ | ០,៦ |
| អណ្តូងស្នប់ អណ្តូងខួង | ១៧,៤ | ៤១,១ | ១៥,១ |
| ទឹកទិញ | ១,១ | ៧,១ | ០,៥ |
| ទឹកគ្មានអនាម័យ | ៨០,៧ | ៤៨,១ | ៨៣,៨ |
| អណ្តូងជីក | ៥២,៩ | ២៥,៩ | ៥៥,៥ |
| ទឹកចេញពីក្រោមដី ទន្លេ អូរ បឹង ស្រះ ទឹកភ្លៀង | ២៤,៣ | ១៩,៨ | ២៤,៧ |
| ផ្សេងៗ | ៣,៥ | ២,៤ | ៣,៦ |
| សរុប | ១០០ | ១០០ | ១០០ |
| បង្គន់អនាម័យក្នុងបរិវេណ | ៦,០ | ២៩,៩ | ៣,៧ |

ប្រភពពី ក្រសួងផែនការ ជំរឿន ក្នុងឆ្នាំ ១៩៩៨



## ខេត្តពោធិ៍សាត់

| | សរុប | ទីក្រុង | ជនបទ |
|---|---|---|---|
| ទឹកស្អាត (%) | ១២,៣ | ៣៣,៣ | ៨,៣ |
| ទឹកម៉ាស៊ីន រឺ ទឹកក្បាលម៉ាស៊ីន | ២,៩ | ១១,០ | ១,៣ |
| អណ្ដូងស្នប់  អណ្ដូងខួង | ៣,៥ | ១,១ | ៤,០ |
| ទឹកទិញ | ៥,៩ | ២១,២ | ៣,០ |
| ទឹកគ្មានអនាម័យ | ៨៧,៧ | ៦៦,៧ | ៩១,៧ |
| អណ្ដូងជីក | ៥៣,៣ | ៣១,១ | ៥៧,៥ |
| ទឹកចេញពីក្រោមដី ទន្លេ អូរ បឹង ស្រះ ទឹកភ្លៀង | ២៩ | ៣៤,៧ | ២៨,០ |
| ផ្សេងៗ | ៥,៤ | ០,៩ | ៦,២ |
| សរុប | ១០០ | ១០០ | ១០០ |
| បង្គន់អនាម័យក្នុងបរិវេណ | ៨,៥ | ២០,៨ | ៦,២ |

ប្រភពពី ក្រសួងផែនការ ជំរឿន ក្នុងឆ្នាំ ១៩៩៨



## ខេត្តបាត់ដំបង

| | សរុប | ទីក្រុង | ជនបទ |
|---|---|---|---|
| ទឹកស្អាត (%) | ២១,៧ | ៥៧,០ | ១៤,២ |
| ទឹកម៉ាស៊ីន ទឹកក្បាលម៉ាស៊ីន | ៤,១ | ១៧,៥ | ១,៣ |
| អណ្តូងស្នប់ អណ្តូងខួង | ៧,៨ | ៤,៩ | ៨,៤ |
| ទឹកទិញ | ៩,៨ | ៣៤,៦ | ៤,៥ |
| ទឹកគ្មានអនាម័យ | ៧៨,៣ | ៤៣,០ | ៨៥,៨ |
| អណ្តូងជីក | ៣៧,៨ | ២២,៣ | ៤១,០ |
| ទឹកចេញពីក្រោមដី ទន្លេ អូរ បឹង ស្រះ ទឹកភ្លៀង | ៣៩,១ | ២០,១ | ៤៣,១ |
| ផ្សេងៗ | ១,៤ | ០,៦ | ១,៧ |
| សរុប | ១០០ | ១០០ | ១០០ |
| បង្គន់អនាម័យក្នុងបរិវេណ | ១៩,៩ | ៥៦,២ | ១២,២ |

ប្រភពពី ក្រសួងផែនការ ជំរឿន ក្នុងឆ្នាំ ១៩៩៨



## ខេត្តសៀមរាប

| | សរុប | ទីក្រុង | ជនបទ |
|---|---|---|---|
| ទឹកស្អាត (%) | ១៣,៤ | ៤៧,១ | ៦,៨ |
| ទឹកម៉ាស៊ីនរ៉ី ទឹកក្បាលម៉ាស៊ីន | ០,៦ | ១,៧ | ០,៤ |
| អណ្តូងស្នប់ អណ្តូងខួង | ១២,២ | ៤៤,៩ | ៥,៨ |
| ទឹកទិញ | ០,៦ | ០,៥ | ០,៦ |
| ទឹកគ្មានអនាម័យ | ៨៦,៦ | ៥២,៩ | ៩៣,២ |
| អណ្តូងជីក | ៦៩,៧ | ៣៨,០ | ៧៦,០ |
| ទឹកចេញពីក្រោមដី ទន្លេ អូរ បឹង ស្រះ ទឹកភ្លៀង | ១០,៩ | ៧,០ | ១១,៦ |
| ផ្សេងៗ | ៦,០ | ៧,៩ | ៥,៦ |
| សរុប | ១០០ | ១០០ | ១០០ |
| បង្គន់អនាម័យក្នុងបរិវេណ | ៦,៦ | ២៨,១ | ២,៤ |

ប្រភពពី ក្រសួងផែនការ ជំរឿន ក្នុងឆ្នាំ ១៩៩៨



## ខេត្តកំពង់ធំ

| | សរុប | ទីក្រុង | ជនបទ |
|---|---|---|---|
| ទឹកស្អាត (%) | ៣,៦ | ១៥,៣ | ២,១ |
| ទឹកម៉ាស៊ីនរ៉ី ទឹកក្បាលម៉ាស៊ីន | ១,៧ | ៧,២ | ១,០ |
| អណ្តូងស្នប់ អណ្តូងខួង | ១,៤ | ៦,១ | ០,៨ |
| ទឹកទិញ | ០,៥ | ២ | ០,៣ |
| ទឹកគ្មានអនាម័យ | ៩៦,៤ | ៨៤,៧ | ៩៧,៩ |
| អណ្តូងជីក | ៧៧,៥ | ៤៥,៩ | ៨១,៦ |
| ទឹកចេញពីក្រោមដី ទន្លេអូរ បឹង ស្រះ ទឹកភ្លៀង | ១៦,២ | ៣១,៣ | ១៤,២ |
| ផ្សេងៗ | ២,៧ | ៧,៥ | ២,១ |
| សរុប | ១០០ | ១០០ | ១០០ |
| បង្គន់អនាម័យក្នុងបរិវេណ | ១៣,១ | ៣៥,២ | ១០,៣ |

ប្រភពពី ក្រសួងផែនការ ជំរឿន ក្នុងឆ្នាំ ១៩៩៨

### ទឹកនៅជនបទ




ទិន្នន័យ និងចំណុចគោលដៅដែលបានប្រើប្រាស់ទឹកស្អាតនៅកម្ពុជាឆ្នាំ ២០១៥




របាយការណ៍គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ កម្ពុជា២០០៣

ក្រសួងផែនការបានអោយដឹងថា នៅឆ្នាំ២០០៣ របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ៥០% នៃប្រជាជនជនបទ ដែលបានទទួលទឹកស្អាតសំរាប់ ឆ្នាំ២០១៥ ហើយគេប៉ាន់ស្មានថា ៨០% ដែលប្រជាជនទីក្រុងទទួលទឹកស្អាតប្រើប្រាស់ ។ សំរាប់ទីក្រុង និងប្រជុំជនកម្ពុជា និងស្ថិតនៅក្រោមចំណុចដៅកំណត់ ៨០% របស់ខ្លួនប្រហែលជា ១០% ក្រសួងផែនការបានអោយដឹងថា ក្នុងឆ្នាំ២០១៥ សមាមាត្រប្រជាជនដែលទទួលទឹកស្អាតប្រើប្រាស់ទំហំធំធេងគឺ នៅទីក្រុង និងទីប្រជុំជន ហើយមានទំហំធំជាងនៅតំបន់ជនបទ ចំនួននេះទ្វេរដងទៅដល់ ២៧% ។




របាយការណ៍ គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ កម្ពុជា២០០៣

# ១៣

# ប្រភេទត្រី និង សត្វក្នុងទឹកផ្សេងៗ



PHOTO: MITCHELL ISAACS

# ប្រភេទត្រី និងសត្វក្នុងទឹកផ្សេងៗ

ទន្លេមេគង្គមានត្រីច្រើនជាង ១000ប្រភេទ បច្ចុប្បន្នមានប្រហែល ៥00ប្រភេទ ត្រូវបានគេប្រទះឃើញមាននៅក្នុងប្រទេសកម្ពុជា ហើយប្រមាណជាង ២00ប្រភេទ មាននៅបឹងទន្លេសាប ។ ដោយសារតែភាពខុសៗគ្នានេះ បានធ្វើអោយត្រីរស់នៅគ្រប់កន្លែង និងអាចរកចំណីផ្សេងៗជាច្រើនសំរាប់ការរស់នៅរបស់ពួកវា ។ សំរាប់ប្រទេសមួយដែលមានផលិតផលត្រីខ្ពស់ដូចជាប្រទេសកម្ពុជា ជីវៈចំរុះមានសារៈសំខាន់ណាស់ នៅខណៈពេលដែលវាដើរតួជា "គំរបសុវត្ថិភាព" នៅតាមរដូវនីមួយៗ ។ ឧទាហរណ៍ : ការបាត់បង់នូវពពួកត្រីមួយចំនួនវាកើតឡើងដោយសារជំងឺ និងដោយសារការនេសាទហួសប្រមាណនៅក្នុងរដូវដែលអាចត្រូវបានផ្តល់មកវិញដោយការកើនឡើងនូវពពួកដទៃផ្សេងវិញ ។

ពពួកត្រី មានចាប់ពីត្រីក្អិតនៅក្នុងស្រែដែលមានប្រវែង២សង់ទីម៉ែត្រ រហូតដល់ត្រីរាជ ជាត្រីទឹកសាបដែលមានទំហំធំជាងគេបំផុតនៅលើពិភពលោក ហើយវាអាចមានប្រវែងរហូតដល់ ៣ម៉ែត្រ ។ កាន់តែច្បាស់ជាងនេះទៀតមាន ដូចជា : ត្រីឆ្លាំង ត្រីគល់រាំង ត្រីរ៉ស់ ត្រីក្រាញ់ ហើយនៅតាមបឹងដែលជាតំបន់ទឹកសាបនៅខាងក្នុងក៏ជាជំរកត្រីដូចជា : ត្រីកន្ធោង ត្រីកំពត ត្រីខ្ជឹង ត្រីឆ្លាម ត្រីក្របែល និងត្រីដទៃជាច្រើនទៀតផងដែរ ។ ត្រីរាប់រយប្រភេទនៅក្នុងអំបូរជាច្រើន ដែលមានទំរង់ផ្សេងៗគ្នា មានជំរកដែលមានចំណីអាហារ និងលក្ខណៈនៃការកកើតឡើងវិញ ។

ទោះបីជាពពួកត្រីមួយចំនួនបានពងនៅតាមតំបន់វាលទំនាបក៏ដោយ ក៏មួយចំនួនធំបានផ្លាស់ទីទៅសំងំពងនៅតំបន់ដៃទន្លេមេគង្គខាងលើ នៅពាយ័ព្យប្រទេសកម្ពុជា នៅប្រទេសឡាវ និងប្រទេសវៀតណាម ។ ក្រោយពីត្រីពង ហើយពួកវាបានវិលទៅកាន់តំបន់វាលទំនាប ដើម្បីរកចំណីរហូតដល់រដូវទឹកទន្លេចាប់ផ្តើមស្រក ។ ចំណែកតំបន់ព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបជាទីកន្លែងសំបូរទៅដោយអាហារចិញ្ចឹមយ៉ាងពិសេស ។

តំបន់បឹងបួរមួយចំនួនបានជួយផ្តល់ដល់សត្វក្នុងទឹកដទៃទៀត ។ សត្វទាំងនេះមានដូចជា : ក្រពើ ល្មៀស ខ្យង ពស់ អណ្តើក កង្កែប កូនក្អុក និងកំពីស ព្រមទាំងសត្វស្លាប និងសត្វល្អិតផ្សេងៗដូចជា : ចៃទឹកជាដើម ។ ប្រទេសកម្ពុជា បរិភោគពពួកវារីជាតិប្រមាណពី ៥0,000តោន ទៅ ១00,000តោន ជារៀងរាល់ឆ្នាំ ។

ទោះបីនៅប្រទេសកម្ពុជាយើងសំបូរទៅដោយជីវៈចំរុះ បរិមាណត្រីដែលនេសាទបានមានចំនួនច្រើនបំផុតក៏ដោយ តែការនេសាទធ្វើឡើងទៅលើត្រីចំនួនប្រហែល១0ប្រភេទ ។ យោងតាមរបាយការណ៍នៃការស្រាវជ្រាវមួយ ដែលបានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៩0 បានបង្ហាញថា : ការនេសាទត្រូវធ្វើឡើងលើត្រីចំនួនពី ៤៤ ទៅ ៧៥ប្រភេទ ហើយការនេសាទនេះ គឺមានលក្ខណៈជាទ្រង់ទ្រាយធំ និងមធ្យម ។ ពពួកត្រីចំនួន ១0ប្រភេទ ដែលស្មើនឹង ៤0% នៃពពួកត្រីដែលត្រូវបាននេសាទ ។ នៅតាមឡូតិ៍នេសាទមានប្រភេទត្រីសំខាន់ៗដូចជា : ត្រីឆ្តោ ត្រីរៀល ត្រីឆ្កោក និងត្រីប្រា ។ សំរាប់ការនេសាទដោយប្រើដាយនៅខាងជើងទីក្រុងភ្នំពេញវិញ ពពួកត្រីដែលមានច្រើនបន្ទាប់ពីត្រីរៀល គឺត្រីស្លឹកឫស្សី និងត្រីក្រុស ហើយពពួកដែលមានច្រើនបន្ទាប់ទៀត គឺត្រីអាចម៍កុក ត្រីព្រួល ត្រីឆ្ពិនប្រាក់ និងត្រីរ៉ស់ ។

ត្រីដែលរស់នៅវាលទំនាបមានដូចជាត្រីរ៉ស់ និងត្រីឆ្តោ ដែលត្រូវបានចាត់ទុកថាជា "ត្រីខ្មៅ" ហើយនៅពេលដែលវារស់នៅក្នុងទឹកដែលមានសារធាតុ



PHOTOS: MRC









ត្រីត្រសក់ស-THICKLIP BARB

ត្រីក្រាញ់-CLIMBING PERCH





SOLDIER CATFISH



ត្រីរៀល-TREY RIEL



ត្រីក្បក-LAOTIAN SHAD

ត្រីដំរី-SAND GOBY



ត្រីក្អី-INDOCHINA FEATHERBACK



ត្រីកាហែក្រហម-RED TAILED TINFOILS



FROGFISH







គឺមីដែលបានមកពីការរលួយពពួករុក្ខជាតិនោះ បានប្រែពណ៌ទៅជាខ្មៅ ។

ត្រីខ្មៅគឺវាអាចធន់ទ្រាំជាមួយនឹងទឹកដែលខ្វះអុកស៊ីសែន ហើយសំបូរដោយជាតិអាស៊ីតច្រើនដែលភាគច្រើនវាអាចដកដង្ហើមយកខ្យល់ និងអាចធ្វើដំណើរទៅរកប្រភពទឹកថ្មីទៀត និងមួយចំនួនទៀតវាអាចក្រាំងក្នុងភក់រងចាំរហូតដល់មានទឹកជំនន់មកដល់ ។ ក្រៅពីត្រីឆ្ដោ ដែលជាប្រភេទត្រីខ្មៅមួយនៅកម្ពុជា ក៏មានប្រភេទត្រីផ្សេងៗទៀតដូចជា : ត្រីក្រាញ់ ត្រីអណ្ដែង ត្រីកន្ធរ អន្ទង់ ដែលត្រីទាំងអស់នេះអាចរស់នៅដោយគ្មានទឹកក្នុងរយៈពេលយូរ ។

ពពួកត្រីដែលមានការបំលាស់ទីពីតំបន់ទំនាបឆ្ពោះទៅកាន់ទន្លេ គឺវាផ្លាស់ទីនៅរដូវទឹកស្រក គឺជាប្រភេទត្រីស ដែលពពួកនេះវារស់នៅស្ទើរតែមួយជីវិតរបស់វានៅក្នុងទឹកទន្លេហូរ ។ ពពួកត្រីទាំងនេះគឺជាត្រីចេញពីទំនាបដូចជា ត្រី ឆ្លាំង រហូតទៅដល់ត្រីដែលមានតំលៃខ្ពស់គឺត្រីដីរ ដែលត្រីទាំងនោះត្រូវបាននាំយកទៅលក់នៅទីផ្សារអន្តរជាតិដូចជា ហុងកុង  សឹង្ហបូរី ។ ពពួកត្រីដទៃទៀតមានដូចជា ត្រីប្រា ត្រីសណ្ដាយ ត្រីកាហែ ត្រីពោ និងត្រីប្រម៉ា ។

នៅតំបន់ទន្លេមេគង្គមានពពួកត្រីចំនួន ៩ប្រភេទ ដែលត្រូវបានចុះក្នុងបញ្ជីក្រហមនៃអង្គការអន្តរជាតិសំរាប់អភិរក្សធម្មជាតិ ដែលជាពពួកទទួលរងការគំរាមកំហែងក្នុងនោះមាន ៦ប្រភេទ ធ្លាប់ជាពពួកសំខាន់នៅកម្ពុជា ។ ប្រភេទត្រីរាជទទួលរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរមានន័យថា វាប្រឈមមុខទៅនឹងគ្រោះថ្នាក់យ៉ាងខ្លាំងរហូតដល់ផុតពូជនៅក្នុងពពួកសត្វ ។ នៅក្នុងចំណោមត្រីចំនួន ៥ប្រភេទ ដែលបានចុះបញ្ជីស្ថិតនៅក្នុងប្រភេទដែលកំពុងរងការគំរាមកំហែង និងការគំរាមកំហែងខ្ពស់ឈានទៅការផុតពូជនោះគឺ ត្រីត្រសក់ ត្រីត្បូក និងត្រី ៣ប្រភេទទៀតដែលឋិតក្នុងកំរិត គ្រោះថ្នាក់ទាប ក្នុងនោះមានត្រីក្រាយ ហើយក្នុងបញ្ជីក្រហមវិញក៏មានចុះប្រភេទត្រីត្រសក់ស និងត្រីពោព្រុយ ជាប្រភេទត្រីដែលពុំមានព័ត៌មានគ្រប់គ្រាន់បង្ហាញថាត្រីទាំងពីរប្រភេទនេះរងការគំរាមកំហែង ប៉ុន្ដែបញ្ហានេះតំរូវអោយមានព័ត៌មានបន្ថែមដើម្បីបញ្ជាក់ ។

ភាពសំបូរបែបនៃពពួកត្រីចំនួន ៦ ប្រភេទនេះបានធ្លាក់ចុះយ៉ាងខ្លាំងបណ្ដាលមកពីការនេសាទច្រើនលើសលុប និងបណ្ដាលមកពីការប្រែប្រួលនៃជំរកជលសាស្រ្ត និងការធ្វើដំណើរបំលាស់ទី ។ ប្រសិនបើផលប៉ះពាល់បណ្ដាលមកពីការនេសាទត្រូវបានគ្រប់គ្រងស្តុកអាចត្រូវបានស្តារឡើងវិញ ប្រសិនបើបញ្ហាបរិស្ថានរងផលប៉ះពាល់យ៉ាងធំ ធ្វើអោយការគិតគូរទៅលើសំណង់ទំនប់វាប់ពាន់ និងសំណង់ដទៃទៀតដែលបានសាងសង់នៅក្នុងតំបន់ទន្លេមេគង្គ គឺត្រូវបានរៀបចំឡើងដោយមានគំរោងផែនការ ។ នៅអតីតកាលទីភ្នាក់ងារដែលទទួលខុសត្រូវលើវិស័យគ្រប់គ្រងទឹកនៅតំបន់ទន្លេមេគង្គ មិនត្រូវបានយកចិត្តទុកដាក់លើបញ្ហាជលផលទេ ។ ដើម្បីការពារពពួកត្រីក្នុងបញ្ជីក្រហម និងពពួកត្រីមួយចំនួនកំពុងតែជិតផុតពូជ ការត្រួតពិនិត្យ ទប់ស្កាត់ និងការគ្រប់គ្រងបរិស្ថាន ជាការសំខាន់សំរាប់ពេលអនាគត ។

ប្រភព : គណៈកម្មការទន្លេមេគង្គ



# ១៤

# ពពួកសត្វស្លាបផ្សេងៗ



# ពពួកសត្វស្លាបផ្សេងៗ

ពពួកសត្វស្លាបត្រូវបានធ្វើការសិក្សាយ៉ាងទូលំទូលាយ និងបានដឹងច្បាស់ពីក្រុមសត្វនៅក្នុងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ចាប់តាំងពីឆ្នាំ ២០០១ អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានអនុវត្តលើការងារសកម្មភាពអភិរក្ស និងសកម្មភាពត្រួតពិនិត្យលើហ្វូងសត្វស្លាបពីរប្រភេទដែលមានសារសំខាន់ជាសកល ។ នៅក្នុងតំបន់ស្នូលព្រែកទាល់ ក្នុងខេត្តបាត់ដំបង បានធ្វើការរាប់ និងការពារហ្វូងសត្វស្លាបទឹកធំៗ ចាប់តាំងពីទសវត្សឆ្នាំ១៩៩០ និងរឹតតែមានការជឿនលឿនខ្លាំងលើការត្រួតពិនិត្យនេះចាប់តាំងពីឆ្នាំ២០០៣ ។ អ្នកវិទ្យាសាស្ត្របានត្រួតពិនិត្យស្រាវជ្រាវលើប្រភេទសត្វក្សឹប និងពពួកសត្វស្លាបដទៃទៀតចាប់តាំងពីឆ្នាំ ២០០១ នៅតាមតំបន់វាលស្មៅ និងតំបន់កសិកម្មនៃតំបន់វាលទំនាបក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប ។

នៅតំបន់បឹងទន្លេសាប មានហ្វូងសត្វធំជាងគេបំផុតនៃហ្វូងសត្វស្លាបទឹកដែលទទួលរងគ្រោះថ្នាក់នៅអាស៊ីអាគ្នេយ៍នេះ ហើយបឹងទន្លេសាបនេះជាទីកន្លែងសំខាន់មួយសំរាប់ពពួកសត្វស្លាបដែលទទួលការគំរាមកំហែងផ្សេងទៀតផងដែរ ។ នៅឆ្នាំ ២០០៥ អ្នកវិទ្យាសាស្ត្របានរាយការណ៍អោយដឹងថា មានសត្វស្លាបចំនួន ២១០ប្រភេទ ដែលក្នុងនោះ ១៧ប្រភេទ ទទួលរងការគំរាមកំហែង រឺស្ទើរតែរងការគំរាមកំហែង (សូមពិនិត្យប្រអប់) ។ នៅតំបន់ព្រែកទាល់ជាកន្លែងធំបំផុត និងក៏ជាទីកន្លែងសំរាប់ធ្វើសំបុកនៅក្នុងអាស៊ីអគ្នេយ៍សំរាប់ពពួកសត្វស្លាបទឹកចំនួន ៧ប្រភេទ ដែលរងទទួលការគំរាមកំហែងជិតផុតពូជផងដែរ ។ ពពួករងគ្រោះថ្នាក់ប្រឈមនឹងគ្រោះថ្នាក់ដល់ផុតពូជនៅក្នុងព្រៃនោះមាន សត្វក្សឹប ត្រដក់ធំ ។ ពពួលដែលមិនមានការគំរាមកំហែងធ្ងន់ធ្ងរដែលងាយទទួលរងគ្រោះមាន : ត្រដក់តូច ទុងប្រផេះ រនាលស និងពពួលទឹក ដែលទទួលរងគ្រោះផុតពូជនៅក្នុងព្រៃ ។ ចំណែកពពួក ដែលឈានទៅរងទទួលការគំរាមកំហែង រួមមាន : រនាលពណ៌ក្រខ្លួនស ស្មោញ និង អង្កត់ខ្មៅ ដែលត្រូវបានគេហៅម្យ៉ាងទៀតថា ដំបងក្រញូង ។ តំបន់ព្រែកទាល់គឺ ជាទីកន្លែងមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលពពួកសត្វស្លាបចុងក្រោយនេះត្រូវបានគេដឹងថាកំពុងបង្កើតកូនចៅរបស់វា ។ តំបន់ស្នូលក៏បានជួយផ្តល់រហូតដល់៣០% នៃពពួកសត្វស្លាបដទៃទៀតស្ទើរតែទាំងអស់ ។

ប្រភេទសត្វស្លាបធំៗ ដទៃទៀតដែលបានបង្កើតកូនចៅរបស់វានៅជុំវិញតំបន់ព្រែកទាល់ មានសារសំខាន់ជាសកល ។ ពពួកសត្វស្លាបទាំងនេះមានច្រើនជាង ១% នៃពពួកសត្វស្លាបរស់នៅក្នុងអាស៊ី ដែលពពួកសត្វទាំងនេះមានដូចជា ក្អែកតូច ក្អែកទឹកមធ្យម កុកគ្រោងធំ និង ចង្កៀលខ្យង ។



PHOTO: ALLAN MICHAUD WCS



PHOTO: ALLAN MICHAUD WCS


រនាលពិណ-PAINTED STORK[3]


ទងប្រផេះ
SPOT-BILLED PELICAN[2]


ត្រយងយក្ស-GIANT IBIS[1]


ត្រខ្លួនស - BLACK-HEADED IBIS[2]


ត្រដក់តូច
LESSER ADJUSTANT[3]


សត្វខ្សឹប
BENGAL FLORICAN[1]


ចាបពួកទ្រូងលឿង
ASIAN GOLDEN WEAVER[1]


កដបទ្រូងស
WHITE-THROATED KINGFISHER[1]


សារិការកែវព្រៃ
WHITE-VENTED MYNA[1]


កេងកងតូច
ORIENTAL PIED HORNBILL[3]


ខ្លែងឆាបលឿងក្រម៉ៅ
BRAHMINY KITE[3]


ត្រដេវវិចទូល
RED-WATTLED LAPWING[1]

## លក្ខណៈនៃការទទួលរងការគំរាមកំហែង

យោងតាមក្រុមអភិរក្សនៃអង្គការជីវិតសត្វអន្តរជាតិ ដែលមានទីតាំងស្ថិតនៅប្រទេសអង់គ្លេស ដែលជាអាជ្ញាធរចុះបញ្ជីសត្វស្លាបទៅក្នុងបញ្ជីក្រហមអន្តរជាតិលើពពួកសត្វ ដែលទទួលរងការគំរាមកំហែងផុតពូជ ។ អង្គការអន្តរជាតិសំរាប់អភិរក្សធម្មជាតិ (IUCN) បានធ្វើការចងក្រងចាប់តាំងពីឆ្នាំ ១៩៩៤ ដែលប្រភេទសត្វស្លាបទាំងនេះ ត្រូវបានធ្វើការវាយតំលៃ ដោយយោងទៅតាមកត្តាជីវៈដូចជាការធ្លាក់ចុះទំហំ និងការបែងចែកចំនួនសត្វស្លាប ព្រមទាំង ការបែងចែកទៅតាមទីតាំងភូមិសាស្ត្រផងដែរ ។ នៅឆ្នាំ២០០៦ ការចុះបញ្ជីឈ្មោះមានចំនួនច្រើនជាង ១៦ ០០០ប្រភេទ ដែលទទួលរងការគំរាមកំហែងជាសកល ក្នុងនោះមាន ( ៧៧២៥ ជាប្រភេទរុក្ខជាតិ និង ៨៣៩៤ ជាប្រភេទជាសត្វ ) ហើយក្នុងនោះ សត្វស្លាប ១២% នៃពពួកទាំងនោះកំពុងរងការគំរាមកំហែង ។

ពពួកសត្វច្រើនជាង ៨០០ ប្រភេទ ត្រូវបានវិនាសបាត់បង់ ហើយត្រូវបានបែងចែកជាពីរប្រភេទ :

- **ការផុតពូជ (extinct)**
  ពុំមានការសង្ស័យណាមួយដែលសមហេតុសមផលថា ប្រភេទចុងក្រោយបានផុតពូជនោះឡើយ
- **ការផុតពូជនៅក្នុងព្រៃ EW (extinct in the wild)**
  នៅមានជីវិតដោយសារតែការចាប់យកចេញ រឺការប្រមាញ់ចេញពីតំបន់ រឺភូមិសាស្ត្រដែលវាធ្លាប់រស់នៅ

## ប្រភេទនៃការទទួលរងការគំរាមកំហែងមាន ៣ គឺ:

- **ដែលទទួលរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ (critically endangered)**
  ដែលទទួលរងគ្រោះថ្នាក់ពីការផុតពូជធ្ងន់ធ្ងរបំផុតនៅក្នុងព្រៃ
- **ដែលជិតផុតពូជ (endangered )**
  ដែលទទួលរងគ្រោះថ្នាក់ពីការផុតពូជធ្ងន់ធ្ងរនៅក្នុងព្រៃ
- **ដែលងាយរងទទួលរងការគំរាមកំហែង (vulnerable )**
  ដែលងាយទទួលរងគ្រោះថ្នាក់ផុតពូជខ្ពស់នៅក្នុងព្រៃ

## ប្រភេទដទៃទៀតផ្សេងៗទៀត

- **ដែលស្ទើរតែរងការគំរាមកំហែង (near threatened )**

ដែលឈានទៅរកការទទួលរងការគំរាមកំហែង និងជិតផុតពូជ បើមិនមានកិច្ចខិតខំប្រឹងប្រែងក្នុងការអភិរក្ស

*PHOTO CREDITS: [1]ALLAN MICHAUD WCS, [2]ELEANOR BRIGGS WCS, [3]WCS

- ដែលស្ទើរតែគ្មានការព្រួយបារម្ភណ៏ ( Least Concern )

  ជាប្រភេទដែលមិនមានទទួលការគំរាមកំហែង ឬក៏ស្ទើរតែមិនមានការគំរាមកំហែង រួមមានប្រភេទ ដែលសំបូរហូរហៀរ

- ទិន្នន័យមិនគ្រប់គ្រាន់ ( data deficient)

  មិនមានព័តិមានគ្រប់គ្រាន់ ដើម្បីធ្វើការវាយតំលៃ

- មិនមានការវាយតំលៃ (not evaluated)

  មិនត្រូវបានធ្វើការវាយតំលៃនៅឡើយ

ប្រភព: អង្គការសហព័ន្ធអភិរក្សពិភពលោក

តំបន់បឹងទន្លេសាបក៏មានពពួកសត្វស្លាបទឹកធំៗដទៃទៀត មានចំនួនកាន់តែកើនឡើង ដែលពួកនេះវិនាសផុតពូជ ឬរងការគំរាមកំហែងនៅក្នុងប្រទេសជិតខាង ។ ពពួកសត្វស្លាបទឹកទាំងនេះមាន ក្រសារប្រផេះ ដែលពពួកវាបានវិនាសផុតពូជរួចទៅហើយនៅពេលដែលកើតកូនចៅនៅក្នុងប្រទេសថៃ។



PHOTO: ELEANOR BRIGGS WCS

ពួកផ្សេងទៀតមានសត្វ កុកស និងសត្វក្អែកទឹកធំ ដែលពពួកទាំងពីរនេះត្រូវបានទទួលរងគ្រោះធ្ងន់ធ្ងរនៅក្នុងប្រទេសថៃ និងសត្វក្រសារថ្មង់ ដែលមានការគំរាមកំហែងតែបន្តិចបន្តួច ប៉ុន្តែវាក៏ទទួលរងគ្រោះផងដែរនៅក្នុងប្រទេសថៃ ហើយពពួកសត្វទាំងអស់នេះក៏មានការទទួលរងគ្រោះផុតពូជនៅក្នុងប្រទេសឡាវផងដែរ ។

ពពួកសត្វស្លាទឹកធំនីមួយៗបានយកទីតាំងតំបន់ព្រែកទាល់តែមួយប៉ុណ្ណោះសំរាប់រដូវកើតកូនរបស់ពួកវា ។ ក្រោយពីការកើតកូន ពពួកសត្វស្លាបស្ទើរតែទាំងអស់បានផ្លាស់ទីទៅកាន់ផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា មានតំបន់អភិរក្សសត្វក្រៀលនៅត្រពាំងថ្ម ក្នុងខេត្តបន្ទាយមានជ័យ និងវាលទំនាបភាគខាងជើង ។ ពពួកសត្វទាំងនេះមួយចំនួនតូចបានទៅដល់ភាគខាងត្បូងប្រទេសឡាវ ភាគខាងជើង និងកណ្តាលប្រទេសថៃ និងភាគខាងត្បូងប្រទេសវៀតណាម ។

## ពពួកដែលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ

- សត្វក្ងួនខ្មៅ

ពពួកនេះមានរបូតដល់២០ប្រភេទ ត្រូវបានប្រទះឃើញនៅក្នុងខេត្តកំពង់ធំ នៅពេលវេលាខុសៗគ្នា គឺនៅ ឆ្នាំ ១៩៩៩ និង ឆ្នាំ ២០០៤ ហើយពពួកទាំងនេះបានវិនាសសាបសូន្យនៅក្នុងប្រទេសថៃ។

## ពពួកទទួលរងគ្រោះថ្នាក់

- ពពួកសត្វ ក្បៀប

នៅតំបន់វាលទំនាបខាងកើតបឹងទន្លេសាប ត្រូវបានគេរាយការណ៍ថា មានពពួកសត្វទាំងនេះ បានបង្កបង្កើតកូនចៅយ៉ាងច្រើននៅតំបន់អាស៊ីអាគ្នេយ៍នេះ និងអាចនៅលើពិភពលោក។ ការត្រួតពិនិត្យទៅលើពពួកសត្វឈ្មោល ត្រូវបានធ្វើឡើងទៅលើតំបន់ចំនួន ០៣ កន្លែង នៅចន្លោះ ឆ្នាំ ២០០២ និង ឆ្នាំ ២០០៤ បានបង្ហាញអោយដឹងថា មានប្រភេទសត្វពី ៦៤ប្រភេទ ទៅ ១២២ប្រភេទ ផ្សេងៗគ្នា ។

- ពពួកសត្វត្រដក់ធំ



ពពួកទាំងនេះមាន ៥៤ ប្រភេទរស់នៅបង្កើតកូននៅឆ្នាំ ២០០៣-២០០៤ តំបន់ស្នូលព្រែកទាល់ និង ជាហ្វូងធំ ទី២នៅលើពិភពលោក ដែលមានប្រមាណជា ១០% នៃល្បាយសត្វទូទាំងពិភពលោក។ ពពួកទាំងនេះរងទទួលគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសថៃ។

## ពពួកងាយទទួលរងគ្រោះថ្នាក់

- ត្រដក់ទឹក

តំបន់ព្រែកទាល់ មានពពួកសត្វស្លាបនេះមកពងកូនយ៉ាងធំនៅតំបន់អាស៊ីអគ្នេយ៍ ដែលមានប្រមាណជា ១០%នៃល្បាយសត្វនៅទូទាំងពិភពលោក។ ចំនួននេះកើនឡើងពីការមកពងកូនចំនួន ១៤៩គូ នៅឆ្នាំ ២០០៣-៤ ទៅ ២០៩គូ នៅឆ្នាំ ២០០៤-៥ ហើយដែលពពួកទាំងនេះទទួលរងគ្រោះធ្ងន់ធ្ងរនៅក្នុងប្រទេសថៃ ។

- ពពួកសត្វទុងប្រផេះ

តំបន់ព្រែកទាល់ ជាតំបន់ដែលមានហ្វូងសត្វទុងប្រផេះដ៏ធំបំផុតនៅលើពិភពលោក។ តាមការវាយតំលៃបានអោយដឹងថា មានពី ៩០០ ទៅ ១ ១០០ គូ នៅឆ្នាំ ២០០៥ ប្រហែលជា ២០% នៃល្បាយសត្វនៅលើពិភពលោក។ ពពួកសត្វទាំងនេះ មានការទទួលរងគ្រោះធ្ងន់ធ្ងរនៅក្នុងប្រទេសថៃ ។

- ## ពពួកសត្វរនាលស

ពពួកសត្វប្រភេទនេះ ត្រូវបានគេធ្វើការវាយតំលៃថា មានរហូតដល់ ១០គូ ដែលបានបន្តពូជនៅតំបន់ព្រៃកទាល់ ពួកវាបន្តពូជនៅតំបន់ដែនគោកនៅអាស៊ីអគ្នេយ៍។ ជាមួយគ្នានេះ សត្វស្លាបប្រភេទនេះមាននៅសេសសល់ប្រហែលជា ១០ប្រភេទ រស់នៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជា វាអាចនឹងកើតមានឡើងវិញយ៉ាងឆាប់ៗនាពេលខាងមុខនេះនៅអាស៊ីអាគ្នេយ៍។

- ## ពពួកសត្វក្រៀល

ពពួកនេះមានហ្វូងរបស់វារហូតដល់ ៣០ហ្វូង ដែលត្រូវបានគេជួបប្រទះនៅតំបន់ទំនាបវាលស្មៅជុំវិញតំបន់ស្ទឹងសែន សន្ទុក និងបារាយណ៏ ក្នុងខេត្តកំពង់ធំ នៅពេលដែលពួកវាបានផ្លាស់ទីកន្លែង ពួកវាបន្តពូជក្នុងទំនាបភាគខាងជើងឆ្ពោះទៅតំបន់ត្រពាំងថ្ម ក្នុងខេត្តបន្ទាយមានជ័យ។ ចាប់តាំងពី ២០០២ ពពួកសត្វប្រភេទនេះ មានការកើនឡើងដោយមិនមានល្បាយកើតកូនចៅ ដោយពួកវារស់នៅក្នុងស្មៅតាមប្រឡាយនៅរដូវប្រាំងក្នុងតំបន់ស្ទឹងសែន។ នៅឆ្នាំ ២០០៥ ពពួកទាំងនេះបានកើនលើសដល់ ៣០ក្បាល ហើយបានវិនាសបាត់បង់ពីប្រទេសថៃ។

# ប្រភេទដែលជិតទទួលរងការគំរាមកំហែង

- ## សត្វរនាលពណិ

តំបន់ព្រៃកទាល់អាចជួយទ្រទ្រង់ដល់ការបន្តពូជល្បាយសត្វប្រហែលជា ១០០០គូរ ឬ ២០% នៃល្បាយសត្វ នៅលើពិភពលោក។ ពពួកនេះទទួលរងគ្រោះថ្នាក់នៅក្នុងប្រទេសថៃ។

- ## សត្វក្ងួនស

ទោះបីជាចំនួនសត្វនេះមិនអាចត្រូវបានរាប់គួរអោយទុកចិត្តបាន ដោយសារតែពពួកសត្វទាំងនេះបានពង នៅក្នុព្រៃក្រាស់ក៏ដោយ ក៏តំបន់ព្រៃកទាល់ជួយអោយហ្វូងសត្វទាំងនេះបានបន្តពូជយ៉ាងធំបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានផងដែរ។ ការរាប់ចំនួនជំរកបន្តពូជនៅតំបន់មណ្ឌលអភិរក្សសត្វក្រៀលក្នុងខេត្តបន្ទាយមានជ័យឡើងដល់ ១៦០០ក្បាល នៅឆ្នាំ ២០០៣។ ប្រសិនបើការបន្តពូជនេះ គឺជាពពួកសត្វធំនោះ វាមានចំនួន ៤០០គូ អាចមានពី ៨-១៥% នៃចំនួននៅលើពិភពលោក។ ពពួកនេះទទួលរងគ្រោះនៅក្នុងប្រទេសថៃ ។

- ## សត្វស្មោញ

ចំនួនសត្វស្មោញ បានកើនឡើងគួរអោយកត់សំគាល់ពី ២៨០ ទៅ ១ ៨៧០ សំបុក នៅក្នុងឆ្នាំ ២០០៤-៥ ។ ការកើនឡើងបន្ថែមទៀតនេះអាច មានបញ្ហាលើការគ្រប់គ្រង។ ពពួកនេះមានការរងគ្រោះថ្នាក់យ៉ាងខ្លាំងនៅក្នុងប្រទេសថៃ ។

ប្រភព: អង្គការ សមាគមអភិរក្សសត្វព្រៃ លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប

# ១៥

# នានាភាពនៃពពួកល្មូន



# នានាភាពនៃពពួកល្មូន

តំបន់បឹងទន្លេសាបជាតំបន់ដីសើមដ៏សំខាន់បំផុតមួយសំរាប់ការអភិរក្សពពួកសត្វល្មូននៅតំបន់អាស៊ីអគ្នេយ៍ ។ គេមានការជឿជាក់ថា ឋបនីយជីវមណ្ឌលបឹងទន្លេសាប ជួយទ្រទ្រង់ដល់ពពួកសត្វល្មូនសំខាន់ៗជាសកល យ៉ាងហោចណាស់មានចំនួន ៨ប្រភេទ ដែលពពួកទាំងនេះត្រូវទទួលរងគ្រោះដល់ផុតពូជ ឬក៏ពពួកឈានទៅរកការទទួលរងគ្រោះ (សូមពិនិត្យមើល ប្រភេទដែលទទួលរងគ្រោះ) ។ ពពួកល្មូនដែលទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរមានដូចជា ក្រពើត្រី ពស់ថ្លាន់កោម និងពពួកអណ្តើកទឹកសាប មានចំនួន ៦ប្រភេទ ដោយរាប់បញ្ចូលពពួកអណ្តើកក្របីក្បាលពណ៌លឿង ។

ឋបនីយជីវមណ្ឌលក៏ជាទីកន្លែងប្រមូលផលសត្វពស់មានចំនួនច្រើនបំផុតនៅលើពិភពលោក ដែលផ្តល់ផលដោយមានការកើនឡើងយ៉ាងខ្លាំងនូវចំនួនកសិដ្ឋានចិញ្ចឹមក្រពើនៅជុំវិញបឹងទន្លេសាប កាលពីប៉ុន្មាន ឆ្នាំថ្មីៗនេះ ។ នៅចន្លោះពីពាក់កណ្តាលឆ្នាំ ២០០៤ និងដើមឆ្នាំ ២០០៥ ពស់ចំនួនប្រមាណ ៣.៨ លានក្បាល ត្រូវបានចាប់ដោយប្រើប្រាស់ឧបករណ៍ចាប់ពស់ព្រលឹតឆ្នុតឥន្ទធនូមាន រវាងពី ៧២% និង៨០% នៃការចាប់ទាំងអស់ ហើយប្រភេទពស់ ដែលមានសារសំខាន់បន្ទាប់ពីនៅជុំវិញបឹងទន្លេសាបមានប្រមាណពាក់កណ្តាលនៃការចាប់នៅខាងត្បូងនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ចំពោះការធ្វើអាជីវកម្ម អាចធ្វើការគំរាមកំហែងទៅលើពពួកដែលរស់នៅក្នុងបឹង និងត្រូវបានជឿជាក់ថា ជាពពួកល្មូនរស់នៅតាមតំបន់នៃប្រទេសកម្ពុជា ហើយពពួកដទៃទៀតមានពស់កាចាន់ ឬពស់ត្រី និង ពស់ចាន់ល្មម ឬពស់ត្រីរស់ ដែលពពួកសត្វពស់ទាំងពីរប្រភេទនេះ ជាគោលដៅសំរាប់យកស្បែករបស់វានាំចេញទៅលក់នៅប្រទេសថៃ វៀតណាម និង ប្រទេសចិន ។ នៅឆ្នាំ២០០៤ ស្បែកសត្វពស់ប្រភេទនេះមួយមានតំលៃរហូតដល់ ១០ដុល្លា និងត្រូវបានយកសាច់របស់វាដើម្បីលក់ដូរលើទីផ្សារ ។ គេចាត់ទុកសត្វពស់ប្រភេទនេះជាសត្វកំរ ដែលបណ្តាលមកពីការចាប់ហួសប្រមាណ ។



PHOTO: ALLAN MICHAUD WCS

## ប្រភេទដែលទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ

- ពពួកក្រពើត្រី

  ល្បាយសត្វដែលរស់នៅក្នុងព្រៃបានធ្លាក់ចុះកាលពីពេលថ្មីៗនេះ នៅពេលដែលស៊ុត កូនតូច និងកូនធំរបស់វាត្រូវបានចាប់យក និងប្រមូលទៅទុកដាក់នៅកសិដ្ឋានចិញ្ចឹមក្រពើ និងយ៉ាងហោចណាស់ មានក្រពើប្រមាណជា ១០៥ក្បាល ត្រូវបានចាប់ពីតំបន់បឹងទន្លេសាបនៅចន្លោះ ឆ្នាំ ១៩៩៨ និង ឆ្នាំ ២០០២ ។ មួយចំនួនតូចបំផុត ដែលគេជឿថា មានរស់នៅក្នុងតំបន់ស្នូលចំនួន ៣កន្លែង គឺតំបន់ ជីវនាត ឡូតិ៍នេសាទលេខ៦ និងតំបន់ព្រៃលិចទឹក ដែលនៅជាប់នឹងតំបន់ព្រែកទាល់ ដែលតាមពិត ក្រពើទាំងនេះ អាចជាសត្វដែលរួចចេញពីកសិដ្ឋានចិញ្ចឹមក្រពើ។ ក្រពើទាំងនេះ រួមមាន : ក្រពើគុយបា និងប្រភេទកូនកាត់បានចិញ្ចឹមនៅក្នុងកសិដ្ឋានផងដែរ ។

- អណ្តើកទន្លេ

  នៅក្នុងរបកគំហើញ ស្នូកអណ្តើកពីរដែលបានកប់នៅក្នុងល្បប់ភក់ក្នុងបឹងនៅឆ្នាំ១៩៨៥ ដោយអះអាងថា ពពួកប្រភេទនេះធ្លាប់មានរស់នៅក្នុងតំបន់បឹងទន្លេសាប ប៉ុន្តែតាមការស្រាវជ្រាវកាលពីពេលថ្មីៗនេះ មិនមានភស្តុតាងបង្ហាញថាមានរស់នៅជុំវិញបឹងទេ ។ ប្រភេទទាំងនេះ ត្រូវបានចាត់ទុកជាសត្វល្អនតំណាងអោយប្រទេសកម្ពុជា ។

## ប្រភេទដែលទទួលរងគ្រោះ

- អណ្តើកក្របីក្បាលលឿង

  កម្ពុជាជាប្រទេសមួយដែលសំខាន់បំផុតនៅតំបន់ទន្លេមេគង្គក្រោមនេះ ចំពោះសត្វអណ្តើក ហើយបានចាត់ទុកថា ជាសត្វដែលមានលក្ខណៈធម្មតាបំផុតនៅក្នុងលំដាប់ទី ៣ នៅក្នុងបឹងទន្លេសាប ។ វារស់នៅក្នុងតំបន់ព្រែកទាល់ និងត្រូវបានរាយការណ៍ថា មានលក់នៅតាមទីផ្សារក្នុងតំបន់ចុងឃ្នាស និងខេត្តកំពង់ធំ និងអ្នកប្រមាញ់ក៏បានរាយការណ៍ផងដែរថា មាននៅក្នុងខេត្តកំពង់ឆ្នាំង ស្រុកកំពង់លែង ។

- កន្ធាយអាស៊ី

  ប្រទេសកម្ពុជាជួយទ្រទ្រង់ដល់ពពួកសំខាន់ៗ នៅក្នុងតំបន់នៃប្រភេទសត្វដែលមានអាថិកំបាំង និងជាប្រទេសមួយដែលសំខាន់បំផុតនៅតំបន់អាស៊ីអាគ្នេយ៍ ។ ជារឿយៗ ពពួកទាំងនេះត្រូវបានរាយការណ៍ថាមានរស់នៅក្នុងតំបន់បឹងទន្លេសាប ប៉ុន្តែពុំមានរូបភាពធ្វើការបញ្ជាក់អះអាងណាមួយទេ។

- អណ្តើកព្រិច

  ពពួកសត្វអណ្តើកប្រភេទនេះត្រូវបានឃើញមានកាលពីថ្មីៗនេះ និងមានលក់នៅទីផ្សារក្នុងខេត្តកំពង់ឆ្នាំង ប៉ុន្តែមិនមានរូបភាពណាមួយដើម្បីបញ្ជាក់អះអាងថា វានៅមានក្នុងតំបន់បឹងទន្លេសាបនោះទេ។



អណ្តើកក្របីក្បាលលឿង
YELLOW-HEADED TEMPLE TURTLE[3]



ក្រពើត្រី-SIAMESE CROCODILE[1]



ត្រកួត
BENGAL MONITOR[3]



កន្ធ្រង
WATER DRAGON[1]



ពស់ថ្លាន់តូច-BURMESE PYTHON



1



តុកកែ-TOKAY[1]



កន្ធាយអាស៊ី-AIATIC SOFTSHELL TURTLE[1]



ពស់ទឹក-WATER SNAKE[2]

## ពពួកដែលងាយទទួលរងគ្រោះ

- **អណ្តើកបិទមុខស្នូកខ្មៅ**

  អណ្តើតប្រភេទនេះវាមានលក្ខណៈទូទៅលំដាប់ទី២ នៅក្នុងតំបន់បឹងទន្លេសាប ហើយបានក្លាយជាសត្វដែលមានការលំបាកក្នុងការស្វែងរកនៅក្នុងព្រៃ ហើយកាលពីពេលថ្មីៗនេះត្រូវបានគេរាយការណ៍ថាសត្វអណ្តើកនេះមាននៅក្នុងតំបន់ព្រៃកទាល់ និងត្រូវបានថតរូបនៅក្នុងភូមិសារី ក្នុងខេត្តកំពង់ធំ ។ សត្វប្រភេទនេះត្រូវបានគេជឿជាក់ថា មានរស់នៅក្នុងតំបន់ទំនាបប្រទេសកម្ពុជា ដែលអាចទ្រទ្រង់ដល់ល្បាយពពួកសត្វដែលធំបំផុតនៅក្នុងតណ្ឌចិននេះ ។

- **អណ្តើកក្អែកខ្មៅ**

  ល្បាយអណ្តើកក្អែកខ្មៅកម្ពុជា អាចមានចំនួនច្រើនបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ ។ វារស់នៅតាមត្រពាំង បឹងនៅជុំវិញបឹងទន្លេសាប ដោយសាច់របស់វាមិនត្រូវបានគេចូលចិត្តទេ ដោយមានក្លិនអាក្រក់ថែមទាំងមិនអាចបរិភោគបានទៀតផង ។

- **អណ្តើកសោមញី**

  តាមរបាយការណ៍នៅក្នុងខេត្តកំពង់ឆ្នាំងថ្មីៗនេះ  អណ្តើកប្រភេទនេះត្រូវបានចាត់ទុកថាជាសត្វកំរ ។

- **អណ្តើកសកល**

  អណ្តើកប្រភេទនេះ មានចំនួនច្រើនបំផុតរស់នៅជុំវិញបឹងទន្លេសាប សាច់របស់វាត្រូវបានគេចូលចិត្ត ហើយត្រូវបានប្រើប្រាស់សំរាប់ជាថ្នាំបុរាណ ។ វាមាននៅក្នុងវាលស្រែពេលស្រូវឡើងទឹកក្នុងខេត្តកំពង់ធំ នៅចន្លោះពីខែសីហា និងខែធ្នូ  និងត្រូវបានគេជឿថា  វាមានជំរកនៅក្នុងព្រៃលិចទឹក ។

- **កន្ធាយអាស៊ី**

  ទោះបីជាសត្វកន្ធាយប្រភេទនេះ ត្រូវបានចាត់ទុកថា ជាសត្វធម្មតានៅជុំវិញបឹងទន្លេសាបក៏ដោយក៏ចំនួនរបស់វាមានការធ្លាក់ចុះគួរអោយមានការព្រួយបារម្ភណ៍ និងជាពពួកសត្វកំរនៅក្នុងខេត្តកំពង់ឆ្នាំង សាច់របស់វាគឺត្រូវបានគេចូលចិត្តយ៉ាងខ្លាំង ។

## ពពួកសត្វដែលស្ទើរតែទទួលរងការគំរាមកំហែង

- **ពស់ថ្លាន់គោ រឺពោះថ្លាន់ក្រហម**

  នៅក្នុងតំបន់ស្នួលស៊ឹងសែន និងបឹងទន្លេឆ្មារ  សត្វពស់ប្រភេទនេះត្រូវបានគេចាប់ ដើម្បីយកស្បែក សាច់ និងឈាមរបស់វាសំរាប់ទីផ្សារក្នុងស្រុក និងសំរាប់ធ្វើការនាំចេញទៅក្រៅប្រទេស ។ នៅក្នុងតំបន់ស្នួលព្រែកទាល់  អ្នកនេសាទបានប្រើប្រាស់ឧបករណ៍មងពិសេស ដើម្បីចាប់ពស់ថ្លាន់គោ អ្នកនេសាទដទៃទៀតបានចាប់សត្វពស់ដោយដៃផ្ទាល់ ។  ចំណែកស្ត្រីដែលចាប់ពស់ ពួកគេបានយកមងដាក់នៅលើដីក្នុងព្រៃក្រាស់នៅក្នុងរដូវប្រាំង ជាធម្មតាពួកគេប្រមូលបានពងពី ២០ ទៅ ៣០ពង ។

ប្រភព: អង្គការសមាគមអភិរក្សសត្វព្រៃ   អង្គការមូលនិធិសារព័ត៌មានឯករាជ្យ

*PHOTO CREDITS: [1]ALLAN MICHAUD WCS, [2]ELEANOR BRIGGS WCS, [3]WCS

# ១៦

# ពពួកថនិកសត្វផ្សេងៗ



PHOTO: ALLAN MICHAUD WCS

# ពពួកថនិកសត្វផ្សេងៗ

ពពួកថនិកសត្វនៅតំបន់បឹងទន្លេសាបមិនទាន់ត្រូវបានធ្វើការសិក្សាអោយបានល្អប្រសើរនៅឡើយទេ ហើយក៏មិនមានការស្រាវជ្រាវជាក់ច្បាស់ទៅលើប្រភេទថនិកសត្វណាមួយដែរ ។ ជាមួយគ្នានេះដែរក៏មានការអង្កេតបន្ទាប់បន្សំបានធ្វើឡើងនៅក្នុងពេលនៃការសិក្សាស្រាវជ្រាវទៅលើពពួកសត្វស្លាប និងពពួកល្មូន ។ តាមរបាយការណ៍ពីក្រុមអ្នកល្បាតផ្នែកបរិស្ថាននៅតំបន់ព្រែកទាល់បានអោយដឹងថា នៅតាមទីផ្សារ មានដាក់តាំងបង្ហាញពពួកសត្វដែលចាប់បាន ។

ពពួកថនិកសត្វធំៗ មួយចំនួនដូចជា ដំរី ក្របីព្រៃ និងក្តាន់ បានបាត់បង់ពីព្រៃនៅជុំវិញបឹងទន្លេសាប ហើយការបាត់បង់នេះទើបតែមានក្នុងរយៈពេល ១០ឆ្នាំ ថ្មីៗកន្លងទៅនេះ ។ វាហាក់បីដូចជាតំបន់ទំនាបបឹងទន្លេសាបធ្លាប់ជាជំរកសំខាន់របស់ពពួកថនិកសត្វទៅតាមរដូវ និងមានការបាត់បង់ត្រីផ្សោតពីបឹងទន្លេសាបនៅពេលថ្មីៗនេះផងដែរ ។

នៅក្នុងពពួកថនិកសត្វដែលរស់នៅជុំវិញបឹងទន្លេសាប មានពពួកខ្លះទទួលរងការគំរាមកំហែងជាសាកល (សូមពិនិត្យប្រភេទពពួករងគ្រោះនៅខាងក្រោម) ។ ជាងនេះទៅទៀត ពពួកថនិកសត្វដែលនៅមានជីវិតរស់នៅមួយចំនួន គឺមានសារៈសំខាន់ជាអន្តរជាតិ ។

## ពពួកងាយទទួលរងគ្រោះ

- ពពួកសត្វភេខ្លួនរលោង (Smooth otter)



នៅឆ្នាំ២០០២ អ្នកប្រមាញ់នៅក្បែរក្បាលតោល ក្បែរនឹងតំបន់ស្នូលព្រែកទាល់ ចាប់បានពពួកសត្វភេនេះ ដែលជាតួលេខតែមួយគត់បង្ហាញពីប្រភេទនានានៅបរិយជីវមណ្ឌល ។

- ខ្លាត្រី (Fishing cat)

ជារឿយៗ ប្រជាពលរដ្ឋក្នុងតំបន់បានរាយការណ៍អោយដឹងពីពពួកសត្វប្រភេទនេះ ។ នៅឆ្នាំ ២០០២ ត្រូវបានរាយការណ៍ថា បានជួបប្រទះដានជើងខ្លាត្រីនៅពេលដែលបឹងមានការរីងស្ងួតនៅក្នុងតំបន់ទំនាបខាងក្រៅនៃតំបន់ព្រែកទាល់ និងមានដានជើងផ្សេងទៀតត្រូវបានគេរាយការណ៍ថា មាននៅតំបន់គ្រួសក្រោម ។

- រញ្ជីភ្លើង (Pygmy Slow loris)



តាមការរាយការណ៍ពីអ្នកនេសាទ និងអ្នកបរបាញ់បានអោយដឹងថា មានពពួករញ្ជីភ្លើងនេះនៅក្នុងតំបន់ព្រែកទាល់ ។ នៅឆ្នាំ២០០០ អាជ្ញាធរធ្លាប់បានធ្វើការរឹបអូសពីអ្នកបរបាញ់នៅតំបន់ព្រែកទាល់ ប៉ុន្តែពពួកសត្វទាំងនេះមិនត្រូវបានគេបញ្ជាក់អះអាងទេ ។

PHOTO: CARLY STARR


ទោចម្កុដ-PILEATED GIBBON[1]


ស្វាត្រោស-PIG-TAILED MACAQUE[3]


ខ្មឹង-LARGE INDIAN CIVET[3]


ជ្រឹង-FLYING-FOXES[1]


រញ្ជ-SLOW LORIS[4]


ស្វាអង្គត់-STUMP-TAILED MACAQUE[1]


ភេ-OTTER[5]


សំពោចកលឿង-YELLOW-THROATED MARTEN

## ពពួកដែលស្ទើរតែទទួលរងការគំរាមកំហែង

- ស្វាក្តាម ( Long-tailed macaque)

ស្វាប្រភេទនេះមានរស់នៅពាសពេញ ក្នុងតំបន់ព្រៃលិចទឹកខ្ពស់ៗ និងតំបន់ព្រៃរបោះនៅជុំវិញបឹងទន្លេសាប ជាពិសេសនៅតាមបណ្តោយមាត់បឹង ឬព្រែក ។ ចំនួនសត្វស្វាទាំងនេះបានធ្លាក់ចុះដោយមានតែមានការប្រមាញ់សំរាប់ធ្វើការបង្កាត់ពូជនៅក្នុងប្រទេសកម្ពុជា ប្រទេសចិន និងប្រទេសវៀតណាម ។ អាជ្ញាធរបានធ្វើការរឹបអូសស្វារហូតដល់ ១៧០ក្បាល ពីអ្នកបរបាញ់ និងអ្នកជំនួញនៅក្នុងតំបន់ព្រែកទាល់ និងកំពង់ធំ ជាពិសេស នៅក្នុងរដូវភ្លៀង ។ សត្វស្វាដែលចាប់បានត្រូវបានគេប្រទះឃើញមាននៅក្នុងភូមិបណ្តែតទឹកជាច្រើននៅជុំវិញបឹងទន្លេសាប ។

## ពពួកប្រភេទសត្វដែលពុំមានទិន្នន័យគ្រប់គ្រាន់

- ពពួកស្វាព្រាម (Germain's silver leaf monkey)

ទោះបីជាកាលពីពេលថ្មីៗនេះ ពពួកនេះមិនទាន់ត្រូវបានធ្វើការចុះបញ្ជីដោយសហព័ន្ធអភិរក្សពិភពលោកក៏ដោយ ក៏សត្វស្វាប្រភេទនេះទទួលរងការគំរាមកំហែងជាសកលផងដែរ ដែលមានមួយចំនួន ត្រូវបានគេជឿជាក់ថា វាជាពពួកងាយរងគ្រោះ ឬក៏ថែមទាំងជាពពួកដែលទទួលរងគ្រោះថ្នាក់នៅពេលអនាគតផងដែរ ។ ពពួកដែលរស់នៅក្នុងតំបន់ស្នូលព្រែកទាល់ និង បឹងទន្លេឆ្មារ ព្រមទាំងតំបន់ការពារសត្វស្លាបវាលសង្រ្កាយ ។ សារសំខាន់ដែលពាក់ព័ន្ធនៃប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាបនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ។



- ភេរោមច្រមុះ (hairy-nosed otter)

តាមរបាយការណ៍ពីរ ក្នុងចំណោមរបាយការណ៍ ៤ ដែលបានបញ្ជាក់អះអាងនៃពពួកភេប្រភេទនេះទទួលបានពីតំបន់បឹងទន្លេសាប ដែលសត្វភេពីរប្រភេទមាននៅក្នុងតំបន់ព្រែកទាល់ ។ តាមប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បាននិយាយថា ពពួកទាំងនេះប្រហែលជាឈានទៅរកការផុតពូជនៅក្នុងតំបន់ព្រែកទាល់នេះ ។

ប្រភព: អង្គការអភិរក្សសត្វព្រៃ WCS

*PHOTO CREDITS: [1]ALLAN MICHAUD WCS, [2]ELEANOR BRIGGS WCS, [3]WCS, [4]CARLY STARR, [5]NICK COX WWF

# ១៧

# ជីវៈចំរុះនៅតំបន់ស្នូលបឹងទន្លេឆ្មារ



PHOTO: ELEANOR BRIGGS WCS

# ជីវៈចំរុះនៅតំបន់ស្នូលបឹងទន្លេឆ្មារ

បឹងទន្លេឆ្មារគឺជាតំបន់ស្នូលមួយក្នុងចំណោមតំបន់ស្នូលទាំងបីនៃបរិមណ្ឌលជីវមណ្ឌលបឹងទន្លេសាប ហើយតំបន់នេះ ត្រូវបានទទួលស្គាល់ជាសកលដោយអនុសញ្ញារ៉ាមសារ ។ ជីវៈចំរុះនៃបឹងទន្លេសាប និងស្ទឹងព្រែកតូចៗនៅជុំវិញមានតំលៃសំរាប់អភិរក្សសំរាប់ការសិក្សាអប់រំ និងសំរាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ។

មានស្ទឹងពីរ បានហូរពីខ្ពង់រាបខាងជើងនៃប្រទេសកម្ពុជាចាក់មកតំបន់នេះ ។ ស្ទឹងទាំងពីរនោះមានឈ្មោះថា  ស្ទឹងស្ទោងដែលមានផ្ទៃអាងរងទឹកភ្លៀងប្រមាណជា ១,៨៩៥ គម២ និងស្ទឹងជីក្រែងមានផ្ទៃអាងរងទឹកភ្លៀងប្រមាណ ១៩២០គម២ ។ ការិតទឹកភ្លៀងតាមរដូវ និងរុក្ខជាតិដែលដុះនៅតាមប្រព័ន្ធនៃស្ទឹងធ្វើអោយតំបន់នេះសំបូរទៅដោយភាវៈរស់ អាហារចិញ្ចឹម និងផលិតផលដែលអាចទាញយកផលបាន ។

បឹងទន្លេឆ្មារត្រូវបានបែងចែកជា៤ តំបន់ផ្សេងៗពីគ្នា ។ តំបន់ផ្លូវទឹក បឹង និងស្ទឹងតូចៗ គឺជាតំបន់លំហូរទឹកនៃបឹងបឹងទន្លេឆ្មារមានផ្ទៃប្រហែល ៤,000ហិកតា តំបន់ព្រៃលិចទឹកដែលជិតទៅនឹងបឹងទន្លេសាប តំបន់រុក្ខជាតិលិចទឹក និងតំបន់វាលស្មៅដែលគ្របដណ្តប់ដោយព្រៃត្រែង និងព្រៃព្រិច ។

តាមការសិក្សាស្រាវជ្រាវរុក្ខជាតិនៅតំបន់បឹងទន្លេឆ្មារ បានអោយដឹងថា តំបន់នេះរុក្ខជាតិចំនួន ១៩0ប្រភេទ ស្ថិតនៅក្នុង ៦៧ក្រុម ។ ជាទូទៅរុក្ខជាតិដែលដុះនៅក្នុងតំបន់មានលក្ខណៈខុសៗគ្នា រវាងរុក្ខជាតិដែលដុះនៅតាមមាត់ព្រែក ឬស្ទឹង និងរុក្ខជាតិដែលដុះនៅតាមវាលភក់នៅក្រោយមាត់ទឹក ។ ពពួករុក្ខជាតិបណ្តែតទឹកដូចជាកំប្លោកមានដុះច្រើននៅតាមបណ្តោយមាត់ព្រែក ស្ទឹង និងជាធម្មតាឃើញមានពពួករុក្ខជាតិដែលគ្មានឬសដូចជាសារាយផងដែរ ។ នៅតំបន់នោះ ក៏មានប្រភេទដើមរុក្ខជាតិធំៗផងដែរ ដែលដើមរបស់វាមានកំពស់រហូតដល់ទៅ ១៥ម៉ែត្រ ដូចជាដើមរាំងទឹក  ដើមតាឪ  ដើមផ្ទោល ។  តំបន់ព្រៃរបោះខាងក្រោយវាលភក់មានវាលស្មៅទាបៗ  និងដើមកន្ទ្រាំងហែរ ។



PHOTO: ELEANOR BRIGGS WCS

បឹងទន្លេឆ្មារគឺជាតំបន់សំខាន់សំរាប់ការធ្វើបំលាស់ទីរបស់ពពួកសត្វ ។ តាមរបាយការណ៍ មានពពួកថនិកសត្វដូចជា ស្វាក្តាម ស្វាព្រាម ខ្លាត្រី ភេ និងសំពោចរស់នៅក្នុងតំបន់ ។ តំបន់នេះមានសត្វបក្សីទឹកជាច្រើន រួមទាំងប្រភេទដែលរងការគំរាមកំហែងជាសកលត្រូវបានធ្វើការកត់ត្រាទុកជាពិសេសនៅរដូវប្រាំងនៅពេលដែលពួកវាចេញរកចំណី ។ ប្រភេទសំខាន់ៗនៃបក្សីទឹកមានដូចជា : ទុងប្រផេះ ត្រដក់ធំ ត្រដក់តូច ត្រយង ក្ងួនខ្មៅ ត្រដក់ប្រផេះ ស្មោញចង្រ្កៀលខ្យង ។ លើសពីនេះពស់មានចំនួន ២៣ប្រភេទ ត្រូវបានធ្វើអត្តសញ្ញាណកម្ម និងពពួកសត្វតុកកែ ត្រូវបានរៀបរាប់នៅក្នុងរបាយកាណ៍ផងដែរ ។ម្យ៉ាងវិញទៀត អណ្តើកជាសត្វធ្លាប់តែសំបូរនោះ តែបច្ចុប្បន្ននេះបានក្លាយជាសត្វកំរ ។ តាមរបាយការណ៍ចំពោះត្រី សត្វជលថនិក និងពពួកសត្វឥតឆ្អឹងខ្នង វាហាក់បីដូចជាមិនទាន់មានការសិក្សាក្នុងតំបន់បឹងទន្លេឆ្មារនៅឡើយទេ ទោះបីជាពពួកសត្វកន្ទុំរុយ  និងសត្វកន្ទុំរុយរាងតូច ជាសត្វល្អិតដែលមានលក្ខណៈផ្សេងៗគ្នា មានបរិមាណយ៉ាងច្រើននៅតំបន់វាលភក់ខាងក្រោយ ជាពិសេសគឺសត្វកណ្តូប និងចង្រិត ។

ការអនុវត្តមិនប្រកបដោយនិរន្តរភាព ត្រូវបានរៀបរាប់ដោយការធ្លាក់ចុះនូវប្រភេទត្រីទាំងអស់ និងការនេសាទធន់តូចអាចត្រូវបានកំណត់ពីតំលៃនៃធនធាននៅតំបន់ស្នូលបឹងទន្លេឆ្មារ និងការបំផ្លាយនិរន្តរភាពរយៈពេលវែង ។  កិច្ចខិតខំប្រឹងប្រែងការពារធនធាននៅក្នុងតំបន់តំរូវអោយមានវិធីរួមពាក់ព័ន្ធដល់អ្នកដែលចូលរួម ជាពិសេសគឺ ប្រជាពលរដ្ឋ ដែលរស់នៅក្នុងសហគមន៏ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងជលផល និងការធ្វើកសិកម្មប្រកបដោយនិរន្តរភាព ។ ចំណេះដឹងតាមមូលដ្ឋាន ស្តីពីសារសំខាន់នៃព្រៃលិចទឹកត្រូវតែ



PHOTO: ALLAN MICHAUD WCS



PHOTO: ALLAN MICHAUD WCS

បង្កើនឡើង និងការប្រកបមុខរបរចិញ្ចឹមជីវិតតាមមធ្យោបាយផ្សេងៗ ព្រមទាំងតំរូវអោយមានការអភិវឌ្ឍប្រភពថាមពល ។ នៅខណៈពេលជាមួយគ្នានេះដែរ មានគំនិតផ្តួចផ្តើមដែលតំរូវអោយការកាត់បន្ថយការទាញយកធនធាននៅក្នុងតំបន់ និងជំរុញអោយមានការស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីជៀសវាងការប្រើប្រាស់នូវធនធាននៅក្នុងតំបន់ ។

ប្រភព: ក្រសួងបរិស្ថាន

# ១៨

# គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍



# គោលដៅអភិវឌ្ឍន៍សហសវត្សរ៍

អនុលោមតាមសេចក្តីប្រកាសសហសវត្សរ៍ ដែលចុះហត្ថលេខាដោយសមាជិកចំនួន ១៨៩រូប នៅឯមហាសន្និបាត អង្គការសហប្រជាជាតិនាឆ្នាំ ២០០០ រដ្ឋាភិបាលត្រូវបានកំណត់អោយមានការធានាលើនិរន្តរភាពបរិស្ថានថ្នាក់ជាតិ ។ ក្នុងនោះទិសដៅមួយក្នុងចំណោមទិសដៅទាំង២៥ ត្រូវបានអនុវត្តដោយព្រះរាជាណាចក្រកម្ពុជានៅត្រឹមឆ្នាំ២០១៥ គឺ "ការដាក់បញ្ចូល នូវគោលការណ៍អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ទៅក្នុងគោលនយោបាយរាជរដ្ឋាភិបាល និងកម្មវិធីធ្វើការកែប្រែលើការបាត់បង់ធនធានធម្មជាតិ" ។ យោងតាមរបាយការណ៍ថ្មីៗដែលបានចេញផ្សាយដោយក្រសួងផែនការនៅឆ្នាំ២០០៤ បានបង្ហាញថា ទិសដៅមួយនៃទិសដៅទាំងបីដែល "ប្រហែលនឹង" ត្រូវបានអនុវត្តនៅឆ្នាំ២០១៥ និងបង្ហាញថា មានការជួយគាំទ្រសំរាប់ការប្រជុំលើទិសដៅ ៣ ផ្សេងទៀត (បន្ថយការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងបែងចែកប្រជាពលរដ្ឋ ដែលមិនទទួលបាននូវទឹកស្អាត និងការកែលំអអនាម័យ) ។ ប៉ុន្តែការគាំទ្រមានត្រឹមតែ "មធ្យម" លើការអនុវត្តទិសដៅបរិស្ថាន ដែលត្រូវបានធ្វើការវាស់ស្ទង់ដោយសុច្ឆន្ទៈច្បាស់លាស់ ចំនួន ១៤ ។

នៅក្នុងចំនុចចាប់ផ្តើមនៃរបាយការណ៍ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងពីសារៈសំខាន់ និងគោលដៅបរិស្ថាន។ "ធនធានធម្មជាតិប្រទេសកម្ពុជាត្រូវតែបន្តការយកចិត្តទុកដាក់ ប្រសិនបើយើងបានបន្សល់ទុកនូវកេរ្តិ៍តំណែលដ៏ធំធេងនៃបេតិកភ័ណ្ឌបរិស្ថានដ៏សំបូរបែបសំរាប់អ្នកជំនាន់ក្រោយ" ។

តាមរបាយការណ៍បានបង្ហាញថា ខេត្តសៀមរាប ខេត្តកំពង់ធំ គឺជាខេត្តដែលស្ថិតនៅក្នុងខេត្តទាំង ៩ ដែល "មានកំរិតទាបបំផុត" ទាក់ទងនឹងទឹកស្អាត អនាម័យ ផ្ទៃគំរបព្រៃឈើ និងការពឹងផ្អែកទៅលើអុសសំរាប់ដុត ។ ស្ថានភាពក្នុងខេត្ត ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តបាត់ដំបង "ទទួលបានជាមធ្យម" ។ នៅមិនទាន់មានខេត្តណាមួយនៅជុំវិញបឹង ទន្លេសាប មានស្ថានភាព "ល្អឥតខ្ចោះ" នោះទេ ដោយមានតែខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តក្រចេះ និងខេត្តកោះកុង ព្រមទាំងក្រុងភ្នំពេញ ក្រុងប៉ៃលិន និងក្រុងព្រះសីហនុផងដែរ ។

ទំហំគំរបព្រៃឈើទូទាំងប្រទេសត្រូវបានធ្លាក់ចុះនៅក្រោមកំរិតកំណត់ ៦០% រវាងឆ្នាំ ២០០៥ និង ២០១៥ ។ ទោះបី មានការដាំដើមឈើឡើងវិញចាប់តាំងពីឆ្នាំ ១៩៨៥ ក៏ដោយ ក៏របាយការណ៍ត្រូវបានកត់សំគាល់ថា ទំហំគំរបព្រៃឈើ ដែលមាន ៧៣% នៅឆ្នាំ ១៩៦៩ បានធ្លាក់ចុះមកតិចជាង ៥៩% នៅឆ្នាំ ១៩៩៧។ ជាមួយនេះដែរត្រឹមឆ្នាំ ២០០២ ព្រៃឈើជិត ២លានហិកតា ត្រូវបានបាត់បង់ដោយអត្រាប្រចាំឆ្នាំបានធ្លាក់ចុះចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ ដែលមានប្រហែល 0.៥ % ក្នុង ១ឆ្នាំ។

ចំពោះការដែលអាចទទួលបាននូវទឹកស្អាតប្រកបដោយសុវត្ថិភាព និងការកែលំអអនាម័យ ទស្សនះវិស័យនេះត្រូវបានកំណត់ ។ របាយការណ៍បានបង្ហាញថា រដ្ឋាភិបាលស្ថិតនៅលើផ្លូវដើម្បីឆ្ពោះទៅរកទិសដៅមួយដែលមាន៥០% នៃលំនៅស្ថាននៅជនបទត្រូវមានសិទ្ធិក្នុងការទទួលបាននូវទឹកស្អាតនៅត្រឹមឆ្នាំ២០១៥ និងប្រហែលជា៨០% សំរាប់លំនៅស្ថាននៅទីក្រុង។ ម្យ៉ាងវិញទៀត កិច្ចខិតខំប្រឹងប្រែងដើម្បីកែលំអអនាម័យមានទិសដៅឆ្ពោះទៅមុខយ៉ាងល្អ ដោយបង្ហាញថា ១០០% នៃប្រជាពលរដ្ឋនៅក្នុងទីក្រុង និង ៥៥% នៃប្រជាពលរដ្ឋដែលរស់នៅជនបទត្រូវតែទទួលបាននូវការកែលំអ អនាម័យនៅឆ្នាំ ២០១៥ ។ ដើម្បីទទួលបាន

នូវទិសដៅនេះ ធនាគារពិភពលោក បានធ្វើការវាយតំលៃថា ទឹកប្រាក់ចំនួន ៦០០លានដុល្លាអាមេរិក នឹងត្រូវធ្វើការវិនិយោគលើបញ្ហាទឹកស្អាត និងអនាម័យ ។ អនុលោមតាមយុទ្ធសាស្ត្រ ស្តីពី ទឹក និងអនាម័យ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅឆ្នាំ ២០០៣ ។ ប្រជាជនគ្រប់រូបនៅជនបទត្រូវបានចាត់ទុកថា មានសិទ្ធិទទួលបានការផ្គត់ផ្គង់ទឹកស្អាត និងសេវាអនាម័យនៅឆ្នាំ ២០២៥ ។ យុទ្ធសាស្ត្រ ដែលបាននឹងកំពុងអភិវឌ្ឍ ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរំពឹងទុកផងដែរថា ប្រជាពលរដ្ឋទាំងអស់នៅជនបទរស់នៅប្រកបដោយ "បរិស្ថានស្អាត" នៅឆ្នាំ ២០២៥ ។

## ទិសដៅដើម្បីធានានិរន្តរភាពបរិស្ថាន

| សូចនាករ | ចំណុចកំណត់ ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
|---|---|---|---|---|
| ទំហំព្រៃឈើ (% នៃផ្ទៃដីសរុប) | ៦០+ | ៦០ | ៦០ | ៦០ |
| តំបន់ការពារទាំង ២៣ (លានហិកតា) | ៣.៣ | ៣.៣ | ៣.៣ | ៣.៣ |
| តំបន់ព្រៃការពារទាំង៦ (លានហិកតា) | ១.៣៥ | ១.៣៥ | ១.៣៥ | ១.៣៥ |
| ឧទ្យានុរក្សនៅតំបន់ការពារ | ៦០០ | ៧៧២ | ៩៨៧ | ១២០០ |
| ឧទ្យានុរក្សនៅតំបន់ការពារទាំង ៦ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| ឡូតិ៍នេសាទលែលកទុកសំរាប់សហគមន៍(%) | ៥៦ | ៥៨ | ៦០ | ៦០ |
| ចំនួនសហគមន៍នេសាទ | ២៦៤ | ៣៦៤ | ៤៦៤ | ៥៨៩ |
| តំបន់ការពារជលផល (រាប់ពាន់ហិកតា) | ២៦៤ | ៥៨១ | ៥៨១ | ៥៨១ |
| លំនៅស្ថានដែលពឹងអាស្រ័យលើអុស(%) | ៩២ | ៧០ | ៦១ | ៥២ |
| ប្រជាពលរដ្ឋជនបទរស់នៅដោយមានទឹកស្អាត(%) ២៤ | ៣០ | ៤០ | ៥០ | |
| ប្រជាពលរដ្ឋរស់នៅទីក្រុងដោយមានទឹកស្អាត (%) ៦០ | ៦៨ | ៧៤ | ៨០ | |
| ប្រជាពលរដ្ឋរស់នៅជនបទដោយមានអនាម័យល្អ(%) ៨.៦ | ១២ | ២០ | ៣០ | |
| ប្រជាពលរដ្ឋរស់នៅទីក្រុងដោយមានអនាម័យល្អ(%) ៤៩ | ៥៩ | ៦៧ | ៧៤ | |
| ដីដែលមានដាក់ឈ្មោះ (%) | ១៥ | ១៦ | ៣២ | ៦៥ |

+ ចំណុចកំណត់ ត្រូវបានរៀបរាប់យោងទៅតាម ទំហំនៃការព្យាករណ៍ទុកជាមធ្យមចន្លោះពីឆ្នាំ ១៩៩២ - ២០០២

ប្រភព : ក្រសួងផែនការ

ការប្រើប្រាស់ថាមពលជំនួសគឺជាបញ្ហាគន្លឹះសំរាប់ឆ្លើយតបទៅក្នុងទិសដៅបរិស្ថាន ។ រដ្ឋាភិបាលមានបំណងកាត់បន្ថយពីការពឹងអាស្រ័យទៅលើការប្រើប្រាស់អុសពី ៩២% មកនៅត្រឹម៥២% នៃលំនៅស្ថាននាឆ្នាំ ២០១៥ ។ ប្រជាពលរដ្ឋនៅតាមជនបទមានការប្រើប្រាស់អុសសំរាប់យកថាមពលស្ទើរតែទាំងស្រុង ។ ដូច្នេះ ការវិនិយោគនៅក្នុងផ្នែកផលិតកម្ម និងការចែកចាយនូវជំរើសផ្សេង ដែលមានតំលៃថោកគឺ ត្រូវយកមកពិចារណាជាអាទិភាព ។

បញ្ហាដទៃទៀតមានការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិសហគមន៍ និងការគ្រប់គ្រងដីសាធារណៈ ព្រមទាំងសំរបសំរួលជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងម្ចាស់ជំនួយ ។ តាមរបាយការណ៍របស់ក្រសួងផែនការ បានកត់សំគាល់ថា ទំនាស់រវាងក្រសួងរបស់ស្ថាប័នរដ្ឋនោះគឺបណ្តាលមកពី " ការធ្វើការត្រួតគ្នា " ដែលការទទួលខុសត្រូវរបស់ក្រសួងនីមួយៗ ត្រូវតែធ្វើការបែងចែកអោយបានច្បាស់លាស់ ។ របាយការណ៍ក៏ត្រូវបានធ្វើការអំពាវនាវអោយមានការសំរបសំរួលគ្នារវាងទីភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយ និងរវាងម្ចាស់ជំនួយខ្លួនឯងផងដែរ ។



▲ ឧបករណ៍បំបែកធាតុ ។ គ្រួសារមួយដាក់លាមកសត្វទៅក្នុងថង់ ដែលបន្ទាប់មកបំបែកធាតុទៅជាឧស្ម័នដែលអាចប្រើសំរាប់ចំអិនអាហារ ។



▲ កំបោកគឺជាជំរើសលខ្ញុំសំរាប់រុក្ខជាតិ

ច ង្កានសន្សំសំចៃថាមពល-ប្រើឈើតិច ទទួលបានលទ្ធផលដូចគ្នា

ការកាត់បន្ថយកំណើនប្រជាពលរដ្ឋ និងការកែលំអសមត្ថភាពរដ្ឋាភិបាលដើម្បីធ្វើការគ្រប់គ្រងបរិស្ថានក៏មានសារ សំខាន់ផងដែរ ។ របាយការណ៍បានបង្ហាអោយឃើញថា ប្រទេសកម្ពុជាទទួលរងគ្រោះដោយ " ការខ្វះខាតសមត្ថភាពបច្ចេកទេស" ជាច្រើនផ្នែកអំពីបញ្ហាបរិស្ថានចាប់តាំងពីបញ្ហាការគ្រប់គ្រងដីធ្លី រហូតដល់ បញ្ហាការគ្រប់គ្រងជីវៈចំរុះព្រៃឈើ ហើយបានលើកឡើងពីតំរូវការក្នុងការអនុវត្តយុទ្ធសាស្ត្រ និងនយោបាយ ។

របាយការណ៍បានរៀបរាប់ថា ច្បាប់របស់ប្រទេសកម្ពុជា "មិនត្រូវបានអនុវត្តត្រឹមត្រូវ ដោយសារ ឥទ្ធិពលនយោបាយ ការអភិវឌ្ឍមិនមានការត្រួតពិនិត្យ និងមិនមានការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ" ។ ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាព ដើម្បីប្រឆាំងនឹងអំពើពុករលួយ ដែលតំរូវអោយមានការអំពាវនាវរកយុត្តិធមិ និងតំរូវអោយមានកំណែទំរង់យោធា និងនគរបាល ។



▲ សួនបណ្តែតទឹកនៅសៀមរាប

ក្រសួងផែនការបានធ្វើការសន្និដ្ឋានថា ការគ្រប់គ្រងធនធានធម្មជាតិអោយកាន់តែប្រសើរអាចជួយបង្កើតថាមពល សំរាប់ប្រទេសកម្ពុជា ជួយកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍន៍ជនបទ និងបង្កើតការងារ ។ បន្ថែមទៅលើការកែលំអ ការគ្រប់គ្រង និងពង្រឹងសមត្ថភាពស្ថាប័នដើម្បីអនុវត្តអនុសញ្ញាស្តីពីជីវៈចំរុះ ហើយរបាយការណ៍ក៏បានធ្វើការអំពាវនាវអោយអនុវត្តច្បាប់ស្តីពីស្តង់ដារទឹក និងអនាម័យ ។ ការត្រួតពិនិត្យលើយុទ្ធសាស្ត្រ និងច្បាប់ដែលតំរូវអោយអនុវត្តស្របតាមការគ្រប់គ្រងរួមនៃធនធានអុស ។ នៅក្នុងរបាយការណ៍បានអំពាវនាវអោយធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងសាងសង់វារីអគ្គិសនីទាញយកកំលាំងទឹកនៅក្នុងតំបន់ការពារ និងទំរង់ការងារដើម្បីកែលំអសន្តិសុខដីធ្លីក្នុងរយៈពេល នៃយុទ្ធនាការផ្សព្វផ្សាយសិទ្ធិកាន់កាប់ដីធ្លី ។ ដើម្បីកាត់បន្ថយអាស្រ័យលើធនធានព្រៃឈើ របាយការណ៍ក៏បានជំរុញអោយមានការស្វែងរកដំណោះស្រាយផ្សេងសំរាប់មុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ការពារធម្មជាតិដោយជំរុញអោយមានការវិនិយោគលើផ្នែកថាមពល ផ្នែកទឹក និងព្រៃឈើ របាយការណ៍បានលើកឡើងពីសារៈសំខាន់នៃតម្លាភាព និងសមភាពរបស់ច្បាប់ដែលអនុវត្ត ។ ហើយក៏បានសង្កត់ធ្ងន់លើសេចក្តីត្រូវការនៃការកែច្នៃសំភារៈដោយឧស្សាហកម្ម ។

ប្រភព : ក្រសួងផែនការ



▲ ផ្សិតអំបោះអាចបណ្តុះនៅលើដំបូល

# ១៩

# ការអប់រំបរិស្ថាន



PHOTO: KAREN YOUNG L&I

# ការអប់រំបរិស្ថាន

ការអប់រំបរិស្ថាននៅជុំវិញឋបនីយជីវមណ្ឌលបឹងទន្លេសាបបានកំណត់តាមគោលដៅដល់សហគមន៍ គ្រូបង្រៀន និងសិស្សានុសិស្សនៅសាលាបឋមសិក្សា ប៉ុន្តែវាស្ថិតលើដំណើរនៃការចាប់ផ្តើមនៅឡើយ ។ អ្នកផ្តល់ការអប់រំនោះរួមមាន អង្គការអូស្មូស (Osmose) និងអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) នៅក្នុងខេត្តសៀមរាប ស្របពេលជាមួយនឹងអង្គការម្លប់បៃតង អង្គការសង្គ្រោះសត្វព្រៃនៅកម្ពុជា (SCW) និងអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live and Learn Environmental Education) នៅភ្នំពេញក៏ បានធ្វើការបណ្តុះបណ្តាលលើការអប់រំបរិស្ថាននេះផងដែរ ។ វាជាការលំបាកក្នុងការកំណត់ពីផលប៉ះពាល់ ដែលជាមធ្យោបាយទទួលបានជោគជ័យ និងមិនអាចនាំមកនូវការប្រែប្រួលពិតប្រាកដ ពេលដែលគ្មានគំនិតផ្តួចផ្តើមវាយតំលៃជាផ្លូវការ ។

នៅឆ្នាំ ២០០៣ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ ក្រោមកិច្ចការសហការជាមួយ អង្គការអូស្មូស អង្គការសង្គ្រោះសត្វព្រៃកម្ពុជា និងអង្គការម្លប់បៃតង បានបោះពុម្ពឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថានចំនួន ១០០ច្បាប់ ដែលមាន១៤ ផ្នែក ។ នៅចុងឆ្នាំ ២០០៤ អង្គការទាំងនោះបានពិនិត្យកែសំរួលសៀវភៅឡើងវិញ ដោយយោងតាមយោបល់ពីលោកគ្រូ អ្នកគ្រូ នៅក្នុងឆ្នាំ ២០០៥ អង្គការអូស្មូស បានបណ្តុះបណ្តាលគ្រូប្រមាណ ៤០នាក់ ដើម្បីអោយពួកគាត់អាចប្រើប្រាស់សៀវភៅនេះបាន ។ ចំណែកឯអង្គការម្លប់បៃតងបានបណ្តុះបណ្តាលគ្រូ ៣២នាក់ ផ្សេងទៀតក្នុងការប្រើប្រាស់ផ្នែកផ្សេងៗក្នុងសៀវភៅ ដើម្បីរៀបចំអនុវត្តកម្មវិធីបង្រៀនបន្ថែមម៉ោង "ក្លឹបបរិស្ថាន" ដល់សិស្សបឋមសិក្សាក្នុងខេត្តកំពង់ស្ពឺ ។ អង្គការ សង្គ្រោះសត្វព្រៃនៅកម្ពុជាបានបណ្តុះបណ្តាលដល់គ្រូជាង ២០០នាក់ ក្នុងខេត្តកំពត កោះកុង ពោធិ៍សាត់ ក្រចេះ មណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ។ អង្គការម្លប់បៃតង និងអង្គការអូស្មូស បានផ្តល់ថវិកាដល់គ្រូក្នុងការន្ថែមកម្មវិធីបរិស្ថានស្របតាមមេរៀនសាលា ។ អង្គការម្លប់បៃតង បានដាក់បញ្ចូលកម្មវិធីផ្សព្វផ្សាយវិទ្យុរយៈពេល ១៥នាទី ស្តីពីបញ្ហាបរិស្ថានជាផ្លូវការពីរដងក្នុងមួយសប្តាហ៍ តាមរយៈមជ្ឈមណ្ឌលព័តិមានស្ត្រីកម្ពុជា និងមួយម៉ោងក្នុងការឆ្លើយសំណួរតាមទូរស័ព្ទ ប្រសិទ្ធភាពនៃកម្មវិធីនេះមិនទាន់បានទទួលជោគជ័យតាមការវាយតំលៃនោះទេ ។

នៅឆ្នាំ១៩៩៩ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ បានដាក់តាំងបង្ហាញនូវបច្ចេកទេស និងការប្រកបរបរចិញ្ចឹមជីវិត ដែលបានអនុវត្តនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប នៅទីស្នាក់ការតុកកែ (Gecko) ការិយាល័យបរិស្ថានចុងឃ្នៀស ក្នុងខេត្តសៀមរាប ។ សំណាញ់បណ្តែតទឹកក៏បានដាក់បង្ហាញផងដែរនូវជីវៈចំរុះផ្សេងៗ នៅពេលដែលអ្នកចូលមកទស្សនានាពេលខាងមុខ ត្រូវបានចាត់ទុកមុខនឹងជាប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ និងអ្នកទេសចរ ភាគច្រើនជាសិស្សដែលរស់នៅក្បែរមជ្ឈមណ្ឌលនេះ ។ តាមការរាយការណ៍ មានសិស្សប្រមាណ ៥០០០ នាក់ បានមកទស្សនាមជ្ឈមណ្ឌលនៅចុងឆ្នាំ ២០០៥ ក្នុងនោះ សិស្សបឋមចំនួន ៦ក្រុម បានទស្សនាមជ្ឈមណ្ឌលតុកកែ ពីរដងក្នុងមួយសប្តាហ៍ មានរយៈពេល១ម៉ោងដោយណែនាំ ឬបង្រៀនតាមឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថាន ។ មជ្ឈមណ្ឌលក៏បានបង្កើតខ្សែវីដេអូរ ស្តីពីការការពារព្រៃលិចទឹក ព្រមទាំងបដាផ្សព្វផ្សាយ និងស្លាកសញ្ញាផងដែរ ។

អង្គការស្បៀងអាហារ និងកសិកម្មក៏បានបណ្តុះបណ្តាលដល់ព្រះសង្ឃ និងបានរៀបចំសៀវភៅបណ្តុះបណ្តាល ស្តីពី បរិស្ថាន ដោយផ្តោតតាមធម៌ព្រះពុទ្ធ ។ ព្រះសង្ឃចំនួន២០អង្គមកពីវត្តចំនួន៤ បានទទួលការបណ្តុះបណ្តាលនៅចុងឆ្នាំ ២០០៥ ចំណែកឯអង្គការមូលបៃតងក៏បានអនុវត្តការអប់រំបរិស្ថានតាមរយៈវត្តអារាមផងដែរ ។

នៅក្នុងចំណោមគំនិតផ្តួចផ្តើមដទៃទៀត អង្គការអភិវឌ្ឍន៍គ្រួសារកម្ពុជា (CFDS) អង្គការស៊ីប៉ា (SIPAR) និង អង្គការ NGO Forum បានរៀបចំសំភារៈអប់រំមានទំហំតូចផងដែរ ដែលភាគច្រើនជាបដាផ្សព្វផ្សាយ និងរឿងខ្លីៗ សំរាប់សហគមន៍ ។ ទន្ទឹមនឹងនោះដែរ អង្គការ អនុវត្តគំរោងកែច្នៃសំណល់រឹង-សំរាម (CSARO) នៅទីក្រុងភ្នំពេញ និងអង្គការទីភ្នាក់ងារសហប្រតិបត្តិការអង្គការអន្តរជាតិជប៉ុន (JICA) បានបញ្ចូលកម្មវិធីបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលលើផ្នែកបរិស្ថាននេះផងដែរ ។

មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ និងបាត់ដំបងបានរៀបចំប៉ាដាផ្សព្វផ្សាយ ។ បដាទាំងនោះរៀបចំជាមួយនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និងនាយកដ្ឋានបរិស្ថាន នៃក្រសួងបរិស្ថាន ព្រមទាំងអង្គភាពសំរបសំរួលបច្ចេកទេសនៅព្រែកទាល់ ។ ក្រសួងខ្លួនឯងក៏មានអង្គភាពមួយឈ្មោះថា នាយកដ្ឋានអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ដោយ



ផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងតាមសហគមន៍ " ទិវាភពផែនដីស្អាត" និងមានចេញអត្ថបទនេះចេញរៀងរាល់ត្រីមាស ។

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប(TSEMP) ជាផ្នែកមួយស្ថិតក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលមានសកម្មភាពសំខាន់ពីរទាក់ទងជាមួយការអប់រំបរិស្ថាន ។ ចំនុច១ ពាក់ព័ន្ធជាមួយអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ដែលកំពុងអនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិមានរយៈពេល ១៨ខែ បានអនុវត្តនៅពាក់កណ្តាល ឆ្នាំ២០០៥ ។ ពាក់ព័ន្ធថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ យុទ្ធនាការបានផ្តោតទៅលើទិដ្ឋភាពបរិស្ថានសេដ្ឋកិច្ច និងសង្គមនៃបឹងទន្លេសាប ដែលជាអ្នកផ្តល់ម្ហូបអាហារមានជលសាស្ត្រជាក់លាក់ និងរងការគំរាមកំហែង ។ នៅដើមឆ្នាំ២០០៦ យុទ្ធនាការនេះបានរៀបចំរបាយការណ៍ ស្តីពី ស្ថានភាពនៃការអប់រំបរិស្ថានប្រទេសកម្ពុជា និងបានបង្កើតកម្មវិធីវិទ្យុ ការសំដែងសិល្បៈ និងកម្មវិធីផ្សព្វផ្សាយតាមកាសែតរស្មីកម្ពុជារយៈពេលមួយឆ្នាំក្នុងខេត្តចំនួន៥នៅជុំវិញបឹងទន្លេសាប ចំណែកគំនិតផ្តួចផ្តើមសំខាន់ផ្សេងទៀតពាក់ព័ន្ធនឹងគំរោងអភិរក្សបឹងទន្លេសាប កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) និង មូលនិធិបរិស្ថានពិភពលោក (GEF) ដែលគំរោង នេះមានកម្មវិធីអប់រំ និងចំណេះដឹងបរិស្ថាន និងចំណេះដឹងផ្សេងទៀតតាមរយៈសាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបរិស្ថាន ។ ទាំងនេះមានបញ្ចូលនូវមជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូល ចំនួន ០៣ ទៅក្នុងបរិវេណមណ្ឌលបឹងទន្លេសាប (ព្រែកទាល់ បឹងទន្លេឆ្មារ និងស្ទឹងសែន) និងមជ្ឈមណ្ឌលបណ្តែតទឹកក្នុងខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ ព្រមទាំងមជ្ឈមណ្ឌលតុកកែ (Gecko) នៅខេត្តសៀមរាប ។

(ប្រភព : អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន)

PHOTO: TERRY WOOLTORTON L&L

# ២០

## សន្ធានុក្រម



# សន្ទានុក្រម

## ការបន្សាំ

Adaptive ជាទូទៅ គឺជាប្រភេទសត្វ ដែលអាចបន្សាំខ្លួន ឬរស់នៅដោយសំរបសំរួលខ្លួនទៅនឹងការប្រែប្រួលបរិស្ថានរបស់វា ។ កាលណាប្រភេទទាំងនេះកាន់តែអាចផ្សាំទៅនឹងលក្ខខណ្ឌរស់នៅ និងការចិញ្ចឹមជីវិតកាន់តែខ្លាំង នោះលំនៅដ្ឋានធម្មជាតិ និងភាពធន់ទ្រាំរបស់វាទៅនឹងការរំខានផ្សេងៗក៏កាន់តែធំដែរ ។ នៅក្នុងការគ្រប់គ្រងបរិស្ថានពាក្យ "ការបន្សាំ" គឺមានន័យថា យុទ្ធសាស្ត្រ ដែលមានលក្ខណៈរលូន ហើយអាចបញ្ចូលព័ត៌មានថ្មីៗទៅក្នុងយុទ្ធសាស្ត្រ ឬ គោលនយោបាយគ្រប់គ្រងមួយ ដែលបានពិនិត្យឡើងវិញ និងបង្កើនគុណភាព ។

## ការវាយតំលៃ

Assessment: ការសំដែងចេញយ៉ាងច្បាស់លាស់នូវតំលៃបរិស្ថានដ៏ពិតប្រាកដបានកំណត់ ដែលចាំបាច់ត្រូវការពារ ។

## Endpoints

### Assessment endpoint

គឺជាសេចក្តីអធិប្បាយ ឬគោលដៅពាក់ព័ន្ធទៅនឹងលក្ខខណ្ឌអេកូឡូស៊ី (ដូចជា ឥទ្ធិពលនៃការបង្កកំណើតលើសាពាង្គកាយក្នុងទឹក) ដែលចាំបាច់ត្រូវធ្វើការវាយតំលៃ និងការពារ ។ Assessment endpoints ជារឿយៗតែងតែផ្សារភ្ជាប់ទៅនឹងការឆ្លើយតបនឹងភាពតានតឹងបរិស្ថាន (Environmental stresses) របស់ប្រភេទនៅក្នុងអេកូឡូស៊ី ដែលជាអ្នកទទួលរងឥទ្ធិពល (Ecological receptor species) ប៉ុន្តែពួកវាក៏មានផ្នែកខ្លះ ដែលពឹងអាស្រ័យទៅលើលក្ខណៈអេកូឡូស៊ីទាំងនោះ ដែលគេដឹងថា មានតំលៃខ្ពស់សំរាប់មនុស្ស ។

## កំហាប់ជីវៈ

Bioconcentration:
គឺជាដំណើរការនៃការប្រមូលផ្តុំធាតុគីមី ទៅក្នុងសាពាង្គកាយរស់នៅក្នុងទឹក ដោយផ្ទាល់ពីទឹក ។ ដំណើរការនេះ រួមមាន ការស្រូបយក (តាមរយៈស្រកី ឬជាលិកាស្បែក) និងការបញ្ចេញចោល ។

## ការបំបែកធាតុ

Decomposition: គឺជាដំណើរការជីវៈមួយប្រភេទ ដែលពាក់ព័ន្ធទៅនឹងការទំពារ ឬបំបែកសរីរាង្គដ៏ស្មុគស្មាញ អោយទៅជាទំរង់ងាយ ដោយសាពាង្គកាយមួយចំនួន ដែលគេអោយឈ្មោះថាការបំបែកធាតុ ដូចជា បាក់តេរី និងផ្សិតជាដើម ។

## ការបញ្ចេញទឹក/ការបង្ហូរទឹកចេញ

Drainage

Drainage basin: (សូមពិនិត្យមើល ឬអាចនៅត្រង់ពាក្យ " Catchment ") ។

## រំហួត

Evaporation: ការបាត់បង់មូលេគុលទឹក ដោយសារដំណើរប្រែប្រួលពីភាពរូបរាវ ទៅជាឧស្ម័ន ។ ជាទូទៅ ជាលទ្ធផលនៃការបាត់បង់ទឹកនៅពេលដែលវត្ថុរាវនេះត្រូវបានបំលែងទៅជាចំហាយ ។

## ការប៉ះពន្លឺ

Exposure: ប្រតិកម្មដោយផ្ទាល់ រវាងភ្នាក់ងារគីមី ភ្នាក់ងារជីវៈមួយប្រភេទ និងប្រព័ន្ធជីវៈមួយ (គោលដៅ ឬផ្នែកនៃបរិស្ថាន ដែលទទួលរងឥទ្ធិពល) ។

## ការសំដិល

Exposure គឺជាការប៉ះគ្នាដោយផ្ទាល់នៃភាពតានតឹងបរិស្ថាន (Environmental stressor) ជាមួយនឹងផ្នែកនៃបរិស្ថាន ដែលទទួលរងឥទ្ធិពល (Environmental receptor) ។

## និរន្តរភាពជំរក

Habitat sustainability: តួលេខដែលត្រូវបានគេប្រើប្រាស់ក្នុងការកំណត់គុណភាពខ្ពស់បំផុតនៃលំនៅដ្ឋានធម្មជាតិ index នៅក្នុងតំបន់មួយ ។ វត្តមាននៃប្រភេទក្នុងស្រុក និងប្រភេទនាំចូលពីក្រៅផ្ទៃដីនៃលំនៅដ្ឋានធម្មជាតិ និងកំរិតនៃផលប៉ះពាល់ គឺជាកត្តាសំខាន់ក្នុងការកំណត់ភាពស្ថិតស្ថេរក្នុងរយៈពេលវែងនៃលំនៅដ្ឋានធម្មជាតិនៅក្នុងតំបន់មួយ ។

## ការផ្លាស់ទី

Migratory ការផ្លាស់ទី ដែលជាធម្មតា គឺអាចអោយគេព្យាករណ៏បាន ( អាស្រ័យទៅលើប្រភេទដែលរស់នៅក្នុងទឹកនីមួយៗ) ពីតំបន់ ឬអាកាសធាតុមួយទៅតំបន់ ឬអាកាសធាតុមួយផ្សេងទៀត ដោយសារមូលហេតុនៃការស្វែងរកចំណីអាហារ ឬបន្តពូជ ។ល។

## កន្លែងសារធាតុចិញ្ចឹម

Nutrient sink: តំបន់ដីសើមដែលមានមុខងារជាឃ្លាំងស្តុកជីជាតិ ឬធាតុគីមីទាំងឡាយ ។

## ការធ្វើអាជីវកម្មហួសកំរិត

Overexploitation: ការធ្វើអាជីវកម្ម ឬ ប្រើប្រាស់ធនធានធម្មជាតិលើសពីសមត្ថភាពដែលបានផ្តល់របស់វាក្នុងការកកើតឡើងវិញ ឬទ្រទ្រង់និរន្តរភាពដោយធម្មជាតិរបស់វា ។

## ការបំពុល

Pollution

Pollution-tolerant taxa: បានដល់ការប្រើប្រាស់សត្វឥតឆ្អឹងកង ដែលរស់នៅក្នុងបរិស្ថានទឹក ជាកត្តាត្រួតពិនិត្យការប្រែប្រួល ។ Pollution tolerant taxa គឺជាប្រភេទទាំងឡាយណា ដែលគេចាត់ទុកថាអាចទ្រាំរស់នៅ និងលូតលាស់នៅក្នុងបរិស្ថាន ដែលមានវត្តមាននៃសារធាតុពុល ។ ភាពច្រើនលើសលប់ Pollution-tolerant taxa ( ដូចជា សត្វឈ្លើង) ជាប់ពាក់ព័ន្ធទៅនឹង ការថយចុះនៃចំនួន Pollution-sensitive taxa ដែលជាទូទៅត្រូវបានគេចាត់ទុកជាភស្តុតាងនៃការខូចខាតគុណភាពទឹក ។

## កំណកអាកាស

Precipitation: រាល់ទ្រង់ទ្រាយនៃទឹកទាំងអស់ មិនជាអង្គធាតុរាវ ( ភ្លៀង) ឬអង្គធាតុតាន់ ( ព្រឹល ឬ ទឹកកកសំឡី) ដែលធ្លាក់ពីបរិយាកាសទៅដល់ដី ឬគំរបស្លឹករុក្ខជាតិ ។

## កំទេចកំណ ( កករ)

Sediment

Sediment grain size: រង្វាស់ទំហំនៃគ្រាប់ដី រាប់បញ្ចូលចាប់ពីថ្មធំៗ (Lager cobbles) គ្រួស (Gravels) គ្រាប់ដីឥដ្ឋតូចៗ (Finer Clays) និងគ្រាប់ដីល្បាប់ (Silts) ។ ទំហំនៃគ្រាប់ដី គឺជាប៉ារ៉ាម៉ែត្រដ៏សំខាន់មួយក្នុងការត្រួតពិនិត្យនៅពេលធ្វើការកំណត់វត្តមាន ឬបរិមាណនៃធាតុកខ្វក់មួយនៅក្នុងជីវិតដែលរស់ក្នុងទឹក (Aquatic life) ។ ជាទូទៅ ដីដែលមានគ្រាប់តូច ហើយសំបូរដោយសារធាតុសរីរាង្គមានសមត្ថភាពបឺតផ្ទុកសារធាតុកខ្វក់ច្រើន ។ គ្រាប់ដីតូចមានផ្ទៃខាងក្រៅធំជាងដីគ្រាប់ធំ បើគិតជាភាគរយទៅនឹងមាឌរបស់វា ។ លើសរីរាង្គនេះទៀត ធាតុគីមីកខ្វក់ជាច្រើនមានទំនោរក្នុងការជ្រៀតចូល ឬតោងភ្ជាប់ទៅលើកំណកដីល្បាប់ដែលមានសារធាតុសរីរាង្គខ្ពស់ ។

## កំណកំទេចក្នុងទឹក

Sediment/water interface:

ការជួបគ្នារវាងទឹក (water column) និងកំណកដីល្បាប់នៅបាតក្រោម ឬដែលនៅក្នុងទឹក ។

## តំណគ្នា

Succession: ការប្រែប្រួលរូបសាស្ត្រ (Dynamic) មួយលំដាប់ ឬសេរីនៃមុខងាររចនាសម្ព័ន្ធ និងសមាសភាពនៃប្រភេទនៅក្នុងប្រព័ន្ធអេកូឡូស៊ីមួយក្នុងរយៈពេលមួយ ។ ជាលទ្ធផលក្រុមមួយនៃសាពាង្គកាយធ្វើការប្រជែងរស់យ៉ាងជោគជ័យលើក្រុមមួយទៀត ឬផ្សេងៗទៀត តាមរយៈដំណាក់កាលមួយចំនួន ដែលធ្វើអោយក្រុមនេះមានសក្តានុពលជាសហគមន៍ ធម្មជាតិ (A potential natatal community) ឬហៅម៉្យាងទៀតថា climax stage ។

## ការវាស់កំរិតពុល

Toxicity test: មធ្យោបាយ ឬ វិធី ដែលតាមរយៈនោះ កំរិតពុលនៃធាតុគីមី ឬសមាសធាតុផ្សេងៗទៀត ដែលបានធ្វើពិសោធន៍ ត្រូវបានគេកំណត់ ។ ការធ្វើពិសោធន៍សាកល្បងអំពីកំរិតពុល ត្រូវបានប្រើប្រាស់ ដើម្បីធ្វើការវាស់ស្ទង់កំរិតនៃការឆ្លើយតប (degree of response) ដែលបានបង្កើតឡើងតាមរយៈការដាក់ដោយផ្ទាល់ ទៅនឹងកំរិតនៃកត្តាជំរុញ (Stimuls) ឬ កំរិតនៃសារធាតុគីមីពិសេសណាមួយ ។



PHOTO: L&L

ការធ្វើពិសោធន៍សាកល្បងកំរិតពុលអាចត្រូវបានគេប្រើប្រាស់ ដើម្បីវាស់ឥទ្ធិពលនៃផលប៉ះពាល់របស់សារធាតុមួយទៅលើក្រុមសាពាង្គកាយមួយប្រភេទដែលបានជ្រើសរើសនៅក្រោមលក្ខខណ្ឌកំណត់មួយ ។ ការធ្វើពិសោធន៍សាកល្បងកំរិតពុលនៅក្នុងទឹក ជាទូទៅអាចវាស់ a) សមាមាត្រនៃសាពាង្គកាយដែលទទួលរងឥទ្ធិពល ឬ b) កំរិតនៃឥទ្ធិពលជះបន្ទាប់ពីការដាក់ដោយផ្ទាល់ទៅនឹងសារធាតុមួយជាកំណត់ ដែលគេធ្វើការសាកល្បង (ឧទាហរណ៍ សំណាកគំរូនៃកំណកដីល្បាប់ ឬកាកសំណល់រាវ) ។

## គ្រោះថ្នាក់

Hazard

Hazard quotient: រូបមន្តដែលត្រូវបានគេប្រើប្រាស់សំរាប់គណនាការប៉ាន់ស្មាន ភាពគ្រោះថ្នាក់នៃសារធាតុកខ្វក់មួយជាកំណត់ ។ Hazard quotient (HQ) ត្រូវបានកំណត់ដោយផលចែករវាងកំហាប់បរិស្ថាន ដែលគេបានរំពឹងទុក (EEC) និងកំហាប់គោល (benchmark concentration “BC ”) ។ កាលណា HQ មានតំលៃតូចជាង ១ (HQ<1) នោះ បញ្ជាក់ថា ភាពគ្រោះថ្នាក់មានលក្ខណៈអាចអោយគេទាត់ចោលបាន ។ ម៉្យាងទៀត កាលណា Hazard quotient មានតំលៃស្មើ ១ (HQ=1) នោះ បញ្ជាក់ថា មានវត្តមាននៃគ្រោះថ្នាក់ ។

## ខ្សែអាហារ

Food chain: ការផ្ទេរថាមពលពីអ្នកផលិតដំបូងគេ (រុក្ខជាតិ) តាមរយៈសាពាង្គកាយមួយសេរី ឬលំដាប់ ដែលជាអ្នកស៊ី នឹងត្រូវបានគេស៊ីបន្ត ហើយដែលសន្មតថា សាពាង្គកាយនីមួយៗចិញ្ចឹមជីវិតដោយស៊ីតែសាពាង្គផ្សេងៗទៀតមួយប្រភេទប៉ុណ្ណោះ (ឧទាហរណ៍ វដ្ឋនកម្មនៃជន្លេន គ្រលីងគ្រលោង ចាប និងស្ទាំង) ។ នៅក្នុងដំណាក់កាលនៃការប្រើ

ប្រាស់ថាមពល ត្រូវបានបំលែងជាកំដៅ ដែលកំណត់ចំនួនដំណាក់កាល ឬវគ្គ ឬកំរិតជីជាតិ (Trophic level) នៅក្នុងចង្វាក់អាហារជា ៤ ឬ ៥ ។ មូលដ្ឋាននៃការទទួលស្គាល់ចង្វាក់អាហារ គឺពពួកស៊ីសរីរាង្គរស់ និងពពួកស៊ីសរីរាង្គស្លាប់ (ពពួកទំពារ ឬបំបែកធាតុ) ។ អន្តរអំពើទាំងនេះ កើតឡើងនៅក្នុងបណ្តាញចំណីអាហារដ៏ស្មុគស្មាញមួយ ។

## គ្មានអុកស៊ីសែន

Anaerobic: (1) លក្ខខណ្ឌបរិស្ថាន ដែលក្នុងនោះគ្មានវត្តមានអុកស៊ីសែន

(2) សាពាង្គកាយដែលអាចរស់នៅបាន ដោយគ្មានវត្តមានអុកស៊ីសែន

(3) ដំណើរការដែលអាចកើតមានឡើងបាននៅក្នុងលក្ខខណ្ឌដែលគ្មានអុកស៊ីសែន ។

## គ្រោះថ្នាក់អាចនឹងកើតមាន ការប្រថុយ

Risk

Risk estimate: ការបង្ហាញ ឬបញ្ជាក់ថា បរិមាណតាមរយៈប្រូបាប៊ីលីតេ នៃឥទ្ធិពលមិនល្អ ដែលកើតឡើងពីការដាក់ដោយផ្ទាល់ទៅនឹងបរិស្ថាន ដែលមានកំហាប់នៃសារធាតុពុលមួយ ។

## ចំរុះ នានាភាព

Diversity

Diversity indices: រង្វាស់ផ្សេងៗ ដែលត្រូវបានគេប្រើប្រាស់សំរាប់គណនា ចំរុះភាពនៃប្រភេទរបស់លំនៅដ្ឋានធម្មជាតិមួយជាកំណត់ ។ ជាទូទៅកាលណា diversity indices កាន់តែធំគឺបញ្ជាក់ថាប្រព័ន្ធអេកូឡូស៊ីកាន់តែមានសុខភាពល្អ ។

## ចែកជាភាគ

fragmentation: ដែលជាលទ្ធផលនៃការកែប្រែ ឬការបំលែងទេសភាព ដោយការរំខាន ឬប៉ះពាល់ ។

## ចំណោត

Slope

Slope gradient:
គឺជាជ្រុងដែលផ្ទៃរាបនៃផ្ទៃខាងលើ ទ្រេត ឬចោតប្រៀបធៀបទៅនឹងប្លង់ដេក ។ ឧទាហរណ៏ ចំណោទស្មើរាបស្មើ (Mearly level slopes) មានកំរិតចោត (Stope gradient) ពី 0-3% ហើយចំណោទខ្លាំង មានកំរិតចោតពី ៣0-៦៥%

## ជលធរណីវិទ្យា

Hydrogeology: ការសិក្សាអំពីចលនានៃទឹកក្រោមដីឆ្លងកាត់សារធាតុដីធម្មជាតិ ។

## ជីវៈចំរុះ

Biodiversity: ជាពាក្យ ដែលត្រូវបានគេប្រើប្រាស់ដើម្បីពិពណ៌នានូវរាល់ទស្សនៈទាននៃភាពចំរុះប្រភេទនៃអេកូឡូស៊ី ជាពិសេស គឺរាប់បញ្ចូលនូវភាពសម្បូរនៃប្រភេទភាពស្មុគស្មាញនៃប្រព័ន្ធអេកូឡូស៊ី និងនានាភាពនៃសេនេទិច ។ រង្វាស់ដែលមានទំហំធំ ឬខ្ពស់នៃ biodiversity ។ ជាទូទៅគេចាត់ទុកថាជាសន្ទស្សន៍បញ្ជាក់អំពីសុខភាពដ៏ល្អប្រសើរនៅក្នុងប្រព័ន្ធអេកូឡូស៊ី

## ជំរាបទឹក

Infiltration: ចលនានៃទឹកលើដី ទៅក្នុងដី ឬថ្មតាមរយៈក្រហែងបែក ឬចន្លោះប្រហោងផ្សេងៗ ។

## ផលិតភាព

Productivity: អត្រាផលិត ជីវម៉ាស (Biomass) ដោយរុក្ខជាតិរស់ជាទំរង់សារធាតុសរីរាង្គ ដែលភាគច្រើន ត្រូវបានប្រើប្រាស់ជាចំណីអាហារ ។

## ការជ្រើសរើស ការកេណ្ឌ

Recruitment" ចំនួនបន្ថែម ឬការបន្តពូជនីនៃឯក្កតៈនីមួយៗទៅក្នុងសារព័ន្ធ (Population) ។

### ដែលគ្មានជីវិត

Abiotic: នៃផ្នែកដែលគ្មានជីវិត

### ដង្ហើមទឹក

Aquifer: តួអង្គ ឬបន្ទុំ (Body) នៃថ្ម គ្រួស (gravel) ខ្សាច់ដែលជ្រាបទឹក ហើយដែលមានសមត្ថភាពអាចផ្ទុកបរិមាណទឹកដ៏ច្រើន ដែលក្រាលពីក្រោមដោយរូបធាតុមិនជ្រាបទឹក ហើយដែលតាមរយៈបន្ទុំទឹកនេះ (Body) ទឹកក្រោមដីត្រូវបានគេទាញយក ។

### ដីអិនអេ/អាដេអិន

DNA (Deixyribonucleic acid): ម៉ូលេគុលអាស៊ីដនុយក្លេអិចដ៏ស្មុគស្មាញមួយ ។ វាគឺជារូបធាតុសេនេទិចនៃគ្រប់សាពាង្គកាយទាំងអស់ ។

### ដែលមានខ្យល់/ដែលមានអុកស៊ីសែន

Aerobic: (1) លក្ខខ័ណ្ឌបរិស្ថានដែលក្នុងនោះមានអុកស៊ីសែន

(2) សាពាង្គកាយដែលចាំបាច់ត្រូវការអុកស៊ីសែនសំរាប់ជីវិតរស់នៅ

(3) ដំណើរដែលអាចកើតមានឡើងបាន តែក្នុងលក្ខខណ្ឌ ដែលមានវត្តមានអុកស៊ីសែន ។

### ដែលមានកំណត់

Finite: ដែលមានក៏រិត ឬកំណត់ ។

### ដីវិទ្យា

Pedology: ការសិក្សាជាលក្ខណៈវិទ្យាសាស្ត្រអំពីលក្ខណៈទូទៅ ប្រភព និងចំណាត់ថ្នាក់នៃដី ។

### ដៃទន្លេ

Tributary: ជាទូទៅគឺជាផ្លូវទឹកតូចៗ ដែលហូរចាក់ទៅផ្លូវទឹកមួយផ្សេងទៀត ដែលមានទំហំធំជាង ។

### តំបន់

Endemi: គឺជាប្រភេទក្នុងស្រុក ជារឿយៗ គឺជាប្រភេទដែលមានកំណើតនៅក្នុងលំដាប់នៃស្ថានភាពភូមិសាស្ត្រកំណត់មួយ ។

### ថលជលិក

Amphibian: សត្វឆ្អឹងកងដែលមានឈាមត្រជាក់ស្ថិតក្នុងថ្នាក់ Amphibia ដែលអាចរស់នៅក្នុងទឹកក៏បាន និងលើគោកក៏បាន ។

លក្ខណៈមួយចំនួនរបស់ វារួមមាន :

1) នៅពេលពេញវ័យរស់នៅលើដី ប៉ុន្តែត្រឡប់ទៅក្នុងទឹកវិញនៅពេលបង្កកំណើត

2) អាចប្រើប្រាស់ស្បែក និងមាត់សំរាប់បន្ទូរអុកស៊ីសែននៅក្នុងទឹក

3) ក្រពេញស្បែកគ្មានរោម ស្រកា ឬស្លាប់

4) ស៊ុតញាស់បង្កើនជាកូនញាស់ដែលរស់នៅក្នុងទឹក ។

### ថ្នាំពុលកសិកម្ម (ដេដេតេ)

DDT; (Dichloro-Diphenyli-Trichloroethane, or 1, 1, 1-Trichloro-2,2-bislp-chlorophenyl): គឺជាថ្នាំសំរាប់សត្វល្អិតមួយប្រភេទ ដែលមានសារធាតុសរីរាង្គ និងក្លរ (organochlorinated pestiside) ។ DDT អាចមានជាទំរង់ p,p'-DDT និង o,p'-DDT ។ ជាទូទៅ DDT បានដល់វត្តមាននៃ DDT ទាំងអស់ដែលមានទំរង់មេតាបូលីកបញ្ចូលគ្នា (លើកលែងតែមានករណីបញ្ជាក់ផ្សេងៗពីនេះ) ។ DDT គឺជាថ្នាំគីមី ដែលមានក៏រិតពុលខ្លាំង និងជាអង្គធាតុសមាសដែលមានទំរង់ធន់យូរអង្វែង ពោលគឺមិនងាយបែកធាតុ (Persistem chemical compound) ។

## ទំនាបលិចទឹក

Floodplain: គឺជាតំបន់ទំនាបជាប់ដងទន្លេ ស្ទឹង ឬផ្លូវទឹក ដែលនៅលើនោះទឹកជំនន់តែងតែគ្រប ដណ្តប់ ។ តំបន់នេះកើតឡើងពីកំណកដីល្បាប់ ដែលមានលក្ខណៈធូរ (Unconsolidated material) ដែលជាទូទៅ រងធ្លាក់ចុះពីទឹកជំនន់ក្នុងពេលមុន ។ ទំហំនៃទំនាបលិចទឹកនេះ ប្រែប្រួលទៅតាមមាឌ ឬទំហំទឹកជំនន់ ហើយហេតុនេះ ទើបវាត្រូវបាន កំណត់ដោយទំហំនៃតំបន់ជំនន់នីមួយៗ ។ ឧទាហរណ៍ តំបន់ទំនាបលិចទឹកចំនួន ១០ដង ក្នុងរយៈពេល ១០ឆ្នាំ (10 years floodplain) នឹងត្រូវកំណត់ដោយទឹកជំនន់ ដែលធំជាងគេ ដែលបានកើតឡើងជាមធ្យមរាងរាល់ឆ្នាំម្តង ។

## ទឹកក្រោមដី

Groundwater: ទឹកដែលកើតមាននៅក្នុងដី ដែលស្ថិតនៅក្នុងចន្លោះប្រហោងលំហរនៃសិលាស្រទាប់ក្រោម និងសារធាតុខនិជនៃដីស្ថិតនៅជាប់ពីលើសិលាស្រទាប់ក្រោម (Bedrock) នេះ ។

## ទឹកប្រៃ

Saltwater

Saltwater intrusion (Salinisation): ការជ្រាប ឬហូរចូលនៃទឹកប្រៃទៅក្នុងប្រព័ន្ធអេកូឡូស៊ីតំបន់ទឹកសាប ដែលជាលទ្ធផលបង្កឡើងដោយការរំខាននៃមនុស្ស ឬធម្មជាតិ ឬកិច្ចអភិវឌ្ឍន៍ដោយសកម្មភាពមនុស្ស ។ ការប្រែប្រួល គឺកំហុក ឬរហ័សនៃសមាសភាពប្រភេទ អាចកើតមានឡើង ។

## ទឹកក្រោមដី

Water column: ជំហរនៃទឹកតាមបែបទស្សនទាន (A conceptual column of water) ពីផ្ទៃលើនៃទឹកបឹងរហូតដល់បាតបឹង ដែលជាកំណកដី ។

## ទឹកក្រោមដី

Water table: កំរិតខ្ពស់ជាងគេនៅក្នុងដីនៃទឹកក្រោមដី ។water tuble បង្កើតជាព្រំប្រទល់រវាងតំបន ដែលឆ្អែតដោយទឹក (Zone of saturation) (គ្មានអុកស៊ីសែន) និងតំបន់ដែលមានប្រហោយខ្យល់ (Zone of aerating) (មានវត្តមានអុកស៊ីសែន) ។

Watershed: សូមអានពាក្យ Catchment ។

## ធរណីវិទ្យា/ភូគព្ភសាស្ត្រ

Geology: វិទ្យាសាស្ត្រដែលទាក់ទិនទៅនឹងប្រវត្តិនៃភពផែនដី និងជីវិតរបស់វា ពិសេសគឺព័ត៌មានដែលកត់ត្រានៅក្នុងសិលាផ្សេងៗ ។

## ធារាសាស្ត្រ

Hydrology: វិទ្យាសាស្ត្រសិក្សាអំពីទឹកនៅលើ នៅក្នុង និងនៅពីខាងលើតំបន់មួយនៃភពផែនដី រួមមាន របាយទឹក ការវិលចុះឡើង (Circulation) នៃទឹក លក្ខណៈរូបរូប និងគីមីនៃទឹក ព្រមទាំងប្រតិកម្មនៃបរិស្ថានជាមួយទឹកខ្លួនឯងផងដែរ ។

## ធនធាន

Resource

Resource exploitation: ការប្រើប្រាស់ ឬការធ្វើអាជីវកម្មធនធានធម្មជាតិមួយ ដែលលើសពីសមត្ថភាពនៃធនធាននោះក្នុងការបន្តពូជ ឬមានវត្តមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី ។

## នៃគុណភាព

Qualitative: ដែលជាការអធិប្បាយ ដែលមិនអាចរាប់បាន

## នៃបរិមាណ

Quantitative: ដែលអាចរាប់បាន ផ្អែកលើការរាប់ ការវាស់វែង ។

## និរន្តរភាព

Sustainable

Sustainable yield: បរិមាណនៃធនធានមួយជាកំណត់ ដែលអាចផលិតជាអចិន្ត្រៃយ៍ដោយចីរភាព ក្រោមវិធីសាស្ត្រគ្រប់គ្រងមួយ ( ដូចជា ការកំណត់អត្រាដកហូត ឬ ប្រមូលផលអោយស្មើគ្នាទៅនឹង អត្រាផលិតដោយធម្មជាតិ) ។ តួលេខនៃទិន្នផលដោយនិរន្តរភាព សំរាប់រយៈពេលវែងមួយ ( ឧទាហរណ៍ បរិមាណឈើដែលបានកាប់រំលំ) ដែលគេអាចជ្រើសរើស ដើម្បីអោយស្របគ្នាទៅនឹងការគ្រប់គ្រង ដែលបានកំណត់ទុកជាមុន និងគោលដៅនៃសង្គម ។

## បដិបក្ខភាព ភាពផ្ទុយគ្នា

(Antagonism): បាតុភូតដែលក្នុងនោះ កំរិតពុលនៃល្បាយធាតុគីមីមួយទាបជាងកំរិតពុល ដែលបានរំពឹងទុកចេញពីការបូកផ្សំនៃកំរិតពុលនៃធាតុគីមីនីមួយៗនៅក្នុងល្បាយនោះ ។



## បង់តូស

Benthos : បណ្តុំនៃសារពាង្គកាយមួយចំនួន ( រួមមានរុក្ខជាតិ និងសត្វ) រស់នៅក្នុង ឬលើកំណកដីល្បាប់នៃលំនៅដ្ឋានធម្មជាតិទឹក ។

## បណ្តុំជីវៈ

Bioaccumulation: ពាក្យទូទៅប្រើសំរាប់អធិប្បាយ អំពីដំណើការ ដែលតាមរយៈនោះធាតុគីមីទាំងឡាយ ត្រូវបានទាញយកដោយផ្ទាល់ពីទឹកដោយសារពាង្គកាយទឹក ។ របៀបនៃការទាញយកនេះ រួមមានការស៊ីចំណីអាហារ និងកំណកដីល្បាប់ដែលមានផ្ទុកធាតុគីមី ។

## ប្រសព្វគ្នា ( ទន្លេ)

Confluence: ចំណុចដែលនៅទីនោះ ចរន្តទឹកហូរនៃអាងទឹកលើដីពីរ (water bodies) ( ដូចជា ទន្លេស្ទឹង ឬផ្លូវទឹក តូចៗ) ជួបគ្នា ហើយហូររួមគ្នា ។

## ប្រភេទសត្វស៊ីសំណល់សរីរាង្គនៃសារពាង្គកាយនានា

Detrivore

Detrital feeders: ប្រភេទដែលចិញ្ចឹមជីវិតដោយស៊ីសរីរាង្គស្លាប់នៅស្រស់ ឬរលួយនៃរុក្ខជាតិ ឬសត្វ ។

## ប្រភេទត្រីនាំចូល

Exotic fish species: គឺជាប្រភេទត្រីទាំងឡាយដែលមិនមែនជាប្រភេទក្នុងស្រុក ហើយត្រូវបាននាំចូលពីខាងក្រៅ ឬពីក្រៅប្រទេស ។ ជួនកាលប្រភេទនាំចូលនេះ អាចប្រជែងរស់យ៉ាងជោគជ័យទៅលើប្រភេទក្នុងស្រុក ដោយសារវាធន់ទៅនឹងជំងឺផ្សេងៗ ( ឬកត្តាកំណត់ប្រជាសាស្ត្រផ្សេងៗ ទៀត " Population-limiting " ជាងប្រភេទក្នុងស្រុក ។

## បណ្ដាញអាហារ

Food web: គឺជាឱឡារក្រាមជាទស្សទាន ដែលតាងអោយទំនាក់ទំនងនៃការចិញ្ចឹមជីវិតរបស់សាពាង្គទាំងឡាយនៅក្នុងប្រព័ន្ធអេកូឡូស៊ីមួយ ។ វាផ្សំឡើងដោយសេរី ឬលំដាប់មួយចំនួននៃចង្វាក់អាហារដែលតភ្ជាប់គ្នាទៅវិញទៅមក ។

## បឹងវិទ្យា

Limnology: ការសិក្សាជាលក្ខណៈវិទ្យាសាស្ត្រនៃអាងស្តុកទឹកសាប ដូចជា បឹងជាដើម ។

## ប្រភេទ សមាសភាព

Species

Species composition: របាយនៃចំនួនប្រភេទ និងចំនួនឯកតៈ (individuals) នៃប្រភេទនីមួយៗ នៅក្នុងសហគមន៍មួយ ។

## ភាពសម្បូណ៍នៃប្រភេទ៏

Species richness: ចំនួននៃប្រភេទនៅក្នុងតំបន់មួយ ដោយមិនរាប់បញ្ចូលនូវរបាយរបស់វាឡើយ ។

## បំលែងកំរិតពុល

Transformation rate: អត្រាដែលធាតុគីមីធ្វើការបំលែងទ្រង់ទ្រាយនៅក្នុងតំបន់ដីសើម ។ ការឡើងចុះកំរិតកំពស់ទឹក និងការស្រូបយកជីជាតិ អាចជះឥទ្ធិពលទៅលើកំរិតបំលែងជាតិពុលនេះ ។

## ប្រព័ន្ធទឹកហូរ

Water budget

តុល្យភាពនៃទឹកដែលហូរចូល និងហូរចេញ នៅក្នុងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមមួយ ។

## ប៉ារ៉ាម៉ែត

Parameter: ការប្រែប្រួលផ្សេងៗ ការបញ្ជាក់ន័យ ឬលក្ខណៈរូបសាស្ត្រនៃការកំណត់ ការប្រែប្រួល ឬលក្ខណៈ ដែលត្រូវបានគេដាក់បញ្ចូលគ្នានូវលក្ខណៈ និងតួនាទីនៃប្រព័ន្ធអេកូឡូស៊ីមួយ ។ ជាទូទៅ Parameter មានលក្ខណៈអាចអោយគេវាស់បាន ដូចជា បរិមាណអុកស៊ីសែនរលាយក្នុងទឹកជាដើម ។

## អាងរងទឹកភ្លៀង

Catchment: គឺជាតំបន់ដែលពីទីនោះ ផ្លូវទឹកលើដី ឬប្រព័ន្ធទឹកក្រោមដី ទទួលទឹកពីប្រព័ន្ធបង្ហូរទឹក នៅក្នុងអាងនៃបឹង ឬស្ទឹង ទន្លេ ។ Catchment ប្រមូល និងបង្ហូរទឹកចេញតាមរយៈច្រកចេញ ឬមាត់មួយ ។ ព្រំប្រទល់នៃ catchment ជាទូទៅកំណត់ដោយខ្សែរយៈកំពស់ ឬ ឋានលេខានៃតំបន់ខ្ពស់ ។

## ពាម

Estuary: អាងស្តុកទឹកនៅតាមតំបន់ឆ្នេរសមុទ្រ ដែលអាចតភ្ជាប់ដោយផ្លូវទឹកមួយ ឬច្រើន ទៅនឹងសមុទ្រ ហើយដែលទីនោះទឹកសាប គឺបានមកពីប្រព័ន្ធបង្ហូរទឹកនៅលើដី (Land drainage) លាយឡំជាមួយនឹងទឹកប្រៃ ។ Estuaries ជាទូទៅតែងតែទទួលរងសកម្មភាពទឹកជោរ-នាច ហើយមានតំលៃខ្ពស់ ដែលជាថ្នាលប្រព័ន្ធអេកូឡូស៊ីមួយសំរាប់ជីវិតជាច្រើនប្រភេទ ដែលរស់នៅក្នុងទឹកសមុទ្រ ។

## ពពួកសត្វ

Fauna: សហគមន៍សត្វនៅក្នុងលំនៅដ្ឋានធម្មជាតិ ឬតំបន់ណាមួយ ។

## ពពួករុក្ខជាតិ

Flora: សហគមន៍រុក្ខជាតិនៅក្នុងតំបន់ ឬលំនៅដ្ឋានធម្មជាតិណាមួយ ។

## ភាវៈរស់

Biota: គ្រប់សាពាង្គកាយមានជីវិតទាំងអស់ (រុក្ខជាតិ សត្វ ផ្សិត និងមីក្រូសាពាង្គកាយទាំងឡាយ) ដែលមាននៅក្នុងតំបន់នីមួយៗ ។

### ភក់ ល្បាប់ម៉ដ្ឋ

Siltation (Sedimentation): ការធ្លាក់រងចុះ និងកកករគរលើគ្នានៃកំទេចកំទីដី ដែលបានទទួលការហូរច្រោះ ឬរេចរឹល នៅក្នុងទឹកព្រែកតូចៗ បឹង ទន្លេ ឬអាងស្តុកទឹកផ្សេងៗទៀត ។ បាតុភូត Siltation នៅក្នុងបរិស្ថាន ទឹក អាចមានផលប៉ះពាល់បរិស្ថានដ៏អាក្រក់ ដូចជា ការកាប់ដីបាតទឹកដែលជាកន្លែងត្រីពង ឬបង្កើនភាពល្អក់កករ (Turbidity) ដែលអាចប៉ះពាល់ដល់ការដកដង្ហើមនៃសាពាង្គកាយរស់នៅក្នុងទឹកទាំងឡាយ ។

### ភក់ សំណល់

Sludge: សមាសភាពនៃអង្គធាតុរឹង និងអង្គធាតុរាវ ដែលជាលទ្ធផលនៃដំណើរការប្រព្រឹត្តកម្មទឹកសំអុយ ដោយមិនបានទទួលរងនូវការធ្វើអោយខាប់ដោយប្រព្រឹត្តកម្មរូប ឬគីមី មុនពេលធ្វើប្រព្រឹត្តកម្មទឹកសំអុយ ។

### ភាពពុល

Toxicity: សក្តានុពលដែលមាននៅក្នុងសារធាតុជីវៈ ឬគីមីមួយ ក្នុងការបង្កឥទ្ធិពលអាក្រក់ទៅលើសាពាង្គកាយមានជីវិតនៅពេលដែលសាពាង្គកាយនោះ ត្រូវបានគេដាក់ដោយផ្ទាល់ទៅលើសារធាតុនោះ ។

ការធ្វើពិសោធន៍សាកល្បងកំរិតពុលអាចត្រូវបានគេប្រើប្រាស់ ដើម្បីវាស់ឥទ្ធិពល ប៉ះពាល់នៃសារធាតុមួយទៅលើក្រុមសាពាង្គកាយមួយប្រភេទ ដែលបានជ្រើសរើសនៅក្រោមលក្ខខណ្ឌកំណត់មួយ ។ ការធ្វើពិសោធន៍សាកល្បងកំរិតពុលនៅក្នុងទឹក ជាទូទៅអាចវាស់ a) សមាមាត្រនៃសាពាង្គកាយដែលទទួលរងឥទ្ធិពល ឬ b) កំរិតនៃឥទ្ធិពលជះ បន្ទាប់ពីការដាក់ដោយផ្ទាល់ទៅនឹងសារធាតុមួយជាកំណត់ ដែលគេធ្វើការសាកល្បង (ឧទាហរណ៍ សំណាកគំរូនៃកំណកដីល្បាប់ ឬកាកសំណល់រាវ) ។

### ភាពជ្រាបទឹក

Permeability: គឺជារង្វាស់មួយនៃភាពងាយស្រួលដែលជាមួយនោះឧស្ម័ន ឬវត្ថុរាវ អាចជ្រាប ឬឆ្លងកាត់ប្រហោងខ្យល់មួយចំនួននៃសារធាតុមួយ ។ នៅក្នុងដី Permeability នេះ ត្រូវបានគេកំណត់ដោយទំហំ របៀបតភ្ជាប់ (arrangement) និងសមាសភាពនៃគ្រាប់ដី (Soil particles) និងដោយកំរិតនៃភាពហាប់នៃដី ។

### ភ្លៀងអាស៊ីដ

Acid rain: ទឹកភ្លៀងដែលមាន pH ទាបជាង ៥,៦ ។ កំរិតកើនឡើងនៃជាតិអាស៊ីដអាចបង្កឡើងដោយធម្មជាតិ (ដូចជា ដោយសារការបញ្ចេញឧស្ម័ននៅក្នុងពេលមានបន្ទុះភ្នំភ្លើង) ឬដោយ ការរំខានដោយមនុស្ស (ដូចជា ចំហេះឥណ្ឌនៈ ឬធាតុឆេះផ្សេងៗ....) ។

### មំសាសី

Carnivore: សត្វទាំងឡាយ ដែលស៊ីតែសាច់សត្វផ្សេងៗទៀត (មាំង្សាសត្វ) ។

### មហន្តរាយ

Catatrophe

Catastrophic: ការប៉ះពាល់ ឬការរំខានធ្ងន់ធ្ងរ ដែលកើតមានភ្លាមៗ និងវិសាមញ្ញ (មានកំរិតខ្ពស់កើតឡើងមិនញឹកញាប់ ឬយូរៗម្តង “Low frequency” ។

### មេតាបូលីស

Metabolism: រាល់ដំណើរការគីមីទាំងអស់ ដែលកើតឡើងនៅក្នុងសាពាង្គកាយទាំងដំណើរការធ្វើសំយោគ និងបំបែកសារធាតុសរីរាង្គ រួមមាន ការរំលាយអាហារជាដើម ។

## រំហួតចំហាយទឹក

Evapotranspiration: គឺជាចលនានៃទឹកពីដី ឬរុក្ខជាតិនីមួយៗ និងសហគមន៍រុក្ខជាតិ (Plent commumities) ទៅក្នុងបរិយាកាសតាមរយៈ ការបំភាយជាចំហាយ (Evaporation) នៃទឹកពីដី និងការបំភាយនៃទឹកតាមរយៈដំណើររស្មីសំយោគ (Transpiration) ដោយរុក្ខជាតិ ។

## រ៉ាមសារ

Ramsar: អនុសញ្ញាស្ដីអំពី តំបន់ដីសើម ដែលបាន ចុះហត្ថលេខានៅ Ramsar ប្រទេសអៀរ៉ង់ ក្នុងឆ្នាំ ១៩៧១ គឺជាសន្ធិសញ្ញាអន្តរជាតិ ដែលផ្តល់ក្របខណ្ឌ សំរាប់សកម្មភាពថ្នាក់ជាតិ និង កិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ ក្នុងការអនុវត្តអនុសញ្ញា និងការ ប្រើប្រាស់ដ៏សមស្របចំពោះតំបន់ដីសើម និងធនធាន របស់វា ។ រហូតមកទល់បច្ចុប្បន្ននេះ ឈ្មោះនៃអនុសញ្ញានេះ ត្រូវបានគេសរសេរថា អនុសញ្ញា ស្តីពី តំបន់ដីសើម "(Convention on wetlands (Ramsar, Iran, 1971) " ដែលត្រូវបានគេស្គាល់ និងនិយមប្រើប្រាស់ជាអនុសញ្ញា Ramsar "Ramsar Convention" ។ បច្ចុប្បន្ននេះ អនុសញ្ញានេះ មានភាគីចុះកិច្ចសន្យាចំនួន ១២៨ ដែលមានតំបន់ដីសើមចំនួន ១០៩០កន្លែង មានផ្ទៃដីសរុប ៨២.៤ លាន ហិកតា ដែលត្រូវបានគេកំណត់ នៅក្នុងតារាងតំបន់ដីសើម ដែលមានសារៈសំខាន់ ថ្នាក់អន្តរជាតិ Ramsar (Ramsar List of Wetland of International Importance) ។

## រស្មីសំយោគ

Photosynthesis: គឺជាដំណើរការដែលតាមរយៈ នោះ រុក្ខជាតិធ្វើការបំលែង $CO_2$ និង $H_2O$ ទៅជា កាបូអ៊ីដ្រាត (Carbohydrates) និងសមាធាតុ ផ្សេងៗទៀត ដោយប្រើប្រាស់ជាថាមពលពីព្រះ អាទិត្យ



## រំភាយចំហាយទឹក

Plant transpiration: ការបាត់បង់ចំហាយទឹកពី រុក្ខជាតិទៅក្នុងបរិយាកាស ។

## ល្បាប់

Alluvium

Alluvial deposits:

កំទេចកំទីដែលហូរនាំមកដោយ ស្ទឹង ទន្លេ ឬផ្លូវទឹក ផ្សេងៗ ហើយរងធ្លាក់ចុះបង្កើតបានជា ទំនាបលិច ទឹកនៅជាប់នឹងទន្លេ ឬផ្លូវទឹកទាំងនោះ ។

## លំនឹង តុល្យភាព

Equilibrium: គឺជាប្រព័ន្ធមួយដែលស្ថិតក្នុងភាព លំនឹង ឬស្ថេរភាពជាមួយនឹងធនធាន និងលទ្ធផល (inputs and outputs matching) ។ លក្ខខ័ណ្ឌ នៃភាពនឹងថ្កល់ ឬប្រែប្រួលតិច (Conditions of stasis) ។

## លំនៅឋាន ជំរក

Habitat: ការប្រែប្រួល ឬការបែកបាក់ខូចខាតនៃ លំនៅដ្ឋានធម្មជាតិ ទៅលើជាកោះដាច់ៗពីគ្នា ។

### លំហោស ភាពស្ពោត

Porosity: ភាពដែលអាចជ្រាបអង្គធាតុរាវ ឬឧស្ម័ននៃសារធាតុមួយ ហើយដែលបានឆ្លុះបញ្ចាំង ឬគិតជាមាឌនៃលំហ ដែលបំពេញប្រហោងចន្លោះរវាងគ្រាប់ដី (Soil particles)

### លីពីត

Lipid: ម៉ូលេគុលខ្លាញ់ ឬប្រេង

### វិភាគ

Analyse: ផ្នែកណាមួយជាកំណត់ដែលត្រូវបានវាស់វែងនៅក្នុងការវិភាគគីមី ។ គឺអ្វីដែលត្រូវបានគេកត់សំគាល់ និងកំណត់បរិមាណនៅក្នុងដំណើរការវិភាគសំណាកគំរូ (sample) ។

### វិនីទ្រីកម្ម

Denitrification: ការបាត់បង់អាសូតតាមរយៈការបំលែងរបស់វាផលិតផលឧស្ម័ន (ដែលសំខាន់ជាងគេនោះ គឺម៉ូលេគុល អាសូត " N " និងអាសូតអុកស៊ីត " $N_2O$ ") ។ ដំណើរការនេះ គឺធ្វើឡើងដោយពពួកមីក្រូសាពង្គកាយ (បាក់តេរី) នៅក្នុងលក្ខខណ្ឌបរិស្ថានមួយ ដែលគ្មានអុកស៊ីសែន ។



PHOTO: L&L

សកម្មភាពដាំដើមឈើ

### សហគមន៍

Community: ក្នុងន័យអេកូឡូស៊ី គឺជាសាពង្គកាយមានជីវិតទាំងឡាយនៃប្រព័ន្ធអេកូឡូស៊ីពិសេសមួយ ពោលគឺ ជាពិភពរុក្ខជាតិ សត្វ ផ្សិត និងមីក្រូសាពង្គកាយ ។

### សារធាតុបំពុល

Contaminant

Contaminant sink: គឺជាប្រព័ន្ធមួយ (ឧទាហរណ៍ តំបន់ដីសើមមួយ) ដែលត្រូវបានគេប្រើប្រាស់ជាអាងស្តុកទុកទាំងស្រុងនូវសារធាតុកខ្វក់ (Contaminants) ណាមួយជាកំណត់ ។ ឬដោយប្រើពាក្យម៉្យាងទៀត ធាតុគីមីដែលបង្ហូរចូលប្រព័ន្ធនេះមានបរិមាណដ៏ច្រើនលើសលប់ បើប្រៀបទៅនឹងបរិមាណធាតុគីមីដែលបង្ហូរចេញ ។

### ស៊ីតូប្លាស

Cytoplasm: ផ្នែកផ្សំ ដែលមានជីវិតនៃកោសិកា ក្រៅពីនុយក្លេអ៊ែរ ។

### ស្ថានប្រព័ន្ធ

Ecosystem: គឺជាក្រុមមួយប្រព័ន្ធមានជីវិត និងគ្មានជីវិត ដែលមានអន្តរអំពើទៅលើគ្នាទៅវិញទៅមក បង្កើតបានជាប្រព័ន្ធមួយមានស្ថេរភាព ។ តាមទស្សនៈទានជាមូលដ្ឋាននោះគឺ រាប់បញ្ចូលនូវទឹក និងវដ្តនៃជីជាតិ ចរន្តនៃថាមពលតាមរយៈចង្វាក់អាហារ និងបណ្តាញអាហារ (Food webs) ។ ជាទូទៅប្រព័ន្ធអេកូឡូស៊ី (Ecosystem) មួយគឺជាប្រព័ន្ធនៃដំណើរការថាមពល និងការបង្កើនជីជាតិ ដែលផ្នែកនីមួយៗរបស់វាពាក់ព័ន្ធទៅនឹងរយៈពេលមួយដ៏វែង ។ គោលការណ៍នៃប្រព័ន្ធអេកូឡូស៊ីអាចត្រូវបានគេយកទៅអនុវត្តនៅគ្រប់កំរិតទាំងអស់ ពីត្រពាំងនីមួយៗរហូតដល់បឹង សមុទ្រ និងផែនដីទាំងមូល ។

### សេនេទិច

Genetic

Gene pool: គឺជា សែនសរុបទាំងអស់នៃសត្វ ឬរុក្ខជាតិបង្កាត់នីមួយៗនៅក្នុងប្រជាសាស្ត្រ (Population) នៅក្នុងពេលតែមួយ ។

### សំរាម

Litter

Litter production: ការប្រមូលផ្តុំដោយធម្មជាតិនៃស្រទាប់លើដីក្នុងតំបន់ព្រៃឈើ ។ សំរាមផ្សំឡើងពីសារធាតុសរីរាង្គដែលមិនទាន់បែកធាតុក្នុងទំរង់ជាចំណែកនៃដីស្រទាប់លើ ( ស្លឹក មែកតូច ដែលបានធ្លាក់ចុះពីគំរបស្លឹកនៃដើមឈើ) ។ សំរាមគឺជាប្រភពដំបូងបង្អស់នៃសារធាតុសរីរាង្គចំពោះដីព្រៃឈើ ។

### សារធាតុចិញ្ចឹម

Nutrient

### សារធាតុចិញ្ចឹមសរីរាង្គ

Nutrient budget: ការពិពណ៌នាមួយ អំពីបរិមាណដែលបានដាក់ បាត់បង់ និងបរិមាណដ៏រ ដូចជា ផូស្វ័រ កាបូន អាសូត ដែលវិលវល់ ឬចូលទៅក្នុងប្រព័ន្ធអេកូឡូស៊ីមួយ ។

### សារធាតុចិញ្ចឹមបន្ត

Nutrient cycling: គន្លងផ្លូវធរណី ជីវៈ គីមី នៃជីជាតិជីវៈសំខាន់ ដូចជា កាបូន អាសូត និងអុកស៊ីសែននៅក្នុងមណ្ឌលជីវៈ ។ គន្លងផ្លូវ ឬផ្លូវឆ្លងកាត់នេះរួមមាន ការស្រូបយកជីជាតិ ការបំលែងជីជាតិ

ការប្រើប្រាស់ជីជាតិ និងការបញ្ចេញចោល ដោយសារពាង្គកាយ “A “ ហើយបន្ទាប់មក បញ្ជូនទៅ និងស្រូបយកដោយសារពាង្គកាយ “B “ ។

### សត្វរំពា

Predator

Predatory: សត្វដែលពោង សំលាប់ និងស៊ីសត្វផ្សេងៗទៀត

### សំយោគ

Synthesis

Synthesize: ការផ្សំគ្នានូវធាតុផ្សំនីមួយៗ អោយទៅជាសមាសធាតុមួយ (A unified whole) ។ ជាពិសេស គឺដំណើរការនៃការចងសម្ព័ន្ធសមាសធាតុគីមីពីសារធាតុ ដែលផ្សំឡើងដោយប្រតិកម្មគីមីមួយ ឬច្រើន ។

### សំណល់រាវបង្ហូរចេញ

Effluent: គឺជាកាកសំណល់ដ៏ស្មុគស្មាញមួយ ( ដូចជា កាកសំណល់រាវចេញពីរោងចក្រឧស្សាហកម្ម ឬទឹកសំអុយ) ដែលអាចត្រូវបានគេទាត់ចោលទៅក្នុងបរិស្ថាន ។

### សមត្ថភាពការងារ

Energy: សមត្ថភាពក្នុងការបំពេញការងារ ។

### អាងស្តុកទឹក ( បាសាំង)

Basin: តំបន់ទំនាបដែលគ្មាន ឬមានច្រកបង្ហូរចេញតិចតួចបំផុត សំរាប់ទឹកលើដី ឧទាហរណ៍ រួមមាន អាង បឹង ឬទន្លេណាមួយ ។

### អឺត្រូភីកាស្យុង

Eutrophication: គឺជាជីជាតិធម្មជាតិ ឬជារឿយៗជាការបង្កដោយមនុស្ស ទៅក្នុងអាងស្តុកទឹក ដែលបណ្តាលអោយមានអត្រាផលិតកម្មសារធាតុសរីរាង្គខ្ពស់ ។ Eutrophication បង្កើតអោយមានឥទ្ធិពលប៉ះពាល់ផ្សេងៗទៀត (side effects) ជាច្រើនដែលគេមិនបានរំពឹងទុកជាមុន រួមមាន

បន្ទុំនៃពពួកស្លែ ដែលមានការលូតលាស់ខ្លាំង (Alqal blooms) កើតអុកស៊ីសែន ទាបទៅតាមរដូវ និងបន្ថយការរស់នៅនៃត្រី និងពពួកសត្វឥតឆ្អឹងកងរស់នៅក្នុងទឹកផ្សេងៗទៀត ។

### អ្នកកាត់បន្ថយ

Reductionist: ទ្រឹស្តីមួយដែលគ្រប់ប្រព័ន្ធស្មុគ្រស្មាញទាំងអស់ អាចត្រូវបានគេយល់យ៉ាងច្បាស់នូវផ្នែកទាំងឡាយរបស់វា ។ ឬម្យ៉ាងទៀត ការរុករក ឬស្វែងរក ដើម្បីធ្វើការកាត់បន្ថយទិន្នន័យ ឬបាតុភូតដែលមានលក្ខណៈស្មុគស្មាញអោយក្លាយទៅជាលក្ខខណ្ឌមួយ ដែលមានភាពងាយយល់ (Simple terms) ។

### អាចកើតឡើងវិញ

Renewable: ធនធានជីវៈទាំងឡាយ ដែលមានសមត្ថភាពអាចកើតឡើងជាថ្មីវិញ ដោយគ្មានកំណត់ (នៅក្នុងកំឡុងពេលមួយនៃមនុស្សមួយជំនាន់ៗ) ដោយសន្មតថា មានការអនុញ្ញាត ឬ ទទួលយកលើបញ្ហានេះ ពីសំណាក់កំលាំងទូទៅនៃបរិស្ថានសង្គម និងនយោបាយ ។

Dichlorodiphenel: ផលិតផលមួយដែលបានមកពីការបែកធាតុដោយធម្មជាតិនៃ DDT ។

di-chloroethylene (DDE)

### ឌីអុកស៊ីន

Dioxin: ក្រុមមួយនៃធាតុគីមី ដែលមានចំនួនប្រហែល ៧៥ ប្រភេទនៃគ្រួសារ ក្លរីលោភីតឌីបង់សូឌីអុកស៊ីន (Chlorinated debenzodioxin famity) ។ សារធាតុ ២, ៣, ៧, ៨-TCDD គឺត្រូវបានគេចាត់ទុកថាជាទំរង់ដែលមានកំរិតពុលខ្លាំងជាងគេបំផុត ។ គឺជា ផ្នែកទូទៅមួយនៃកាកសំណល់រាវចេញពីរោងចក្រផលិតម្សៅប្រដាស ។

### ឧស្ម័នផ្ទះកញ្ចក់

Greenhouse gases: ឧស្ម័នសំគាល់ (Trace gases) មួយចំនួននៅក្នុងបរិយាកាស ដែលរក្សាសីតុណ្ហភាពភពផែនដីអោយនៅកំរិតមធ្យម ដែលយើងមានសព្វថ្ងៃនេះ ។ ឧស្ម័នទាំងនេះត្រូវបានគេហៅថា “greenhouse gases “ ហើយប្រភេទសំខាន់ជាងគេដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសកម្មភាពរបស់មនុស្ស គឺឧស្ម័នកាបូនិច មេតាន អាសូតអុកស៊ីត និង CFCs-Chlorinated fluorocarbons ដូចជា Freon ។ បរិមាណនៃឧស្ម័នផ្ទះកញ្ចក់ គឺជាលំនឹង ឬតុល្យភាពមួយរវាងអ្វីដែលបញ្ជាក់ថា តើក្នុងល្បឿនលឿនប៉ុណ្ណា ដែលឧស្ម័ននេះ ត្រូវបានបញ្ចេញទៅក្នុងបរិយាកាស (ប្រភព) និងអ្វីដែលបញ្ជាក់ថា តើវាបាត់បង់ទៅវិញនៅក្នុងល្បឿនលឿនកំរិតណាដែរ ។ យើងទាំងអស់គ្នា កំពុងចាប់អារម្មណ៍អំពី អ្វីដែលថាតើសកម្មភាពរបស់មនុស្សអ្វីខ្លះដែលកំពុងធ្វើអោយប្រែប្រួលកំរិតកើតឡើងដោយធម្មជាតិនៃឧស្ម័នកាបូនិច និងមេតាន ។

Phreactic zone: ស្រទាប់ក្រោមផ្ទៃលើ ដែលក្នុងនោះរាល់សត្វឥតឆ្អឹងកងទាំងអស់ ត្រូវបានបំពេញដោយទឹក ដែលមានសំពាធធំជាងសំពាធបរិយាកាស ។ ក្នុងសិលាផ្សេងៗ កំរិតនៃភាពស្ពោតជះឥទ្ធិពលលើលទ្ធភាពនៃឧស្ម័ន ឬអង្គធាតុរាវ ធ្វើចលនាឆ្លងកាត់សិលា ឬដី ។

Taxa richness: ចំនួននៃថ្នាក់នីមួយៗ (Individual taxa) ដែលបានប្រមូលនៅស្ថានីយ៍ស្រង់សំណាកគំរូ (Sampling station) ។ តួលេខនេះ អាចជាតំណាងនៃសម្បូណ្ណភាពមធ្យមមួយ (Amean richness) ឬសម្បូណ្ណភាពនៃក្រុម ឬសហគមន៍មួយ (A pooled rechness) ។

# ២១

# អក្សរកាត់



# អក្សរកាត់

ACAPE អង្គការ ACAPE ( Association Cambodgienne d'Approvisionnement en Eau)

ACCB មជ្ឈមណ្ឌលអង្គរ សំរាប់ការអភិរក្សជីវៈចំរុះ (Angkor Center for the Conservation of Biodiversity)

ADB ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)

AEAM ការគ្រប់គ្រង និង វាយតំលៃការប្រែប្រួលបរិស្ថាន (Adaptive Environmental Assessment and Management)

AJA សមាគម AJL (Association de la Jeunesse pour l'Animation)

ATT អាងត្រពាំងធំ (Ang Trapeang Thom)

AOX អាឡូសែនសរីរាង្គដែលស្រូបយកបាន (Adsorbable Organic Halogens)

APDO អង្គការចូលរួមអភិវឌ្ឍន៍អង្គរ (Angkor Participatory Development Organization)

AWC អង្គការជំរឿនបក្សីទឹកអាស៊ី (Asian Waterfowl Census)

BC ការប្រមូលផ្តុំគំរុយ (Benchmark Concentration)

BDP ផែនការអភិវឌ្ឍន៍អាងស្តុក (Basin Development Plan)

BFD អង្គការព្រះពុទ្ធសាសនា សំរាប់អភិវឌ្ឍន៍ (Buddhism for Development)

BFDKT អង្គការព្រះពុទ្ធសាសនា សំរាប់អភិវឌ្ឍន៍ខេត្តកំពង់ធំ (Buddhism for Development Kompong Thom)

BOD តំរូវការ អុកស៊ីសែនជីវៈ (Biological Oxygen Demand)

CEA ការវាយតំលៃឥទ្ធិពលកើនឡើង (Cumulative Effects Assessment)

CEARC ក្រុមប្រឹក្សាស្រាវជ្រាវវាយតំលៃបរិស្ថាននៃប្រទេសកាណាដា (Canadian Environmental Assessment Research Council)

CED សហគមន៍អភិវឌ្ឍន៍សេដ្ឋកិច្ច (Community Economic Development)

CEIA ការវាយតំលៃហេតុប៉ះពាល់បរិស្ថានកើនឡើង (Cumulative Environmental Impact Assessment)

CEQ ក្រុមប្រឹក្សា គុណភាពបរិស្ថាន (សហរដ្ឋអាមេរិក) (Council on Environmental Quality "United States of America")

CEPA សមាគមអភិរក្សបរិស្ថាន និងវប្បធម៌ (Culture and Environment Preservation Association)

CFDS សេវាកម្មអភិវឌ្ឍន៍គ្រួសារកម្ពុជា (Cambodian Family Development Services)

CITES អនុសញ្ញាស្តីពី ការធ្វើពាណិជ្ជកម្មអន្តរជាតិចំពោះប្រភេទសត្វ និង រុក្ខជាតិ ជិតផុតពូជ (Convention on International Trade in Endangered Species of Wild Fauna and Flora)

CLEC មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ (Community Legal Education Centre)

CNMC គណៈកម្មាធិការជាតិទន្លេមេគង្គ កម្ពុជា (Cambodian National Mekong Committee)

CSARO អង្គការសហគមន៍កែច្នៃ និងអនាម័យសហគមន៍ " ស្ការ៉ូ " (Community Sanitation and Recycling Organization)

DAC សមាគមអភិវឌ្ឍន៍កម្ពុជា (Development Association of Cambodia)

DOF រដ្ឋបាលជលផល (Department of Fisheries)

DPKS កម្មវិធីអភិវឌ្ឍនសិស្ស និស្សិតខ្មែរ (Development Program for Khmer Students)

EA ការវាយតំលៃបរិស្ថាន (Environmental Assessment)

EC/SPEC អង្គការ SPEC/EC (European Commission Support for the Environment Sector in Cambodia)

EE ការអប់រំបរិស្ថាន (Environmental Education)

EP កម្មវិធីបរិស្ថាន (Environment Program)

C50 ការប្រមូលផ្តុំឥទ្ធិពល (សំរាប់ ៥០% សារពាង្គកាយដែលធ្វើពិសោធន៍) (Effect Concentration "for 50% of the test organisms")

EEC ការប្រមូលផ្តុំបរិស្ថានដែលរំពឹងទុក (Expected Environmental Concentration)

EEM ការតាមដានប្រសិទ្ធភាពបរិស្ថាន (Environmental Effects Monitoring )

EES សេចក្តីថ្លែងការណ៍ពីឥទ្ធិពលបរិស្ថាន (Environmental Effects Statement)

EIA ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (Environmental Impact Assessment)

EIED សេចក្តីសំរេចនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (តាមរយៈ OEPP ប្រទេសថៃ) Environmental Impact Evaluation Decision (through OEPP , Thailand)

EIS សេចក្តីថ្លែងការផលប៉ះពាល់បរិស្ថាន (Environmental Impact Statement)

EMS ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (Environmental Management System)

EPDO អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (Environment Protection and Development Organization)

ETP កម្មវិធីបណ្តុះបណ្តាលបរិស្ថាន (Environment Training Program)

EPT សន្ទស្សន៍ អេម៉ុបផ្ទែរ៉ា,ផ្លេកុបផ្ទែរ៉ា,ទ្រីកុបផ្ទែរ៉ា (Ephemoptera, Plecoptera, Tricoptera Index)

ERA ការវាយតំលៃគ្រោះថ្នាក់បរិស្ថាន (Ecological Risk Assessment)

FACT សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (Fisheries Action Coalition Team)

FAO អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ (Food and Agriculture Organization)

FCC អង្គការអនាគតកុមារកម្ពុជា (Future for Cambodian Children)

FIMC គណៈកម្មាធិការគ្រប់គ្រងវិនិយោគទុនបរទេស (រដ្ឋាភិបាលឡាវ)

(Foreign Investment Management Committee "Government of Lao PDR")

FP កម្មវិធីជលផល (Fisheries Program)

GECKO ការិយាល័យបរិស្ថាន ចុងឃ្នៀស (Great Environment Chhong Kneas Office)

GEF ស្ថានភាពបរិស្ថានទាំងមូល GEF (Global Environment Facility)

GIS ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (geogrpahic information system)

GNP ផលទុនជាតិ (Gross National Product)

GPS ស្ថានភាពប្រព័ន្ធទាំងមូល GPS (global positioning system)

HQ ផលចែកសារធាតុពុល (Hazard Quotient)

IAA ភ្នាក់ងារជំនួយអន្តរជាតិ (International Assisting Agency)

ICF អង្គការមូលនិធិអភិរក្សសត្វក្រៀលអន្តរជាតិ ICF (international Crane Foundation)

IEE ការត្រួតពិនិត្យបរិស្ថានដំបូង (Initial Environmental Examination)

IFReDI វិទ្យាស្ថានអភិវឌ្ឍន៍ និងស្រាវជ្រាវជលផលទឹកសាប (Inland Fisheries Research and Development Institute)

IJF មូលនិធិសារព័ត៌មានឯករាជ្យ (Independent Journalism Foundation)

IMWG ក្រុមការងារអន្តរៈក្រសួង (រដ្ឋាភិបាលឡាវ) (Inter-Ministerial Working Group "Government of Lao PDR")

IUCN សហភាពអន្តរជាតិសំរាប់ការអភិរក្សធនធានធម្មជាតិ (International Union For Conservation of Nature And Natural Resources)

Koc មេគុណអុកតាណុល-ទឹក (Water-Octanol Coefficient)

ISO អង្គការអន្តរជាតិសំរាប់រៀបចំស្តង់ដា (International Organization for Standardization Designation)

JICA ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency)

PNKA សមាគមភ្នំនាងកង្រី (Phnom Neang Kangrei Association)

Lao PDR សាធារណៈរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ (Lao People's Democratic Republic)

LC50 ការប្រមូលផ្តុំសារពាង្គកាយស្លាប់(គិតយក ៥០%នៃសារពាង្គកាយដែលធ្វើពិសោធន៍) (Lethal Concentration (for 50% of the test organisms))

LEP ច្បាប់ស្តីពីការការពារបរិស្ថាន (វៀតណាម) (Law on Environmental Protection "Vietnam")

LMB អាងទន្លេមេគង្គខាងក្រោម (Lower Mekong Basin)

LLEE អង្គការ ការអប់រំស្តីពី ការរស់នៅជាមួយបរិស្ថាន (Live and Learn Environmental Education)

LNMC គណៈកម្មាធិការជាតិមេគង្គ ឡាវ (Lao National Mekong Committee)

LOEC ការប្រមូលផ្តុំប្រសិទ្ធភាពតាមការអង្កេតទាបបំផុត (Lowest Observable Effects Concentration)

MAFF ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture Forestry and Fisheries)



សកម្មភាពដាំដើមឈើ

MDGs គោលដៅអភិវឌ្ឍន៍សហសវត្ស (Millennium Development Goals)

MOEYS ក្រសួងអប់រំ យុវជន និងកីឡា (Ministry of Education,Youth and Sport)

MOE ក្រសួងបរិស្ថាន (Ministry of Environment)

MOP ក្រសួងផែនការ (Ministry of Planning)

MOSTE ក្រសួងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន (វៀតណាម និង ថៃ) Ministry of Science, Technology and Environment (Thailand and Vietnam)

MOU អនុស្សរណៈនៃការយោគយល់ (Memorandum of Understanding)

MOWRAM ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resources and Meteorology)

MRB អាងទន្លេមេគង្គ (Mekong River Basin)

MRC គណៈកម្មការទន្លេមេគង្គ (Mekong River Commission)

MRCS លេខាធិការដ្ឋាននៃគណៈកម្មាធិការទន្លេមេគង្គ (Mekong River Commission Secretariat)

NEAP ផែនការសកម្មភាពបរិស្ថានជាតិកម្ពុជា (National Environment Action Plan "Cambodia")

NEEAC យុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ (National Environmental Education and Awareness Campaign)

NEPA នយោបាយបរិស្ថានជាតិ (សហរដ្ឋអាមេរិក) (National Environment Policy "United States of America")

NEQA ការអភិរក្សនិងកែលំអសេចក្ដីសំរេចពីគុណភាពបរិស្ថានជាតិ (ប្រទេសថៃ) (Enhancement and Conservation of the National Environmental Quality Act "Thailand")

NGO អង្គការមិនមែនរដ្ឋាភិបាល
(Non Government Organization)

NRM គ្រប់គ្រងធនធានធម្មជាតិ
(Natural Resource Management)

NOEC ការប្រមូលផ្តុំប្រសិទ្ធភាពមិនបានអង្កេត
(No Observable Effects Concentration)

OEPP ការិយាល័យនយោបាយ និងផែនការ
បរិស្ថាន (ប្រទេសថៃ)

(Office of Environmental Policy and
Planning "Thailand")

PDA សកម្មភាពសាកល្បងរយៈខ្លី
(Pilot and Demonstration Activity)

PDE មន្ទីរបរិស្ថានខេត្ត
(Provincial Department of Environment)

PIO ការិយាល័យអនុវត្តន៍គំរោង
(project implementation office)

PIU អង្គភាព រឺ ផ្នែកអនុវត្តន៍គំរោង
(project implementation unit)

PPPs នយោបាយ ផែនការ និងកម្មវិធី
(Policies, Plans and Programs)


សំបុកឃ្មុំពីត្រឡោកដូង

PRC សាធារណរដ្ឋប្រជាមានិតចិន
(People's Republic of China)

RAP ការវាយតំលៃនៃការយល់ដឹង
(Rapid Assessment of Perceptions)

RCEDO អង្គការ អភិវឌ្ឍន៍បរិស្ថានសហគមន៍
ជនបទ (Rural Community Environment
Development Organization)

RRFAs សកម្មភាពអនាគតដែលប្រមើលទុកជា
មុនតាមហេតុផល (Reasonably Foreseeable
Future Actions)

RUPP សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
(Royal University of Phnom Penh)

SEA ការវាយតំលៃយុទ្ធសាស្រ្តបរិស្ថាន
(Strategic Environmental Assessment)

SEA សមាគមសេវាកម្មសមណៈគ្មានព្រំដែន
(Samanak Service Endlessness
Association)

SEIs ផលប៉ះពាល់បរិស្ថានសំខាន់ (Significant
Environmental Impacts)

SIPAR អង្គការ ស៊ីប៉ា (Soutien a l'Iniative
Pour l'Aide a la Reconstruction)

SoE សកម្មភាពបរិស្ថាន (State of the
Environment)

SPEC អង្គការគាំទ្រផ្នែកបរិស្ថាននៅកម្ពុជា
សហគមន៍អឺរ៉ុប (European Commission
Support for the Environment Sector in
Cambodia)

SSP ស្រ្តីសន្តិភាព ដើម្បីបរិស្ថាន (Strey
Santepheap Deiombeiy Parethan)

STEA ទីភ្នាក់ងារវិទ្យាសាស្រ្ត បច្ចេកវិទ្យា និង
បរិស្ថាន (ឡាវ) (Science, Technology and

Environment Agency “Lao PDR”)

TCH អង្គភាពសំរបសំរួលបច្ចេកទេស (Technical Coordination Unit)

TNMC គណៈកម្មាធិការជាតិទន្លេមេគង្គថៃ (Thai National Mekong Committee)

TOC កាបោនសរីរាង្គសរុប (Total Organic Carbon)

TOR ឯកសារយោង (Terms of Reference)

TSBR ជីវមណ្ឌលបឹងទន្លេសាប (Tonle Sap Biosphere Reserve)

TSBR លេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាប (Tonle Sap Biosphere Reserve Secretariat)

TSBS យុទ្ធសាស្ត្រអាងបឹងទន្លេសាប (Tonle Sap Basin Strategy)

TSCP គំរោងអភិរក្សបឹងទន្លេសាប (Tonle Sap Conservation Project)

TSEMP គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (Tonle Sap Environmental Management Project)

TSI កំរងគំរោងបឹងទន្លេសាប (Tonle Sap Initiative)

TSS សារធាតុកករអណ្តែតសរុប /សារធាតុកករវិលវិលវល់ (Total Suspended Solids)

UNDP អង្គការ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Program)

UNEP អង្គការ កម្មវិធីបរិស្ថានសហប្រជាជាតិ (United Nations Environment Program)

UNESCO អង្គការ សហប្រជាតិសំរាប់អប់រំ វិទ្យាសស្ត្រ និងវប្បធម៌ ” យូណេស្កូ ” (United Nations Educational, Scientific and Cultural Organisation)

UNICEF អង្គការ មូនិធិកុមាររបស់អង្គការសហប្រជាជាតិ (United Nations Children’s Fund)

USEPA ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក (United States Environmental Protection Agency)

VECs សមាសភាគប្រព័ន្ធបរិស្ថាន និងបរិស្ថានដែលបានវាយតំលៃ (Valued Environmental / Ecosystem Components)

VNMC គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម (Vietnam National Mekong Committee)

VSG ក្រុមគាំទ្រភូមិ (Village Support Group)

WAP កម្មវិធីយល់ដឹងពីបញ្ហាទឹក (Water Awareness Programme)

WCS អង្គការអភិរក្សសត្វព្រៃ (Wildlife Conservation Society)

WEC អង្គការអប់រំពិភពលោក កម្ពុជា (World Education Cambodia)

WFC មជ្ឈមណ្ឌលជលផលពិភពលោក (World Fish Center)

WHO អង្គការសុខភាពពិភពលោក (World Health Organization)

WPO ការិយាល័យការពារសត្វព្រៃ (Wildlife Protection Office)

WUP កម្មវិធីប្រើប្រាស់ទឹក (Water Utilisation Program)

WWF អង្គការ មូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិ (World Wide Fund for Nature)

# ២២

# បញ្ជីឈ្មោះ និង
# អាស័យដ្ឋានរបស់ស្ថាប័ន



# បញ្ជីឈ្មោះ និង អាស័យដ្ឋានរបស់ស្ថាប័ន

ខាងក្រោមនេះ ជាតារាងឈ្មោះស្ថាប័នរដ្ឋាភិបាល ភ្នាក់ងារពហុភាគី អ្នកផ្តល់ជំនួទ្វេរភាគី និង អង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធជាមួយការអប់រំបរិស្ថាននៅកម្ពុជា ។ តារាងនេះមានដាក់បញ្ចូលនូវព័ត៌មានពីគណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា (CCC) ។

## អង្គការ ចូលរួមអភិវក្សអង្គរ APDO (Angkor Participatory Development Organization) ខេត្តសៀមរាប

អង្គការ APDO បានបង្កើតឡើងដោយអតីតអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិនៅឆ្នាំ ២000 ដោយមាន ពាក់ព័ន្ធជាមួយសកម្មភាពសហគមន៏នៅជុំវិញអង្គរ ។ គំរោងរបស់អង្គការនេះគឺសំរាប់អភិវឌ្ឍន៏ធនធានមនុស្សប្រកបដោយចេរភាពក្នុងគោលបំណងពង្រឹងសមត្ថភាពជនបទដើម្បីកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ភូមិនូវការជឿទុកចិត្តលើខ្លួនឯង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម វប្បធមិ និងបរិស្ថាន ។

លោក តឹក សាកាន សារុធ
នាយកអង្គការ
E-Mail: adpo@camintel.com
Web: www.adpoangkor
# 0៦៣0 ក្រុម១២ ភូមិវត្តបូរ ឃុំសាលាកំរើក
ខេត្តសៀមរាប

## អង្គការ ACAPE (Association Cambodgienne d’Approvisionnment en Eau) ភ្នំពេញ

អង្គការ ACAPE បានអនុវត្តគំរោងទឹកស្អាតនៅប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៨៨ និង បានបង្កើតក្រុមបណ្ដុះបណ្ដាល វិជ្ជាជីវៈនៅឆ្នាំ១៩៩១ ។ សមាគមនេះ ត្រូវបានបង្កើតជាអង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំ ១៩៩៥ និងមានបទពិសោធន៏លើការផ្គត់ផ្គង់ និង អនាម័យទឹកតាមសហគមន៏ ។

អង្គការនេះ ផ្តោតលើការងារនៅខេត្តបន្ទាយមានជ័យ កំពង់ធំ កំពង់ស្ពឺ ពោធិ៏សាត់ កំពត និង ខេត្តកណ្តាល ។

លោក រស់ សារឿន នាយកអង្គការ
Tel: 023 802 131
E-Mail: acape@forum.org.kh
# 282 ផ្លូវន័រប្រើត ស្លែងរលើង សង្កាត់ទឹកថ្លា
ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ

## សមាគម AJA (Association de la Jeunesse pour l’Animation ) ភ្នំពេញ

អនុញ្ញាតដោយក្រសួងមហាផ្ទៃនៅឆ្នាំ ១៩៨៨ ។ សមាគម AJA សំរបសំរួលផែនការសំរាប់ការសិក្សាអប់រំ ជាផ្នែកនៃ Accueil Cambodgien ។ វាមានទីតាំងនៅខេត្តកំពត និងផ្តល់ការអប់រំភាសាបរទេស និងថ្នាក់បន្ថែមក្រៅម៉ោង សំរាប់មុខវិជ្ជាសាលា ព្រមទាំងមានកម្មវិធីកុំព្យូទ័រ កម្មវិធីកីឡា និង កម្មវិធីដទៃទៀត ។ សមាគម ក៏បានផ្តល់ផងដែរ នូវការអប់រំផ្នែកសុខភាព និងបរិស្ថាន ។

Mao Kolbtr នាយកសមាគម
Tel: 881 363/016 880 593
E-mail: aja@forum.org.khaja, mjc@forum.com.kh
# ២៨២ ផ្លូវ៦0៨ បឹងកេងកង២ ខណ្ឌចំការមន
ក្រុងភ្នំពេញ

## អង្គការ បណ្តុះកុមារ (Bondos Komar), ភ្នំពេញ

បង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាលរបស់បារាំង Partage បានដំណើរការចាប់តាំងពីឆ្នាំ ១៩៩៩ ។ អង្គការនេះ ជួយគាំទ្រដល់សាលាបឋម

PHOTO: SONJA ENDLWEBER

សិក្សា និងសាលាមតេយ្យរបស់រដ្ឋតាមរយៈគំរោងជាច្រើនមានការសាងសង់ និង ការស្តារឡើងវិញលើផ្នែកអនាម័យ អប់រំសុខភាព និងច្បារដំណាំ ។ អង្គការបណ្តុះកុមារអនុវត្តការងារនៅខេត្តពោធិ៍សាត់ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ។

លោក គង់ សារុំ នាយកអង្គការ
Tel: (០២៣) ២១៦ ០២៣ ផាខ៍ ២១៥ ៩៩១
E-mail: bondoskomar@camnet.com.kh
#៦ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន ភ្នំពេញ

## អង្គការ ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ “BFD” (Buddhism for Development) បាត់ដំបង

BFD ត្រូវបានកសាងដោយអ៊ីនដាណាម៉ូ ប៊ីគូ និង លោក ហេង មុន្នីចិន្តា និង ព្រះសង្ឃមួយក្រុមនៅឯជុំរំជនភៀសខ្លួនសាយធូប្រទេសថៃឆ្នាំ ១៩៩០ ។ បច្ចុប្បន្ននេះ អង្គការនេះមានទីតាំងនៅក្នុងវត្តមួយខេត្តបាត់ដំបង និងមានគោលបំណងដើម្បីសំរេចអោយបានលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចេរភាពរបស់ប្រជាពលរដ្ឋនៅតំបន់ពាយ័ព្យ ប្រទេសកម្ពុជា ។ អង្គការនេះ អនុវត្តការងារនៅខេត្តមួយចំនួនទៀតដូចជា : បន្ទាយមានជ័យ ក្រុងប៉ៃលិន សៀមរាប កំពង់ធំ ព្រះវិហារ និងទីក្រុងភ្នំពេញ ។



លោក ហេង មុន្នីចិន្តា នាយកអង្គការ
Tel: (053) 370 041
E-mail: bfdkhmer@camintel.com
Web: www.bfdkhmer.org
វត្តអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង

## អង្គការ ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ BFDK (Buddhism for Development Kompong Thom) កំពង់ធំ

ចុះឈ្មោះជាអង្គការក្រៅរដ្ឋាភិបាលចាប់តាំងពីឆ្នាំ ២០០០ ហើយអង្គការ BFDK ពាក់ព័ន្ធជាមួយគំរោងសហគមន៍ព្រៃ ឈើ និងគំរោងកសិកម្មសិរីរាង្គ ។ លោក លី ខុម បានចាប់ផ្តើមសកម្មភាពការងាររបស់អង្គការនៅវ៉រយីវ (Vor Yeav) ឆ្នាំ១៩៩៧ ដោយបង្កើតជាក្រុមសង្គ្រោះនៅក្នុងភូមិចំនួន៣ ដូចជាក្រុមថែរក្សាភ្លឺស្រែ០២ និងក្រុមថែរក្សាបណ្តុះកូនឈើ០១ ។

លោក លី ខុម នាយកអង្គការ
Tel: 012 734 467
E-mail: 012 734467@mobitel.com,kh
ផ្លូវជាតិលេខ ៦ កំពង់ធំ

## អង្គការ អភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ CED (Community Economic Development) ក្រចេះ

បានចុះឈ្មោះនៅក្រសួងមហាផ្ទៃឆ្នាំ ២០០៣ និងអនុវត្តការងារនៅភូមិចំនួន៦៧ ១៦ឃុំ និង ៤ស្រុក ក្នុងខេត្តក្រចេះ ។ អង្គការនេះពាក់ព័ន្ធជាមួយកម្មវិធីសំខាន់ចំនួន០៣គឺ កម្មវិធីអប់រំក្រៅប្រព័ន្ធ កម្មវិធីអប់រំសុខភាព និង កម្មវិធីកសិកម្ម និងការចិញ្ចឹមសត្វ ។ សកម្មភាពការងារដទៃទៀតមានការអភិរក្សធនធានធម្មជាតិ ។

យស ភារី អ្នកសំរបសំរួលក្រុម
E-mail: cedcam@camintel.com
ផ្លូវលេខ៣ ត្រពាំងព្រីង ខេត្តក្រចេះ

## មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ CLEC (Community Legal Education Centre) ភ្នំពេញ

អង្គការនេះផ្តល់ការអប់រំ ការតស៊ូមតិ និងសេវាកម្មផ្នែកច្បាប់ដទៃទៀត និង វាបានបង្កើតឡើងនៅឆ្នាំ ១៩៩៦ ជាមជ្ឈមណ្ឌលធនធានច្បាប់ ដើម្បីលើកកំពស់តួនាទីច្បាប់ យុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យ ។ ឆ្នាំ ១៩៩៦-២០០១ អង្គការនេះបានអនុវត្តទៅតាមសាកលវិទ្យាល័យច្បាប់ San Francisco និងគាំទ្រមូលនិធិដោយ USAID ។ ឆ្នាំ២០០២ បានចុះបញ្ជី ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងមានអនុវត្តគំរោងតស៊ូមតិតាមផ្លូវច្បាប់ ក្នុងការការពារប្រយោជន៍សាធារណៈដោយផ្តោតលើបញ្ហាដីធ្លី និង ធនធានធម្មជាតិ ។ ការងារសំខាន់របស់អង្គការគឺនៅខេត្តរតនៈគីរី និងមណ្ឌលគីរី ។

លោក យ៉េង វីរៈ នាយកប្រតិបត្តិ
Tel: 023 211 723
E-mail: clec@online.com.kh
Web: http://www.bigpond.com.kh/users/usfpp/CLEC_home.htm
# ៩៦ ផ្លូវ ៣០៦ ស.ក បឹងកេងកង ១ ភ្នំពេញ

## អង្គការ ស្ការ៉ូ CSARO (Community Sanitation and recycling Organization) ភ្នំពេញ

បានបង្កើតឡើងនៅឆ្នាំ១៩៩៧ ក្នុងគោលបំណងលើកកំពស់ស្តង់ដារអនាម័យ សុខភាព និងបរិស្ថាន និងបង្កើតឱកាសថ្មី ដល់អ្នកដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ ។ ការងាររបស់អង្គការផ្តោតលើនៅក្រុងភ្នំពេញ ។

លោក ហេង យូគួរ៉ា នាយកកម្មវិធី
Tel/Fax: (023) 211 116
E-mail: scaro@online.com.kh
Web: http://www.bigpond.com.kh/users/scaro/organization_info.htm
# ៧១ ផ្លូវ ៣៦៨ សង្កាត់ ទួលស្វាយព្រៃ១ ខណ្ឌចំការមន ភ្នំពេញ

## សមាគមអភិរក្សវប្បធម៌ និង បរិស្ថាន CEPA (Cultural and Environmental Preservation) ភ្នំពេញ

បង្កើតឡើងនៅឆ្នាំ១៩៩៥ និងចុះបញ្ជីឈ្មោះជាអង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំបន្ទាប់ ។ សមាគម CEPA ផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន ដល់និស្សិតសាកលវិទ្យាល័យ បុគ្គលិកអង្គការ និងមន្ត្រីរដ្ឋាភិបាល ។ តំបន់ដែលបានកំនត់គឺទីក្រុងភ្នំពេញ និងខេត្តស្ទឹងត្រែង ។ សកម្មភាពមានដូចជាសហគមន៍ព្រៃឈើ សហគមន៍ជលផល និងបណ្តាញការងារការពារទន្លេសេសាន និងការគ្រប់គ្រងទន្លេ ។

លោក ទេព ប៊ុណ្ណារិទ្ធិ : នាយកស្តីទី
Tel: (023) 369 179 / 720 062
E-mail: cepa@online.com.kh
Web:www.cepa-cambodia.org
# ៤០. ផ្លូវ ៣៥២. បឹងកេងកង១ ចំការមន ភ្នំពេញ

## សមាគមអភិវឌ្ឍន៍ កម្ពុជា DAC (Development Association of Cambodia) ភ្នំពេញ

ចាប់ផ្តើមនៅឆ្នាំ១៩៩៤ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃឆ្នាំ១៩៩៩ ។ សមាគមមានកិច្ចព្រមព្រៀងសហប្រតិបត្តិការ លើការអប់រំក្រៅប្រព័ន្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ។ សមាគមនេះផ្តោតលើខេត្តពោធិ៍សាត់ និងមានគោលបំណងផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីបរិស្ថាន លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

លោក ប៉ូ ទៀង នាយកសមាគម
Tel: 016 55 144 / 012 923 642
E-mail: potiengdac@yahoo.com
៦ ផ្លូវ ២១៤/១៤៣. បឹងព្រលឹត ៧មករា. ភ្នំពេញ

## អង្គការ កម្មវិធីអភិវឌ្ឍន៍សំរាប់និស្សិតខ្មែរ DPKS (Development Programe for Khmer Student) ភ្នំពេញ

បង្កើតដោយប្រជាពលរដ្ឋដែលមានជំនាញផ្នែកអប់រំ ផ្នែកទំនាក់ទំនង និងសិទ្ធិកុមារ ។ អង្គការ DPKS ជួយឧបត្ថម្ភ គាំទ្រដល់កុមារ និងយុវជនដែលការទទួលបានសិទ្ធិតិចតួច ។ អង្គការនេះបានចុះបញ្ជីជាមួយអាជ្ញាធរខេត្ត និងក្រសួងមហាផ្ទៃនៅឆ្នាំ ២០០០ និងពាក់ព័ន្ធជាមួយសហគមន៍ព្រៃឈើ និងការពារបរិស្ថាន ។

លោក ឡូវ ប៊ុនលាង នាយកអង្គការ
Tel/Fax: 092 932 654
E-mail: dpkspur@yahoo.com
#៤៤៤ ផ្សារចាស់ ពាលញ្ញាត១ សំពៅមាស. ខេត្តពោធិ៍សាត់

## អង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន EPDO (Environmental Protection and Development Organization) ខេត្តពោធិ៍សាត់

បង្កើតឡើងនៅឆ្នាំ១៩៨៨ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការជាតិ និង អន្តរជាតិ ក្នុងខេត្តពោធិ៍សាត់ ។ អង្គការ EPDO អនុវត្តការងារលើផ្នែកអភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ និងមានការពាក់ព័ន្ធជាមួយសហគមន៍ព្រៃឈើ និងសកម្មភាពប្រកបរបរចិញ្ចឹមជីវិត និងខិតខំប្រឹងប្រែងដើម្បីជំរុញការចូលរួមពីសាធារណៈនៅក្នុងលទ្ធិប្រជាធិបតេយ្យ ។

លោក អ៊ុត សិរិទ្ធ នាយកប្រតិបត្តិអង្គការ
Tel/Fax: 012 962 635 Fax: 052 951 665
E-mail: dpdopur@yahoo.com
#៤. ពាលញ្ញាត១ . ឃុំផ្ទះព្រៃ. ស្រុកសំពៅមាស. ខេត្តពោធិ៍សាត់

## អង្គការ សម្ព័ន្ធសកម្មភាពដើម្បីអភិរក្សធនធានជលផល FACT (Fisheries Action Coalition Team) ភ្នំពេញ

អង្គការ FACT បានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយសមាជិកអង្គការក្រៅរដ្ឋាភិបាល ខាងផ្នែកជលផល និងបញ្ហា បរិស្ថាននៅជុំវិញបឹងទន្លេសាប ។ បង្កើតជាផ្នែកមួយនៃអង្គការ NGO Forum លើផ្នែកជលផល ទទួលបានការគាំទ្រពី អង្គការអន្តរជាតិផ្សេងៗដូចជា : Oxfam និងអង្គការមូលនិធិយុត្តិធម៌បរិស្ថាន ។

ឆ្នាំ២០០៤ បានបែកចេញពី NGO Forum ។ អង្គការ FACT ធ្វើការតស៊ូមតិលើផ្នែកបញ្ហាជលផល និងត្រួតពិនិត្យលើកំណែទំរង់គោលនយោបាយ ដោយអនុវត្តការងារនៅជុំវិញបឹងទន្លេសាប និងខេត្តដែលមានជាប់សមុទ្រ ។

លោក ម៉ក់ សិទ្ធីរិទ្ធ នាយកប្រតិបត្តិ
Tel: (023) 992 044
E-mail: factpp@camnet.com.kh
#៧១. ផ្លូវ ៥៩២. បឹងកក់២. ខណ្ឌទួលគោក. ភ្នំពេញ

## អង្គការ ស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ FAO (United Nations Food & Agriculture Organiztion) ភ្នំពេញ

អាណត្តិរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីលើកកំពស់ផ្នែកចំណីអាហារ កែលំអផលិតផលកសិកម្ម និង ធ្វើអោយជីវភាពរស់នៅតាមជនបទកាន់តែប្រសើរ និងមានកំណើនសេដ្ឋកិច្ច ។ នៅប្រទេសកម្ពុជា សកម្មភាពរបស់ អង្គការ FAO មានការគ្រប់គ្រងធនធានធម្មជាតិ និង គ្រប់គ្រងថ្នាំសំលាប់សត្វល្អិតកសិកម្ម ។ អង្គការនេះមានសកម្មភាពជាពិសេសនៅក្នុងខេត្តសៀមរាប ។

Tel: (855 23) 216 566 992 044
E-mail: fao@un.org.kh

Web: http://www.fao.org/countryprofile
#០៥. ផ្លូវ ៣៧០. បឹងកេងកង១ ភ្នំពេញ

## អង្គការ អនាគតដើម្បីកុមារកម្ពុជា FCC (Future for Cambodian Children) ខេត្តសៀមរាប

បានចុះបញ្ជីឈ្មោះនៅក្រសួងមហាផ្ទៃឆ្នាំ ២០០០ ។ អង្គការ FCC មានគោលបំណងអប់រំកុមារអំពីសិល្បៈ និង វប្បធម៌ ហើយសកម្មភាពរបស់អង្គការមានសិល្បៈល្ខោនស្បែក ។

លោក គី មឿង នាយកប្រតិបត្តិ
Tel: 012 920 506
E-mail: anakotkomar@
Web: www.h6.dion.ne.jp/fcc
ប្រាសាទបាគង ខេត្តសៀមរាប

## អង្គការ JICA (Japan International Cooperation Agency) ភ្នំពេញ

ប្រតិបត្តិការងារនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩៣ ។ ភ្នាក់ងាររដ្ឋាភិបាលជប៉ុនមានការងារលើការគ្រប់គ្រងធនធានបរិស្ថាន ដែលជាគោលបំណងសំខាន់មួយ ។ អង្គការនេះប្រតិបត្តិជាសកល ។

Mr. Juro Chikararaishi, តំណាងអង្គការ JICA នៅកម្ពុជា
Tel: (023) 212 142/ 023 211 673/ 217 129
Fax: (023) 211 675 / 015 913 639
E-mail: jica@online.com.kh
Web: www.jica.org.com.kh
# 440 A /448 Eo, មហាវិថីព្រះមុន្នីវង្ស

## អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន L&L (Live and Learn Environmental Education) ភ្នំពេញ

បានចុះបញ្ជីជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនៅឆ្នាំ ២០០៥ ។ អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន មានសកម្មភាពលើកកំពស់ការអនុវត្ត និងការយល់ដឹងអោយកាន់ប្រសើរដល់និរន្តរភាពបរិស្ថាន និងមនុស្ស តាមរយៈការអប់រំ និងការពិភាក្សា ។ ក្រសួងបរិស្ថាន បានចុះកិច្ចសន្យាជាមួយអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ដើម្បីអនុវត្ត យុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ ដែលជាផ្នែកនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ឆ្នាំ ២០០៥ និង ២០០៦ ។ សកម្មភាពមាននៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងកំពង់ធំ ។

លោក គាត ប៊ុនថាន មន្ត្រីអប់រំបរិស្ថាន
លោក ជុំ សំអួន មន្ត្រីផ្សព្វផ្សាយ
Tel: (023) 224 053
E-mail: livelearn@online.com.kh
Web: http://www.idea.org.au/liveandlearn/
#364, មហាវិថីព្រះមុនីវង្ស ខណ្ឌចំការមន ភ្នំពេញ

## ក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ : ភ្នំពេញ

ក្រសួងមាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ហើយបុគ្គលិកផ្សព្វផ្សាយក៏មាននៅក្នុងរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ។

Tel: (023) 211 351 Fax: (023) 217 320
E-mail: maff@everyday.com.kh
Web: www.maff.gov.kh/
# ២០០ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ

## ក្រសួង អប់រំ យុវជន និងកីឡា

ក្រសួងមានមហាវិទ្យាល័យគរុកោសល្យ ដែលបណ្តុះបណ្តាលគរុកោសល្យដល់និស្សិត បានបញ្ចប់ការសិក្សាមុនចាប់ផ្តើមការបង្ហាត់បង្រៀន ។ កម្មវិធីនេះមានរយៈពេល១ឆ្នាំ ដោយដាក់បញ្ចូលនូវចំណេះដឹងមូលដ្ឋានផ្នែកបរិស្ថានទៅក្នុងមុខវិជ្ជាបង្រៀន ។

សាស្ត្រាចារ្យ គង់ ភូមិការ អនុប្រធានការិយាល័យសិក្សា
Tel: (023) 362 342
E-mail: kong_phoumicka@yahoo.com
Web: www.idea.org.au/liveandlearn/
មហាវិថីព្រះនរោត្តម ភ្នំពេញ

## ក្រសួង បរិស្ថាន ភ្នំពេញ

ក្រសួងមាននាយកដ្ឋានអប់រំ និង ផ្សព្វផ្សាយព័ត៌មានបរិស្ថាន ដែលមានតួនាទីភារកិច្ច កែលំអចំណេះដឹងបរិស្ថានតាមរយៈការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដើម្បីធានាថា ធនធានធម្មជាតិត្រូវបានគ្រប់គ្រង និងអភិរក្សដោយប្រុងប្រយ័ត្ន និងប្រកបដោយនិរន្តរភាព ។ ការិយាល័យបណ្តុះបណ្តាល និងអប់រំបរិស្ថាន ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ។

លោក ស៊ូ ស្វុំធ ប្រធាននាយកដ្ឋាន
លោក រ័ត្ន សិទ្ធ ប្រធានាការិយាល័យបណ្តុះបណ្តាល និងអប់រំបរិស្ថាន
Tel: (023) 216 019
Fax: (023) 212 540
E-mail: eetoffice@yahoo.com
Web: www.idea.org.au/liveandlearn/
# ៤៨ សម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ

## ក្រសួង ធនធានទឹក និង ឧតុនិយម ភ្នំពេញ

ក្រសួងអនុវត្តការផ្សព្វផ្សាយនៅទូទាំងប្រទេស

Tel: (023) 724 327 / 882 160
E-mail: mowram@cambodia.gov. com
Web: www.idea.org.au/liveandlearn/
# 47 មហាវិថីព្រះនរោត្តម ភ្នំពេញ

## អង្គការ មួប់បៃតង ភ្នំពេញ

ជាអង្គការក្រៅរដ្ឋាភិបាលមួយក្នុងចំណោមអង្គការមួយចំនួននៅកម្ពុជា មានគោលបំណងសំខាន់ផ្តោតទៅលើផ្នែកអប់រំបរិស្ថាន ។ អង្គការនេះ បានបង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាលប្រទេសអង់គ្លេសនៅឆ្នាំ ១៩៩៨ និងបានចុះបញ្ជីនៅឆ្នាំ ២00១ ដោយមានគោលបំណងដើម្បីបង្កើនចំណេះដឹង និងការអភិរក្សបរិស្ថានតាមរយៈការអប់រំបណ្តុះបណ្តាល ការតស៊ូមតិ និងសេវាកម្មដទៃទៀត ដើម្បីគាំទ្រការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងសមភាព ។ ការងាររបស់គេមាននៅក្នុងខេត្តកំពង់ស្ពឺ និង កំពងធំ ។

លោក វ៉ា មឿន នាយកប្រតិបត្តិ
Tel: ១0២៣ធ ២១៤ ៤0៩
E-mail: mlup@online.com.kh
Web: www.mlup.org/
# ៣៧បេ ផ្លូវ ១១៣ សង្កាត់ បឹងកេងកង ២ ខណ្ឌ ចំការមន ភ្នំពេញ

## វេទិកាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា NGO Forum – ភ្នំពេញ

កើតឡើងពីយុទ្ធនាការជាអន្តរជាតិដើម្បីបញ្ចប់ការរឹបអូសជំនួយប្រទេសកម្ពុជានៅឆ្នាំ ១៩៨៦ ។ បច្ចុប្បន្ន អង្គការ NGO Forum ផ្តោតលើបញ្ហាជាតិដូចជា គោលនយោបាយអភិវឌ្ឍន៍ និង ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ អង្គការនេះពាក់ព័ន្ធលើផ្នែកចំណេះដឹងសាធារណៈ ការប្រកបរបរចិញ្ចឹមជីវិត ព្រៃឈើ និងការងារនៅតំបន់ទន្លេសេសាន ។

Rossell Perteson, តំណាង នៅក្នុងប្រទេស
លោក ស៊ុំ សាទីត្យ អ្នកតំណាងរង
Tel: (023) 986 269
E-mail: mlup@online.com.kh
Web: www.ngoforum.org.kh
# ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌ ចំការមន ភ្នំពេញ

## សមាគម ភ្នំនាងកង្រី PNKA (Phnom Neang Kangrey Association) ខេត្តកំពងឆ្នាំង

សមាគម PNKA ពាក់ព័ន្ធជាមួយនឹងគំរោងសហគមន៏នេសាទ និង សហគមន៍ព្រៃឈើក្នុងខេត្តកំពង់ឆ្នាំង ។

លោក អ៊ុក សាម៉ែត – នាយកសមាគម
Tel: 092 903 908
E-mail: kangreikcg@yahoo.com
# ភូមិឡូទឹកត្រី ឃុំកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

## សមាគម ព្រហ្មវិហារធម៌ (Promvihearthor) – ខេត្តពោធិ៍សាត់

បង្កើតឡើងនៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ នាឆ្នាំ ២០០០ ។ សមាគមព្រហ្មវិហារធម៌ពាក់ព័ន្ធជាមួយការងារគ្រឿងចំលាក់ លើកកំពស់ការចិញ្ចឹមសត្វ ការដាំដើមឈើ និង បន្លែ ។ បន្ថែមទៅលើសហគមន៍ព្រៃឈើ និង សកម្មភាពកសិកម្ម ។ សមាគមក៏មានការងារក្នុងវិស័យសិទ្ធិមនុស្ស និងជំងឺអេដស៍ (HIV/AIDS) ផងដែរ ។

លោក ខួន ណារិន – នាយកប្រតិបត្តិ
Tel: 092 903 908
E-mail: promvihearthor@cambodiacic.org
ភូមិពាលញ៉ែក ឃុំផ្ទះត្រី ស្រុកសំពៅមាស ខេត្តពោធិ៍សាត់

## អង្គការ Room to Read

អង្គការ Room to Read ផ្តល់ការអប់រំដល់កុមារក្រីក្រ និងមជ្ឈមណ្ឌលសហគមន៍ ដោយមានការបោះពុម្ពសៀវភៅជាភាសាខ្មែរ និងទិញរឿងខ្លីៗជាភាសាខ្មែរ និងបាននាំសៀវភៅសំរាប់កុមារពីអ្នកបោះពុម្ពផ្សាយអាមេរិក ។ បណ្ណាល័យមាននៅទីក្រុងភ្នំពេញ បាត់ដំបង និងខេត្តសៀមរាប ។

## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ RUPP (Royal University of Phnom Penh)

ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាននៃសាកលវិទ្យាល័យ បានផ្តល់កម្មវិធីបរិញ្ញាប័ត្ររយៈពេល៤ឆ្នាំ ដោយផ្តោតលើការគ្រប់គ្រងបរិស្ថាន ។ កម្មវិធីបង្រៀនមានពីរផ្នែក គឺ ការគ្រប់គ្រងធនធានធម្មជាតិ និងការសិក្សាលើបរិស្ថានទីក្រុង មានការឧបត្ថម្ភដោយអង្គការ ដានីដា និង សាកលវិទ្យាល័យ Roskli នៅប្រទេស ដាណឺមាក ព្រមទាំងវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT) ប្រទេសថៃ ។ នាយកដ្ឋានមានកម្មវិធីសិក្សាចំនួន ៣៣មុខ និង ក៏បានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លីដូចជា : ការគ្រប់គ្រងសំណល់រឹង និងការធ្វើផែនការគ្រប់គ្រងបរិស្ថាន ។ នាយកដ្ឋានបានអនុវត្តគំរោងសិក្សាស្រាវជ្រាវមួយចំនួន រួមទាំងគំរោងសិក្សា ការគ្រប់គ្រងជលផលនៅបឹងទន្លេឆ្មារ ។

កញ្ញា វ៉ា ដានី និង លោក សៀក សុផាត
Tel: 011 876 037 / 016 506 888
E-mail: usepam@everyday.com.kh
បន្ទប់ ១១២ RUPP Main Building
មហាវិថីសហព័ន្ធរុស្ស៊ី ភ្នំពេញ

## អង្គការ អភិវឌ្ឍន៍បរិស្ថានសហគមន៍ជនបទ RCEDO (Rural Community Environmental Development Organization)- ខេត្តបន្ទាយមានជ័យ

បានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅឆ្នាំ ១៩៩៨ និង ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នៅឆ្នាំ ២០០៣ ។ អង្គការនេះ មានកម្មវិធីជីកអណ្តូង និងមានការពាក់ព័ន្ធនឹងការងារអប់រំសុខភាពផងដែរ ។

លោក សំ សេរីវឌ្ឍនា – នាយកអង្គការ
Tel: (054) 958 870 / 012 832 870
E-mail: redobmc@forum.org.kh
ផ្លូវ ៥៩ សូភី កំពង់ស្វាយ សេរីសោភ័ណ
ខេត្តបន្ទាយមានជ័យ

## សមាគមសេវាកម្មសមណៈគ្មានព្រំដែន Samanak SEA (Service Endlessness Association) ខេត្តបាត់ដំបង

បង្កើតឡើងនៅវត្តសង្កែ ក្នុងខេត្តបាត់ដំបង ឆ្នាំ២០០៣ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ឆ្នាំ ២០០៤ ។ គោលបំណងរបស់សមាគមគឺ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន និងដើម្បីធ្វើការកែលំអចំណេះដឹងនៃការការពារបរិស្ថាន ។

លោក ផាន សុហួត – នាយកប្រតិបត្តិ
Tel: 012 647 541 Fax: (035) 852 448
E-mail: phansokhoeut@yahoo.com
វត្តសង្កែ ភូមិរតនៈ ខេត្តបាត់ដំបង

## អង្គការសង្គ្រោះសត្វព្រៃកម្ពុជា SCW (Save Cambodia's Wildlife) ភ្នំពេញ

អង្គការ SCW យកចិត្តទុកដាក់ទៅលើការអប់រំបរិស្ថាន ។ អង្គការបានចុះបញ្ជីជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ឆ្នាំ ២០០០ គោលបំណងរបស់អង្គការ SCW គឺការពារ និងអភិរក្សសត្វព្រៃ និងជំរកសត្វព្រៃតាមរយៈការអប់រំ ។ គំរោង របស់អង្គការ SCW គ្រប់ដណ្តប់ទៅលើចំណេះដឹងសាធារណៈដូចជា ការដោះមីន សិទ្ធិក្នុងការរស់នៅ និងធនធាន និងការគ្រប់គ្រងធនធានធម្មជាតិ ។ ការងារអនុវត្តនៅខេត្តកំពត កោះកុង ពោធិ៍សាត់ ស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី និង ខេត្ត ឧត្តមានជ័យ ។

Tel: (855-23 ) 211 263
Fax: (855-23) 222 036
E-mail: wildlife@online.com.kh
Web: www.cambodiaswildlife.org
# ២៧២ ផ្លូវ ១៩៧ បឹងព្រលឹត ខណ្ឌ ៧មករា ភ្នំពេញ

## អង្គការ ស៊ីប៉ា SIPAR (Soutien a l'Iniative Pour l'Aide a la Reconstruction) - ភ្នំពេញ

អង្គការ SIPAR មានបណ្ណាល័យចល័ត ០៣ នៅក្នុងទីក្រុងភ្នំពេញ ហើយអង្គការនេះបានបណ្តុះបណ្តាលដល់បណ្ណារក្ស ចាប់ពីឆ្នាំ២០០០ ។ អង្គការមានកម្មវិធីបោះពុម្ពជាភាសាខ្មែរក្នុងគោលបំណងផ្តល់សៀវភៅអប់រំមានគុណភាព និងមានតំលៃទាប ។ សៀវភៅ មានចំណងជើងថា "ខ្ញុំចង់ដឹង" ដែលបោះពុម្ពផ្សាយជាបន្តបន្ទាប់ រាប់ញ្ចូលសៀវភៅ ស្តីពីជីវិតនៅជុំវិញបឹងទន្លេសាប ។

Tel: (855-23 ) 987 908
E-mail: siparpp@online.com.kh
# ៩ ផ្លូវ២១ ទន្លេបាសាក់ ខណ្ឌ ចំការមន ភ្នំពេញ

## អង្គការ ស្រែខ្មែរ (Srer khmer) - ភ្នំពេញ

ជួយផ្តល់ចំណេះដឹងដល់កសិករ និងជួយពង្រឹងសមត្ថភាពរបស់ពួកគាត់ ដើម្បីដឹកនាំ និងគ្រប់គ្រងជីវភាពរបស់ខ្លួនតាម វិធីផ្សេងៗ ដែលកសាងចំណេះដឹងអំពីទំនាក់ទំនងរវាងកសិកម្ម បរិស្ថាន សង្គមនៅជនបទ ។ អង្គការមានការងារជិតស្និទជាមួយកសិករ ស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ។

ប៉ូឡូ យិច - នាយកអង្គការ
Tel: (855-23 ) 210 217 / 012 944 240
E-mail: ipm.cambodia@bigpond.com.kh
ភ្នំពេញ

## អង្គការ ស្ត្រីសន្តិភាពដើម្បីបរិស្ថាន SSP (Strey Santepheap Deiombeiy Parethan) - ខេត្តក្រចេះ

បង្កើតឡើងនៅឆ្នាំ ២០០០ និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ ឆ្នាំ ២០០២ ។ អង្គការ SSP អប់រំដល់ប្រជាពលរដ្ឋរស់នៅក្នុងព្រៃសម្បទាន អំពីច្បាប់ព្រៃឈើ ជាពិសេសសិទ្ធិរបស់សហគមន៍ និងកាតព្វកិច្ចរបស់សម្បទាននិក ។ អង្គការនេះអនុវត្តការងារនៅខេត្តក្រចេះ មណ្ឌលគិរី និងខេត្តស្ទឹងត្រែង ។

អ៊ុច គឹមណារី - អ្នកសំរបសំរួល
Tel: 012 670 188
E-mail: sp_org@yahoo.com
អូរឫស្សី១ ខេត្តក្រចេះ

## មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ UNICEF - ភ្នំពេញ

អាទិភាព នៃកម្មវិធីរបស់អង្គការ UNICEF នៅកម្ពុជា រួមមានសិទ្ធិកុមារចំពោះការអប់រំដោយមានសមភាព ដោយ បង្កើនឱកាសចូលសាលារៀន និងកាត់បន្ថយបញ្ហាគម្លាតគ្នា និងបញ្ហាយេនឌ័រ ។

អង្គការនេះ មានការចូលរួមយ៉ាងសកម្ម ក្នុងការអប់រំ និងវិធីសាស្ត្រអប់រំសុខភាព និងជាមួយការអប់រំបរិស្ថាន ។

Kerstin Karlstorm - មន្ត្រីរៀបចំកម្មវិធី
Tel: (023) 426 214  Fax: (023) 426 284
E-mail: unicef_phnom Penh@unicef.org
Web: http://www.unicef.org/infobycountry/
#១១ ផ្លូវ៧៥ សង្កាត់ស្រះចក ភ្នំពេញ

## អង្គការ សហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ UNESCO (United Nations Educational, Scientific and Cultural Organization) ភ្នំពេញ

ឆ្នាំ១៩៥១ ប្រទេសកម្ពុជាបានចូលក្នុងអង្គការ UNESCO ។ វិធីសាស្ត្ររបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិលើការ អប់រំបរិស្ថានបានបញ្ចូលនូវវិន័យទាំងអស់ និងគ្របដណ្តប់លើគ្រប់កំរិត និងគ្រប់ប្រភេទនៃការអប់រំ រួមទាំងការសិក្សារយៈពេលវែង ។ សកម្មភាពវិទ្យាសាស្ត្រថ្នាក់តំបន់រួមទាំងបណ្តាញការងារ ជីវមណ្ឌលអាស៊ីអាគ្នេយ៍ ត្រូវបានសំរបសំរួលតាមរយៈ ការិយាល័យប្រចាំនៅទីក្រុង Jakartar ។

Tel: (855-23) 42 67 6 / 21 72 44
Fax: (855-23) 42 61 63 / 21 70 22
Web: http://www.unesco.org
# ៣៨ មហាវិថីសម្តេចព្រះសុធារស ភ្នំពេញ

## អង្គការ ក្រុមគាំទ្រភូមិ VSG (Village Support Group) - ខេត្តបាត់ដំបង

បានចុះបញ្ជីនៅឆ្នាំ១៩៩៥ ជាអង្គការគ្រប់គ្រងកម្មវិធីសុវត្ថិភាពម្ហូបអាហារ និងជំនឿ នៅខេត្តបាត់ដំបង មុននឹងចូលទៅការអភិវឌ្ឍសហគមន៍នៅឆ្នាំ១៩៩៧ ។ សកម្មភាពរបស់អង្គការមានដូចជា ការផ្តួចផ្តើមផ្តោតគំនិតទៅលើការការពារបរិស្ថាន និងមានការអនុវត្តន៍នៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។

រស់ ឆួលវីរីន- នាយកប្រតិបត្តិ
Tel: 012 915 540 / 053 730 355
E-mail: vsg@online.com.kh
ក្រុម ២១ កំពង់ក្របី ស្វាយប៉ោ ខេត្តបាត់ដំបង

## អង្គការ ដីសើមអន្តរជាតិ (Wetlands International) - ភ្នំពេញ

កម្មវិធីអង្គការដីសើមអន្តរជាតិបានប្រតិបត្តិនៅក្នុងទីក្រុងភ្នំពេញចាប់ពីឆ្នាំ១៩៩៦ ។ សកម្មភាពបានចាប់ផ្តើមដោយមានជំនួយពីរដ្ឋាភិបាលក្នុងការយល់ព្រមជាមួយ អនុសញ្ញារ៉ាមសារ (Ramsar Convention) និងបានកំពុងអនុវត្តគំរោង ដើម្បីអភិវឌ្ឍន៍តំបន់គ្រប់គ្រង ដែលជាគំរោងការងារស្របច្បាប់ និងគោលការណ៍ណែនាំអនុវត្តសំរាប់ឧទ្យានជាតិរាម ។ កម្មវិធីបានរៀបចំជាសៀវភៅសារពើភ័ណ្ឌដីសើមអាស៊ី ។

លោក ម៉ម កុសល - អ្នកសំរបសំរួលកម្មវិធី
Tel: 012 593 007  Fax: 211 944
E-mail: wetlan@online.com.kh
# ២១ ផ្លូវ ៣៦០ បឹងកេងកង ខណ្ឌ ចំការមន ភ្នំពេញ

## អង្គការ សមាគមអភិរក្សសត្វព្រៃ WCS (Wildlife Conservation Society) - ភ្នំពេញ

អង្គការអន្តរជាតិចាប់ផ្តើមការងារក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៩ និងបានក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកក្នុងឆ្នាំ ២០០០ ។ អង្គការ WCS មានគោលបំណងនាំមកនូវការអភិរក្សនៅក្នុងលំដាប់មុខនៃការអប់រំវិទ្យាសាស្ត្រ ដោយអះអាងថា ការយល់ដឹងច្បាប់ពីដំណើររបស់ធម្មជាតិគឺជាការត្រឹមត្រូវរបស់សិស្សដែលបញ្ចប់ថ្នាក់វិទ្យាល័យ និងតួនាទីរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុលទិប្រជាធិបតេយ្យ ។ អង្គការនេះធ្វើការនៅក្នុងប្រទេស

កម្ពុជា ដោយយកចិត្តទុកដាក់ទៅលើវាលទំនាបខាងជើង និងព្រៃឈើខាងកើតនៅជុំវិញបឹងទន្លេសាប ។

លោក សួន វិសាល - មន្ត្រីគំរោង
Tel: (023) 217 205 / (023) 219 443
E-mail: cambodia@wcs.org
Web: http://www.wcs.org/international/Asia
# ២១ ផ្លូវ២១ ទន្លេបាសាក់ ខណ្ឌ ចំការមន ភ្នំពេញ

## អង្គការ អន្តរជាតិសំរាប់អភិរក្សធម្មជាតិ- IUCN (World Conservation Union) - ភ្នំពេញ

អង្គការ IUCN បានចាប់ផ្តើមការងារនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ ដែលគោលបំណងរបស់អង្គការនេះទៅលើ កម្មវិធីដីសើមប្រកបដោយនិរន្តរភាពនៅខេត្តស្ទឹងត្រែង ការអភិរក្សព្រៃកោងកាង ជំរុញសេចក្តីសំរេចរបស់គណៈកម្មការពិភពលោកស្តីពីទំនប់ និងធ្វើការពិនិត្យលើតំបន់ការពារឡើងវិញ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។

លោក ម៉ៅ កុសល អ្នកសំរបសំរួល កាបណ្តុះបណ្តាលដីសើមជាតិ
Tel: (023) 222 311 Fax: ( 023) 211 944
E-mail: iucncambodia@online.co.kh
Web: http://www.wcs.org/international/Asia
# ២១ ផ្លូវ៣០៦ សង្កាត់បឹងកេងកង ខណ្ឌចំការមន ភ្នំពេញ

## អង្គការ អប់រំពិភពលោក កម្ពុជា WEC (World Education Cambodia) - ភ្នំពេញ

អង្គការ WEC បានផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ធនធានមនុស្សនៅប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៩២ មក ដំបូងផ្តោតទៅលើមនុស្សពេញវ័យ ។ ចាប់តាំងពីឆ្នាំ ១៩៩៨ ការយកចិត្តទុកដាក់របស់អង្គការនេះគឺ ស្ថិតនៅលើការអប់រំជាមូលដ្ឋាន និងបណ្តុះបណ្តាលគ្រូបង្រៀន ។ ការងារផ្នែកអប់រំបឋមសិក្សារួមមាន បណ្តុះបណ្តាលគ្រូបង្រៀន និងរៀបចំ កម្មវិធីបង្រៀននៅក្នុងជំនាញបំនិនជីវិត ។ ការងាររបស់គេផ្តោតនៅក្នុងខេត្តកំពង់ចាម ខេត្តព្រៃវែង ។

Mr. Richard Geeves - នាយកគំរោង
Tel: (023) 216 854 /012 811 428
012 811 429
Fax: (023) 218 369
E-mail: worldedcam@online.com.kh
Web: http://www.worlded.org/weiinternet/
# ៤៦ ផ្លូវ ២៩៤ សង្កាត់ បឹងកេងកង ខណ្ឌ ចំការមន ភ្នំពេញ

## អង្គការ មូលនិធិពិភពលោក សំរាប់អភិរក្សធម្មជាតិ WWF (World Wide Fund for Nature) - ភ្នំពេញ

អង្គការ WWF បានដំណើរការងារនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៩៣ និងបានបើកការិយាល័យនៅឆ្នាំ ១៩៩៨ ។

សកម្មភាពអភិរក្សយកចិត្តទុកដាក់ទៅលើផ្នែក 04 គឺតំបន់ព្រៃធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ទឹកសាប ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងតំបន់ឆ្នេរ និងពពួកសត្វផ្សេងៗ និងរុក្ខជាតិដែលកំពុងត្រូវបានចាប់អារម្មណ៍ជាពិសេស ។ ការងាររបស់អង្គការធ្វើនៅខេត្តរតនៈគីរី មណ្ឌលគីរី កំពង់ស្ពឺ ស្ទឹងត្រែង និងខេត្តក្រចេះ ។

លោក សេង ទៀក - នាយកអង្គការ
Tel: (023) 218 034 Fax:( 023) 211 909
E-mail: wwfcam@everyday.com.kh
Web: http://www.worlded.org/weiinternet/
# ៤៦ ផ្លូវ២៩៤ សង្កាត់ បឹងកេងកង ខណ្ឌ ចំការមន ភ្នំពេញ

# ២៣

# ការអប់រំ និងផ្សព្វផ្សាយបរិស្ថាន



PHOTO: KAREN YOUNG L&L

# គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប

## ១. សេចក្តីផ្តើម

### ក. គំរោង និង ផែនការសកម្មភាព

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប មានទឹកប្រាក់ចំនួន២០លាន ដុល្លាអាមេរិក ត្រូវបានគាំទ្រហិរញ្ញវត្ថុរួមដោយធនាគារអភិវឌ្ឍន៏អាស៊ី (ADB) ទីភ្នាក់ងារអង្គការសហប្រជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។ នៅខែមិថុនា ឆ្នាំ២០០៥ ក្រសួងបរិស្ថានបានចុះកិច្ចសន្យាអោយអង្គការ Live and Learn ក្នុងការអនុវត្តន៏យុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ ។ អង្គការ Live and Learn គឺជាអង្គការដែលមិនរកប្រាក់កំរៃមួយ និងមានទំនាក់ទំនងជាមួយទីក្រុង Melbourne, Australia ដោយមានការិយាល័យកណ្តាលនៅ Fiji និងប្រតិបត្តិការងារនៅក្នុងប្រទេសមួយចំនួន ដូចជា ប្រទេសប៉ាពូញូហ្គីនា កោះសូឡូម៉ុង និងប្រទេស Vanuatu ព្រមទាំងប្រទេសកម្ពុជា និងប្រទេស Maldives ។

ដោយបានអនុម័តកាលពីឆ្នាំ ២០០២ គំរោងទាំងមូលត្រូវបានចែកចេញជា ០៣ ផ្នែក ដូចជា : ផ្នែកពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ផ្នែករៀបចំសហគមន៏ និងផ្នែកអភិរក្សជីវចំរុះនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ យុទ្ធនាការផ្សព្វផ្សាយ និងអប់រំ ដែលមានរយះពេល ១៨ខែ ត្រូវបានដឹកនាំដោយអង្គការ Live and Learn ក្នុងការអនុវត្តផ្នែកទី១ នៃគំរោង និងមានទំនាក់ទំនងជាមួយផ្នែកទី ៣ នៃគំរោង ដោយរាប់



PHOTO: L&L

បញ្ចូលទាំងការបង្កើតអោយមានយន្តការនៃសំរបសំរួល និងព័ត៌មានសំរាប់ថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលបានបង្កើតឡើងដោយអង្គការយូណេស្កូ នៅឆ្នាំ ១៩៩៧ ។

ភាគច្រើននៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបត្រូវបានផ្តល់ថវិកាកម្ចី ចំនួន ១០. ៩ លានដុល្លាអាមេរិក ពីធនាគារ ADB  និងមានការផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា មានទឹកប្រាក់ស្មើ ៣.៩ លានដុល្លាអាមេរិក (ស្មើនឹង ១.៦ កោដ រៀល) ។ អង្គការ GEF បានឧបត្ថម្ភហិរញ្ញវត្ថុ ៣.៩ លានដុល្លាអាមេរិក និងអង្គការ UNDP បានផ្តល់ថវិកាចំនួន ៦២៣ ០០០ ដុល្លាអាមេរិក ដើម្បីធ្វើការកែលំអបទបញ្ញត្តិច្បាប់ និងគ្រប់គ្រងជលផលទឹកសាប និង ធនាគារ ADB ផ្តល់ថវិកាចំនួន ៤០ ០០០ ដុល្លាអាមេរិក សំរាប់ជាជំនួយលើផ្នែកបច្ចេកទេស ។

ផែនការសកម្មភាពរបស់គំរោងផ្តោតទៅលើទិដ្ឋភាពបរិស្ថាន សេដ្ឋកិច្ច និងសង្គម នៃតំបន់បឹងទន្លេសាប ជាប្រភពនៃម្ហូបអាហារនៅក្នុងតំបន់ដែលមានលក្ខណៈជលសាស្ត្រពិសេស និងក៏ទទួលរងការគំរាមកំហែងច្បាស់លាស់ផងដែរ ។ ផែនការសកម្មភាពនេះ មានទិសដៅចំពោះទៅសាធារណៈជនទូទៅ អ្នកធ្វើការសំរេចចិត្ត ប្រព័ន្ធផ្សព្វផ្សាយ គ្រូបង្រៀន និងទីភ្នាក់ងាររាជរដ្ឋាភិបាល ដោយមានការប្រើប្រាស់បណ្តាញការងារដែលមានស្រាប់ សកម្មភាព និង សំភារៈជាអាទិភាព ត្រូវបានផ្តល់ដោយគ្រូបង្រៀន សហគមន៍ អ្នកសារព័ត៌មាន និងអ្នកធ្វើការសំរេចចិត្ត ។

## ខ. បញ្ហាប្រឈមមុខចំពោះបឹងទន្លេសាប

តំបន់បឹងទន្លេសាប គឺជាតំបន់មួយដែលមានទំហំធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ។ តំបន់នេះមានទំហំ២ ៥០០ គម² នៅរដូវប្រាំង ចំណែកឯនៅចុងរដូវវស្សា បឹងទន្លេសាបលាតសន្ធឹងរហូតដល់ ១៦ ០០០គម² ដោយ មានកំរិតកំពស់ទឹកកើនឡើងរហូតដល់ ១០ម ។ តំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ និងតំបន់ព្រៃរបោះជាកន្លែងពងកូនរបស់ពពួកត្រី ល្មូន សត្វស្លាប និងពពួកថនិកសត្វផ្សេងៗ ។ ដោយពពយត្រីមានភាពសំបូរបែបនោះវាបានទ្រទ្រង់ដល់ប្រជាពលរដ្ឋច្រើនជាង ១លាននាក់ ។

ធនាគារអភិវឌ្ឍន៍អាស៊ីមានការព្រួយបារម្ភណ៍ដោយសារតែបឹងទន្លេសាបទទួលរងសំពាធដោយមានប្រជាជនប្រើប្រាស់ធនធានកាន់តែមានបរិមាណច្រើនឡើង ។ បញ្ហាទាំងនេះមាន ការធ្វើអាជីវកម្មហួសហេតុលើធនធានត្រី សត្វព្រៃ  ការរានយកដីនៅរដូវប្រាំង និងការកាប់ព្រៃលិចទឹក និងការបំផ្លាញសារពើរុក្ខជាតិធម្មជាតិ គឺវាបំផ្លាញជំរកសត្វ ការបាត់បង់គុណភាពទឹក និងដី ព្រមទាំងមានការកើនឡើងនូវអត្រានៃដីល្បាប់ ។

គ្រួសារប្រមាណពី៤០% ទៅ ៦០% នៅក្នុងខេត្តជុំវិញបឹងទន្លេសាប គឺស្ថិតនៅក្រោមបន្ទាត់ក្រីក្រ ទោះបីជាអនុម័តមានដល់ ៨០% ស្ថិតនៅក្នុងតំបន់មួយចំនួនក៏ដោយ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានកត់សំគាល់ឃើញថា ប្រជាពលរដ្ឋជាច្រើនគ្រួសារគឺពឹងពាក់ស្រ័យទាំងស្រុងទៅលើផលនេសាទ ។ ជំលោះទ្រព្យសម្បត្តិកើតមានឡើងជាទូទៅ និងបញ្ហាដទៃទៀតដូចជា ភាពគ្មានសមាមាត្រនៃមេគ្រួសារដែលស្ត្រី និងបញ្ហាជនជាតិភាគតិច (វៀតណាម និងខ្មែរអីស្លាម) ។ ការបាត់បង់ធនធានធម្មជាតិ វាក៏មានការទាក់ទងជាមួយនឹងបញ្ហាបរិស្ថានធ្ងន់ធ្ងន់ដល់ប្រទេសជិតខាងផងដែរ ។

ធនាគារអភិវឌ្ឍន៍អាស៊ីបានព្រមានថា " បឹងទន្លេសាបហាក់បីដូចជាត្រូវបានធ្វើអាជីវកម្មហួសប្រមាណទៅនឹងកំរិតប្រកបដោយនិរន្តរភាព" ។ កាលពី ២០ឆ្នាំ មុន ការស្រុះស្រួលគ្នាទៅនឹងធនធានបឹងទន្លេសាប ជាពិសេសផ្នែកជលផល មានចាត់ចំនាត់ថ្នាក់មិនស្មើភាពគ្នា មិនយុត្តិធម៌ និងអឺករាល

ដាលនូវអំពើពុករលួយ ការបាត់បង់គុណភាពបរិស្ថាន ពីការធ្វើអាជីវកម្មដោយមិនមាននិរន្តរភាព និងការកើតមានជំលោះកាន់តែច្រើនឡើង ។ ធនាគារអភិវឌ្ឍន៍អាស៊ីបាននិយាយថា ការរេចរឹលកាន់តែកើនឡើង អាចមានផលវិបាក ដែលមិនអាចទាយទុកបាននៅពេលដែលការបំផ្លាញប្រព័ន្ធអេកូឡូស៊ីមិនអាចត្រូវបានស្តារអោយមានដូចដើមឡើងវិញ ដោយសារការនេសាទលើសកំរិត និងធ្វើអោយការនេសាទនោះមានការធ្លាក់ចុះភ្លាមៗ ការធ្លាក់ចុះបែបនោះ វានាំអោយមានផលប៉ះពាល់ដល់សុខមាលភាព និងសង្គមធ្ងន់ធ្ងរ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានកត់សំគាល់ថា ត្រីបានផ្តល់ប្រូតេអ៊ីនច្រើនបំផុតសំរាប់ប្រជាពលរដ្ឋកម្ពុជា ព្រមទាំងបន្ថែមប្រាក់ចំណូលសំរាប់ទិញស្រូវ អង្ករ ។

## គ. យុទ្ធសាស្ត្រ

នៅខែកុម្ភៈ ឆ្នាំ ២០០៥ ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅទីក្រុងម៉ានីល បានអនុម័តយុទ្ធសាស្ត្រ និងកម្មវិធី សំរាប់អនុវត្តនៅក្នុងប្រទេសកម្ពុជា ។ នៅក្រោមជំនួយនេះ ប្រទេសកម្ពុជាបានរៀបចំទទួលប្រាក់កម្ចី ១០៤ លាន ដុល្លាអមេរិក និងប្រមាណ ៣.៥ លាន ដុល្លា អមេរិក ជាជំនួយទៅលើផ្នែកបច្ចេកទេស សំរាប់ឆ្នាំ ២០០៥ និងឆ្នាំ ២០០៦ ។ ជំនួយនេះត្រូវបានចែកចេញជា ៣ផ្នែក "ដែលមាននៅក្នុងការអភិវឌ្ឍសង្គម" គឺ : កម្មវិធីកែលំអការអប់រំ កម្មវិធីផ្តល់អំណាចទៅដល់អ្នកដែលបាត់បង់សមត្ថភាព ការត្រួតពិនិត្យលើការព្យាបាលជំងឺ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមតំបន់ជនបទ និង គ្រប់គ្រងធនធានធម្មជាតិនៅជុំវិញបឹងទន្លេសាប ។

នៅខែមេសា ឆ្នាំ២០០៥ ធនាគារអភិវឌ្ឍន៍អាស៊ីបាននិយាយថា យុទ្ធសាស្ត្រសំរាប់គ្រប់គ្រងបឹងទន្លេសាប ត្រូវបានរៀបចំឡើងសំរាប់រយៈពេល ០២ឆ្នាំ និងអាចគាំទ្រដល់យុទ្ធសាស្ត្រប្រទេសចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបាននិយាយថា យុទ្ធសាស្ត្រ "ការផ្តល់ព័ត៌មាន និងការទទួលព័ត៌មាន" នៅក្នុងគោលការណ៍ ជាគន្លឹះដែលជាមូលដ្ឋានសំរាប់រៀបចំជំនួយអាទិភាព និងជំនួយលើផ្នែកផែនការចំពោះប្រទេសកម្ពុជាសំរាប់រយៈពេល ៥ឆ្នាំ ទៅ ១០ឆ្នាំ ក្រោយ ។

## ឃ. ការផ្តួចផ្តើមគំនិតលើការអប់រំបរិស្ថានកន្លងមក

ការអប់រំបរិស្ថាននៅក្នុងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវបានធ្វើចំពោះសហគមន៍ក្នុងតំបន់ គ្រូ បង្រៀន និងសិស្សនៅថ្នាក់បឋមសិក្សា ។ អ្នកដែលបានជួយឧបត្ថម្ភមានដូចជា អង្គការ FAO និងភ្នាក់ងារមិនមែនរដ្ឋាភិបាលដូចជា អង្គការអូស្មូស (Osmose) អង្គការម្លប់បៃតង អង្គការសង្គ្រោះសត្វព្រៃ និងមានទីភ្នាក់ងារដទៃទៀតមាន អង្គការអន្តរជាតិ និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួន ក៏មានសកម្មភាពក្នុងការចូលរួមខ្លះៗ ផងដែរ ។ អង្គការ UNDP បានធ្វើការកត់សំគាល់ឃើញថា ការអប់រំបរិស្ថាននៅតំបន់នោះគឺ ស្ថិតនៅក្នុងស្ថានភាពក្មេងខ្ចីនៅឡើយ ។ ជាងនេះទៅទៀត អត្ថន័យក្នុងការអប់រំផ្នែកបរិស្ថានមានលក្ខណៈខុសគ្នាពីអង្គការមួយទៅអង្គការមួយ ។

ដោយមានកិច្ចសហការជាមួយអង្គការអូស្មូស និងអង្គការម្លប់បៃតង អង្គការ FAO បានបោះពុម្ពសៀវភៅណែនាំកម្មវិធីសិក្សាចំនួន ១០០ច្បាប់ ដែលមាន១៤ ផ្នែក។ ដើម្បីអោយពួកគាត់អាចប្រើប្រាស់សៀវភៅនេះបាន អង្គការអូស្មូសបានបណ្តុះបណ្តាលគ្រូប្រមាណ៤០នាក់តាមរយៈសិក្ខាសាលារយៈពេល ០២ថ្ងៃ ចំណែកអង្គការ ម្លប់បៃតងបានបណ្តុះបណ្តាលគ្រូ ២៥នាក់ ផ្សេងទៀតក្នុងការប្រើប្រាស់ផ្នែកផ្សេងៗ ក្នុងសៀវភៅដើម្បីរៀបចំអនុវត្ត



PHOTO: KAREN YOUNG L&L

កម្មវិធីបង្រៀនបន្ថែមម៉ោង "ក្លឹបសាលា" សំរាប់សិស្សបឋមសិក្សានៅជុំវិញរាជធានីភ្នំពេញ ។ អង្គការទាំងពីរ បានផ្តល់ថវិកាដល់គ្រូបក្នុងការន្ថែមកម្មវិធីបរិស្ថានស្របតាមមេរៀនសាលា ។ អង្គការម្លប់បៃតង បានដាក់បញ្ចូលកម្មវិធីផ្សព្វផ្សាយតាមវិទ្យុរយៈពេល១៥នាទីស្តីពីបញ្ហាបរិស្ថានជាផ្លូវការចំនួនពីរដងក្នុងមួយសប្តាហ៍តាមរយៈមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងមួយម៉ោងក្នុងការឆ្លើយសំណួរតាមទូរស័ព្ទ ប្រសិទ្ធភាពនៃកម្មវិធីនេះមិនទាន់បានទទួលជោគជ័យតាមការវាយតំលៃនោះទេ ។

នៅឆ្នាំ១៩៩៩ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ បានបង្កើតអគារបន្តែតទឹកដែលត្រូវបានគេស្គាល់ថា មជ្ឈមណ្ឌលអប់រំបរិស្ថាន ចុងឃ្មៀស (Gecko) នៅខេត្តសៀមរាប ។ នៅចុងឆ្នាំ ២០០៥ ក្នុងនោះសិស្សបឋមសិក្សាចំនួន៦ក្រុម បានទស្សនាមជ្ឈមណ្ឌលតុកកែមួយដងក្នុងមួយសប្តាហ៍ មានរយៈពេល១ម៉ោង តាមដឹងមានសិស្សប្រមាណ ៥០០០នាក់ បានមកទស្សនាមជ្ឈមណ្ឌលដោយយកលំនាំតាមសៀវភៅបណ្តុះបណ្តាល ។ អង្គការ FAO បានរៀបចំការអប់រំក្រៅផ្លូវការនៅក្នុងសហគមន៍នេសាទផងដែរ ។



នៅក្នុងចំណោមគំនិតផ្តួចផ្តើមដទៃទៀត និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ បានបណ្តុះបណ្តាលដល់ព្រះសង្ឃ និងបានរៀបចំសៀវភៅបណ្តុះបណ្តាលស្តីពីបរិស្ថានដោយផ្តោតតាមធម៌ព្រះពុទ្ធ ។ អង្គការអភិវឌ្ឍន៍គ្រួសារ កម្ពុជា(CFDS) អង្គការស៊ីប៉ា

(SIPAR) និងអង្គការ Forum NGO មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ និង បាត់ដំបង បានរៀបចំសំភារៈអប់រំមានទំហំតូចផងដែរ ដែលភាគច្រើនជាបដាផ្សព្វផ្សាយ និងរឿងខ្លីៗសំរាប់សហគមន៍ នៅក្នុងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ទន្ទឹមនឹងនោះដែរ អង្គការ អនុវត្តគំរោងកែច្នៃសំណល់រឹង-សំរាម (CSARO) នៅទីក្រុងភ្នំពេញ និងអង្គការទីភ្នាក់ងារសហប្រតិបត្តិការ អង្គការអន្តរជាតិជប៉ុន (JICA) បានបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលលើផ្នែកបរិស្ថាននេះផងដែរ ។

## ង. ការយល់ដឹងលើបញ្ហាបរិស្ថាននៅតំបន់បឹងទន្លេសាប

នៅឆ្នាំ២០០៤ ការវាយតំលៃលើបញ្ហាបរិស្ថាននៅតំបន់បឹងទន្លេសាបត្រូវបានធ្វើឡើងតាមរយៈកម្មវិធីសិក្សា ល្ខោន វិទ្យុ និងតាមរយៈវីដេអូ ឬទូរទស្សន៍ ។ កម្មវិធីទាំងនេះ ទាក់ទងជាមួយការអនុវត្តផែនការសកម្មភាពរបស់គំរោង ។

ប្រជាពលរដ្ឋភាគច្រើនដែលរស់នៅក្នុងតំបន់បឹងទន្លេសាបនេះ មានការយល់ដឹងពីបញ្ហាបរិស្ថាន ប៉ុន្តែពួកគេពុំមានឥទ្ធពលអំណាច វិធីវិកាដើម្បីដោះស្រាយអ្វីមួយទៅលើបញ្ហានេះឡើយ ។ ដូច្នេះ យុទ្ធនាការនេះ នឹងជំរុញការយល់ដឹងពីឋបនីយជីវមណ្ឌលទៅដល់ចំណោមអ្នកកាន់អំណាច អ្នកដឹកនាំសាសនា និងមន្ត្រីរាជការ ។

ទោះបីជា ការបំពុលទឹកមានឥទ្ធិពលគ្រោះថ្នាក់ទៅលើសុខភាពសាធារណៈក៏ដោយ ប៉ុន្តែប្រជាពលរដ្ឋមានទស្សនៈផ្សេងៗគ្នា អំពីសារសំខាន់នៃបរិស្ថានស្អាត ។ ការសំដែងសិល្បៈនឹងស្វែងរកការចូលរួមពីប្រជាពលរដ្ឋតាមរយៈគំរោងអនុវត្តន៍ ។

វិធីសាស្ត្រតាមលក្ខណៈប្រពៃណីទៅលើការអប់រំបរិស្ថានចាំបាច់ត្រូវធ្វើការវាយតំលៃឡើងវិញ ។ សំភារៈ សំរាប់ការអប់រំត្រូវដាក់បង្ហាញទៅតាមសកម្មភាព និងបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សា បើអាចធ្វើទៅបាន ។

ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃតំបន់បឹងទន្លេសាប ត្រូវបានទទួលការយល់ដឹងតិចតួច ។ ផលប្រយោជន៍នៃការចាត់វិធានការ និងភាពគ្រោះថ្នាក់ដែលបណ្តាលមកពីការមិនបានអនុវត្តការងារអ្វីមួយត្រូវបានលើកឡើង នៅក្នុងចំណោយអ្នកធ្វើការសំរេចចិត្ត អ្នកដឹកនាំសាសនា និងមន្ត្រីរាជការ ។

ការអប់រំប្រជាពលរដ្ឋស្តីពីបញ្ហាបរិស្ថានត្រូវបានធ្វើឡើងយ៉ាងផុសផុល ។ ប្រសិនបើប្រជាពលរដ្ឋមានការចាប់អារម្មណ៍កាន់តែខ្លាំងទៅបញ្ហាបរិស្ថាននោះពួកគេត្រូវតែមានអំណាចបន្ថែមដែរ ។

ការិយាធិបតេយ្យ និងនិច្ចលភាព កំណត់ពីការផ្លាស់ប្តូរ ។ អំពើពុករលួយបានបង្កការស្ទុះគ្រស្ទាញដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីទទួលបាននូវការកែលំអរយៈពេលវែង គឺត្រូវតែទទួលការគាំទ្រដោយឆន្ទៈនយោបាយ ។

ការទទួលខុសត្រូវលើការអប់រំបរិស្ថាន ត្រូវបានបែងចែករវាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា ។ កិច្ចខិតខំប្រឹងប្រែងទៅលើបញ្ហានេះ ត្រូវបានធ្វើឡើងដើម្បីពង្រឹងទំនាក់ទំនងរវាងក្រសួងទាំងនេះ ដើម្បីសំរេចអោយបាននូវវិធីសាស្ត្រអោយបានកាន់តែរលូនបន្ថែមទៀត ។

ការអប់រំបរិស្ថាន មានន័យផ្សេងគ្នា រវាងមនុស្សផ្សេងគ្នា ។ វាក្យស័ព្ទថ្មី គឺត្រូវបានរឹកសុះសាយ និងត្រូវការការពន្យល់បកស្រាយ ។ វិធីក្នុងការអប់រំគួរតែលើកឡើង អំពីសារសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ច ការអប់រំ និង សង្គមស៊ីវិល ។

ក្រសួងអប់រំ យុវជន និងកីឡា នៅមានការស្ទាក់ស្ទើរក្នុងការគាំទ្រការសិក្សាអប់រំបរិស្ថាន លុះត្រាតែវាបានមើលឃើញថាជាវិធីសាស្ត្រមានប្រសិទ្ធ

PHOTO: KAREN YOUNG L&L





ភាពដើម្បីទទួលបានគោលបំណងអាទិភាព ។ ផែនយុទ្ធនាការអាចដាក់បញ្ចូលវិធីសាស្ត្រអប់រំ ទៅក្នុងគោលនយោបាយ "សិស្សក្លឹបបរិស្ថាន" និងសលាកំរងរបស់ក្រសួង ។

ការអប់រំបរិស្ថាន គឺជាបរិធានមួយសំរាប់កែទំរង់ការអប់រំដែលមានរយៈពេលវែង ។ ប្រធានបទដែលទាក់ទងនឹងការអភិវឌ្ឍក្របកដោយនិរន្តរភាព គួរដាក់បញ្ចូលទៅក្នុងកម្មវិត្តទាក់ទងជាមួយបញ្ហាសង្គម វប្បធម៌ និងប្រវត្តិសាស្ត្រ នៅក្នុងសាលាបរិស្ថាន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ។

ប្រសិនបើការអប់រំក្នុងប្រព័ន្ធធ្វើការកែលំអដល់ឱកាសស្វែងរកការងារនោះ ឪពុកម្តាយ អាចបញ្ជូនកូនចៅរបស់ខ្លួនទៅកាន់សាលារៀន ។ យុទ្ធនាការគួរប្រើ "សាលាក្លឹបបរិស្ថាន" ដើម្បីបង្កើនជំនាញដោយដាក់បញ្ចូលការងារសាលាជាមួយការអប់រំក្រៅប្រព័ន្ធ ។

ការដែលមិនមានលទ្ធផលជាក់ស្តែងសំរាប់រយៈពេលខ្លីនេះ ធ្វើឱ្យការយល់ដឹងនូវវិធីគ្រប់គ្រងធនធានធម្មជាតិ មិនមានតំលៃផងដែរ ។ ឋបនីយជីវមណ្ឌលត្រូវបានចាត់ទុកថាមានសារៈសំខាន់ នៅពេលដែលទទួលបាន ការផ្សព្វផ្សាយតាមឯកសារ និងការផ្សព្វផសាយតាមវិទ្យុ និងទូរទស្សន៍ អំពីសារសំខាន់នៃបឹងទន្លេសាប ។

ចំណេះដឹងបរិស្ថានរួម នៅមានកំរិតទាប នៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ សាលារៀនត្រូវតែធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការផ្នែកបរិស្ថាន ដូច្នេះឃុំអាចដើរអនុវត្ត និងចែករំលែកចំណេះដឹងបែបប្រពៃណីផលដែរ ។

# ២. វិធីសា     ស្ត និងការអនុវត្ត

## ច. វិធីសាស្ត្រដែលទូលំទូលាយ

ការអប់រំបរិស្ថានត្រូវតែធ្វើការបញ្ជាក់អោយបានច្បាស់លាស់ពីអត្ថន័យនៃពាក្យថា អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ បឹងទន្លេសាបមិនគ្រាន់តែជាឋបនីយជីវមណ្ឌលប៉ុណ្ណោះទេ តែវាក៏ជាកំលាំងមួយក្នុងការជំរុញដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ដែលមានទំនាក់ទំនងជិតស្និតជាមួយអត្តសញ្ញាណជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ។

យុទ្ធនាការមានគោលបំណងចំនួន ០៧ និងត្រូវបែងចែកជា ៤៨ សកម្មភាព ។ វានឹងធ្វើការសង្កេតលើតួនាតួនាទីរបស់ស្ថាប័នផ្សេងៗ និងទំនាក់ទំនងរវាងបរិស្ថាន  ជីវភាពរស់នៅ និងសុខភាព និងកំណើនសេដ្ឋកិច្ច ។

វប្បធម៌កម្ពុជា ត្រូវតែមានការយកចិត្តទុកដាក់ជានិច្ច ។ យុទ្ធនាការត្រូវតែធ្វើឡើងអោយច្បាស់លាស់ ជាក់ស្តែង និងចែកចាយព័ត៌មានដោយផ្ទាល់ ដែលទាំងអស់នោះគឺត្រូវបានធ្វើឡើងដោយល្អិតល្អន់ និងអាចធ្វើជាគំរូបានច្រើនយ៉ាងផងដែរ ព្រមទាំងត្រូវបង្ហាញពីតំបន់បឹងទន្លេសាបទាំងមូល ។

យុទ្ធនាការនឹងបង្ហាញពីសារសំខាន់ជាលក្ខណៈជាតិ និងអន្តរជាតិនៃបឹងទន្លេសាប ។ មន្ត្រីរាជការ អ្នកធ្វើការសំរេចចិត្តនៅថ្នាក់មូលដ្ឋាន អ្នកដឹកនាំសាសនា នឹងត្រូវបានផ្តល់ការយល់ដឹង អំពីកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ប្រទេសកម្ពុជា ។

គំនិតប្រកបដោយការច្នៃប្រឌិត គឺជាការចាំបាច់ ។  ប្រសិនបើការអប់រំនាំមកនូវការផ្លាស់ប្តូរនោះ ប្រជាពលរដ្ឋត្រូវតែធ្វើការអង្កេតពីបញ្ហានៅក្នុងតំបន់ ដែលអាចអនុវត្តបាន ។ ជំនាញបែបនេះតំរូវអោយបញ្ជាក់បង្ហាញ ពីបញ្ហាបរិស្ថាន ។

## ឆ. ការចូលរួម

ផែនការសកម្មភាពត្រូវបានកំនត់តាមក្រុមការងារ ដោយមានចំនួនតំណាងជាក់លាក់របស់អង្គការជាតិ ។ ក្រុមគោលដៅ ០៣ សំរាប់ធ្វើការផ្សព្វផ្សាយអប់រំ និងសារព័ត៌មាន នឹងត្រូវបង្កើតឡើងដើម្បីអភិវឌ្ឍន៍ធនធាន និងអនុវត្តការបណ្តុះបណ្តាល និងត្រួតពិនិត្យទៅលើប្រសិទ្ធភាពនៃយុទ្ធនាការ ។ ក្រុមទាំងនេះនឹងជួបប្រជុំគ្នាជាប្រចាំ និងត្រូវបានបង្ហាញពីបច្ចេកទេសថ្មីនៅក្នុងការអប់រំបរិស្ថាន ។








## ជ. ការយកចិត្តទុកដាក់របស់យុទ្ធនាការ

យុទ្ធនាការនេះធ្វើការបង្ហាញសំខាន់ ចំនួន ០៥ ចំណុច ដែលកំពុងតែប្រឈមមុខជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ចំណុចទាំងនេះមាន កាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជាលើការអភិរក្សប្រព័ន្ធអេកូឡូស៊ី ផ្នែកគុណភាពទឹក ផ្នែកអនាម័យ និងផ្នែកសុខភាព ។ យុទ្ធនាការនឹងបង្ហាញពីការបញ្ចុះបញ្ចូល និង ការធ្វើសេចក្តីសំរេចចិត្ត ព្រមទាំងសារៈសំខាន់នៃព្រៃលិចទឹក និងផលប្រយោជន៍នៃតំបន់ការពារធម្មជាតិផងដែរ ។ ក្រុមការងារនឹងរៀបចំមាតិកានៃផែនការសកម្មភាព ដោយមានភ្ជាប់មកជាមួយនូវគោលបំណង ដើម្បីជំរុញការផ្លាស់ប្តូរ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

## ឈ. ការពិនិត្យព័ត៌មានឡើងវិញ

ការត្រួតពិនិត្យព័ត៌មានឡើងវិញនឹងផ្តោតលើការងាររបស់ក្រុមគោលដៅ ។ ការងារនេះនឹងផ្តោតលើការផ្តួចផ្តើមគំនិតកន្លងមក និងថាតើយើងអាចយកមកប្រើនៅក្នុងយុទ្ធនាការយ៉ាងដូចម្តេច

## ញ. ក្រុមគោលដៅ

ក្រុមគោលដៅរួមមានសមាជិកពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និងសាលាបណ្តុះបណ្តាល ។ ក្នុងការរៀបចំផែនការសកម្មភាព និងធនធានសំរាប់វគ្គបណ្តុះបណ្តាល ក្រុមការងារនឹងត្រូវបង្ហាញផ្លូវដោយទិន្នន័យពីការត្រួតពិនិត្យឡើងវិញ និងរបាយការណ៍ពីមុនរបស់អង្គការ Live and Learn ស្តីពីបឹងទន្លេសាប ។

## ដ. ការយល់ដឹងរបស់សហគមន៍

ការកែលំអការអប់រំ និងលើកកំពស់ចំណេះដឹងបរិស្ថាន នឹងផ្តោតទៅលើ ការសំដែងល្ខោន វិទ្យុ និងតាមរយៈការបើកវគ្គបណ្តុះបណ្តាល សំរាប់អ្នកធ្វើការសំរេចចិត្តនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ។ ការសំដែងល្ខោនត្រូវតែដាក់បញ្ចូលទៅក្នុងការបង្ហាត់បង្រៀនធម៌ព្រះពុទ្ធ និងរឿងនិទានខ្មែរ ។ ឈុតផ្សព្វផ្សាយតាមវិទ្យុសំរាប់រយៈពេល ០១នាទី អាចលើកឡើងពីករណីសិក្សាប្រកបដោយជោគជ័យ និងត្រូវបានទទួលដោយប្រជាពលរដ្ឋតាមមូលដ្ឋាន ឬជាស្ត្រី ។

សំភារៈអប់រំសំរាប់ឃុំ គួរបញ្ចូលការអនុវត្តជាគំរូផ្សេងៗនៃការអប់រំបរិស្ថាន ដែលអាចជួយកាត់បន្ថយភាពក្រីក្រ ។ ពួកគេគួរបង្ហាញពីចំណេះដឹងតាមបែបប្រពៃណីតាមតំបន់នីមួយៗ ដូចជា: ការប្រើប្រាស់រុក្ខជាតិ សត្វ ដី ទឹក និងការនេសាទប្រកបដោយនិរន្តរភាព ដែលចំណេះដឹងនេះអាចប្រើប្រាស់ដើម្បីសំភារៈអប់រំគួរបង្ហាញពីបញ្ហាសំខាន់ពេលបច្ចុប្បន្ន និងសកម្មភពដែលអាចនាំទៅរកកំណើនសេដ្ឋកិច្ច ។

## ឋ. ការអប់រំ

សំភារៈអប់រំផ្លូវការ នឹងត្រូវកំណត់ចំពោះគ្រូបង្រៀន មជ្ឈមណ្ឌលគរុកោសល្យ និងមន្ត្រីផ្នែកអប់រំ ។ សំភារៈទាំងនេះនឹងបង្ហាញពីជីវសាស្ត្រតំបន់ទន្លេសាបដែលផ្សារភ្ជាប់ជាមួយភាពក្រីក្រ ការប្រកបរបរចិញ្ចឹមជីវិត សុខភាព និងសុមាលភាព ។

ការអភិវឌ្ឍដោយមាននិរន្តរភាពនឹងត្រូវបញ្ចូលក្នុងកម្មវិធីសិក្សា និងសាលារៀនក្លឹបនឹងត្រូវបានបង្កើតឡើង ។ បរិក្ខាអប់រំនឹងត្រូវរៀបចំបង្កើតឡើងដើម្បីជំរុញដល់ការគិតគូរដោយច្នៃប្រឌិត ការដោះស្រាយបញ្ហា ការចូលរួមពីសិស្សានុសិស្ស និងដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន ។ ដំណោះស្រាយបែបអនុវត្តនឹងត្រូវបានជំរុញ ។ សំភារៈអប់រំ មានភ្ជាប់ជាមួយនូវឯកសារណែនាំគ្រូពីផ្នែកកម្មវិធីសិក្សាទាំងប្រាំទៅលើបញ្ហាបរិស្ថានចំបងៗនៅតំបន់បឹងទន្លេសាប និងឯកសារណែនាំដល់សកម្មភាពរបស់សាលា ។

## ឩ. ទំហំនៃការផ្សព្វផ្សាយ

ផែនការសកម្មភាពនឹងជំរុញផ្នែកចំណេះដឹងសាធារណៈ ស្តីពី អំពីសារសំខាន់របស់បឹងទន្លេសាបអោយបាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និង កម្មវិធីបណ្តុះបណ្តាលសារព័ត៌មាននៅសាកលវិទ្យាល័យភ្នំពេញ ។ ក្រុមការងារ ផ្សព្វផ្សាយនឹងរៀបចំឡើងមានការទាក់ទងគ្នាយ៉ាងជិតជាមួយនឹងអត្ថបទផ្សព្វផ្សាយប្រចាំត្រីមាស ។ យុទ្ធនាការនឹងផ្តល់ដល់អ្នកសារព័ត៌មាន និងអ្នកបណ្តុះបណ្តាល នូវព័ត៌មានស្តីបញ្ហានៅបឹងទន្លេសាប និងឱកាសសំរាប់ការរស់នៅនិងការងារនៅក្នុងតំបន់នេះ ។ យុទ្ធនាការនឹងផ្សាយចេញនូវព័ត៌មាន រៀបចំសន្និសីទ រៀបចំកិច្ចពិភាក្សាតុមូល និងជំរុញការចេញផ្សាយរបាយការណ៍ស្តីពីបឹងទន្លេសាបអោយបានត្រឹមត្រូវ តាមរយៈអ្នកសារព័ត៌មាននៅតាមខេត្ត និងនៅភ្នំពេញ ។

សំភារៈសំរាប់ផ្សព្វផ្សាយ នឹងត្រូវបានរៀបចំឡើង ដោយមានសំភារៈសំរាប់បណ្តុះបណ្តាលអាចត្រូវបានប្រើប្រាស់ជាការណែនាំទូលំទូលាយក្នុងរបាយការណ៍ស្តីពីបញ្ហាបរិស្ថាននៅតំបន់បឹងទន្លេសាប ។ សំភារៈសំរាប់ការអប់រំមាន វីដេអូ និងដាក់បង្ហាញពីបរិស្ថានបឹងទន្លេសាបនឹងត្រូវបានប្រើប្រាស់ ដើម្បីជំរុញការងាររបស់ក្រុមការងារផ្សេងៗនៅក្នុងចំណោមប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ។



## ឈ. ការត្រួតពិនិត្យ និងវាយតំលៃ

ដំណើរការត្រួតពិនត្យ និងវាយតំលៃលើផែនការសកម្មភាព ត្រូវតែធ្វើការចាប់ផ្តើមពីដំណាក់កាលដំបូង ។ បរិមាណនៃមធ្យោបាយត្រូវដាក់បញ្ចូលពីចំនួនប្រជាពលរដ្ឋដែលទទួលបានប្រយោជន៍ពីការអនុវត្តផែនការសកម្មភាព និងចំនួនធនធានត្រូវបានបង្កើតឡើង ទោះបីជាមិនអាចធ្វើការវាស់បានពីផលប៉ះពាល់អោយបានសមល្មម ដូចជាការកំណត់តំលៃ និងការកែប្រែគំនិតរបស់ប្រជាពលរដ្ឋ ។

គុណភាពវិធីសាស្ត្រនឹងផ្តោតទៅលើគណនេយ្យភាពបុគ្គលនៃការផ្លាស់ប្តូរដែលមានសារសំខាន់បំផុតអាចកើតមាន ។ តាមមធ្យោបាយនេះ ក្រុមការងារនឹងធ្វើអោយមានការផ្លាស់ប្តូរ០៤ ផ្តោតលើ ផ្នែកគុណភាពនៃជីវិត ការចូលរួមពីសហគមន៍ សមត្ថភាពក្រុមការងារ និងផ្នែកផ្សេងៗទៀត ។ បុគ្គលិកនិងក្រុមគោលដៅនឹងទទួលបានការបណ្តុះបណ្តាលទៅលើការចោទសួរ ស្តាប់ និងកត់ត្រា ។ ក្រុមការងារ និងតំណាងឃុំ ដែលបានកំណត់ និងធ្វើការជ្រើសរើសរឿងសំខាន់ៗ នៅក្នុងផ្នែកនីមួយៗដែលអាចយកទៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

## ណ. វេទិកាជាតិ

យុទ្ធនាការនឹងរៀបចំវេទិកាជាតិ ។ វេទិកានេះនឹងផ្តល់អោយក្រុមការងារ និងអង្គការផ្សេងៗ ដែលមានគោលបំណងចូលរួមផ្តល់បទពិសោធន៍ និងពិភាក្សាលើទិសដៅ និងផែនការសំរាប់ពេលអនាគតសំរាប់ការអប់រំបរិស្ថាននៅប្រទេសកម្ពុជា ។

## ត. ដៃគូពាក់ព័ន្ធ

ប្រសិទ្ធភាពនៃយុទ្ធនាការ គឺវាអាស្រ័យទៅលើភាពជាដៃគូ បណ្តាញការងារ និងសម្ព័ន្ធភាព ដែលបានរៀបចំឡើង ដូច្នេះការយកចិត្តទុកដាក់ខ្លាំងគឺក្រុមការងារ ។ យុទ្ធនាការមានអត្ថន័យទូលំទូលាយសំរាប់មូលដ្ឋាន ស្ថាប័នជាតិ រឺអន្តរជាតិ ។ ក្រុមការងារ និងដៃគូដទៃទៀតត្រូវពិនិត្យអោយបានល្អិតល្អន់ដើម្បីជំរុញយុទ្ធនាការតាមរយៈផែនការកម្មវិធី និងបណ្តាញការងារដទៃទៀត ។ ទីភ្នាក់ងាររដ្ឋាភិបាលជាតិ និងអង្គការក្រៅរដ្ឋាភិបាលតំរូវអោយមានការយកចិត្តទុកដាក់ជាពិសេស ។

ដៃគូត្រូវតែជ្រើសរើសចេញពីអង្គការអភិវឌ្ឍន៍ និង បរិស្ថានក្នុងស្រុក ដែលបានចុះបញ្ជីឈ្មោះនៅប្រទេសកម្ពុជា ។ អង្គការទាំងនោះនឹងអនុវត្តការងារតាមរយៈក្រុមបានបង្កើតឡើងសំរាប់ផ្សព្វផ្សាយចំណេះដឹង និងអប់រំដល់សហគមន៍ និងការផ្សព្វផ្សាយ ។ បុគ្គលិកអនុវត្តនផែនការសកម្មភាពដើរតួជាអ្នកសំរបសំរួលតាមរយៈបទពិសោធន៍របស់ដៃគូរក្នុងសំភារៈ និងសកម្មភាពដទៃទៀត នៅពេលដែលបានទទួលការយល់ដឹងពីសារសំខាន់ទៅលើអ្វីដែលកំពុងអនុវត្តធ្វើនៅក្នុងបឹងទន្លេសាប ។

## ថ. ទំនាក់ទំនងសំខាន់

យុទ្ធនាការនឹងធ្វើការទាក់ទងជាមួយផ្នែកផ្សេងទៀតនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជាពិសេសកម្មវិធីអប់រំ និងចំណេះដឹងបរិស្ថានដោយចុះដល់មូលដ្ឋាន ។ ដោយមានការឧបត្ថម្ភពីអង្គការ UNDP និង GEF ការងារទំនាក់ទំនងស្ថិតនៅក្នុងផ្នែកទី៣ ដែលមានកម្មវិធីជំរុញលើផ្នែកចំណេះដឹងការអភិរក្សជីវៈចំរុះ ។ បទដ្ឋានសំភារៈ និងធនធានបានរៀបចំតាមផែនការសកម្មភាព នឹងត្រូវចែករំលែកជាមួយគំរោងគ្រប់គ្រងទាំងមូល ។ ដើម្បីធានាដល់ប្រយោជន៍រួមជាអតិប្បរមា ការត្រួតពិនិត្យទាំងនេះត្រូវមានទំនាក់ទំនងជាមួយសកម្មភាពដទៃទៀតដែលចាំបាច់បន្ត ។

យុទ្ធនាការនេះក៏ធ្វើការភ្ជាប់ទៅជាមួយនឹងគំនិតផ្តួចផ្តើមអន្តរជាតិ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ដើម្បីទទួលបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរបស់អង្គការ UNDP ។ គំនិតផ្តួចផ្តើមដាក់បញ្ចូលកម្មវិធីអប់រំរបស់អង្គការយូណេស្កូលើគ្រប់ផែនការសកម្មភាព ដែលបានអនុវត្តនៅក្នុងប្រទេសថៃនៅឆ្នាំ១៩៩០ អាណត្តិក្នុងការអប់រំរបស់អង្គការសហប្រជាជាតិបានព្រព្រៀងឆ្ពោះទៅកាន់អាហ្វ្រិកខាងត្បូង ឆ្នាំ ២០០២ និង ដាក់បញ្ចូលអាណត្តិការអនុវត្តទឹកសំរាប់សុខភាព ដែលបានចាប់ផ្តើមនៅឆ្នាំ ២០០៣ ។

ការរំពឹងទុកពីការគ្រប់គ្រង បញ្ជាក់ពីអ្វីដែលយុទ្ធនាការអាចធ្វើបាន និងចំណាយធនធានប្រកបដោយប្រសិទ្ធភាពទៅលើការផ្តល់ចំណេះដឹងដល់សហគមន៍ ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានគឺជាការចាំបាច់ ។ វិធីសាស្ត្រមានប្រសិទ្ធិភាពមួយគឺត្រូវផ្គត់ផ្គង់ដល់អង្គការមូលដ្ឋាន និងអង្គការជាតិនូវសំភារៈ និងជំនាញ ។ វិធីសាស្ត្រផ្សេងទៀត គឺត្រូវលើកកំពស់ចំណេះដឹងទៅដល់អ្នកធ្វើការសំរេចចិត្តដោយអនុលោមទៅតាមបញ្ហាដែលកំពុងតែប្រឈមមុខនៅតំបន់បឹងទន្លេសាប និងផលវិបាកដែលយើងមិនយកវាមកដោះស្រាយ ។

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តំលៃដែលចាំបាច់ដើម្បីធានាទៅលើធនធានធម្មជាតិរបស់តំបន់បឹងទន្លេសាប មិនអាចកើតមានឡើងដោយសារតែការអប់រំបរិស្ថានមួយមុខប៉ុណ្ណោះទេ។ ប៉ុន្តែការអប់រំ គឺជាសរសរកណ្តាលក្នុងការជំរុញអោយទទួលបាននូវតំលៃទាំងនោះ ។ វាត្រូវតែខិតខំលើកទឹកចិត្តដល់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីអោយមានការជឿជាក់ថា ពួកគាត់អាចនាំអោយមានការប្រែប្រួលនៅលើពិភពលោក និងសំដៅទៅការបង្កើនសមត្ថភាពក្នុងការកែប្រែការយល់ដឹងទៅជាការអនុវត្ត។ ការអប់រំត្រូវលើកតំលៃនៃអាកប្បកិរិយា និងរបៀបរស់នៅក្នុងការធានាដល់ការអភិវឌ្ឍ និងការគិតគូរពីអនាគត ។

ការអប់រំចាំបាច់ត្រូវបង្ហាញពីបញ្ហាដោយជំរុញអោយមានការផ្លាស់ប្តូរ។ សាធារណជនមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនធានបឹងទន្លេសាប។ ដើម្បីអោយមាននិរន្តរភាព ការអភិវឌ្ឍសេដ្ឋកិច្ចគឺមិនត្រូវគិតគូរពីបរិស្ថាន និងមានការទទួលខុសត្រូវចំពោះសង្គមផងដែរ។ ប៉ុន្តែការងារ មិនទាន់ត្រូវបានកំណត់បានឆាប់រហ័សនៅឡើយទេ ។ ទស្សនៈវែងឆ្ងាយត្រូវការការតាំងចិត្ត និងវិធីសាស្ត្រនៅគ្រប់កំរិតនៅក្នុងសង្គមកម្ពុជា ។

## ៤. អនុសាសន៍

យុទ្ធនាការមិនត្រឹមតែផ្តោតទៅលើព័ត៌មាន និងការផ្តល់សារប៉ុណ្ណោះទេ  តែវាក៏ជាការផ្លាស់ប្តូរនូវឥរិយាបថ និងអកប្បកិរិយារបស់ប្រជាពលរដ្ឋផងដែរ ។ រយៈពេលនៃការងារពិភាក្សាផ្តល់យោបល់ត្រូវតែមានការប្រែប្រួលទៅលើទំហំនៃការងារ និងការចូលរួមពីក្រុមការងារ។ នាយកគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបនឹងត្រូវជូនព័ត៌មានក្នុងការប្រែប្រួលអ្វីមួយ ។



PHOTO: KAREN YOUNG L&L